សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université royale de droit et des sciences économique

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# អយ្យការអមសាលាដំបូងរាជធានី-ខេត្ត

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ កញ្ញា **លឹម ធារី**

កញ្ញា **ថុន ម៉ានិត**

ណែនាំដោយ

លោក **ច័ន្ទ តារារស្មី**


ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# **សេចក្តីថ្លែងអំណរគុណ**

ជាបឋមយើងខ្ញុំឈ្មោះ **លឹម ឆារី** និង **ថុន ម៉ានិត** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៣ នៅក្នុងឆ្នាំសិក្សា ២០១៩-២០២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ សូមធ្វើការគោរព និងថ្លែងនូវកតញ្ញូដឹងគុណដ៏ជ្រាលជ្រៅបំផុត ដែលមិនអាចកាត់ថ្លៃបានជូនដល់ លោកឪពុកអ្នកម្តាយ ដែលជាអ្នកមានគុណទាំងទ្វេរបស់យើងខ្ញុំដែលលោកបានផ្តល់កំណើត ព្រមទាំងការចិញ្ចឹមបីបាច់ថែរក្សាអប់រំប្រដៅយើងខ្ញុំដែលត្រូវជាកូនប្រុសស្រីដោយក្តី **មេត្តា ករុណា មុទិតា និង ឧបេក្ខា** ជាអនេកប្បការបំផុត។ ដោយលោកលះបង់ទាំងកម្លាំងកាយ កម្លាំងចិត្ត ចំពោះយើងខ្ញុំដែលត្រូវជាកុលបុត្រ កុលធីតា គ្រប់រូបដោយមិនគិតពីឧបសគ្គអ្វីទាំងអស់ចំពោះខ្លួនឡើយ និងបានជួយទំនុកបម្រុងគាំទ្រទាំងផ្នែកថវិកា ការជំរុញស្មារតី និងផ្តល់ជាមធ្យោបាយអោយយើងខ្ញុំ ដើម្បីបានក្រេបជញ្ជក់យកនូវចំណេះដឹងរហូតដល់ថ្នាក់បរិញ្ញាបត្រនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនដល់ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោកគ្រូអ្នកគ្រូ លោកសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ទាំងអស់ដែលបានខិតខំអស់ពីសមត្ថភាព ក្នុងការផ្ទេរនូវរាល់ចំណេះដឹងដល់យើងខ្ញុំទាំងអស់គ្នា ជាពិសេសជាការតម្រង់ទិសដើម្បីធ្វើឲ្យពួកយើងខ្ញុំក្លាយជា សិស្សល្អ កូនល្អ និងជាមនុស្សល្អ ប្រកបដោយគុណធម៌ សុជីវធម៌ សីលធម៌ និងចំណេះដឹងនៅក្នុងសង្គមជាតិទាំងមូល ដែលប្រកបដោយភាពជោគជ័យនិងគុណភាព នៃចំណេះដឹងយ៉ាងពិតប្រាកដ ដោយនៅក្នុងការចូលរួមអភិវឌ្ឍន៍សង្គមជាតិ ដើម្បីអោយមានភាពរីកចម្រើន។

ជាពិសេស យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះលោកគ្រូសាស្ត្រាចារ្យ **ច័ន្ទ តារាវឌ្ឍី** ដែលលោកគ្រូ គឺជាសាស្ត្រាចារ្យណែនាំនៅក្នុងកិច្ចការនៃការសរសេរសារណាមួយនេះ លោកគ្រូបានខិតខំដឹកនាំយើងខ្ញុំ ប្រកបដោយភាពយកចិត្តទុកដាក់បំផុតដោយអស់ពីសមត្ថភាពរបស់លោកគ្រូ ដោយលោកគ្រូបានខិតខំចំណាយនូវពេលវេលាដ៏មានតម្លៃ ទាំងកម្លាំងកាយចិត្ត និងកម្លាំងប្រាជ្ញា ព្រមទាំងលោកគ្រូបានផ្តល់នូវគំនិតនានា ដែលជាយោបល់នៅក្នុងការកែសម្រួលព្រមទាំងជាឯកសារជំនួយស្មារតី និងជួយតម្រង់ផ្លូវដល់យើងខ្ញុំកន្លងមករហូតបានសម្រេចនូវស្នាដៃមួយនេះឡើងមក។

ជាចុងក្រោយយើងខ្ញុំដែលជាកូនៗសូមប្រសិទ្ធិពរជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការ ចូលកើតចូលកើនចម្រើនមានដល់ **លោកអ្នកមានគុណទាំងទ្វេ** លោកគ្រូសាស្ត្រាចារ្យ **ច័ន្ទ តារាវឌ្ឍី** ព្រមទាំងលោកសាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ ដែលបង្ហាត់បង្រៀននៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមអោយជួបប្រទះនូវពុទ្ធពរទាំងឡាយបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

ក្រោយពីបានឆ្លងកាត់នូវការសិក្សា និងបានក្រេបជញ្ជក់នូវចំណេះដឹងអស់រយៈពេល៤ឆ្នាំកន្លងមកនេះ នៅ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** យើងខ្ញុំក៏បានសម្រេចចិត្តជ្រើសរើសយកប្រធានបទ ដែលស្តីពី "**អយ្យការអមសាលាដំបូងរាជធានី-ខេត្ត**" ដែលមានសាស្ត្រាចារ្យដឹកនាំ លោក **ចំនួ តារាស្នី** ដោយ យើងខ្ញុំបានជ្រើសរើសយកនូវប្រធានបទខាងលើនេះ ដើម្បីយកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជាកិច្ចការ សារណា ដែលជាឯកសារបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។

ការជ្រើសរើសយកនូវប្រធានមួយនេះ ដើម្បីយកមកធ្វើការសិក្សាស្រាវជ្រាវ ពិតណាស់ពុំមែនជារឿងចៃដន្យ ទេ ប៉ុន្តែជាការពិចារណាយ៉ាងហ្មត់ចត់តាមរយៈការសិក្សាលើអត្ថបទច្បាប់ ដែលពាក់ព័ន្ធកន្លងមកនេះ។ ដោយយល់ ឃើញថាស្ថាប័នអយ្យការដើរតួនាទីយ៉ាងសំខាន់ នៅក្នុងដំណើរនៃរឿងក្តីព្រហ្មទណ្ឌ ពោល គឺចាប់តាំងពីការចាប់ ផ្តើមដំណើរការនីតិវិធីនៃរឿងក្តីមកម្ល៉េះ ជាពិសេស គឺយើងឃើញនៅក្នុងដំណាក់នៃការចោទប្រកាន់របស់ព្រះរាជ អាជ្ញា ដែលជាដំណាក់កាលមួយដ៏សំខាន់បំផុតដើម្បីបានឈានទៅដំណាក់កាលជាបន្តបន្ទាប់ទៀតនៃរឿងក្តី។

នាងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង ដោយបានសរសេរសារណាមួយនេះ ដែលមាន សាស្ត្រាចារ្យណែនាំលោក **ចំនួ តារាស្នី** ដោយលោកគ្រូបានផ្តល់ជាគំនិតយោបល់ ការណែនាំ ព្រមទាំងបានផ្តល់នូវ ឯកសារផ្សេងៗដល់យើងទាំងពីរនាក់ ដើម្បីជាគំនិតបន្ថែមនៅក្នុងកិច្ចការនៃការសរសេរសារណាមួយនេះ ដើម្បីអោ យទទួលបាននូវផ្លែផ្កា និងបញ្ចប់ទៅបានយ៉ាងល្អប្រសើរ។ យើងខ្ញុំសង្ឃឹមថាសារណាមួយនេះ ដោយជាកិច្ចការដែល បានកើតចេញពីការខិតខំប្រឹងប្រែងនៃក្រុមយើងខ្ញុំផ្ទាល់ ពោល គឺជាផ្នែកមួយដើម្បីជាចំណេះដឹងបន្ថែមដែលបាន ផ្តល់ជាផលប្រយោជន៍ដល់មិត្តអ្នកអាន សិស្សនិស្សិត ឬ អ្នកដែលកំពុងតែធ្វើការសិក្សាស្វែងយល់ និងស្រាវជ្រាវ ទាក់ទិនទៅនិងប្រធានបទមួយនេះ។ ព្រមទាំងបានក្លាយជាឯកសារស្រាវជ្រាវ ធ្វើការចែករំលែកដល់សិស្សនិស្សិត ជំនាន់ក្រោយៗ ដោយបន្សល់ទុកដើម្បីបានជាឯកសារបន្ថែម និងជាឯកសារជំនួយដល់ស្មារតីផងដែរ។

បើទោះបីជាមានការខិតខំសិក្សាស្រាវជ្រាវ និងការត្រួតពិនិត្យបានយ៉ាងហ្មត់ចត់យ៉ាងណាក៏ដោយក៏ការ សរសេរសារណានេះពិតណាស់ និងមានការកើតមានឡើងនូវចំណុចមួយចំនួនដែលខ្វះខាត ដូចនេះយើងខ្ញុំទាំង ពីរនាក់ សូមស្វាគមន៍នូវរាល់មតិរិះគន់នៅក្នុងន័យស្ថាបនាពីសំណាក់ លោកសាស្ត្រាចារ្យ មិត្តអ្នកអាន និងមិត្ត អ្នកសិក្សាស្រាវជ្រាវនៅគ្រប់មជ្ឈដ្ឋានទាំងអស់ ដោយសេចក្តីគោរពសោមនស្សរីករាយបំផុត និងដោយសុទ្ធចិត្ត ពីយើងខ្ញុំផងដែរ។ ដើម្បីធ្វើការកែលម្អនូវកិច្ចការសារណាមួយនេះ ឱ្យកាន់តែមានលក្ខណៈល្អប្រសើរ ពេញលេញ ពោល គឺដើម្បីឱ្យកម្រងឯកសារនៃកិច្ចការសារណាមួយនេះកាន់តែមានអត្ថន័យ ខ្លឹមសារកាន់តែល្អ និងរឹតតែ ច្បាស់លាស់ ព្រមទាំង មានភាពស៊ីជម្រៅថែមទៀតផងដែរ។

# មាតិកា

ទំព័រ

## សេចក្តីផ្តើម


១. លំនាំបញ្ហា នៃកិច្ចការស្រាវជ្រាវ ........................................ ១

២. ចំណោទបញ្ហា នៃកិច្ចការស្រាវជ្រាវ........................................ ២

៣. គោលបំណង នៃកិច្ចការស្រាវជ្រាវ........................................ ៣

៤. ទំហំ និងដែនកំណត់ និងវិសាលភាព នៃកិច្ចការស្រាវជ្រាវ ........................................ ៣

៥. សារៈសំខាន់ នៃកិច្ចការស្រាវជ្រាវ ........................................ ៤

៦. វិធីសាស្ត្រ នៃការសិក្សាស្រាវជ្រាវ........................................ ៥

៧. រចនាសម្ព័ន្ធ នៃការស្រាវជ្រាវ ........................................ ៦


## ជំពូកទី ១

## ស្ថាប័នអយ្យការ


**ផ្នែកទី១៖ បទបញ្ញត្តិទូទៅ** ........................................ ៨

**ផ្នែកទី២៖ សមាសភាព នៃអង្គការអយ្យការអមសាលាដំបូង** ........................................ ៩

១. ព្រះរាជអាជ្ញា ........................................ ៩

២. ព្រះរាជអាជ្ញារង........................................ ១០

៣. ក្រឡាបញ្ជី ........................................ ១១

**ផ្នែកទី៣៖ គោលការណ៍សំខាន់ៗរបស់អង្គការអយ្យការ**........................................ ១២

១. គោលការណ៍សំខាន់ៗ នៃស្ថាប័នអយ្យការ........................................ ១៣

១.១. គោលការណ៍ឯកភាព (ឋានានុក្រម)........................................ ១៣

១.២. គោលការណ៍ឯករាជ្យ........................................ ១៤

២. គោលការណ៍សំខាន់ៗ នៃថៅក្រមអយ្យការ........................................ ១៥

២.១. គោលការណ៍អវិភាគ........................................ ១៥

២.២. គោលការណ៍ នៃការមិនទទួលខុសត្រូវនូវកាតព្វកិច្ចបំពេញការងាររបស់ខ្លួន ........................................ ១៦

២.៣. គោលការណ៍មិនអាចប្តឹងជិតជិត ........................................ ១៧

២.៤. គោលការណ៍នីត្យានុកូលភាព នៃការចោទប្រកាន់........................................ ១៨

២.៥. ការអនុវត្តន៍គោលការណ៍កាលានុវត្តភាព នៃការចោទប្រកាន់ ........ ១៨
២.៦. គោលការណ៍ នៃការអមសាលាជម្រះក្តី ........ ២០
២.៧. គោលការណ៍ នៃការធ្វើបណ្តឹងដោយផ្ទាល់មាត់នៅក្នុងសវនាការព្រហ្មទណ្ឌ ........ ២០
**ផ្នែកទី៤៖ សមត្ថកិច្ច មុខងារ តួនាទី ភារកិច្ច កាតព្វកិច្ច អំណាច និងការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញា** ........ ២០
១. សមត្ថកិច្ច មុខងារ តួនាទី ភារកិច្ច កាតព្វកិច្ច និងអំណាច ........ ២០
១.១. សមត្ថកិច្ចរបស់ព្រះរាជអាជ្ញា ........ ២០
១.២. មុខងាររបស់ព្រះរាជអាជ្ញា ........ ២១
១.៣. តួនាទីរបស់ព្រះរាជអាជ្ញា ........ ២១
១.៤. ភារកិច្ចរបស់ព្រះរាជអាជ្ញា ........ ២៤
១.៥. កាតព្វកិច្ចរបស់ព្រះរាជ្ញា ........ ២៥
១.៦. អំណាចរបស់ព្រះរាជអាជ្ញា ........ ២៦
១.៦.១. អំណាចរបស់ព្រះរាជអាជ្ញានៅក្នុងការធ្វើបណ្តឹងអាជ្ញា ........ ២៧
១.៦.២. អំណាចនៅក្នុងការស៊ើបអង្កេតបឋម ........ ២៩
១.៦.៣. អំណាចនៅក្នុងការឃាត់ខ្លួន ........ ២៩
១.៦.៤. អំណាចនៅក្នុងការបញ្ជូនខ្លួន ........ ៣០
១.៦.៥. អំណាចនៅក្នុងការឆែកឆេរ ........ ៣១
១.៧. អំណាចអធិបញ្ញា ........ ៣៣
២. ទណ្ឌកម្មផ្នែកវិន័យ នៃវិជ្ជាជីវៈក្នុងនាមជាតំណាងអយ្យការ ........ ៣៤
**ផ្នែកទី៥៖ មុខងារ នៃស្ថាប័នអយ្យការ** ........ ៣៦
១. អំណាចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី-ខេត្ត ........ ៣៧
២. សមត្ថកិច្ចតាមដែនដីរបស់ព្រះរាជអាជ្ញា ........ ៣៨

## ជំពូកទី ២

## បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី

**ផ្នែកទី១៖ បណ្តឹងអាជ្ញា** ........ ៣៩
១. អត្ថន័យ នៃបណ្តឹងអាជ្ញា ........ ៣៩

២. កម្មវត្ថុ នៃបណ្ដឹងអាជ្ញា ........ ៤០
៣. ការកកើត នៃបណ្ដឹងអាជ្ញា ........ ៤០
៣.១. ការចាប់ផ្ដើមដំណើរការ នៃបណ្ដឹងអជ្ញាដោយអយ្យការ ........ ៤០
៣.២. ការដាក់បណ្ដឹងអាជ្ញាឲ្យមានចលនាដោយជនរងគ្រោះ ........ ៤១
៣.៣. ការដាក់ពាក្យបណ្ដឹងទាមទារដោយជនរងគ្រោះ ........ ៤៤
៤. ការរលត់ នៃបណ្ដឹងអាជ្ញា ........ ៤៤
៤.១. មូលហេតុផ្សេងទៀត នៃការរលត់បណ្ដឹងអាជ្ញា ........ ៤៦
៥. ឱក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់ ........ ៤៧
៥.១. អាជ្ញាយុកាល នៃបទល្មើស ........ ៤៧
៥.២. ការផ្ដាច់រយៈពេល នៃអាជ្ញាយុកាល ........ ៤៨
៦. អាជ្ញាអស់ជំនុំ ........ ៤៨
**ផ្នែកទី២៖ បណ្ដឹងរដ្ឋប្បវេណី** ........ ៤៨
១. និយមន័យ នៃបណ្ដឹងរដ្ឋប្បវេណី ........ ៤៨
២. បណ្ដឹងរដ្ឋប្បវេណី និងព្យសនកម្ម ........ ៤៩
២.១. ការជួសជុលព្យសនកម្ម ........ ៤៩
៣. ដើមបណ្ដឹងរដ្ឋប្បវេណី ........ ៥១
៤. ចុងចម្លើយ នៃបណ្ដឹងរដ្ឋប្បវេណី ........ ៥២
៥. ការរំលត់ នៃបណ្ដឹងរដ្ឋប្បវេណី ........ ៥៤
**ផ្នែកទី៣៖ ភាពខុសគ្នារវាងបណ្ដឹងអាជ្ញា និងបណ្ដឹងរដ្ឋប្បវេណី** ........ ៥៤
**ផ្នែកទី៤៖ ទំនាក់ទំនងរវាងបណ្ដឹងអាជ្ញា និងបណ្ដឹងរដ្ឋប្បវេណី** ........ ៥៥

## ជំពូកទី ៣

## ការចោទប្រកាន់របស់ព្រះរាជអាជ្ញា

**ផ្នែកទី១៖ កិច្ចចោទប្រកាន់របស់ព្រះរាជអាជ្ញា** ........ ៥៩
**កថាខណ្ឌទី១៖ ការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរ (RI)** ........ ៥៩
១. លក្ខខណ្ឌ នៃការបើកការស៊ើបសួរ ........ ៦០
១.១. ការបើកការស៊ើបសួរចំពោះបទឧក្រិដ្ឋ ........ ៦១

១.២. ការបើកការស៊ើបសួរចំពោះបទមជ្ឈិម ........................................................ ៦៣
២. នីតិវិធី នៃការបើកការស៊ើបសួរ ........................................................ ៦៤
២.១. នីតិវិធី នៃការបើកការស៊ើបសួរតាមរយៈពាក្យបណ្ដឹងដោយផ្ទាល់ ........................................................ ៦៤
២.២. ការបើកការស៊ើបសួរតាមរយៈសំណុំរឿងបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌ ........................................................ ៦៤
៣. ទម្រង់ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ........................................................ ៦៥
៤. ការចូលរួមរបស់អង្គការអយ្យការនៅក្នុងការស៊ើបសួរ ........................................................ ៦៧
៤.១. ការសួរ និងស្ដាប់ចម្លើយ ........................................................ ៦៨
៤.២. ការប្រគល់វត្ថុដែលចាប់យកឲ្យម្ចាស់ដើមវិញ ........................................................ ៦៩
៤.៣. ដំណើរការ នៃការឃុំខ្លួន ........................................................ ៧០
៤.៤. ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ........................................................ ៧១
៤.៥. ដីកាសន្និដ្ឋានស្ថាពរបញ្ចប់ការស៊ើបសួររបស់អង្គការមហាអយ្យការ ........................................................ ៧២
៥. អនុភាព នៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ........................................................ ៧៣
**កថាខណ្ឌទី២៖ ការចោទប្រកាន់តាមរយៈការបញ្ជូនទៅជំនុំជម្រះផ្ទាល់ (CD)** ........................................................ ៧៥
១. លក្ខខណ្ឌ នៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........................................................ ៧៥
១.១. លក្ខខណ្ឌ នៃបទល្មើស ........................................................ ៧៦
១.២. លក្ខខណ្ឌ នៃសាវតារបស់ជនល្មើស ........................................................ ៧៧
២. នីតិវិធី នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........................................................ ៧៨
២.១. ចិរវេលា នៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........................................................ ៧៩
២.២. របៀប នៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........................................................ ៧៩
២.៣. ការពុំគោរពទៅតាមរយៈពេល នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........................................................ ៨១
២.៤. ផលវិបាកនៃការពុំគោរពទៅតាមរយៈពេល នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........................................................ ៨១
៣. ទម្រង់ នៃដីការកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........................................................ ៨២
៤. អនុភាព នៃដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........................................................ ៨៣
**កថាខណ្ឌទី៣៖ ការចោទប្រកាន់តាមរយៈកំណត់ហេតុ នៃការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម (CI)** ........................................................ ៨៥
១. លក្ខខណ្ឌ នៃការបង្ហាញខ្លួនភ្លាម ........................................................ ៨៦
២. នីតិវិធី នៃការបង្ហាញខ្លួនភ្លាម ........................................................ ៨៧

២.១. នីតិវិធីចាត់ការនៅចំពោះមុខព្រះរាជអាជ្ញា.......................................................................................៨៧
២.២. នីតិវិធីចាត់ការនៅចំពោះមុខយុត្តាធិការជំនុំជម្រះ .......................................................................៨៩
៣. អានុភាព នៃការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម..................................................................................៩០
**ផ្នែកទី២៖ បញ្ហាប្រឈម និងដំណោះស្រាយនៅក្នុងកិច្ចចោទប្រកាន់** .................. ៩១
**កថាខណ្ឌទី១៖ បញ្ហាប្រឈម**...................................................................................................៩១
១. ភាពខ្វះចន្លោះនៃច្បាប់.....................................................................................................................៩១
២. ការពុំមានភស្តុតាង និងសាក្សីច្បាស់លាស់.........................................................................................៩១
៣. ការបំពានទៅលើគោលការណ៍អានាគតិ .............................................................................................៩២
៤. ខ្វះធនធានមនុស្សដែលមានចំណេះជំនាញ និងការយល់ដឹងរបស់មន្ត្រីអនុវត្តន៍ច្បាប់នៅមានកម្រិត ៩២
៥. ការអនុវត្តនីតិវិធី និងការបញ្ជូនដីកាដោះលែងមានភាពយឺតយ៉ាវ..............................................................៩៣
៦. ការរត់គេចខ្លួនរបស់ទណ្ឌិត ឬពិរុទ្ធជន ............................................................................................៩៣
៧. ការអន្តរាគមន៍របស់អ្នកមានអំណាច និងកត្តានយោបាយ .......................................................................៩៤
៨. កត្តាខ្វះខាតនូវសម្ភារបច្ចេកទេស និងសម្ភារផ្សេងៗក្នុងការបំពេញមុខងារ ...............................................៩៥
**កថាខណ្ឌទី២៖ ដំណោះស្រាយ**..............................................................................................៩៥
១. ការបង្កើតលិខិតបទដ្ឋានគតិយុត្ត.........................................................................................................៩៥
២. វិធានភស្តុតាងនៅក្នុងនីតិវិធីព្រហ្មទណ្ឌ ..............................................................................................៩៦
៣. ត្រូវគោរព និងអនុវត្តន៍ឲ្យបានត្រឹមត្រូវចំពោះគោលការណ៍ និងបញ្ញត្តិច្បាប់ .............................................៩៧
៤. ការបន្ថែមមន្ត្រីជំនាញ និងការបណ្តុះបណ្តាលផ្នែកច្បាប់ចំពោះមន្ត្រីដែលអនុវត្តន៍ ....................................៩៧
៥. ការពន្លឿននីតិវិធីនៅក្នុងការដោះស្រាយ ............................................................................................៩៨
៦. ការចាត់វិធានការតឹងរឹង ចំពោះការរត់គេចខ្លួនរបស់ទណ្ឌិត ឬពិរុទ្ធជន .................................................៩៨
៧. ការចាត់វិធានការ និងបង្កើតនូវយន្តការច្បាប់ ដើម្បីការពារនិងទប់ស្កាត់...................................................៩៩
៨. ការបំពេញបន្ថែមទៅលើផ្នែកសម្ភារបច្ចេកទេសក្នុងការបំពេញមុខងារ....................................................៩៩
**សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**
១. សេចក្តីសន្និដ្ឋាន ..................................................................................................................១០០
២. អនុសាសន៍.........................................................................................................................១០១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

យើងបានដឹងរួចមកហើយថាប្រទេសកម្ពុជារបស់យើងបានចាប់ផ្តើមធ្លាក់ក្នុងសង្គ្រាមស៊ីវិលជាង៣ទសវត្សន៍មកហើយបើគិតមកទល់ឆ្នាំ ១៩៩៣ ដោយក្រោមការចរចារក្នុងសន្និសញ្ញាទីក្រុងប៉ារីស ទើបព្រះរាជាណាចក្រកម្ពុជាទទួលបាននូវសុខសន្តិភាពពិតប្រាកដ។ ក្នុងរយៈពេលជាង៣ទស្សវត្សន៍នេះផងដែរ ព្រះរាជាណាចក្រកម្ពុជាបានឆ្លងកាត់៥សម័យកាល ដោយក្រោមរូបភាពនៃសង្គ្រាមក្នុងស្រុក ហើយនៅក្នុងការកើតឡើងនៃសង្គ្រាមនេះផងដែរ បានធ្វើឲ្យហេដ្ឋារចនាសម្ព័ន្ធនៃការគ្រប់គ្រងរដ្ឋ មានការប្រែប្រួលទៅតាមសម័យកាលផងដែរនោះ នឹងថែមទាំងបានធ្វើឲ្យប្រព័ន្ធច្បាប់សំខាន់ៗ លែងមានអានុភាពក្នុងការគ្រប់គ្រងប្រទេសឲ្យប្រសិទ្ធភាព។ នៅក្នុងឆ្នាំ ១៩៩៣ សន្និសញ្ញាទីក្រុងប៉ារីស បានធ្វើឲ្យប្រទេសកម្ពុជាចាប់ផ្តើមកកើតរដ្ឋក្លាយជាព្រះរាជាណាចក្រកម្ពុជាទី២ រហូតមកដល់សព្វថ្ងៃនេះ។ ដើម្បីបង្ការមិនឲ្យមានភាពចលាចលក្នុងស្រុកម្តងទៀត និងរក្សាបាននូវសណ្តាប់ធ្នាប់របៀបរៀបរយ និងសុខសន្តិភាពនៅក្នុងសង្គម រាជរដ្ឋាភិបាលបានផ្តួចផ្តើមធ្វើការបង្កើតឡើងនូវច្បាប់សំខាន់ៗទាំងឡាយដោយសម្រាប់គ្រប់គ្រងរដ្ឋ។

ក្រោមការជួយជ្រោមជ្រែង ពីសំណាក់អង្គការសហប្រជាជាតិប្រទេសកម្ពុជាបានបង្កើតនូវច្បាប់នីតិវិធីមួយឡើង។ ដោយនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ច្បាប់នីតិវិធីនេះបានប្រគល់អំណាចឲ្យទៅព្រះរាជអាជ្ញាជាម្ចាស់បណ្តឹង ដែលអាចធ្វើការចោទប្រកាន់ និងបញ្ជូនជនល្មើសទៅតុលាការដើម្បីផ្តន្ទាទោសទៅតាមផ្លូវច្បាប់។ ព្រះរាជអាជ្ញាធ្វើការក្នុងនាមជាបុគ្គលតំណាងឲ្យរដ្ឋ និងតំណាងឲ្យផលប្រយោជន៍រួមនៃសង្គម ដូចនេះនៅពេលដឹងថាមានបទល្មើសកើតឡើងព្រះរាជអាជ្ញាគ្មានជម្រើសអ្វីក្រៅពីធ្វើការចោទប្រកាន់ ហើយបញ្ជូនជនសង្ស័យនោះទៅឲ្យចៅក្រមស៊ើបសួរឡើយ។ ដោយមានការនឹកគិត និងយល់ថាជម្រើសតែមួយមុខគត់ នោះគឺការចោទប្រកាន់ឲ្យមានបើកការស៊ើបសួររបស់ព្រះរាជអាជ្ញា គឺជាមធ្យោបាយដ៏ល្អបំផុត ដើម្បីស្វែងរកនូវយុត្តិធម៌ជូនជនរងគ្រោះ និងជនជាប់ចោទ។ ប៉ុន្តែដោយសារតែការធ្វើសកម្មភាពដដែលៗ និងជាប្រចាំដែលត្រូវទៅតាមច្បាប់កំណត់សម្រាប់ព្រះរាជអាជ្ញានេះ ពោល គឺបានធ្វើឲ្យកំណើននៃរឿងក្តីស៊ើបសួរមានកាន់តែច្រើនឡើងដោយពីមួយថ្ងៃទៅមួយថ្ងៃ រហូតធ្វើឲ្យក្លាយទៅជារឿងអយុត្តិធម៌ចំពោះភាគីជនរងគ្រោះ និងភាគីជនជាប់ចោទទៅវិញ។ ក្រមនីតិវិធីព្រហ្មទណ្ឌអន្តរកាលឆ្នាំ១៩៩៣ ជាក្រមមួយដែលពុំបានចែងឲ្យបានលម្អិតអំពីនីតិវិធីនៅក្នុងកិច្ចដំណើរការនៃរឿងក្តីព្រហ្មទណ្ឌនោះទេ ដែលចន្លោះប្រហោងផ្នែកច្បាប់តម្រូវនូវភាពអវិជ្ជមានទាំងនោះ ប៉ុន្តែក្រោយមករហូតដល់ឆ្នាំ២០០៧ ដើម្បីធ្វើការដោះស្រាយនូវភាពអវិជ្ជមាន ផលវិបាក និងគុណវិបត្តិ ដែលបានកើតមានឡើងពីកំណើននៃសំណុំរឿងក្តីស៊ើបសួរទាំងអស់នេះ។ ដើម្បីអោយមានភាពប្រសើរជាងមុន ក៏ដូចជាបានដោះស្រាយនូវបញ្ហានេះកម្ពុជាបានបង្កើតនូវក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ដែលត្រូវបានចូលធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ហើយបទដ្ឋានគតិយុទ្ធផ្សេងៗទៀតដែលរួមមានក្រមព្រហ្មទណ្ឌអន្តរកាល និង ក្រមនីតិវិធីព្រហ្មទណ្ឌអន្តរកាល ដែលជាច្បាប់ចាស់ ពោល គឺត្រូវបាននិរាករណ៍ដោយច្បាប់ថ្មីដែលត្រូវបានបង្កើតឡើងនេះ។ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ត្រូវបានចែកចេញជា ១១ គន្ថី និង ៦១២ មាត្រា ដែលគន្ថីនីមួយៗមានការបែងចែកពីនីតិវិធី តួនាទី ភារកិច្ច របស់បុគ្គលដែលមានសិទ្ធិនៅក្នុងកិច្ចដំណើរការនៃរឿងក្តីព្រហ្មទណ្ឌ។ ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧ ក្នុងគន្ថីទី២ អង្គការអយ្យការ គឺជាស្ថាប័នឯករាជ្យដែលដឹកនាំដោយអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង ព្រមទាំងមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ដែលជាសេនាធិការនៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ដោយជាការជួយសម្របសម្រួល និងដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈផងដែរនោះ។ ក្រមនីតិវិធីនេះបានផ្តល់អំណាចឲ្យព្រះរាជអាជ្ញាអាចមានជម្រើសច្រើនជាងមុននៅក្នុងការធ្វើការចោទប្រកាន់ ពោល គឺអាចធ្វើការតម្កល់រឿងទុកឥតចាត់ការ ឬការចោទប្រកាន់ឲ្យបើកការស៊ើបសួរ ឬការបញ្ជូនទៅជំនុំជម្រះជាអាទិ៍។ ជម្រើសទាំងអស់នេះ គឺជាមធ្យោបាយថ្មីមួយចំពោះចំណាត់ការទៅលើរឿងក្តីព្រហ្មទណ្ឌរបស់ស្ថាប័នអយ្យការ។

ដោយនៅក្នុងកិច្ចការសារណានេះផងដែរ ពោល គឺក្រុមយើងខ្ញុំនិងលើកយកតែត្រឹមការចោទប្រកាន់របស់តំណាងអយ្យការមកធ្វើការបកស្រាយ និងបង្ហាញជូនតែប៉ុណ្ណោះ។ ដែលនៅក្នុងកិច្ចនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញានេះផងដែរ យើងក៏ឃើញមានដូចជា៖ ដំណាក់កាលនៃការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរ ដំណាក់កាលនៃការចោទប្រកាន់តាមរយៈការបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការចោទប្រកាន់តាមរយៈកំណត់ហេតុនៃការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។ ហេតុដូច្នេះហើយដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់ពីវិសាលភាពនៃនីតិវិធីនេះ ព្រមទាំងអំពីគោលការណ៍ តួនាទី និងសិទ្ធិអំណាចអយ្យការនៃស្ថាប័នអយ្យការ ទើបក្រុមយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយដែលស្តីអំពី "**អយ្យការអមសាលាដំបូងរាជធានី-ខេត្ត**" មកធ្វើការសិក្សាស្រាវជ្រាវ និងផ្តោតសំខាន់ផងដែលទៅលើលក្ខខណ្ឌ ក៏ដូចជាការចោទប្រកាន់នៃបទល្មើសព្រហ្មទណ្ឌរបស់អយ្យការ ព្រមទាំងមូលហេតុនិងនីតិវិធីនៃតំណាក់កាលនិមួយៗ ដែលស្ថិតនៅក្នុងកិច្ចចោទប្រកាន់របស់តំណាងអយ្យការនេះផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

យើងបានដឹងមកហើយថា នៅក្នុងរឿងក្តីព្រហ្មទណ្ឌអយ្យការបានដើរតួនាទីយ៉ាងសំខាន់បំផុតនៅក្នុងការការពារនូវផលប្រយោជន៍សាធារណៈនៃសង្គម។ ចំពោះការធ្វើបណ្តឹងអាជ្ញា ឬ ការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌ គឺជាតួនាទីតែមួយគត់របស់តំណាងអយ្យការ។ ដើម្បីយល់ដឹងឲ្យកាន់តែច្បាស់ និងមានភាពស៊ីជម្រៅអំពីកិច្ចចោទប្រកាន់របស់ព្រះរាជអាជ្ញានៃស្ថាប័នអយ្យការ ដូច្នេះយើងគួរតែសិក្សាយល់ដឹងអំពី៖

- តើគួរយល់ដឹងអំពីសមត្ថកិច្ច មុខងារ តួនាទី ភារកិច្ច កាតព្វកិច្ច អំណាច និងការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញា?
- តើដំណើរការ នៃនីតិវិធីនៅក្នុងកិច្ចចោទប្រកាន់ទៅលើរឿងក្តីព្រហ្មទណ្ឌរបស់អយ្យការយ៉ាងដូចម្តេចខ្លះ?

- តើតំណាងអយ្យការត្រូវអនុវត្តន៍លក្ខខណ្ឌ និងនីតិវិធីដូចម្តេចខ្លះដើម្បីសម្រេចធ្វើការចោទប្រកាន់នៅក្នុងរឿងក្តីព្រហ្មទណ្ឌ?
- តើព្រះរាជអាជ្ញា អាចជួបនូវបញ្ហាប្រឈមអ្វីខ្លះ? នៅក្នុងកិច្ចដំណើរការនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា?
- តើព្រះរាជអាជ្ញាត្រូវមានដំណោះស្រាយអ្វីខ្លះ ចំពោះបញ្ហាប្រឈមដែលកើតមានឡើងទាំងអស់នោះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងសំខាន់ៗ នៃការស្រាវជ្រាវទាក់ទងទៅនឹងការចោទប្រកាន់របស់ព្រះរាជអាជ្ញា នៃស្ថាប័នអយ្យការ គឺផ្តោតទៅលើចំណុចមួយចំនួនដូចជា៖

- សិក្សាយល់ដឹងអំពីអង្គការអយ្យការ ដែលជាស្ថាប័នមួយដែលការពារទៅដល់ផលប្រយោជន៍សាធារណៈរបស់សង្គម
- សិក្សាទៅលើស្ថានភាពទូទៅរបស់ស្ថាប័នអយ្យការ
- សិក្សាទៅលើរចនាសម្ព័ន្ធ សមត្ថកិច្ច មុខងារ តួនាទី ភារកិច្ច កាតព្វកិច្ច អំណាច និងការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញា និងគោលការណ៍សំខាន់ៗរបស់ស្ថាប័នអយ្យការ
- សិក្សាយល់ដឹងលម្អិតទៅលើអ្វីទៅជាបណ្តឹងអាជ្ញា និងអ្វីទៅជាបណ្តឹងរដ្ឋប្បវេណី ថាតើបណ្តឹងទាំងពីរមានភាពខុសគ្នាយ៉ាងដូចម្តេច ហើយតើបណ្តឹងទាំងពីរនេះមានទំនាក់ទំនងនឹងគ្នាដែរ ឬទេ?
- សិក្សាយល់ដឹងអំពីកិច្ចចោទប្រកាន់របស់ព្រះរាជអាជ្ញា
- សិក្សាអំពីលក្ខខណ្ឌ និងនីតិវិធីក្នុងការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌរបស់អយ្យការ
- សិក្សាយល់ដឹងទៅលើបញ្ហាប្រឈមនានា របស់ព្រះរាជអាជ្ញាក្នុងកិច្ចចោទប្រកាន់
- សិក្សាយល់ដឹងទៅនិងដំណោះស្រាយ នៅពេលដែលកើតមាននូវរាល់បញ្ហាប្រឈមទាំងអស់នោះ
- ការធ្វើសេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

### ៤.១. ទំហំ

ស្ថាប័នអយ្យការ គឺជាស្ថាប័នរបស់រដ្ឋមួយ ដែលមានអមនៅគ្រប់តុលាការទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាមូលហេតុធ្វើឲ្យក្រុមយើងខ្ញុំមិនអាចធ្វើការសិក្សាស្រាវជ្រាវលម្អិត បានគ្រប់ស្ថាប័នអយ្យការអមតុលាការទាំងអស់បាននោះទេ។ ដូច្នេះនៅក្នុងដំណើរការនៃកិច្ចការសិក្សាស្រាវជ្រាវមួយនេះ គឺក្រុមយើងខ្ញុំផ្តោតសំខាន់តែលើប្រធានបទ អយ្យការអមសាលាដំបូងរាជធានី-ខេត្ត ដែលមាននៅក្នុងខ្លឹមសារ និងអត្ថន័យ នៃប្រធានបទនេះតែប៉ុណ្ណោះ។

### ៤.២. ដែនកំណត់

ដោយផ្អែកទៅលើប្រធានបទដែលបានកំណត់រួចការសិក្សាស្រាវជ្រាវនេះ គឺស្រាវជ្រាវផ្តោត និងការយកចិត្តទុកដាក់ ដែលស៊ីជម្រៅតែទៅលើចំណុចមួយចំនួនដូចមាននៅខាងក្រោម៖

- ❖ បទបញ្ញត្តិទូទៅ សមាសភាព សមត្ថកិច្ច មុខងារ តួនាទី ភារកិច្ច កាតព្វកិច្ច អំណាច និងការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញា និងគោលការណ៍សំខាន់ៗរបស់ស្ថាប័នអយ្យការ
- ❖ បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីដែលកើតមានឡើងនៅក្នុងរឿងក្តីព្រហ្មទណ្ឌ
- ❖ ភាពខុសគ្នារវាងបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី
- ❖ ទំនាក់ទំនងរវាងបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី
- ❖ ការចោទប្រកាន់ទៅលើរឿងក្តីព្រហ្មទណ្ឌរបស់អយ្យការ
- ❖ នីតិវិធីនៃការចោទប្រកាន់របស់អយ្យការ
- ❖ បញ្ហាប្រឈមនានា ដែលអាចនិងកើតមានឡើងនៅក្នុងកិច្ចនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា
- ❖ ដំណោះស្រាយទៅនិងបញ្ហាប្រឈមដែលបានកើតមានឡើងក្នុងកិច្ចចោទប្រកាន់

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ ការចោទប្រកាន់របស់ស្ថាប័នអយ្យការ បានផ្តល់សារៈសំខាន់មួយចំនួនដូចជា៖

- ❖ ទទួលបាននូវចំណេះដឹងថ្មីៗទាក់ទងនឹងការស្រាវជ្រាវ ព្រមទាំងបានយល់ដឹងកាន់តែលម្អិតទាក់ទងប្រធានបទ
- ❖ យល់ដឹងពីស្ថានភាពទូទៅរបស់ស្ថាប័នអយ្យការនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ❖ យល់ដឹងពីរចនាសម្ព័ន្ធ សមាសភាព និងគោលការណ៍សំខាន់ៗរបស់ស្ថាប័នអយ្យការ
- ❖ យល់ដឹងពីសមត្ថកិច្ច មុខងារ តួនាទី ភារកិច្ច កាតព្វកិច្ច ការទទួលខុសត្រូវ និងសិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា
- ❖ យល់ដឹងកាន់តែច្បាស់ទៅលើបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី ភាពខុសគ្នានៃបណ្តឹងទាំងពីរ ព្រមទាំងទំនាក់ទំនងរវាងបណ្តឹងទាំងពីរ
- ❖ យល់ដឹងពីកិច្ចចោទប្រកាន់របស់ព្រះរាជអាជ្ញា
- ❖ យល់ដឹងពីលក្ខខណ្ឌនិមួយៗ នៃការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌរបស់អយ្យការ
- ❖ យល់ដឹងពីនីតិវិធី និងអានុភាពក្នុងការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌរបស់អយ្យការ
- ❖ យល់ដឹងអំពីបញ្ហាប្រឈម និង ដំណោះស្រាយដែលកើតមាននៅក្នុងកិច្ចនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា

- ពង្រឹងចំណេះដឹងបន្ថែមទាក់ទងទៅនឹងដំណើរការនៃការចោទប្រកាន់របស់ស្ថាប័នអយ្យការ
- ធ្វើការកែប្រែនូវចំណុចអវិជ្ជមានផ្សេងៗ ដើម្បីឲ្យដំណើរការចោទប្រកាន់ នៅក្នុងរឿងក្តីព្រហ្មទណ្ឌរបស់អយ្យការកាន់តែមានភាពប្រសើរឡើងថែមមួយកម្រិតទៀត
- ផ្តល់ជាឯកសារទុកសម្រាប់សិស្សនិស្សិត អ្នកសិក្សា និងអ្នកស្រាវជ្រាវជំនាន់ក្រោយ។

# ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

## ៦.១. វិធីសាស្ត្រប្រមូលទិន្នន័យ

នៅក្នុងការសិក្សាស្រាវជ្រាវមួយនេះ យើងបានធ្វើការប្រមូលព័ត៌មាន និងទិន្នន័យមកសំអាងពីទិន្នន័យចម្បងនិងទិន្នន័យបន្ទាប់បន្សំ។ ដើម្បីឲ្យដំណើរការនៃការស្រាវជ្រាវនេះប្រកបដោយភាពជោគជ័យ យើងទាមទារនូវតម្រូវការទិន្នន័យជាច្រើន ដែលទទួលបានពីប្រភពចម្បងពីរដែលសម្រួលក្នុងការប្រមូលទិន្នន័យ និងវិភាគឲ្យបានគ្រប់គ្រាន់គឺ ទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំ។

### ក. ទិន្នន័យចម្បង

ទិន្នន័យចម្បង ជាទិន្នន័យដែលទទួលបានតាមរយៈមធ្យោបាយមួយចំនួនដូចខាងក្រោម៖

- ការសាកសួរយោលបល់ពីសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រ និងសាស្ត្រាចារ្យណែនាំ
- ការសាកសួរតាមប្រព័ន្ធទំនាក់ទំនងសង្គមជាមួយមន្ត្រីស្ថាប័នរដ្ឋ និងក្រឡាបញ្ជីអមសាលាដំបូង
- ការសាកសួរទៅកាន់សិស្សច្បង និងមិត្តភក្តិដែលសិក្សាផ្នែកនីតិសាស្ត្រ។

### ខ. ទិន្នន័យបន្ទាប់បន្សំ

ទិន្នន័យបន្ទាប់បន្សំ ជាទិន្នន័យដែលទទួលបានតាមមធ្យោបាយមួយចំនួនដូចខាងក្រោម៖

- លិខិតបទដ្ឋានគតិយុត្ត និងច្បាប់ដែលមានជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ និងក្រមព្រហ្មទណ្ឌឆ្នាំ២០១០
- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤
- ឯកសារ និងទ្រឹស្តីដែលបានមកពីការសិក្សាជាមួយសាស្ត្រាចារ្យនៅសាកលវិទ្យាល័យកន្លងមក
- សៀវភៅពុម្ព និងឯកសាររបស់សាស្ត្រាចារ្យដែលទាក់ទងនឹងស្ថាប័នអយ្យការ និងនីតិវិធីព្រហ្មទណ្ឌ
- សារណាស្រាវជ្រាវរបស់និស្សិតនីតិសាស្ត្រជំនាន់មុនៗ
- ការស្រាវជ្រាវនៅតាមបណ្ណាល័យ តូបសៀវភៅ និងបណ្ណាគារផ្សេងៗ
- ការស្រាវជ្រាវបន្ថែមតាមប្រព័ន្ធអ៊ីនធើណែត និងតាមប្រភពផ្សេងៗទៀត។

### ៦.២. វិធីសាស្ត្រវិភាគទិន្នន័យ

ចំពោះវិធីសាស្ត្រវិភាគទិន្នន័យ ដែលប្រើប្រាស់ក្នុងការវិភាគសារណា ដែលទាក់ទងទៅនឹងការចោទប្រកាន់របស់ស្ថាប័នអយ្យការនេះ គឺត្រូវបានកំណត់ និងអនុវត្តន៍នូវវិធីសាស្ត្រតាមបែបគុណភាព និងមិនធ្វើតាមបែបបរិមាណនោះទេ។

សម្រាប់ការវិភាគទិន្នន័យ គឺក្រុមយើងខ្ញុំយកទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំ ដែលប្រមូលបានមកវិភាគ ដើម្បីឈានទៅដល់ការទាញចេញជាសេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានបែងចែកចេញជាបីជំពូកដូចមានខាងក្រោម៖

**ជំពូកទី១៖ ស្ថាប័នអយ្យការ** គឺធ្វើការរៀបរាប់អំពីស្ថាប័នអយ្យការដែលទាក់ទងទៅនឹងរចនាសម្ព័ន្ធ បទបញ្ញត្តិទូទៅ សមាសភាព សមត្ថកិច្ច មុខងារ តួនាទី ភារកិច្ច កាតព្វកិច្ច និងសិទ្ធិអំណាចរបស់អយ្យការ ព្រមទាំងគោលការណ៍សំខាន់ៗរបស់ស្ថាប័នអយ្យការនេះផងដែរ។

**ជំពូកទី២៖ បណ្ដឹងអាជ្ញា និងបណ្ដឹងរដ្ឋប្បវេណី៖** ជាការពិតណាស់ បើតាមការយល់ឃើញ និងគិតដល់មុនគេនោះ ពោល គឺនៅពេលដែលលឺគេនិយាយដល់បណ្ដឹងអាជ្ញា ច្បាស់ណាស់ថាប្រាកដជានឹកឃើញដល់រឿងក្ដីព្រហ្មទណ្ឌពីព្រោះថាបណ្ដឹងអាជ្ញា គឺជាបណ្ដឹងផ្នែកព្រហ្មទណ្ឌ ប៉ុន្តែទន្ទឹមនឹងនេះផងដែលបើយើងធ្វើការសង្កេត និងសិក្សាស្វែងយល់ យើងក៏នឹងឃើញមានការលេចចេញនូវបណ្ដឹងរដ្ឋប្បវេណីផងដែរ ដែលកើតមានឡើងដំណាលគ្នាផងដែលនៅក្នុងរឿងក្ដីតែមួយ។ ហេតុដូចនេះ យើងនឹងត្រូវធ្វើការសិក្សាលម្អិតត្រង់ចំណុចនៃបណ្ដឹងអាជ្ញា បណ្ដឹងរដ្ឋប្បវេណី ភាពខុសគ្នារវាងបណ្ដឹងអាជ្ញានិងបណ្ដឹងរដ្ឋប្បវេណី និងទំនាក់ទំនងរវាងបណ្ដឹងអាជ្ញា និងបណ្ដឹងរដ្ឋប្បវេណី។

**ជំពូកទី៣៖ ការចោទប្រកាន់របស់អយ្យការ៖** រៀបរាប់លម្អិតអំពីការចោទប្រកាន់របស់អយ្យការ ដែលសិក្សាទៅលើចំណុចដូចជា លក្ខខណ្ឌ នីតិវិធីនៃការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរ និងអានុភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ព្រមទាំងសិក្សាទៅលើលក្ខខណ្ឌ នីតិវិធីនៃការចោទប្រកាន់តាមការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ និងអានុភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ចុងក្រោយ គឺសិក្សាទៅលើលក្ខខណ្ឌ នីតិវិធីនៃការចោទប្រកាន់តាមរយៈកំណត់ហេតុបង្ហាញខ្លួនភ្លាម និងអានុភាពនៃការបង្ហាញខ្លួនភ្លាម ព្រមទាំងមានការលើកឡើងអំពីបញ្ហាប្រឈម និងដំណោះស្រាយនៅក្នុងការអនុវត្តន៍នីតិវិធីនៃបញ្ហាប្រឈមនេះផងដែរ។

**សេចក្ដីសន្និដ្ឋាន និងអនុសាសន៍៖** ការស្វែងរកចំណុចវិជ្ជមាន និងចំណុចអវិជ្ជមាន ដែលកើតមានឡើង និងការវិភាគស្វែងរកដំណោះស្រាយ ដ៏សមរម្យដើម្បីចូលរួមកាត់បន្ថយ នូវកង្វះខាតដែលបានកើតឡើងនៅក្នុងកិច្ចការមួយនេះ។

# ជំពូកទី ១
# ស្ថាប័នអយ្យការ

# ជំពូកទី ១

# ស្ថាប័នអយ្យការ

ស្ថាប័នអយ្យការ គឺជាស្ថាប័នមួយដែលយើងឃើញមានតួនាទីសំខាន់ណាស់ នៅក្នុងរឿងក្តីព្រហ្មទណ្ឌ ហើយបើយោងទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏បានបញ្ញត្តិផងដែរថាគាត់ គឺជាម្ចាស់នៃបណ្តឹងអាជ្ញា ដោយមានតែអង្គការអយ្យការទេដែលមានសិទ្ធិ និងមុខងារធ្វើបណ្តឹងអាជ្ញាដែលអនុវត្តនូវមុខងារទៅតាមគោលការណ៍កំណត់របស់ច្បាប់និងបទបញ្ញត្តិជាធរមាន ដោយនៅក្នុងនោះយើងឃើញមានអយ្យការអមសាលាដំបូងរាជធានី-ខេត្តតំណាងដោយព្រះរាជអាជ្ញានិងព្រះរាជអាជ្ញារង ខណៈមហាអយ្យការអមសាលាឧទ្ធរណ៍ និងតុលាការកំពូលតំណាងដោយអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញា។ ស្ថាប័នអយ្យ ការក៏ត្រូវធានារ៉ាប់រងលើការអនុវត្តសេចក្តីសម្រេចខាងបទល្មើសព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន។

យើងសង្កេតឃើញថាក្នុងការដោះស្រាយនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ពោល គឺត្រូវធ្វើឡើងដោយអនុវត្តទៅតាមនីតិវិធីព្រហ្មទណ្ឌ ដោយនៅក្នុងការជំនុំជម្រះនៃរឿងក្តីនិមួយៗ ដែលបានកើតមានឡើងទៅតាមប្រព័ន្ធតុលាការដោយនៅក្នុងនេះផងដែរ យើងឃើញថានៅក្នុងប្រព័ន្ធតុលាការ នៃព្រះរាជាណាចក្រកម្ពុជារបស់យើងបានធ្វើការបែងចែកជា ៣ (បី) ថ្នាក់រួមមាន៖ សាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល។ បើយើងក្រឡេកទៅមើលរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ នៅត្រង់ចំណុចនៃមាត្រា១២៨ យើងឃើញថាអំណាចតុលាការគឺជាអំណាចមួយដែលឯករាជ្យ អំណាចតុលាការជាអំណាចដែលធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ[1]។ សាលាដំបូង គឺជាសាលាជម្រះក្តីជាន់ទាបដែលអមដោយអយ្យការមួយហៅថាអយ្យការអមសាលាដំបូងដែលមាននៅគ្រប់រាជធានី-ខេត្តនៃព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងនេះផងដែរ យើងក៏ឃើញមានការកំណត់នៅក្នុងច្បាប់ផ្សេងទៀត ពោល គឺមានន័យថាសាលាជម្រះក្តីថ្នាក់ទីមួយ ដែលត្រូវបានបង្កើតឡើងឲ្យមាននៅរាជធានីភ្នំពេញ និងនៅគ្រប់ខេត្តនៃព្រះរាជាណាចក្រកម្ពុជា។ ការដាក់ឲ្យដំណើរការសាលាដំបូងនានាត្រូវបានធ្វើឡើងដោយព្រះរាជក្រឹត្យ។ សាលាដំបូង ត្រូវបែងចែកជាតុលាការជំនាញ ដោយសាលាដំបូងគឺជាសាលាជម្រះក្តីទូទៅ ដែលមានសមត្ថកិច្ចជម្រះរឿងក្តីទាំងអស់លើកលែងតែរឿងក្តីដែលស្ថិតនៅក្រោមសមត្ថកិច្ចនៃសាលាជម្រះក្តីពិសេស ឬ សាលាជម្រះក្តីវិសាមញ្ញដែលបង្កើតឡើងដោយច្បាប់ដោយឡែក។[2] សាលាដំបូង គឺជាសាលាជម្រះក្តីជាន់ដំបូងមានទីតាំងនៅតាមខេត្ត និងក្រុងនៃព្រះរាជាណាចក្រកម្ពុជា។[3]

---

[1] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា ១២៨

[2] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤ មាត្រា ១២

[3] ច្បាប់ស្តីពីការចាត់តាំងអង្គការតុលាការ និងអយ្យការ មាត្រា ៥៣

ដោយនៅក្នុងសាលាដំបូង នៃការផ្ដើមនៅនីតិវិធីតាមប្រព័ន្ធតុលាការនេះ ជាជាក់ស្ដែងយើងឃើញថា មានការដើរតួនាទីយ៉ាងសំខាន់ ពោល គឺពីសំណាក់អង្គការអយ្យការនៅគ្រប់ជាន់ថ្នាក់ដោយរួមមានដូចជា៖ មុខការរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល មុខការរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងមុខការរបស់ព្រះរាជអាជ្ញាអមសាលាដំបូង។ ប៉ុន្តែនៅក្នុងប្រធានបទមួយនេះ គឺបានលើកយកតែពីមុខការរបស់ព្រះរាជអាជ្ញាអមសាលាដំបូង ដោយត្រឹមតែការចោទប្រកាន់របស់អយ្យការតែប៉ុណ្ណោះ ដើម្បីយកមកធ្វើការបកស្រាយ និងបង្ហាញជូន ដូច្នេះដើម្បីអោយមានភាពស៊ីជម្រៅទៅនិងប្រធានបទខាងលើដោយនៅក្នុងជំពូកទី១ នេះផងដែរ ជាដំបូង គឺយើងនិងធ្វើការយល់ទៅលើផ្នែកនីមួយៗដែលនឹងត្រូវយកមកធ្វើការបកស្រាយនៅក្នុងចំណុច នៃការចាប់ផ្ដើមនៅក្នុងប្រធានបទមួយនេះផងដែររួមមាន៖

- **ផ្នែកទី១៖** បទបញ្ញត្តិទូទៅ
- **ផ្នែកទី២៖** សមាសភាព នៃអង្គការអយ្យការអមសាលាដំបូង
- **ផ្នែកទី៣៖** គោលការណ៍សំខាន់ៗរបស់អង្គការអយ្យការ
- **ផ្នែកទី៤៖** សមត្ថកិច្ច មុខងារ តួនាទី ភារកិច្ច កាតព្វកិច្ច អំណាច និងការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញា
- **ផ្នែកទី៥៖** មុខងារ នៃស្ថាប័នអយ្យការ

## ផ្នែកទី១៖ បទប្បញ្ញត្តិទូទៅ

បុគ្គលដែលត្រូវបានជ្រើសរើស សម្រាប់អោយបំពេញការងារជាចៅក្រមនិងព្រះរាជអាជ្ញា ពោល គឺត្រូវតែជាអ្នកដែលមានសមត្ថភាព និងជាអ្នកសុចរិត មានសីលធម៌ ស្អាតស្អំ។[4] នៅក្នុងអាជីពរបស់ខ្លួន ចៅក្រមអាចត្រូវបានតែងតាំងជាព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញា ក៏អាចត្រូវបានតែងតាំងជាចៅក្រមវិញបានដែរ។[5]

ចៅក្រម និងព្រះរាជអាជ្ញាត្រូវបានទទួលការការពារសន្តិសុខ សុវត្ថិភាពផ្ទាល់ខ្លួន និងគ្រួសារក្នុងករណីចាំបាច់តាមសំណូមពររបស់សាមីខ្លួន។ ចៅក្រម និងព្រះរាជអាជ្ញា មិនត្រូវទទួលខុសត្រូវខាងបទព្រហ្មទណ្ឌ ឬបទរដ្ឋប្បវេណីណាមួយ ចំពោះការសម្រេចដែលបានធ្វើក្នុងក្របខណ្ឌសមត្ថកិច្ច និងមុខងាររបស់ខ្លួនក្នុងឋានៈជាចៅក្រម ឬ ព្រះរាជអាជ្ញាឡើយ។ គោលការណ៍នេះ មិនត្រូវយកមកអនុវត្តឡើយក្នុងករណីដែលចៅក្រម ឬព្រះរាជអាជ្ញាប្រើប្រាស់ការសម្រេចរបស់ខ្លួន ដោយរំលោភបំពានធ្ងន់ធ្ងរក្នុងចេតនាទុច្ចរិតទៅលើសមត្ថកិច្ច និងមុខងារដែលច្បាប់ប្រគល់ឲ្យ។[6]

---

[4] ច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា ៤

[5] ច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា ៥

[6] ច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា ៦

ចៅក្រម និងព្រះរាជអាជ្ញាទាំងអស់ស្ថិតនៅក្នុងក្របខណ្ឌរដ្ឋបាលកណ្ដាលរបស់ក្រសួងយុត្តិធម៌ និងអាចចាត់ឲ្យបំពេញការងារនៅក្រសួងយុត្តិធម៌បាន។ ក្នុងករណីត្រូវទៅបំពេញការងារនៅក្រសួងយុត្តិធម៌ ចៅក្រមត្រូវស្នើសុំការយល់ព្រមពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ក្នុងរយៈពេលបំពេញការងារនៅក្រសួងយុត្តិធម៌ចៅក្រម និងព្រះរាជអាជ្ញាត្រូវស្ថិតនៅក្រោមលក្ខន្តិកៈព្រះរាជអាជ្ញា និងទទួលបាននូវប្រាក់បៀវត្ស និងប្រាក់បំណាច់មុខងារដូចព្រះរាជអាជ្ញាដែលបម្រើការងារនៅក្នុងអង្គការអយ្យការអមសាលាជម្រះក្ដីដែរ។ ក្នុងករណីដែលប្រាក់បៀវត្ស និងប្រាក់បំណាច់មុខងារមានភាពខុសគ្នា សាមីខ្លួនមានសិទ្ធិជ្រើសរើសយកប្រាក់បៀវត្ស ឬប្រាក់បំណាច់មុខងារណាមួយដែលខ្ពស់ជាង។[7]

នៅក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាបានធ្វើការបញ្ញត្តិថា មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា[8] ព្រះរាជអាជ្ញាជាអ្នកទទួលបន្ទុកស្វែងរកបទល្មើសព្រហ្មទណ្ឌ ធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។ ក្នុងរឿងរដ្ឋប្បវេណី និងរឿងក្ដីផ្សេងទៀត តំណាងអង្គការអយ្យការអាចចូលរួមក្នុងនីតិវិធីតុលាការ និងបញ្ចេញយោបល់បាន ប្រសិនបើខ្លួនយល់ឃើញថាចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ។[9]

## ផ្នែកទី២៖ សមាសភាព នៃអង្គការអយ្យការអមសាលាដំបូង

បើស្របទៅតាមមាត្រា២៩ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាឆ្នាំ ២០១៤ បានចែងអំពីសមាសភាពអយ្យការអមសាលាដំបូងរួមមាន[10]៖ ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលជាមន្ត្រីបម្រើការងារនៅអយ្យការអមសាលាដំបូង។

ដោយអយ្យការអមសាលាដំបូងត្រូវដឹកនាំដោយព្រះរាជអាជ្ញា ០១ (មួយ) រូប និងអមដោយព្រះរាជអាជ្ញារង មួយចំនួនតាមការចាំបាច់។ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងជាតំណាងអយ្យការអមសាលាដំបូងដែលខ្លួនបំពេញការងារ។[11]

### ១. ព្រះរាជអាជ្ញា

ព្រះរាជាអាជ្ញា គឺជាមន្ត្រីដែលស្ថិតនៅក្នុងស្ថាប័នអយ្យការ ជាអ្នកទទួលបន្ទុកស្វែងរកបទល្មើសព្រហ្មទណ្ឌ ដោយធ្វើការចោទប្រកាន់ និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះដែល

[7] ច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា ៧

[8] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា ១៣១

[9] ច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា ៧៤ កថាខណ្ឌទី ៤ និងទី ៥

[10] ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤ មាត្រា ២៩

[11] ច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា ៧៤ កថាខណ្ឌទី ៣

ក្នុងនាមការពារផលប្រយោជន៍សង្គម។ អង្គការអយ្យការ ក៏ធានារ៉ាប់រងការអនុវត្តន៍សេចក្តីសម្រេចខាងបទល្មើស ព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយបង្គាប់អោយចាប់ខ្លួន។ បើយើងក្រឡេកទៅមើល នៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ពោល គឺព្រះរាជអាជ្ញាបើតាមវាក្យសព្ទបច្ចេកទេស នៃ ច្បាប់នេះ គឺសំដៅដល់ព្រះរាជអាជ្ញារង ព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងអគ្គព្រះរាជអាជ្ញា។[12]

ដោយមានន័យថាព្រះរាជអាជ្ញា គឺជាប្រមុខដឹកនាំរបស់អង្គការអយ្យការអមសាលាដំបូងរាជធានីខេត្ត នីមួយៗនៃប្រទេសកម្ពុជា នៅរាល់អយ្យការអមសាលាដំបូងនីមួយៗ ត្រូវបានដឹកនាំដោយព្រះរាជអាជ្ញាចំនួន មួយរូប ព្រះរាជអាជ្ញាប្រើប្រាស់អំណាចទាំងអស់ ដែលបានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ ក៏ដូចជា បទប្បញ្ញត្តិនានាដែលនៅជាធរមានក្នុងការធ្វើសកម្មភាពរបស់ខ្លួនក្នុងនាមជាតំណាងអយ្យការ។ ព្រះរាជអាជ្ញា មានតួនាទី ក្នុងការទទួលខុសត្រូវលើការប្រព្រឹត្តទៅទាំងមូល របស់អង្គការអយ្យការអមសាលាដំបូងរាជធានី ខេត្តដែលមានខ្លួនជាអ្នកដំណាង ដែលជាហេតុនាំឱ្យព្រះរាជអាជ្ញាត្រូវទទួលខុសត្រូវ ចំពោះការងាររបស់ខ្លួនផង និងការងាររបស់ព្រះរាជអាជ្ញារងដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនទាំងអស់ផងដែរ។

### ២. ព្រះរាជអាជ្ញារង

ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង នៃសាលាដំបូងជាតំណាងឱ្យអយ្យការអមសាលាដំបូង ដែលខ្លួន បំពេញការងារ។[13] មានន័យថារាល់អយ្យការអមសាលាដំបូងរាជធានី-ខេត្តនីមួយៗ ត្រូវមានព្រះរាជអាជ្ញាតែ មួយរូបប៉ុណ្ណោះដែលជាតំណាង ប៉ុន្តែអាចមានព្រះរាជអាជ្ញារងជាច្រើនរូប ដែលមិនអាចកំណត់ចំនួនមួយជាក់ លាក់បានឡើយ ពោល គឺអាស្រ័យទៅតាមតម្រូវការការងារ និងភាពចាំបាច់របស់ស្ថាប័ន។

ដោយថាព្រះរាជអាជ្ញារង "នូវរាល់សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញារងត្រូវតែបញ្ជូនទៅឱ្យព្រះរាជអាជ្ញា ត្រួតពិនិត្យជាមុនសិននៅមុនពេលសវនាការ។ ក្នុងករណីដែលព្រះរាជអាជ្ញាមិនយល់ព្រមលើសេចក្តីសន្និដ្ឋាន នោះទេហើយតំណាងអយ្យការដែលជាអ្នកធ្វើសេចក្តីសន្និដ្ឋាននោះនៅតែមិនព្រមធ្វើតាម ព្រះរាជអាជ្ញាអាចចាត់ តាំងព្រះរាជអាជ្ញារងផ្សេងទៀត ឬ ក៏ចាត់តាំងខ្លួនឯងតែម្តងឱ្យធ្វើជាតំណាងអយ្យការក្នុងសវនាការ នៃសាលាដំបូង"។ តាមរយៈមាត្រានេះបានសបញ្ជាក់ថាថ្វីត្បិតតែព្រះរាជអាជ្ញារង មានសិទ្ធិក្នុងការប្រើប្រាស់សិទ្ធិអំណាចទាំងអស់ របស់ព្រះរាជអាជ្ញា ប៉ុន្តែសិទ្ធិអំណាចមួយចំនួននោះត្រូវតែស្ថិតនៅក្រោមការគ្រប់គ្រងត្រួតពិនិត្យ និងសម្រេចរបស់ ព្រះរាជអាជ្ញា។

[12] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា ៣

[13] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា ៧៤ កថាខណ្ឌទី ៣

### ៣. ក្រឡាបញ្ជី

ក្រឡាបញ្ជី គឺជាអ្នកបច្ចេកទេសផ្នែកនីតិវិធីដែលជួយសម្រួលដល់ចៅក្រម និងព្រះរាជអាជ្ញានៅក្នុងសកម្មភាពសាលាជម្រះក្តីទៅតាមលក្ខខណ្ឌដែលមាននៅក្នុងប្បញ្ញត្តិច្បាប់ ឬ បទបញ្ជាដែលមានជាធរមាន។

ក្រឡាបញ្ជី គឺជាសមាសភាពមួយដែលអនុវត្តមុខងាររបស់ខ្លួននៅតាមសាលាក្តីគ្រប់ជាន់ថ្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងអយ្យការអមសាលាដំបូង គឺមានក្រឡាបញ្ជីជាច្រើនរូបដែលជាលេខាធិការផ្ទាល់របស់ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងក្នុងការបំពេញការងារទាំងផ្នែករដ្ឋបាល និងចំណាត់ការលើសំណុំរឿងឱ្យកាន់តែមានភាពងាយស្រួល។ ក្រឡាបញ្ជីជាមន្ត្រីក្របខណ្ឌ នៃក្រសួងយុត្តិធម៌ដែលមានតួនាទីជាជំនួយការរបស់ព្រះរាជអាជ្ញា និងចៅក្រមនៅគ្រប់ដំណាក់កាល។ នៅក្នុងដំណាក់កាលព្រះរាជអាជ្ញា ក្រឡាបញ្ជីស្ថិតនៅក្រោមការបង្គាប់បញ្ជា និងដឹកនាំរបស់ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងដែលខ្លួនស្ថិតនៅអមសម្រាប់កិច្ចការផ្នែកយុត្តាធិការហើយបំពេញតួនាទីមុខងារទាំងផ្នែកកិច្ចការរដ្ឋបាល និងការធ្វើចំណាត់ការលើសំណុំរឿង ដូចជា៖ ធ្វើការកត់ត្រារាល់ព័ត៌មានតាមរយៈការសាកសួរ ឬស្តាប់ចម្លើយរបស់ជនជាប់សង្ស័យ ឬជនល្មើស ឬសាក្សី ការធ្វើកំណត់ហេតុ ការធ្វើសេចក្តីព្រាងដីកា ឬសំណុំលិខិតផ្សេងៗសម្រាប់ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ការចុះលេខសំណុំឯកសារ ការរក្សាទុកនូវសំណុំរឿង និងស្រាវជ្រាវរកនូវឯកសារផ្សេងៗទៀត។ល។ ចំពោះសេចក្តីសម្រេចក៏ដូចជាសេចក្តីសន្និដ្ឋានណាមួយ ដែលជាសមត្ថកិច្ចរបស់ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង គឺក្រឡាបញ្ជីមិនត្រូវបានអនុញ្ញាតឱ្យបំពេញបានឡើយ។

លើសពីនេះទៅទៀត នៅត្រង់សមាសភាពរបស់អង្គការអយ្យការផងដែរ យើងក៏ឃើញមានការបញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដោយចៅក្រមអយ្យការមាន[14]៖

- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល
- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង

**អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលៈ** គឺជាតំណាងនៃស្ថាប័នមហាអយ្យការអមតុលាការកំពូល អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល មានតួនាទីក្នុងការចូលរួមក្នុងការស្នើសុំឲ្យមានការគោរពច្បាប់នៅក្នុងពេលដែលមានបណ្តឹងសាទុក្ខ បណ្តឹងសើរើ និងបណ្តឹងតវ៉ាផ្សេងៗទៀតដែលដាក់ជូនតុលាការកំពូលពិនិត្យ។[15]

[14] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២៨

[15] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៣១ និង ៣២

**អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍:** គឺជាតំណាងនៃស្ថាប័នមហាអយ្យការអមសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញាឃ្លាំមើលការអនុវត្តច្បាប់។

នៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញា អាចធ្វើអធិការកិច្ចនៅអង្គភាពអយ្យការទាំងឡាយដែលស្ថិតនៅក្រោមសមត្ថកិច្ចដែនដីរបស់ខ្លួន។ ក្នុងករណីដែលមានបទល្មើសធ្ងន់ធ្ងរកើតឡើងអគ្គព្រះរាជអាជ្ញាត្រូវធ្វើការរាយការណ៍ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[16] អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ធ្វើការឃ្លាំមើល និងការត្រួតពិនិត្យនគរបាលយុត្តិធម៌។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចកោះអញ្ជើញអ្នកទទួលខុសត្រូវនៃអង្គភាពនគរបាលយុត្តិធម៌ ដើម្បីពិភាក្សាអំពីបញ្ហាដែលទាក់ទង នឹងការប្រព្រឹត្តិទៅរបស់អង្គភាពនគរបាលទាំងនេះ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចប្រគល់ភារកិច្ចដល់មន្ត្រី ឬភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ឲ្យបំពេញកិច្ចការទាំងឡាយ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការគ្រប់គ្រង ឬដំណើរការដ៏ល្អនៃនគរបាលយុត្តិធម៌។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចធ្វើអធិការកិច្ចគ្រប់ពេលវេលានៅអង្គភាពនគរបាលយុត្តិធម៌ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចចូលរួមក្នុងការស្តាប់ចម្លើយ អាចត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ជាពិសេស គឺការគោរពទម្រង់ការច្បាប់ និងការកាន់កាប់គ្រប់គ្រងកន្លែងឃាត់ខ្លួន។ ប្រធានអង្គភាពនគរបាលយុត្តិធម៌ មន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌គ្រប់រូប ត្រូវគោរពតាមអធិបញ្ជារបស់ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តាមដែនសមត្ថកិច្ចរបស់ខ្លួន។[17]

**ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង:** គឺជាតំណាងរបស់អង្គភាពអយ្យការអមតុលាការនេះ។[18]

## ផ្នែកទី៣៖ គោលការណ៍សំខាន់ៗរបស់អង្គការអយ្យការ

ដើម្បីធានាបាននូវយុត្តិធម៌ តម្លាភាព អង្គការអយ្យការត្រូវបានបង្កើតឡើង ដោយគោរពនូវគោលការណ៍សំខាន់ៗមួយចំនួន ក្នុងគោលបំណងដើម្បីធានាបាននូវការអនុវត្តមុខងាររបស់ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង នៅក្នុងតុលាការនៃសាលាដំបូង ឱ្យមានឆន្ទៈក្នុងការចោទប្រកាន់ប្រកបទៅដោយភាពត្រឹមត្រូវមិនលំអៀង និងមិនមានការប្រកាន់បក្សពួកនៅក្នុងការចោទប្រកាន់ ដែលគោលការណ៍សំខាន់ៗទាំងនោះរួមមាន៖ គោលការណ៍សំខាន់ៗ នៃស្ថាប័នអយ្យការ (កថាខណ្ឌទី១) និងគោលការណ៍សំខាន់ៗ នៃចៅក្រមអយ្យការ (កថាខណ្ឌទី ២)

ដូច្នេះយើង ក៏ឃើញមានគោលការណ៍សំខាន់ៗរបស់អង្គការអយ្យការមួយចំនួន ដែលបានកំណត់នៅក្នុងច្បាប់រួមមានជាអាទិ៍ដូចខាងក្រោម[19]៖

---

[16] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៣៣ និង ៣៤

[17] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៣៥

[18] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៣៦

[19] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា ៧៥

# ១. គោលការណ៍សំខាន់ៗ នៃស្ថាប័នអយ្យការ

## ១.១. គោលការណ៍ឯកភាព (ឋានានុក្រម)

ដោយអង្គការអយ្យការ ត្រូវគោរពតាមឋានានុក្រមរបស់ខ្លួន។[20] រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជានាយឋានានុក្រមនៃអង្គការអយ្យការ បន្ទាប់មកទៀតមានអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញាអមសាលាដំបូង។[21] ពោល គឺជាគោលការណ៍មួយដែលតម្រូវឱ្យព្រះរាជអាជ្ញាទាំងអស់ត្រូវស្ថិតនៅក្រោមការដឹកនាំ និងការត្រួតពិនិត្យតាមឋានានុក្រមរបស់ខ្លួន។ ក្នុងន័យនេះតំណាងអយ្យការត្រូវអនុវត្តមុខងាររបស់ខ្លួនក្នុងនាមខ្លួនឯងផ្ទាល់ និងតាមបង្គាប់របស់អ្នកដែលមានឋានានុក្រមខ្ពស់ជាង។ ហើយចំពោះឋានានុក្រម នៃអង្គការអយ្យការទាំងនោះត្រូវបានកំណត់ដូចជា៖

- **រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

គឺជានាយឋានានុក្រម នៃអង្គការអយ្យការដែលខ្ពស់ជាងគេ ហើយស្ថាប័ននេះមានអំណាចគ្រប់គ្រាន់នូវក្នុងការធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់។ ពោល គឺមានន័យថារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជានាយកដែលមានឋានានុក្រមខ្ពស់ជាងគេហើយអាចធ្វើអធិបញ្ញាជាលិខិតណែនាំជាលាយលក្ខណ៍អក្សរទៅគ្រប់ស្ថាប័នអយ្យការ ទាំងមហាអយ្យការអមតុលាការកំពូល មហាអយ្យការអមសាលាឧទ្ធរណ៍ និងអយ្យការអមសាលាដំបូង ដោយមានអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ជាសេនាធិការឱ្យរដ្ឋមន្ត្រីជាអ្នកធ្វើកិច្ចការនេះ។

ក្រៅពីនេះនៅក្នុងក្របខណ្ឌ នៃដំណើរការរឿងក្តីព្រហ្មទណ្ឌព្រះរាជអាជ្ញា ត្រូវគោរពនូវអធិបញ្ញារបស់នាយឋានានុក្រម ដែលមានអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចប្តឹងបរិហារ ឬធ្វើអធិបញ្ញាទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬ ព្រះរាជអាជ្ញាអមសាលាដំបូងអំពីបទល្មើសដែលខ្លួនបានដឹងដើម្បីឲ្យអគ្គព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ឬ ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមការយល់ឃើញរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ទោះជាអគ្គព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញាមិនចង់ធ្វើការបើកបណ្តឹងអាជ្ញានៅក្នុងរឿងហេតុនោះក៏ដោយ។ ប៉ុន្តែការធ្វើអធិបញ្ញាទាំងនេះ ពុំអាចមានកម្មវត្ថុក្នុងការបញ្ជាឲ្យអ្នកស្ថិតក្រោមឋានានុក្រម ទៅតម្កល់រឿងទុកឥតចាត់ការឡើយ គឺអាចធ្វើអធិបញ្ញាទៅលើរឿងនោះដោយអោយធ្វើការចោទប្រកាន់ ឬ ធ្វើសេចក្តីសន្និដ្ឋានតាមការយល់ឃើញរបស់ខ្លួនតែប៉ុណ្ណោះ។ នេះបើយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ថា "រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មិនអាចធ្វើអធិបញ្ញា ដល់អគ្គព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញាឲ្យធ្វើការតម្កល់រឿងទុកឥតចាត់ការ នូវរឿងក្តីព្រហ្មទណ្ឌណាមួយបានឡើយ"។

---

[20] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២៩

[21] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា ៧៥

- **អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល**

គឺជានាយឋានានុក្រម នៃមហាអយ្យការអមតុលាការកំពូល។ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារង នៃមហាអយ្យការអមតុលាការកំពូល ត្រូវធ្វើការស្ថិតនៅក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមពីសំណាក់អគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។

- **អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍**

គឺជានាយឋានានុក្រម នៃមហាអយ្យការអមសាលាឧទ្ធរណ៍។ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារង នៃមហាអយ្យការអមសាលាឧទ្ធរណ៍ ត្រូវធ្វើការស្ថិតនៅក្រោមការដឹកនាំនិងការទទួលខុសត្រូវរួម របស់អគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។

- **ព្រះរាជអាជ្ញាអមសាលាដំបូង**

គឺជានាយឋានានុក្រម នៃអយ្យការអមសាលាដំបូង។ ព្រះរាជអាជ្ញារងទាំងអស់ នៃអយ្យការអមសាលាដំបូង ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមពីសំណាក់ព្រះរាជអាជ្ញាអមសាលាដំបូងដែលជានាយឋានានុក្រមរបស់ខ្លួន។

### ១.២. គោលការណ៍ឯករាជ្យ

ស្ថាប័នអយ្យការ ដែលនៅអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ គឺមានឯករាជ្យដែលមិនស្ថិតនៅក្រោមអំណាច នៃសាលាជម្រះក្តីដែលខ្លួននៅអមនោះទេ។ ពោល គឺជាស្ថាប័នឯករាជ្យដែលមិនចំណុះអោយសាលាជម្រះក្តី សាលាជម្រះក្តីនេះគ្មានអំណាចត្រួតពិនិត្យកិច្ចការរបស់ព្រះរាជអាជ្ញាឡើយ ទោះបីព្រះរាជអាជ្ញាមានកំហុសឆ្គងនៅក្នុងការបំពេញមុខងារក៏ដោយ។ បើទោះបីក្នុងរឿងក្តីផ្សេងទៀតដែលក្នុងករណីចៅក្រមអាសនៈ ឬសាលាជម្រះក្តីយល់ឃើញថា ចៅក្រមអយ្យការបានប្រព្រឹត្តកំហុសណាមួយក៏ដោយ ចៅក្រមអាសនៈអាចបានត្រឹមតែលើកសំណើរទៅនាយឋានានុក្រមណាមួយ នៃចៅក្រមអយ្យការអំពីកំហុសឆ្គងរបស់ព្រះរាជអាជ្ញាដែលប្រព្រឹត្តកំហុសខុសឆ្គងនោះ។[22]

ពោល គឺថាអង្គការអយ្យការជាអង្គឯករាជ្យ បើថ្វីត្បិតតែអង្គការអយ្យការស្ថិតនៅអមសាលាជម្រះក្តីក៏ពិតមែន ប៉ុន្តែអង្គការនេះមិនស្ថិតនៅក្រោមអំណាច នៃសាលាជម្រះក្តីដែលខ្លួននៅអមនោះទេ ព្រោះអង្គការអយ្យការជាអង្គការមួយដែលឯករាជ្យ។ តុលាការមិនអាចធ្វើអធិបញ្ញាលើអំណាចអយ្យការទេហើយសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ក៏មិនអាចធ្វើការត្រួតពិនិត្យលើកិច្ចការ និងដំណើរការរបស់ព្រះរាជអាជ្ញាបានឡើយ ព្រោះវាគឺជាការបំពានគោលការណ៍នៃការបែងចែកមុខងារ និងអំណាចរបស់ស្ថាប័នទាំងបី ព្រះរាជអាជ្ញាមានសេរីភាពនៅក្នុង

[22] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា ៧៥ នៅចំនុចទី ៣

ការនិយាយបានដោយសេរីទៅលើអង្គហេតុ នៃការសាកសួរដេញដោល ដើម្បីរកភស្តុតាងមកធ្វើការដាក់បន្ទុកនៅក្នុងការចោទប្រកាន់ ទៅលើជនជាប់ចោទនៅពេលសវនាការ។ នៅក្នុងការបំពេញមុខងារសាលាជម្រះក្ដីមិនមានអំណាចក្នុងការចេញនូវសេចក្ដីសម្រេចណាមួយរបស់ខ្លួនឡើយ ព្រមទាំងគ្មានអំណាចនៅក្នុងការត្រួតពិនិត្យកិច្ចការរបស់ខ្លួនផងដែរ។ បើទោះបីជានៅក្នុងករណីដែលព្រះរាជអាជ្ញាមានកំហុសឆ្គង ក្នុងការបំពេញមុខងារក៏ដោយក៏មិនអាចស្ដីបន្ទោសអ្វីចំពោះព្រះរាជអាជ្ញាឡើយ។ ហើយការហាមឃាត់នេះ ត្រូវអនុវត្តទាំងក្នុងរឿងព្រហ្មទណ្ឌ និងទាំងក្នុងរឿងក្ដីផ្សេងទៀត ប៉ុន្តែសាលាជម្រះក្ដីអាចលើកសំណើ ទៅនាយឋានានុក្រមរបស់ព្រះរាជអាជ្ញាអំពីកំហុសឆ្គងរបស់ព្រះរាជអាជ្ញាបាន ដើម្បីធ្វើចំណាត់ការលើកំហុសឆ្គងដែលកើតមានឡើងនោះ។

## ២. គោលការណ៍សំខាន់ៗ នៃចៅក្រមអយ្យការ

### ២.១. គោលការណ៍អវិភាគ

ដោយគោលការណ៍នេះ ពោល គឺតម្រូវអោយព្រះរាជអាជ្ញាត្រូវបំពេញមុខងារនៅអង្គការអយ្យការអមសាលាជម្រះក្ដីណាមួយដែលមានកាតព្វកិច្ចបំពេញ។ ចំពោះការងាររួមនៅក្នុងមុខងារដូចគ្នា និងអាចជំនួសគ្នាទៅវិញទៅមកបានដែរ គោលការណ៍នេះតំណាងអង្គការអយ្យការច្រើនរូប អាចបន្តការងារពីគ្នាបាននៅក្នុងសំណុំរឿងតែមួយតាមការចាត់តាំងរបស់នាយឋានានុក្រម។[23]

ពោល គឺតំណាងអង្គការអយ្យការច្រើនរូប អាចបន្តការងារពីគ្នាបាននៅក្នុងសំណុំរឿងតែមួយតាមការចាត់តាំងនៅក្នុងករណីដែលព្រះរាជអាជ្ញាស្ថិតនៅក្នុងស្ថានភាពមិនអាចបំពេញការងាររបស់ខ្លួនបាន ឬ ក្នុងករណីដែលតំណែងព្រះរាជអាជ្ញាស្ថិតក្នុងភាពទំនេរ ឬ ក្នុងករណីមានធុរៈ ឬមានជម្ងឺ ឬអវត្តមានជាដើម នោះរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ ឱ្យធ្វើជាព្រះរាជអាជ្ញាស្ដីទីជំនួសបាន ដើម្បីធានានូវដំណើរការរបស់អយ្យការអមសាលាដំបូង រហូតដល់មានការតែងតាំងព្រះរាជអាជ្ញាជាផ្លូវការ[24]ដូច្នេះ នៅរាល់កិច្ចការ ឬ លិខិតស្នាមដែលចេញដោយតំណាងរបស់អង្គការអយ្យការណាមួយ គឺមានតម្លៃដូចទៅនិងលិខិតស្នាមដែលចេញដោយអង្គការអយ្យការទាំងមូល។ តាមគោលការណ៍អវិភាគនេះ យើងឃើញថាទោះបីជានៅពេលដែលមានវត្តមាន ឬ អវត្តមាននៃនាយឋានានុក្រមតាមស្ថាប័នអយ្យការណាមួយក៏ដោយ ក៏ខ្លួនអាចមានសិទ្ធិក្នុងការចាត់តាំងនូវតំណាងអយ្យការណាម្នាក់ ក្នុងចំណោមតំណាងអយ្យការដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការទទួលស្គាល់របស់ខ្លួនឱ្យទៅបំពេញកិច្ចការនោះជំនួសខ្លួនបាន ពោល គឺចំពោះមហាអយ្យការអមតុលាការកំពូលទោះបីជាមានវត្តមាន ឬ អវត្តមានរបស់អគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រមនៃមហាអយ្យការអមតុលាកំពូលក៏ខ្លួនមានសិទ្ធិចាត់តាំងអគ្គព្រះរាជអាជ្ញារង ឬ ព្រះរាជអាជ្ញាឱ្យធ្វើការក្នុងនាម និងក្រោម

[23] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា ៧៥ នៅចំនុចទី ២

[24] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤ មាត្រា ៣០

ការទទួលខុសត្រូវរបស់ខ្លួនបានដែរ ដែលមានលក្ខណៈដូចគ្នា ទៅនិងមហាអយ្យការអមសាលាឧទ្ធរណ៍ដែរ។ ចំណែកឯ អយ្យការអមសាលាដំបូងវិញទោះបីជាមានវត្តមាន ឬអវត្តមាននៃព្រះរាជអាជ្ញាក៏ដោយព្រះរាជអាជ្ញារង គឺធ្វើការក្នុងនាម និងក្រោមការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។

**ឧទាហរណ៍៖** ព្រះរាជអាជ្ញាមួយជាអ្នកធ្វើសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងសេចក្តីសន្និដ្ឋានស្ថាពរ តែគាត់ក៏អាចបញ្ជាឲ្យព្រះរាជអាជ្ញារងណាម្នាក់មកជំនួសគាត់ នៅក្នុងដំណាក់កាលជំនុំជម្រះបានដែរ។

### ២.២. គោលការណ៍ នៃការមិនទទួលខុសត្រូវនូវភាគព្វកិច្ចបំពេញការងាររបស់ខ្លួន

អង្គការអយ្យការ មិនអាចទទួលខុសត្រូវព្រហ្មទណ្ឌដែលកើតចេញពីការសម្រេចរបស់ខ្លួននោះទេ ប៉ុន្តែ អាចទទួលទណ្ឌកម្មវិន័យ ដែលសម្រេចដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ មានន័យថាព្រះរាជអាជ្ញាមិន អាចទទួលខុសត្រូវព្រហ្មទណ្ឌ ដោយសារតែការសម្រេចនៅក្នុងការចោទប្រកាន់ ឬ ការតម្កល់រឿងទុកឥតចាត់ ការរបស់ខ្លួននោះទេ។[25]

ចៅក្រមអយ្យការបំពេញការងារជាសមូហភាព ធ្វើសេចក្តីសន្និដ្ឋានសម្រេចចិត្ត ដែលតំណាងឱ្យអង្គ អយ្យការរបស់ខ្លួនទាំងមូលមិនមែនក្នុងនាមបុគ្គលណាមួយឡើយ។ ហេតុដូច្នេះ បានជាចៅក្រមអយ្យការមិនត្រូវ បានដាក់ឱ្យទទួលខុសត្រូវ ចំពោះការធ្វើសេចក្តីសម្រេចចិត្តរបស់ខ្លួនណាមួយឡើយ។ ម្យ៉ាងទៀត នៅក្នុង ចំណាត់ការសំណុំរឿងក្តី ក៏មិនបានមើលឃើញថាព្រះរាជអាជ្ញាមានសិទ្ធិ និងអំណាចពាក់ព័ន្ធទៅនឹងការសម្រេច ចិត្តផងដែរ។ ព្រោះថា ចៅក្រមអយ្យការមានតួនាទីត្រឹមតែជាភាគី នៃរឿងក្តីដែលមានសិទ្ធិត្រឹមតែស្នើសុំឱ្យតុលា ការអនុវត្តនូវច្បាប់តែប៉ុណ្ណោះ។

ព្រះរាជអាជ្ញា ជាម្ចាស់នៃបណ្តឹងអាជ្ញា ព្រះរាជអាជ្ញាប្រើសិទ្ធិក្នុងនាមជាអ្នកតំណាងឱ្យរដ្ឋក្នុងការធ្វើការ ចោទប្រកាន់ទៅលើសកម្មភាព ឬ អង្គហេតុណាដែលខ្លួនយល់ឃើញថាជាបទល្មើសព្រហ្មទណ្ឌ ដែលធ្វើឱ្យប៉ះ ពាល់ដល់ប្រយោជន៍សាធារណៈ និងសណ្តាប់ធ្នាប់សង្គម។ ព្រោះ ព្រះរាជអាជ្ញាដើរតួរក្នុងនាមជាអ្នកតំណាង អោយរដ្ឋ នៅក្នុងការចោទប្រកាន់ចំពោះអង្គហេតុទាំងឡាយណាដែលគិតថាជាបទល្មើសព្រហ្មទណ្ឌ។

ចៅក្រមអយ្យការជាអ្នកតំណាងអោយផលប្រយោជន៍សាធារណៈ ដូច្នេះបើខ្លួនចាញ់រឿងក្តីព្រហ្មទណ្ឌ នោះ ក៏ពុំមាននរណាម្នាក់អាចទាមទារអោយទទួលខុសត្រូវបានទេ។[26] តាមគោលការណ៍ច្បាប់ ការចោទប្រកាន់ របស់ព្រះរាជអាជ្ញា គឺអាចត្រូវបានទទួលនូវការច្រានចោលពីសំណាក់ចៅក្រមស៊ើបសួរ ឬ ចៅក្រមជំនុំជម្រះក្នុង ករណីដែលអង្គហេតុ នៃបទល្មើសដែលតំណាងអយ្យការបានចោទប្រកាន់នោះ បានពិនិត្យទៅឃើញថាមិនមែន ជាបទល្មើសព្រហ្មទណ្ឌ ឬ គ្មានភស្តុតាងគ្រប់គ្រាន់ ដើម្បីកំណត់ធាតុផ្សំនៃបទល្មើសសម្រាប់ដាក់បន្ទុកទៅលើ

[25] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា ៦ កថាខណ្ឌទី ២

[26] សៀវភៅលោកគ្រូសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងអ្នកគ្រូសាស្ត្រាចារ្យ ចាំង ស៊ីណាត នីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០១៦ ទំព័រទី៩

ជនជាប់ចោទ ឬ ជនត្រូវចោទជាអាទិ៍។ ប្រសិនបើក្នុងករណីដែលមានការច្រានចោល នៅក្នុងការចោទប្រកាន់ពីសំណាក់ចៅក្រមស៊ើបសួរ ឬ ចៅក្រមជំនុំជម្រះដែលមានមូលហេតុដូចទៅនឹងការរៀបរាប់ខាងលើតាមគោលការណ៍មិនទទួលខុសត្រូវនេះ គឺព្រះរាជអាជ្ញាមិនតម្រូវឱ្យទទួលបាននូវការទទួលខុសត្រូវ លើរាល់ការខូចខាតដែលចេញពីសេចក្ដីសម្រេចលើការចោទប្រកាន់របស់ខ្លួនទៅលើភាគីនៃរឿងក្ដី ជាពិសេសជនជាប់ចោទនៅក្នុងសំណុំរឿងនោះឡើយ។ ពោល គឺព្រះរាជអាជ្ញាមិនទទួលខុសត្រូវខាងព្រហ្មទណ្ឌ ឬ រដ្ឋប្បវេណីណាមួយចំពោះការសម្រេចដែលបានធ្វើក្នុងក្របខណ្ឌសមត្ថកិច្ច និងមុខងាររបស់ខ្លួនក្នុងឋានៈជាព្រះរាជអាជ្ញាឡើយ។ អ្វីដែលគួរឱ្យកត់សម្គាល់នៅក្នុងគោលការណ៍នេះផ្ទាល់គឺ មិនបានការពារនូវរាល់តំណាងអយ្យការណាម្នាក់ ពីកំហុសបទល្មើសព្រហ្មទណ្ឌដែលខ្លួនបានប្រព្រឹត្ដិ នៅក្នុងករណីដែលការប្រព្រឹត្ដិនូវបទល្មើសនោះ កើតចេញពីឆន្ទៈទុច្ចរិតក្នុងការបំពេញមុខងាររបស់ខ្លួនបានទេ។

**ឧទាហរណ៍៖** សកម្មភាពដែលតំណាងអយ្យការមួយរូបណាបានទទួលនូវសំណូកដើម្បីសម្រេច ក្នុងការមិនធ្វើនូវការចោទប្រកាន់ជាអាទិ៍។ ដូច្នេះហើយ យើងឃើញថាព្រះរាជអាជ្ញា ក៏ដូចជាតំណាងអយ្យការគ្រប់រូបត្រូវតែទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌ នៅពេលដែលខ្លួនបានប្រព្រឹត្ដិបទល្មើសព្រហ្មទណ្ឌណាមួយ នៅលើកិច្ចចោទប្រកាន់របស់គាត់ដូចដែលច្បាប់បានបញ្ញត្ដិទុក។

### ២.៣. គោលការណ៍មិនអាចប្ដឹងជំទាស់

តុលាការដែលមានតួនាទីស្វែងរកយុត្តិធម៌ឲ្យកូនក្ដី ពោល គឺមិនត្រូវមានភាពលម្អៀងទៅលើភាគីណាមួយឡើយ។ យ៉ាងណាមិញ បើយោងទៅតាមគោលការណ៍ច្បាប់ប្រសិនបើភាគីណាម្ខាងនៅក្នុងរឿងក្ដីយល់ឃើញថាសមាសភាពជំនុំជម្រះមិនអាចរក និងផ្ដល់ជូននូវយុត្តិធម៌ដល់ខ្លួនបាន ដោយសារមូលហេតុណាមួយ ភាគីនោះមានសិទ្ធិធ្វើការស្នើសុំដើម្បីប្ដូរសមាសភាពជំនុំជម្រះនោះបាន។

ដោយឡែកក្នុងរឿងព្រហ្មទណ្ឌ អង្គការអយ្យការដែលមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ដែលជាតំណាងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត អង្គការអយ្យការមិនអាចក្លាយជាកម្មវត្ថុ នៃការប្ដឹងជំទាស់បាននោះទេ។ ព្រោះតែអយ្យការ គឺជាភាគីនៅក្នុងរឿងក្ដីព្រហ្មទណ្ឌ មានន័យថា អង្គការអយ្យការមិនត្រូវបានភាគីណាមួយអាចប្ដឹងជំទាស់នោះទេដោយមិនមានច្បាប់ ឬ បទដ្ឋានគតិយុត្តណាមួយអនុញ្ញាតឲ្យប្ដឹងចំពោះអង្គការអយ្យការនោះទេ។ ព្រោះថាព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ក្នុងនាមជាអ្នកតំណាងអោយរដ្ឋ និងការពារផលប្រយោជន៍ទូទៅរបស់សង្គម ដោយមិនមែនតំណាងឱ្យខ្លួនឯងនោះទេ។ បើទោះបី ជាព្រះរាជអាជ្ញាមានការជាប់ពាក់ព័ន្ធ និងសាច់ញាតិ ឬ ជាប់ពាក់ព័ន្ធទៅនឹងផលប្រយោជន៍ក្នុងបណ្ដឹងរបស់ភាគីម្ខាងណាក៏ដោយ។

ម្យ៉ាងវិញទៀត បើទោះបីជាមានការចោទប្រកាន់របស់ព្រះរាជអាជ្ញាក៏ដោយ ក៏ការចោទប្រកាន់នេះមិនមែនមានន័យថា បុគ្គលដែលជាជនត្រូវចោទ ឬ ជនជាប់ចោទនឹងត្រូវរងការផ្ដន្ទាទោសដូចទៅនឹងការចោទ

ប្រកាន់របស់ព្រះរាជអាជ្ញាឡើយ។ ដោយសារមូលហេតុទាំងអស់នេះហើយ ដូចនេះព្រះរាជអាជ្ញាមិនអាចក្លាយជាកម្មវត្ថុ នៃការធ្វើបណ្តឹងជិតចិត្តបានទេ ដោយក្រៅពីគោលការណ៍ទាំងឡាយខាងលើព្រះរាជអាជ្ញាទាំងអស់ត្រូវអនុវត្តមុខងារ និងតួនាទីរបស់ខ្លួនដោយឈរលើគោលការណ៍គោរពច្បាប់ ដោយមិនទទួលការគាបសង្កត់ ការគំរាមកំហែង ឬការបំភិតបំភ័យ ការបង្គាប់បញ្ជាដោយផ្ទាល់ ឬដោយប្រយោលពីភាគីណាមួយក្នុងរឿងក្តី ឬពីបុគ្គលណាមួយឡើយ។[27] ដោយនៅក្នុងមាត្រា ៥៥៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា "បណ្តឹងជិតចិត្តអាចត្រូវទទួលបានពាក់ព័ន្ធតែចៅក្រមអាសនៈតែប៉ុណ្ណោះ ដោយមិនអាចអនុវត្តចំពោះចៅក្រមអយ្យការនោះទេ"។[28]

## ២.៤. គោលការណ៍នីត្យានុកូលភាព នៃការចោទប្រកាន់

នៅមុនពេលអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ការចោទប្រកាន់របស់អង្គការអយ្យការត្រូវបានគេជ្រើសរើសតាមគោលការណ៍នីត្យានុកូលភាព នៃការចោទប្រកាន់។

គោលការណ៍នេះមានន័យថា កាលណារឿងព្រហ្មទណ្ឌមួយត្រូវបានប្តឹងមកមន្ទីរអយ្យការ ព្រះរាជអាជ្ញាត្រូវតែសម្រេចចាត់ការបណ្តឹងនោះ ឲ្យតែបទល្មើសដែលត្រូវបានប្តឹងនោះមានធាតុផ្សំខាងអង្គហេតុ និងអង្គច្បាប់គ្រប់គ្រាន់ដោយព្រះរាជអាជ្ញាមិនត្រូវគិតដល់កាលៈទេសៈអ្វីផ្សេងទៀតទេ។ គោលការណ៍នេះមានប្រភពចេញពីគោលការណ៍ដែលថា គ្មានបទល្មើសដែលគ្មានច្បាប់បង្ក្រាប និងគ្មានទោសដោយគ្មានទោសបញ្ញត្តិ។

## ២.៥. ការអនុវត្តន៍គោលការណ៍កាលានុវត្តភាព នៃការចោទប្រកាន់

ក្រោយពីក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ត្រូវបានអនុវត្តគោលការណ៍នីត្យានុកូលភាព នៃការចោទប្រកាន់មិនត្រូវបានគេលើកយកមកអនុវត្តទៀតនោះទេ ដោយហេតុថាក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានលើកនូវគោលការណ៍កាលានុវត្តភាព នៃការចោទប្រកាន់មកអនុវត្តជំនួសវិញ។

គោលការណ៍កាលានុវត្តភាព នៃការចោទប្រកាន់ ដែលត្រូវបានបញ្ចូលនៅក្នុងក្រមនីតិវិធីថ្មីនេះ ជាយន្តការទំនើបកម្ម នៃនីតិក្នុងបរិបទកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៃព្រះរាជាណាចក្រកម្ពុជា។ គោលការណ៍នេះស្របទៅនឹងចរន្តពិភពលោកដែលកំពុងមានការផ្តោតអារម្មណ៍ និងយកចិត្តទុកដាក់ហើយកំពុងត្រូវបានអនុវត្តនៅតាមបណ្តាប្រទេសជឿនលឿនផងដែរ។

ការអនុវត្តគោលការណ៍នេះ ត្រូវបានបញ្ញត្តិដោយក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧ ដែលជាគោលការណ៍មួយពុំធ្លាប់ត្រូវបានអនុវត្តនៅកម្ពុជានាពេលកន្លងមកនោះទេ។ គោលការណ៍ដែលត្រូវបានអនុវត្ត នៅប្រទេសកម្ពុជាចាប់តាំងពីពេល ដែលមាននីតិព្រហ្មទណ្ឌនាយុគ្គសម័យមុនរហូតមកដល់មុនពេលអនុម័តនូវក្រមនីតិវិធី

[27] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា,លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ឆ្នាំ២០១៤ មាត្រា ៧៧

[28] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៥៥៦ កថាខណ្ឌទី ១

ព្រហ្មទណ្ឌឆ្នាំ ២០០៧ គឺប្រទេសកម្ពុជាបានអនុវត្តគោលការណ៍នីត្យានុកូលភាព នៃការចោទប្រកាន់ដោយតាមរយៈនេះស្ថាប័នទទួលបន្ទុកចោទប្រកាន់នូវរឿងក្តីព្រហ្មទណ្ឌ ត្រូវបានចាប់បង្ខំដោយនីតិ ពោល គឺឲ្យធ្វើការចោទប្រកាន់គ្រប់រឿងទាំងឡាយ ដែលមានចរិតលក្ខណៈជាបទល្មើសព្រហ្មទណ្ឌ ដោយមិនគិតអំពីស្ថានភាពនៃបទល្មើស ឬ បរិបទសង្គម ឬ តាមរបៀបមនុស្សធម៌នោះទេ។ ផ្ទុយមកវិញគោលការណ៍ថ្មីខាងលើនេះ ស្ថាប័នចោទប្រកាន់បទល្មើសអាជ្ញាត្រូវបានផ្តល់ឲ្យដោយច្បាប់នូវអំណាចនៅក្នុងការជ្រើសរើសនៃការចោទប្រកាន់ បើទោះបីជាអង្គហេតុទាំងនោះមានចរិតលក្ខណៈជាបទល្មើសព្រហ្មទណ្ឌក៏ដោយ។ ប៉ុន្តែអំណាចដែលផ្តល់ឲ្យដោយច្បាប់នេះពុំមានស្ថានភាពទូលំទូលាយហួសហេតុ ដែលអាចធ្វើបានតាមទំនើងចិត្តនោះដែរ។ វាត្រូវបានកម្រិតដោយលក្ខខណ្ឌគតិយុត្តមួយចំនួន។

គោលការណ៍នេះ ត្រូវបានវិស័យនីតិនិពន្ធតាក់តែងឡើង ដើម្បីបង្កើតនូវវិធានកណ្តាលនៃការចោទប្រកាន់ដោយប្រគល់ឲ្យស្ថាប័នចោទប្រកាន់ ពោល គឺស្ថាប័នអយ្យការនូវជម្រើសដ៏សំខាន់ក្នុងការធ្វើចំណាត់ការសំណុំរឿងក្តីព្រហ្មទណ្ឌ។ តាមរយៈគោលការណ៍នេះអនុញ្ញាតឲ្យស្ថាប័នអយ្យការ មានជម្រើសមិនធ្វើការចោទប្រកាន់បើទោះបីអំពើដែលបរិហារនោះជាបទល្មើសព្រហ្មទណ្ឌក៏ដោយ។ ជម្រើសមិនចោទប្រកាន់នេះសម្តែងចេញតាមរយៈសេចក្តីសម្រេចតម្កល់រឿងទុកមិនចាត់ការ ដែលផ្អែកទៅលើការវាយតម្លៃរបស់ព្រះរាជអាជ្ញាតែមួយគត់។ ដូចគ្នាដែរ ក្នុងករណីដែលមានអំពើច្រើនដែលត្រូវបានប្តឹងមកនោះ មានការពាក់ព័ន្ធក្នុងអង្គហេតុមួយព្រះរាជអាជ្ញាមានជម្រើសធ្វើការចោទប្រកាន់នូវអំពើណាមួយ ហើយមិនចោទប្រកាន់នូវអំពើផ្សេងទៀត។ គោលការណ៍នេះ ក៏បានអនុញ្ញាតឲ្យស្ថាប័នអយ្យការនូវសេរីភាព ក្នុងការជ្រើសរើសមធ្យោបាយធ្វើបណ្តឹងអាជ្ញា កាលបើច្បាប់មិនបានចែងថា ការបើកការស៊ើបសួរតាមផ្លូវយុត្តាធិការស៊ើបសួរមានលក្ខណៈមិនដាច់ខាតនោះទេ។

ចំពោះអង្គការអយ្យការមានជម្រើសដូចជា[29]៖ ការចោទប្រកាន់ និងតម្កល់រឿងទុកឥតចាត់ការ។

**ឧទាហរណ៍៖** មានករណីមួយដែលជនល្មើសជាជនដែលមានជីវភាពក្រីក្រម្នាក់ គាត់បានលួចបេះផ្លែស្វាយរបស់អ្នកភូមិមួយផ្លែដើម្បីចម្អែតក្រពះរបស់គាត់។

បើតាមរយៈសកម្មភាពរបស់ជនល្មើសបានឆ្លើយតប ទៅនឹងនិយមន័យនៃអំពើលួច ដោយតាមបញ្ញត្តិច្បាប់មាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌដែលចែងថា៖ អំពើលួច គឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។ ដូច្នេះបើយើងអនុវត្តតាមគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ ជនល្មើសនេះ គឺនឹងត្រូវចោទប្រកាន់ដោយស្ថាប័នអយ្យការ ក៏ប៉ុន្តែបើយើងអនុវត្តតាមគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់វិញ ដោយផ្អែកតាម

[29] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤០

ស្ថានភាពរបស់ជនល្មើស ព្យសនកម្មនៃអំពើល្មើសវិញនោះ ជនល្មើសនេះអាចត្រូវបានស្តាប់នអយ្យការតម្កល់រឿងទុកឥតចាត់ការបាន។

### ២.៦. គោលការណ៍ នៃការអមសាលាជម្រះក្តី

នៅគ្រប់សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ គឺត្រូវតែមានវត្តមានអង្គការអយ្យការនៅអមជានិច្ច ជាពិសេសនៅពេលសវនាការរឿងក្តីព្រហ្មទណ្ឌ ដាច់ខាតត្រូវអោយមានតំណាងអយ្យការជានិច្ច។[30]

### ២.៧. គោលការណ៍ នៃការធ្វើបណ្តឹងដោយផ្ទាល់មាត់នៅក្នុងសវនាការព្រហ្មទណ្ឌ

តំណាងអយ្យការអាចធ្វើការកត់សម្គាល់ផ្ទាល់មាត់ដោយសេរី តាមការដែលខ្លួនយល់ឃើញថាស្របទៅតាមសតិសម្បជញ្ញៈរបស់ខ្លួន ហើយការកត់សម្គាល់នេះមិនអាចជាកម្មវត្ថុ នៃការដាក់ទណ្ឌកម្មវិន័យនោះទេ។

ចៅក្រមអយ្យការ គ្រប់រូបត្រូវគោរពតាមអធិបញ្ជាថ្នាក់លើរបស់ខ្លួនតាមឋានានុក្រម ប៉ុន្តែនៅពេលសវនាការចៅក្រមអយ្យការធ្វើការកត់សំគាល់ផ្ទាល់មាត់ដោយសេរីតាមការដែលខ្លួនយល់ឃើញថា ស្របទៅតាមសតិសម្បជញ្ញៈរបស់ខ្លួន។ គ្មានការចោទប្រកាន់ខាងវិន័យណាមួយ ដែលអាចត្រូវធ្វើចំពោះចៅក្រមអយ្យការដោយសារតែវាចារបស់ខ្លួន ដែលបានបញ្ចេញនៅពេលសវនាការសោះឡើយ។[31]

## ផ្នែកទី៤៖ សមត្ថកិច្ច មុខងារ តួនាទី ភារកិច្ច ភាតព្វកិច្ច អំណាច និងការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា គឺជាអ្នកតំណាងនិងជាអ្នកដឹកនាំនៅក្នុងអង្គការអយ្យការអមសាលាដំបូង ដើម្បីធានាដល់ប្រសិទ្ធិភាព នៅក្នុងការបំពេញនូវកិច្ចការនៅក្នុងដំណើររឿងក្តីព្រហ្មទណ្ឌនីមួយៗ ដោយធ្វើការចោទប្រកាន់ពីបទល្មើស និងសន្និដ្ឋានអោយតុលាការអនុវត្តច្បាប់ និងធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ ព្រមទាំងជានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់អោយចាប់ខ្លួន។ ក្នុងការបំពេញភារកិច្ចរបស់ខ្លួនចៅក្រមអយ្យការមានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ។ ចៅក្រមអយ្យការត្រូវតែមានវត្តមាននៅក្នុងពេលសវនាការរឿងព្រហ្មទណ្ឌ។[32]

### ១. សមត្ថកិច្ច មុខងារ តួនាទី ភារកិច្ច និងអំណាចរបស់ព្រះរាជអាជ្ញា

#### ១.១. សមត្ថកិច្ចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា មានអំណាចលើព្រះរាជអាជ្ញារងទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ព្រះរាជអាជ្ញាចាត់តាំង និងបែងចែកការងារដល់ព្រះរាជអាជ្ញារងទាំងអស់។

[30] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២៧ កថាខណ្ឌទី ៣

[31] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៣០

[32] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២៧

ព្រះរាជអាជ្ញា មានសិទ្ធិធ្វើអធិបញ្ញាឲ្យព្រះរាជអាជ្ញារងធ្វើការចោទប្រកាន់ ឬ ក៏ចាត់ឲ្យចោទប្រកាន់ ឬ ក៏ធ្វើសេចក្ដីសន្និដ្ឋានយ៉ាងណាតាមដែលខ្លួនយល់ឃើញថាជាការគួរ។ ប៉ុន្តែ នៅពេលសវនាការព្រះរាជអាជ្ញារងអាចធ្វើការកត់សម្គាល់ ដោយផ្ទាល់មាត់បានដោយសេរី តាមការដែលខ្លួនយល់ឃើញថាស្របតាមសតិសម្បជញ្ញៈរបស់ខ្លួន។ គ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចត្រូវធ្វើចំពោះតំណាងអយ្យការ ដោយសារតែការកត់សម្គាល់ផ្ទាល់មាត់របស់ខ្លួននាពេលសវនាការខុសពីសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរឡើយ។[33]

ព្រះរាជអាជ្ញា អាចមានសមត្ថកិច្ចក្នុងការស៊ើបអង្កេត ស្រាវជ្រាវលើរឿងក្ដីព្រហ្មទណ្ឌណាមួយដែលបានកើតឡើងបាន គឺត្រូវមើលទៅលើលក្ខខណ្ឌទីតាំងនៃបទល្មើសនោះ។ នៅពេលដែលមានបទល្មើសមួយកើតមានឡើង នោះការស្រាវជ្រាវនឹងត្រូវបានធ្វើឡើងជាច្រើនកន្លែង ដែលជាទីតាំងដែលពាក់ព័ន្ធដល់ការប្រព្រឹត្តនូវបទល្មើសនោះឡើង។

ដោយព្រះរាជអាជ្ញាដែលមានសមត្ថកិច្ច គឺជាព្រះរាជអាជ្ញានៃ[34]៖ ទីកន្លែងប្រព្រឹត្តបទល្មើស, ទីលំនៅស្ថានរបស់ជនដែលគេសង្ស័យថាបានប្រព្រឹត្តបទល្មើស, ទីកន្លែងចាប់ខ្លួនដែលគេសង្ស័យថាបានប្រព្រឹត្តបទល្មើស។ ដូច្នេះសមត្ថកិច្ចរបស់ព្រះរាជអាជ្ញាគ្រប់រូបគឺ ត្រូវអនុវត្តតាមគោលការណ៍ដែនដី ដែលពាក់ព័ន្ធទៅនឹងទីតាំងបទល្មើសផ្ទាល់។

### ១.២. មុខងាររបស់ព្រះរាជអាជ្ញា

អង្គការអយ្យការ គឺជាអង្គអវិភាគ។ អយ្យការមានមុខងារធ្វើបណ្ដឹងអាជ្ញា និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះព្រមទាំងអនុវត្តមុខងារផ្សេងទៀត តាមការកំណត់របស់ច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង គឺជាតំណាងអយ្យការអមសាលាដំបូងដែលខ្លួនបំពេញការងារ។ ព្រះរាជអាជ្ញារងចូលរួមអនុវត្តមុខងាររបស់អយ្យការក្រោមការដឹកនាំ និងទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូង។

### ១.៣. តួនាទីរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា មានតួនាទីយ៉ាងសកម្មនៅក្នុងចំណាត់ការរឿងក្ដីព្រហ្មទណ្ឌរួមទាំងស្ថាប័នអយ្យការ ដែលច្បាប់អនុញ្ញាត ឬ ស្របតាមការអនុវត្តក្នុងស្រុកក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ដោយពិនិត្យមើលនីត្យានុកូលភាពនៃការស៊ើបអង្កេត ពិនិត្យមើលការអនុវត្តសេចក្ដីសម្រេចរបស់តុលាការ និងការបំពេញតួនាទីផ្សេងទៀតដោយតំណាងឲ្យផលប្រយោជន៍សាធារណៈ។ តួនាទីរបស់អង្គការអយ្យការនៃស្ថាប័នអយ្យការ ដោយផ្អែកតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ត្រង់មាត្រា ១៣១ថ្មី បានផ្ដល់អំណាចផ្ដាច់មុខទៅឲ្យ

[33] ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤ មាត្រា ៣១

[34] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៣៩

អង្គការអយ្យការសម្រាប់ធ្វើបណ្តឹងអាជ្ញា។ ព្រះរាជអាជ្ញាទាំងអស់ត្រូវបំពេញតួនាទីរបស់ខ្លួន ឱ្យបានត្រឹមត្រូវដោយភាពម៉ឺងម៉ាត់ ឆាប់រហ័ស និងប្រកបដោយប្រសិទ្ធិភាពខ្ពស់ហើយត្រូវតែគោរព និងការពារនូវសេចក្តីថ្លៃថ្នូរបស់មនុស្សដោយការលើកកម្ពស់នូវសិទ្ធិមនុស្ស។ ហេតុដូច្នេះត្រូវរួមជាវិភាគទានក្នុងការធានាដល់កិច្ចដំណើរការនៃប្រព័ន្ធយុត្តិធម៌ឱ្យបានត្រឹមត្រូវ និងមានភាពរលូន។

ព្រះរាជអាជ្ញា មិនត្រូវផ្តើមគំនិតចោទប្រកាន់ ឬបន្តចោទប្រកាន់ ឬក៏មិនត្រូវខំប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីតម្កល់រឿងទុកមិនចាត់ការ និងបើកដំណើរការស៊ើបអង្កេតមួយដែលមានលក្ខណៈលំអៀងនោះទេ ព្រោះការធ្វើបែបនេះបង្ហាញឱ្យឃើញថាជាការចោទប្រកាន់នេះពុំមានមូលដ្ឋានត្រឹមត្រូវ។ ព្រះរាជអាជ្ញា ត្រូវផ្តល់ការយកចិត្តទុកដាក់លើការធ្វើបណ្តឹងអាជ្ញាចំពោះមន្ត្រីសាធារណៈ ដែលបានប្រព្រឹត្តិបទឧក្រិដ្ឋ ជាពិសេសពីអំពើពុករលួយ ការរំលោភអំណាច ការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ ឬ បទឧក្រិដ្ឋដទៃៗទៀតដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិ ហើយនិងការស៊ើបអង្កេតអំពីបទល្មើសទាំងនេះនៅទីណា ដែលមានការអនុញ្ញាត្តិដោយច្បាប់ ឬស្របទៅនឹងការអនុវត្តតាមតំបន់។ នៅពេលណាដែលព្រះរាជអាជ្ញា ទទួលបាននូវភស្តុតាងប្រឆាំងចំពោះជនជាប់សង្ស័យដែលគេដឹង និងមានជំនឿលើមូលដ្ឋានសមហេតុផលថា ភស្តុតាងទាំងនោះបានមកដោយប្រើប្រាស់វិធីមិនស្របច្បាប់ ដែលអាចចាត់ទុកបានថាជាការរំលោភយ៉ាងធ្ងន់ធ្ងរ លើសិទ្ធិមនុស្សរបស់ជនជាប់សង្ស័យ ជាពិសេសទាក់ទងទៅនឹងការធ្វើទារុណកម្ម ឬទណ្ឌកម្ម ឬការប្រព្រឹត្តិសកម្មភាពកាចសាហាវ អមនុស្សធម៌ និងបន្ថោកបន្ទាប ឬការរំលោភសិទ្ធិមនុស្សផ្សេងៗទៀត។ ព្រះរាជអាជ្ញាត្រូវបដិសេធមិនប្រើភស្តុតាងបែបនោះប្រឆាំងនឹងជនណាម្នាក់ឡើយ ក្រៅពីអ្នកដែលបានប្រើវិធីបែបនោះខ្លួនឯង ឬ ត្រូវជម្រាបដល់តុលាការតាមនោះ ហើយត្រូវចាត់គ្រប់វិធានការចាំបាច់ទាំងអស់ ដើម្បីធានាថាអ្នកដែលទទួលខុសត្រូវចំពោះការប្រើវិធីបែបនោះត្រូវបាននាំខ្លួនមកកាន់តុលាការ។[35]

អង្គការអយ្យការ ជាម្ចាស់នៃបណ្តឹងអាជ្ញា ឬ បណ្តឹងព្រហ្មទណ្ឌ បានន័យថាមានតែស្ថាប័នអយ្យការទេដែលអាចធ្វើការបណ្តឹងអាជ្ញាទាំងឡាយឲ្យដំណើរការបាន។ និយាយម្យ៉ាងទៀតគឺថា (ជាគោលការណ៍) ម្ចាស់នៃបណ្តឹងអាជ្ញានេះ គឺមានសិទ្ធិក្នុងការប្រើប្រាស់នូវជម្រើសនៃការចោទប្រកាន់របស់ខ្លួនបាន។ ក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិនូវតួនាទីបំពេញបន្ថែមទៀតទៅឲ្យអង្គកាអយ្យការ ដោយមាត្រា ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថាបណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ។[36] អយ្យការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។ អយ្យការធ្វើ

[35] គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា ដែលអនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី ៧ ចាប់ពីថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩០ នៅប្រទេសគុយបា ទីក្រុងកាវ៉ាណា

[36] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤ កថាខណ្ឌទី ១

ការអនុវត្តទោសនៅពេលដែលសេចក្តីសម្រេចរបស់តុលាការបានក្លាយជាស្ថាពរ។[37] ម្យ៉ាងទៀតមាត្រា ២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌក៏បានបញ្ជាក់បន្ថែមពីតួនាទីរបស់អង្គការអយ្យការមួយចំនួនដូចជា៖

- អង្គការអយ្យការធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់
- អង្គការអយ្យការធានារ៉ាប់រងលើការអនុវត្តសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ
- យកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន។

មានន័យថាអង្គការអយ្យការ ឬ ស្ថាប័នអយ្យការដែលអមតុលាការខេត្ត-រាជធានី មានតួនាទីក្នុងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដីកាកោះហៅបញ្ជូនរឿងឲ្យទៅជំនុំជម្រះផ្ទាល់ ឬ ដីកាកោះហៅឲ្យចូលបង្ហាញខ្លួនភ្លាម ដីកាសន្និដ្ឋានស្ថាពរ និងការធ្វើសេចក្តីថ្លែងការប្តឹងសុំដោយផ្ទាល់មាត់ នៅតំណាក់កាលជំនុំជម្រះអង្គការអយ្យការធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់ លើការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន។ ជាពិសេស ត្រូវមានវត្តមានជានិច្ចនៅក្នុងពេលសវនាការរឿងក្តីព្រហ្មទណ្ឌ មានន័យថាស្ថាប័នអយ្យការមានតួនាទីអនុវត្តនូវសេចក្តីសម្រេចដែលធ្វើឡើងដោយចៅក្រម។

**ឧទាហរណ៍៖** ការអនុវត្តសាលក្រមតុលាការ ការអនុវត្តន៍ការចាប់ខ្លួនតាមដីកាចាប់ខ្លួន ការផ្សព្វផ្សាយពីការបង្គាប់ឲ្យចាប់ខ្លួនជាដើម។

លើសពីនេះទៅទៀតបើយើងក្រឡេកទៅមើលច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញាសម្រាប់តួនាទីរបស់ព្រះរាជអាជ្ញាអមសាលាដំបូង ពោលគឺជារៀងរាល់ឆ្នាំ[38]៖

- ព្រះរាជអាជ្ញាអមសាលាដំបូងត្រូវធ្វើរបាយការណ៍អំពីបទល្មើស និងសកម្មភាពការងាររបស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងចម្លងជូនអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ចដែនដី។
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវធ្វើរបាយការណ៍អំពីបទល្មើស សកម្មភាពការងាររបស់ខ្លួន និងសកម្មភាពការងាររបស់អយ្យការអមសាលាដំបូងទាំងអស់ នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួនជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងចម្លងជូនអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។
- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពការងាររបស់មហាអយ្យការអមតុលាការកំពូលជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

[37] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៩៧ កថាខណ្ឌទី ១

[38] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា ៧៦

ព្រះរាជអាជ្ញាទាំងឡាយត្រូវអនុវត្តមុខងារ និង តួនាទីរបស់ខ្លួនដោយឈរលើគោលការណ៍គោរពច្បាប់ ដោយមិនទទួលការគាបសង្កត់ ការគំរាមកំហែង ឬការបំភិតបំភ័យ ការបង្គាប់បញ្ជាដោយផ្ទាល់ ឬដោយប្រយោលពីភាគីណាមួយក្នុងរឿងក្តី ឬពីបុគ្គលណាមួយឡើយលើកលែងតែបញ្ញត្តិនៃមាត្រា៧៧ នៃច្បាប់នេះ។[39]

### ១.៤. តួនាទីរបស់ព្រះរាជអាជ្ញា

ចៅក្រមអយ្យការ នៅពេលបំពេញភារកិច្ចរបស់ខ្លួន ចៅក្រមអយ្យការមានសិទ្ធិអំណាចក្នុងការកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយរបស់ខ្លួន។ នៅពេលសវនាការចៅក្រមអយ្យការ ត្រូវតែមានវត្តមាននៅក្នុងពេលសវនាការរឿងក្តីព្រហ្មទណ្ឌ ការដែលអវត្តមានតំណាងអយ្យការនាំឲ្យមានមោឃភាពនៃនីតិវិធី។[40]

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដើម្បីធានាអោយបាននូវប្រសិទ្ធិភាពព្រះរាជអាជ្ញា ត្រូវឈរលើគោលការណ៍សំខាន់ៗមួយចំនួនរួមមានដូចជា៖

- ជំហរការងាររបស់ព្រះរាជអាជ្ញាត្រូវអនុវត្តមុខងារ និងតួនាទីរបស់ខ្លួនដោយមិនលំអៀង និងជៀសវាងនូវការប្រកាន់និន្នាការនយោបាយ វប្បធម៌ ភេទ សាសនា និង ការរើសអើងគ្រប់ទម្រង់។
- ព្រះរាជអាជ្ញាការពារផលប្រយោជន៍សាធារណៈ យកចិត្តទុកដាក់ចំពោះជនសង្ស័យ និងជនរងគ្រោះដោយមិនមានភាពលំអៀង ព្រមទាំងប្រុងប្រយ័ត្នគ្រប់ស្ថានភាពដែលពាក់ព័ន្ធទាំងអស់ ទោះបីជាស្ថានការណ៍នោះមានប្រយោជន៍ ឬ មិនមានប្រយោជន៍ដល់សង្គមក៏ដោយ។
- រក្សាការសម្ងាត់នៃរឿងក្តី លើកលែងតែដើម្បីតែបំពេញភារកិច្ច ឬ ដើម្បីតម្រូវការរបស់តុលាការបញ្ជាក់អំពីភាពយុត្តិធម៌។
- ព្រះរាជអាជ្ញាត្រូវពិនិត្យមើលទិដ្ឋភាពទូទៅ និង ក្តីបារម្ភរបស់ជនរងគ្រោះនៅពេលដែលមានផលប៉ះពាល់ដល់ប្រយោជន៍របស់ពួកគេ និង បញ្ជាក់ពីសិទ្ធិដល់ជនរងគ្រោះឲ្យស្របតាមសេចក្តីប្រកាសពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋានរបស់ជនរងគ្រោះក្នុងរឿងក្តីព្រហ្មទណ្ឌ និងការរំលោភអំណាច។
- ព្រះរាជអាជ្ញា ត្រូវផ្តល់ការយកចិត្តទុកដាក់លើការធ្វើបណ្តឹងអាជ្ញា ចំពោះមន្ត្រីសាធារណៈដែលបានប្រព្រឹត្តិបទល្មើស ជាពិសេសអំពើពុករលួយការរំលោភអំណាច និងការរំលោភសិទ្ធិយ៉ាងធ្ងន់ធ្ងរ។[41]

---

[39] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា ៧៧

[40] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២៧

[41] គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា ដែលអនុម័តដោយអង្គការសហប្រជាជាតិ ឆ្នាំ១៩៩០ លើកទី ៧ ចាប់ពីថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩០ នៅប្រទេសគុយបា ទីក្រុងហាវ៉ាណា

ព្រះរាជអាជ្ញា ត្រូវរក្សារឿងក្តីដែលមាននៅក្នុងសមត្ថកិច្ចជាការសម្ងាត់ ដើម្បីបញ្ជាក់ពីភាពយុត្តិធម៌នៃតុលាការ។ ម្យ៉ាងវិញទៀត ការការពារផលប្រយោជន៍របស់ជនរងគ្រោះ និងត្រូវបានធានាថាមិនមានការរំលោភបំពានផ្សេងៗដែលនាំអោយជាក្តីបារម្ភរបស់ជនរងគ្រោះឡើយ។

## ១.៥. ភាតព្វកិច្ចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា ត្រូវមានភារកិច្ចទទួលខុសត្រូវចំពោះកិច្ចការដែលបានប្រគល់ឲ្យ និងគោរពឲ្យបានម៉ឺងម៉ាត់នូវក្រមសីលធម៌របស់ខ្លួន។ ក្នុងជីវភាពរស់នៅផ្ទាល់ខ្លួន ព្រះរាជអាជ្ញាមិនត្រូវប្រព្រឹត្តអំពើណាមួយដែលនាំឲ្យអាប់ឱនដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួន និងដល់កិត្យានុភាពនៃអង្គអយ្យការឡើយ។[42]

ព្រះរាជអាជ្ញា ដែលកំពុងបំពេញមុខងារនៅតាមអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ត្រូវសុំការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មុននឹងផ្សាយ ឬ សុំឲ្យផ្សាយតាមគ្រប់មធ្យោបាយទាំងអស់នូវអត្ថបទ ឬការសរសេរសំណើព្រមទាំងមតិផ្សេងៗ ដែលអាចប៉ះពាល់ដល់កិត្យានុភាពនៃស្ថាប័នអយ្យការ ឬ ស្ថាប័នតុលាការ។ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ព្រះរាជអាជ្ញាដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ។ ព្រះរាជអាជ្ញាត្រូវប្រកាន់ដាច់ខាតនូវឥរិយាបថអព្យាក្រឹតក្នុងវិស័យនយោបាយ។ ការរំលោភលើបញ្ញត្តិនៃកថាខណ្ឌទី ២ និងទី ៣ នៃមាត្រា ៩៦ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញានេះត្រូវទទួលទោសវិន័យដោយមិនទាន់គិតដល់ការចោទប្រកាន់ជាបទព្រហ្មទណ្ឌ ប្រសិនបើមាន។[43] ព្រះរាជអាជ្ញាទាំងអស់មិនត្រូវបោះបង់ការងាររបស់ខ្លួន ឬ អវត្តមានដោយគ្មានការអនុញ្ញាតពីថ្នាក់លើផ្ទាល់របស់ខ្លួនជាមុនឡើយ។ សំណើសុំអនុញ្ញាតអវត្តមានរបស់ព្រះរាជអាជ្ញាអមសាលាដំបូង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[44]

ក្រៅពីនេះក្នុងវិជ្ជាជីវៈព្រះរាជអាជ្ញា មានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈដូចជា៖ មុខងារជាតំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា សមាជិករាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការ មុខងារទទួលអាណត្តិដោយបោះឆ្នោតដទៃទៀត ឬ មុខងារជាទីប្រឹក្សាគ្រប់ឋានានុក្រមជាដើម។ បន្ថែមពីលើនេះ ព្រះរាជអាជ្ញាមិនអាចបំពេញមុខងារជាមេធាវី មុខរបរពាណិជ្ជកម្ម ឬ ធ្វើសកម្មភាពណាមួយផ្សេងទៀត ដែលនាំឲ្យមានទំនាស់ផលប្រយោជន៍ ឬ ប៉ះពាល់ដល់កិត្តិយសនៃអង្គចៅក្រម។

ចំពោះព្រះរាជអាជ្ញាដែលត្រូវបានអនុញ្ញាតឲ្យនៅទំនេរ ហើយមានបំណងចង់ប្រកបការងារឯកជននោះត្រូវធ្វើការជូនដំណឹងទៅដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីធ្វើការថ្លឹងថ្លែងថាគួរអនុញ្ញាតឲ្យ ឬ យ៉ាងណាក្នុង

---

[42] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា ៩៦ កថាខណ្ឌទី ២

[43] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា ៩៦

[44] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា ៩៧

ករណីនេះរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចធ្វើការជំទាស់ទៅនឹងការមិនឲ្យប្រកបការងារបាន ប្រសិនបើគាត់យល់ឃើញថាសកម្មភាពនៃការប្រកបការងារនេះមានលក្ខណៈផ្ទុយនឹងកិត្តិយស ឬ សេចក្តីទៀតត្រង់ ឬ ធ្វើឲ្យខូចកិត្យានុភាពនៃមុខងារព្រះរាជអាជ្ញា។ ក្នុងករណីដែលមានការបំពាន នូវកាតព្វកិច្ចវិជ្ជាជីវៈណាមួយទណ្ឌកម្មវិន័យដែលសម្រេចដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ការបោះបង់ការងារ ឬ អវត្តមានឥតច្បាប់ដោយពុំមានមូលហេតុចាប់ពី ១៥ (ដប់ប្រាំ) ថ្ងៃ ឡើងទៅត្រូវទទួលវិន័យផ្អាកមិនឲ្យបើកប្រាក់បៀវត្ស ឬ ដាក់ឲ្យទំនេរគ្មានបៀវត្សដោយគិតពីថ្ងៃបោះបង់ការងារ ឬថ្ងៃអវត្តមានគ្មានការអនុញ្ញាតនោះ។ បើបោះបង់ការងារ ឬអវត្តមានឥតច្បាប់ដោយពុំមានមូលហេតុលើសពី ៣០ (សាមសិប) ថ្ងៃ ហើយព្រះរាជអាជ្ញានោះនៅតែមិនត្រឡប់មកបំពេញការងារវិញ ក្រោយការដាក់កំហិតចំនួនពីរដងនោះ ពោលគឺត្រូវលុបឈ្មោះចេញពីក្របខណ្ឌ។[45]

## ១.៦. អំណាចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា មានសិទ្ធិប្រើប្រាស់នូវសិទ្ធិអំណាចរបស់ខ្លួនស្របទៅតាមច្បាប់ និងបទដ្ឋានគតិយុត្តនានាដែលនៅជាធរមាន។ នីតិវិធីព្រហ្មទណ្ឌបានផ្តល់អំណាច ជូនដល់ព្រះរាជអាជ្ញានៅក្នុងដំណាក់កាល នៃការចោទប្រកាន់ដែលជាដំណាក់កាលមួយ ដែលព្រះរាជអាជ្ញាជាអ្នកមានសមត្ថកិច្ច និងទទួលបន្ទុកលើការផ្តល់ចំណាត់ការក្នុងការដោះស្រាយរឿងក្តីព្រហ្មទណ្ឌ។ ដែលជាគោលការណ៍ក្នុងការទទួលបានគ្រប់ព័ត៌មានទាំងអស់ ដែលជាប្រយោជន៍ក្នុងបណ្តឹង និងទៅតាមច្បាប់ដែលបានកំណត់។ ព្រះរាជអាជ្ញាក្នុងដំណាក់កាលចោទប្រកាន់សិទ្ធិអំណាចអាចធ្វើការបែងចែកជា ៣ គឺ៖ អំណាចលើមន្ត្រីនគរបាលយុត្តិធម៌ អំណាចក្នុងការស៊ើបអង្កេត និងអំណាចក្នុងការចោទប្រកាន់។

- **អំណាចលើមន្ត្រីនគរបាលយុត្តិធម៌**

ព្រះរាជអាជ្ញា គឺជាអ្នកដឹកនាំ និងសម្របសម្រួលសកម្មភាពមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌បានអនុវត្តដីកាសម្រេចចាត់ឲ្យស៊ើបសួរជំនួស នោះមន្ត្រីនគរបាលយុត្តិធម៌ នឹងត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ។ ព្រះរាជអាជ្ញាអាចធ្វើការចុះទៅកន្លែងកើតហេតុដើម្បីធ្វើការស៊ើបអង្កេត និងធ្វើការណែនាំដល់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។ ក្នុងករណីចាំបាច់ ព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ ហើយរៀបចំជំនួសសមាសភាពមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ថ្មី ដើម្បីធ្វើការស៊ើបអង្កេតជំនួស។ ជាមួយគ្នានេះផងដែរ ព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចទៅកាន់អង្គភាពនគរបាលយុត្តិធម៌ដើម្បីត្រួតពិនិត្យពីកិច្ចដំណើរការលើសំណុំរឿង។[46]

---

[45] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា ៩៨

[46] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៣៧

- **អំណាចក្នុងការស៊ើបអង្កេត**

ដើម្បីធ្វើការចោទប្រកាន់ថាជាបទល្មើសចំពោះអំពើណាមួយបាន ព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេត ដោយពិនិត្យមើលទៅលើអង្គហេតុដែលបានកើតឡើង និងត្រូវកំណត់ច្បាស់ថាជាបទល្មើសព្រហ្មទណ្ឌ និងមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ក្នុងការធ្វើការចោទប្រកាន់។

នៅក្នុងការស៊ើបអង្កេត ព្រះរាជអាជ្ញាប្រើប្រាស់អំណាចទាំងអស់ ដែលក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់អោយមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់នៅក្នុងការស៊ើបអង្កេត។[47] ព្រះរាជអាជ្ញា មានសិទ្ធិអំណាចក្នុងការបើកការស៊ើបអង្កេតជាក់ស្តែង និងការស៊ើបអង្កេតបឋមមានជាអាទិ៍ដូចជា៖ ការឃាត់ខ្លួន ការឆែកឆេរ ការចាប់យកវត្ថុតាង ការស្តាប់ចម្លើយ ការធ្វើកំណត់ហេតុ ការធ្វើកោសល្យវិច័យ និងការស្តាប់ការសន្ទនា។

- **អំណាចក្នុងការធ្វើការចោទប្រកាន់**

ក្នុងដំណាក់កាលចោទប្រកាន់ គឺជាអំណាចចំបងមួយនិងសំខាន់បំផុត របស់ព្រះរាជអាជ្ញាប្រើប្រាស់ដើម្បីអោយសំណុំរឿងព្រហ្មទណ្ឌមួយ អាចដំណើរការទៅដំណាក់កាលបន្ទាប់ទៀតបាន។ ព្រះរាជអាជ្ញាមានសមត្ថកិច្ច និងទទួលបន្ទុកក្នុងការធ្វើចំណាត់ការលើសំណុំរឿង ដោយព្រះរាជអាជ្ញាមានសិទ្ធិក្នុងការតម្កល់រឿងទុកឥតចាត់ការ ដោយមិនធ្វើការចោទប្រកាន់បើទោះបីជាមានបទល្មើសព្រហ្មទណ្ឌក៏ដោយ ឬ ក៏ធ្វើការចោទប្រកាន់ដែលហៅថាគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ឬ ជម្រើសនៃការចោទប្រកាន់។

ព្រះរាជអាជ្ញា ក៏អាចធ្វើការចោទប្រកាន់បានផងដែលក្នុងរូបភាពនៃការចោទប្រកាន់ ដែលមានលក្ខណៈវិនិច្ឆ័យជា ៣ សណ្ឋាន៖ គឺការបើកការស៊ើបសួរ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់អោយចូលខ្លួនបង្ហាញភ្លាម[48]។ នៅក្នុងនោះផងដែរ ព្រះរាជអាជ្ញាមានសិទ្ធិនៅក្នុងការបង្ខំរូបរាងកាយ ការលើកលែងទោស ការត្រួត ពិនិត្យ ការព្យួរទោស និងការអនុវត្តទោសបានផងដែរ។

### ១.៦.១. អំណាចរបស់ព្រះរាជអាជ្ញានៅក្នុងការធ្វើបណ្តឹងអាជ្ញា

មានតែអង្គការអយ្យការទេដែលមានសិទ្ធិក្នុងការធ្វើបណ្តឹងអាជ្ញា ដែលកិច្ចការនេះត្រូវបានដឹកនាំដោយព្រះរាជអាជ្ញា និងព្រះរាជ្ញារង។[49] កាលណាព្រះរាជអាជ្ញាទទួលបានពាក្យបណ្តឹងបរិហារពីជនណាម្នាក់ ឬ ពីមន្ត្រីនគរបាលយុត្តិធម៌ដែលទាក់ទងនឹងបទល្មើសឧក្រិដ្ឋ ឬ បទល្មើសមជ្ឈិមណាមួយ ព្រះរាជអាជ្ញាត្រូវចាត់វិធានការតាមនីតិវិធីនៃច្បាប់ដូចតទៅ៖

---

[47] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៣៧ កថាខណ្ឌទី ២

[48] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៣

[49] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា ១៣១ថ្មី (មាត្រា ១១២ចាស់)

❖ **ការស៊ើបអង្កេតផ្ទាល់របស់ព្រះរាជអាជ្ញា**

បន្ទាប់ពីទទួលបានរបាយការណ៍ ពីមន្ត្រីនគរបាលយុត្តិធម៌ហើយ ព្រះរាជអាជ្ញាត្រូវសាកសួរជនល្មើសនូវព័ត៌មានដូចតទៅ៖

- អត្តសញ្ញាណរបស់ជនសង្ស័យ ឈ្មោះ អាយុ មុខរបរ ទីលំនៅ ទីកន្លែង និងថ្ងៃ ខែ ឆ្នាំកំណើត។
- ឈ្មោះ ឪពុក ម្តាយ
- ប្រវត្តិសង្ខេបរបស់ជនសង្ស័យ រួមមានបទល្មើសដែលបានប្រព្រឹត្តិពីមុន
- បទល្មើសដែលត្រូវបានចោទប្រកាន់
- កាលបរិច្ឆេទ និងទីកន្លែងប្រព្រឹត្តបទល្មើស។

ក្រោយពីបានពិនិត្យមើលសំណុំរឿងរួចហើយ ហើយអំពើដែលគេប្តឹងនោះ មិនចូលជាបទល្មើសព្រហ្មទណ្ឌទេ ព្រះរាជអាជ្ញាត្រូវតម្កល់រឿងក្តីនោះទុកមិនចាត់ការ ដោយចុះនិទ្ទេសលើបណ្តឹង ឬ កំណត់ហេតុនោះ ព្រមទាំងចុះលើបញ្ជីបណ្តឹងផង។

❖ **ការតម្កល់រឿងទុកឥតចាត់ការ**

មូលហេតុដែលនាំឲ្យ ព្រះរាជអាជ្ញាតម្កល់រឿងទុកឥតចាត់ការរួមមាន៖

- មរណភាព នៃជនល្មើស
- បណ្តឹងអាជ្ញាត្រូវបានផុតរលត់
- ការលើកលែងទោសជាទូទៅ
- និរាករណ៍ នៃច្បាប់ព្រហ្មទណ្ឌ
- អាជ្ញាអស់ជំនុំ

ក្រៅពីមូលហេតុខាងលើនេះ ព្រះរាជអាជ្ញាអាចតម្កល់រឿងទុកឥតចាត់ការបានផងដែរដូចជា៖

- អង្គហេតុ នៃរឿងមិនមែនជារឿងព្រហ្មទណ្ឌ
- គោលការណ៍កាលានុវត្តភាព នៃការចោទប្រកាន់មានន័យថា អង្គហេតុនៃរឿងជារឿងព្រហ្មទណ្ឌ ប៉ុន្តែវាជាបទល្មើសតូចតាច ដែលអាចធ្វើការលើកលែងមិនធ្វើការចោទប្រកាន់បាន។

ការតម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវផ្ញើរលិខិតជូនដំណឹងទៅឲ្យភាគីដើមបណ្តឹង ដើម្បីប្រាប់ពីការឥតចាត់ការនេះ ដោយនៅក្នុងលិខិតនោះព្រះរាជអាជ្ញាត្រូវបញ្ជាក់ដល់អ្នកប្តឹង អំពីសិទ្ធិពេញលេញក្នុងការប្តឹងទៅសាលាឧទ្ធរណ៍ប្រឆាំង និងសេចក្តីសម្រេចមិនចាត់ការនេះ។ ដោយរយៈពេល នៃការប្តឹងតវ៉ាចំពោះសេចក្តីសម្រេចនេះទៅសាលាឧទ្ធរណ៍ គឺមានរយៈពេល ២ ខែ គិតពីថ្ងៃទទួលពាក្យបណ្តឹង។

### ១.៦.២. អំណាចនៅក្នុងការស៊ើបអង្កេតបឋម

កាលណាមានអំពើដែលអាចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង ព្រះរាជអាជ្ញាមានសិទ្ធិធ្វើការស៊ើបអង្កេតបឋម និងអនុវត្តនូវវិធានការមួយចំនួនដែលច្បាប់ប្រគល់ឲ្យដើម្បីធានាដល់ការស៊ើបអង្កេតដូចជា៖

- ការឃាត់ខ្លួនជនសង្ស័យ និងនាំខ្លួន
- ឃាត់ខ្លួនជនទាំងឡាយណាដែលរឹងទទឹង និងបំរាមហាមឃាត់ចេញពីទីកន្លែងកើតហេតុក្នុងរយៈពេល ២៤ ម៉ោង
- អាចកេណ្ឌកម្លាំងសាធារណៈ ដើម្បីបំពេញមុខងាររបស់ខ្លួន
- ធ្វើការឆែកឆេរក្នុងផ្ទះ និងចាប់យកវត្ថុតាងទាំងឡាយដែលអាចបំភ្លឺដល់ការពិត
- ការសាកសួរយកចម្លើយពីជនសង្ស័យ ឬសាក្សី និងការធ្វើកោសល្យវិច័យ។

បន្ទាប់ពីដឹងថាមានការប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិមណាមួយភ្លាម ព្រះរាជអាជ្ញាត្រូវចាត់វិធានការស៊ើបអង្កេតដែលច្បាប់ប្រគល់ឲ្យខ្លួនក្នុងការរកឲ្យឃើញនូវការពិត។ ក្នុងការស៊ើបអង្កេតបឋមព្រះរាជអាជ្ញាអាចអនុវត្តបានតែចំពោះបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមជាក់ស្តែង ដែលចៅក្រមស៊ើបអង្កេតពុំទាន់ទទួលបានសំណុំរឿងនៅឡើយ។ ចំពោះបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមមិនជាក់ស្តែងព្រះរាជអាជ្ញាអាចធ្វើការស៊ើបអង្កេតបឋមបានផងដែរក្នុងវិធានការស្វែងរកការពិត។ ក្នុងការស៊ើបអង្កេតបឋមចំពោះបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមមិនជាក់ស្តែងនោះ ក្នុងគោលបំណងស្វែងរកសញ្ញាណនៃជនល្មើសដែលបានប្រព្រឹត្តបទល្មើស ដើម្បីឲ្យព្រះរាជអាជ្ញាមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការធ្វើបណ្តឹងអាជ្ញាចោទប្រកាន់ ដោយតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ទៅចៅក្រមស៊ើបអង្កេតក្នុងការស្វែងរកជនល្មើសមកផ្តន្ទាទោសទៅតាមច្បាប់។

### ១.៦.៣. អំណាចនៅក្នុងការឃាត់ខ្លួន

តាមបទប្បញ្ញត្តិនៃមាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ក្នុងការស៊ើបអង្កេតមន្ត្រីនគរបាលយុត្តិធម៌ដែលរួមទាំងព្រះរាជអាជ្ញា អាចធ្វើការឃាត់ខ្លួនជនសង្ស័យថា បានចូលរួមក្នុងបទល្មើសឧក្រិដ្ឋ ឬ បទល្មើសមជ្ឈិមជាក់ស្តែងតែប៉ុណ្ណោះ។ មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនជនទាំងឡាយដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុដែលកើតឡើងបាន។ ចំពោះបុគ្គលដែលអាចផ្តល់ព័ត៌មានតែប្រកែកមិនព្រមផ្តល់ព័ត៌មាន និងមានការយល់ព្រមជាលាយលក្ខណ៍អក្សរឲ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា។[50] ដោយការឃាត់ខ្លួននេះមន្ត្រីនគរ

[50] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៩៦ កថាខណ្ឌទី ១

បាលយុត្តិធម៌ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញា ព្រមទាំងបញ្ជូនគ្រប់ភស្តុតាងទាំងអស់ ដែលតម្រូវអោយមានការឃាត់ខ្លួននេះជូនព្រះរាជអាជ្ញា។ ការឃាត់ខ្លួនមានថិរវេលា ៤៨ ម៉ោង ដែលគិតចាប់ពីម៉ោងដែលសាមីខ្លួនបានមកដល់អង្គភាពនគរបាល ឬ កងកម្លាំងអាវុធហត្ថ។[51]

ប្រសិនបើការឃាត់ខ្លួននេះ បង្ហាញឲ្យឃើញថាមានពិរុទ្ធភាពលើបុគ្គលដែលឃាត់ខ្លួន នោះមន្ត្រីនគរបាលយុត្តិធម៌អាចពន្យាពេលឃាត់ខ្លួនបាន ប្រសិនបើវិធានការនេះជាការចាំបាច់ ដើម្បីឲ្យការស៊ើបអង្កេតប្រព្រឹត្តិទៅបានល្អ ដោយការពន្យាពេលនេះត្រូវសុំទៅព្រះរាជអាជ្ញាដែលត្រូវផ្ទៀងផ្ទាត់មើលមោឃភាព។ ការអនុញ្ញាតឲ្យពន្យាពេលឃាត់ខ្លួនដែលត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង។ ដោយការពន្យាពេលនេះ គឺជាវិធានពិសេស ដែលមិនអាចឲ្យលើសពី ២៤ ម៉ោងឡើយ ដោយមិនគិតពីថិរវេលាចាំបាច់ក្នុងការដឹកជញ្ជូន។[52]

ការពន្យាមិនអាចត្រូវយល់ព្រមបានទេ ប្រសិនបើបុគ្គលដែលឃាត់ខ្លួននោះជាអនីតិជន ដូច្នេះការឃាត់ខ្លួនអាចធ្វើទៅបាន[53]៖

- ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយះពេល ៣៦ ម៉ោង ឡើយ។
- ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយះពេល ២៤ ម៉ោង ឡើយ ។
- ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយះពេល ៤៨ ម៉ោង ឡើយ ។
- ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៦ ឆ្នាំដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយះពេល ៣៦ ម៉ោង ឡើយ ។
- ចំពោះអនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ពុំអាចត្រូវគេឃាត់ខ្លួនបានឡើយ ។

### ១.៦.៤. អំណាចនៅក្នុងការបញ្ជូនខ្លួន

នៅពេលផុតកំណត់ នៃរយះពេលដែលឃាត់ខ្លួនបុគ្គលដែលជាជនសង្ស័យ ដែលត្រូវបានគេឃាត់ខ្លួននោះត្រូវបានមន្ត្រីនគរបាលយុត្តិធម៌ បញ្ជូនបុគ្គលនោះទៅព្រះរាជអាជ្ញា ប្រសិនបើការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួនពុំអាចធ្វើឡើងក្នុងថ្ងៃតែមួយបាន ដោយមានការលំបាកក្នុងការដឹកជញ្ជូន ឬ ចម្ងាយផ្លូវការដឹក

---

[51] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៩៦ កថាខណ្ឌទី ២

[52] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៩៦ កថាខណ្ឌទី ៣

[53] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៩៦ កថាខណ្ឌទី ៤

ជញ្ជូននោះបន្ថែមរយៈពេលបានដោយផ្តល់ដោយព្រះរាជអាជ្ញា។ ក្នុងករណីផុតរយៈពេល នៃការឃាត់ខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួនត្រូវដោះលែងឲ្យមានសេរីភាព ដោយការសម្រេចនេះធ្វើឡើងដោយព្រះរាជអាជ្ញា។[54]

### ១.៦.៥. អំណាចនៅក្នុងការឆែកឆេរ

ព្រះរាជអាជ្ញា អាចចូលរួមក្នុងការឆែកឆេរ និងត្រួតពិនិត្យក្នុងករណីមានបទល្មើសឧក្រិដ្ឋជាក់ស្តែង ឬបទមជ្ឈិមជាក់ស្តែងកើតឡើងនៅក្នុងលំនៅដ្ឋានរបស់បុគ្គល ដែលបានប្រព្រឹត្តិបទល្មើស និងចាប់យកនូវវត្ថុតាងទាំងឡាយ ដែលអាចបំភ្លឺដល់ការពិត។[55]

ដើម្បីឲ្យការឆែកឆេរនេះប្រព្រឹត្តិតាមបញ្ញត្តិនៃច្បាប់ និងដើម្បីជៀសវាងកុំឲ្យមានការរំលោភដល់សិទ្ធិសេរីភាព ទ្រព្យសម្បត្តិ និងកិត្តិយសសេចក្តីថ្លៃថ្នូរដល់ប្រជាពលរដ្ឋ ដោយការឆែកឆេរត្រូវធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ និងមានសំអាងនៃមូលហេតុច្បាប់ និងអនុញ្ញាតពីព្រះរាជអាជ្ញា ទោះបីការអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ។ ហើយការឆែកឆេរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬ បើគ្មានអ្នកកាន់កាប់ត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់ ដោយសាក្សីត្រូវចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌។ ហើយចំពោះសាក្សីមិនអាចជាកងកម្លាំងរាជអាវុធហត្ថ ឬ ជានគរបាលដែលជាកងកម្លាំងរួមប្រតិបត្តិក្នុងការឆែកឆេរបានឡើយ។ ដោយការឆែកឆេរមិនអាចផ្តើមអនុវត្តធ្វើទៅបានមុនម៉ោង ៦ ព្រឹក និងក្រោយម៉ោង ១៨ ល្ងាចឡើយ។[56]

ប៉ុន្តែនៅក្នុងករណីខាងលើនេះផងដែរ យើងឃើញថាការឆែកឆេរ ក៏អាចធ្វើភ្លាមៗបានដោយមិនចាំបាច់គោរពតាមលក្ខខណ្ឌខាងលើ ពោល គឺលើកលែងតែក្នុងករណីដូចមានខាងក្រោម៖

- ដូចករណីដែលមានចែងនៅក្នុងមាត្រា ៨៦ គឺបទឧក្រិដ្ឋ និងបទមជ្ឈិមជាក់ស្តែងពោលគឺ[57]៖
  - បទល្មើសដែលកំពុងប្រព្រឹត្ត
  - បទល្មើសដែលទើបតែប្រព្រឹត្តរួចភ្លាម។

នៅក្នុងករណីខាងក្រោមនេះផងដែរ ដែលត្រូវបានចាត់ទុកថាជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក៖

- ជនដែលគេសង្ស័យ ត្រូវបានសាធារណជនស្រែកដេញប្រដាប់ចាប់ប្រភីង
- បុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬ មានស្លាកស្នាម ឬ តម្រុយច្បាស់លាស់ហើយស៊ីសង្វាក់ផ្សេងទៀតដែលនាំឱ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬ បានចូលរួមប្រព្រឹត្តបទល្មើស។

---

[54] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១០៣

[55] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៩១

[56] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៩១ កថាខណ្ឌទី ២ និងទី ៣

[57] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៨៦

- ដូចករណីដែលមានចែងនៅក្នុងមាត្រា ៨៨ គឺការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែងពោលគឺ[58]៖

ត្រូវបានចាត់ទុកដូចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែងផងដែរ បើទោះបីជាស្ថិតនៅករណីដែលមានចែងក្នុងមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង) ខាងលើនេះក៏ដោយ។ គ្រប់បទឧក្រិដ្ឋ ឬ បទមជ្ឈិមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះសុំឱ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬ ភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ ក្នុងករណីចុងក្រោយនេះ ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌។

- ក្នុងករណីមានសំរែកស្រែកឲ្យគេជួយពីក្នុងទីកន្លែង
- ក្នុងករណីឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោងដែលបើកចំហដល់សាធារណជន
- ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ និងប្រើប្រាស់គ្រឿងញៀន។

មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការឆែកឆេរដែលនៅក្នុងនោះមានចុះ[59]៖

- ការអនុញ្ញាតរបស់ព្រះរាជអាជ្ញាដោយប្រាប់ថ្ងៃ និងម៉ោងនៃការអនុញ្ញាតនេះ
- អត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬរបស់សាក្សីនីមួយៗ។

មន្ត្រីនគរបាលយុត្តិធម៌ មិនអាចធ្វើការឆែកឆេរនៅក្នុងការិយាល័យមេធាវីបានទេ។ មានតែព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ដែលអាចធ្វើការឆែកឆេរនេះបាននៅចំពោះមុខប្រធានគណៈមេធាវី ឬ ប្រតិភូរបស់ប្រធានគណៈមេធាវី ឬ មេធាវីសាមី។[60]

មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរនៅក្នុងអគារសារព័ត៌មាន សហគ្រាសនៃសារព័ត៌មានសរសេរ ឬ សហគ្រាសសារព័ត៌មានសោតទស្សន៍ ដែលការធ្វើនេះបានតែចំពោះមុខព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរម្នាក់ដែលធានាថាប់រងកុំឱ្យការឆែកឆេរនេះ ប៉ះពាល់ដល់ការប្រកបដោយសេរីនូវមុខរបរអ្នកសារព័ត៌មាន និងធ្វើឱ្យយឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាននេះដោយមិនត្រឹមត្រូវ។[61]

---

[58] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៨៨

[59] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៩១ កថាខណ្ឌទី ៤

[60] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៩១ កថាខណ្ឌទី ៥

[61] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៩១ កថាខណ្ឌទី ៦

## ១.៧. អំណាចអធិបញ្ញា

អំណាចអធិបញ្ញា គឺជាអំណាចនៅក្នុងការធ្វើអធិបញ្ញា នៃអង្គការអយ្យការដែលត្រូវធ្វើទៅតាមឋានានុក្រមដូចតទៅ[62]៖ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍, ព្រះរាជអាជ្ញាអមសាលាដំបូង, ព្រះរាជអាជ្ញារងអមសាលាដំបូង។

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌៖** អាចប្តឹងបរិហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬ ព្រះរាជអាជ្ញាអមសាលាដំបូង អំពីបទល្មើសដែលខ្លួនបានដឹង និងអាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿងឱ្យអគ្គព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញាដើម្បីធ្វើការចោទប្រកាន់ ឬ ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមការដែលរដ្ឋមន្ត្រីយល់ឃើញថាជាការគួរ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មិនអាចធ្វើអធិបញ្ញាដល់អគ្គព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញាឱ្យធ្វើការតម្កល់រឿងទុកឥតចាត់ការ នូវរឿងក្តីព្រហ្មទណ្ឌណាមួយបានឡើយ។

**អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍៖** មានអំណាចលើចៅក្រមអយ្យការទាំងអស់ ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន។ អគ្គព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញាឱ្យចោទប្រកាន់ ឬ ក៏ចាត់ឱ្យចោទប្រកាន់ ឬ ក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាដែលខ្លួនយល់ឃើញថាជាការគួរ។ អគ្គព្រះរាជអាជ្ញាមានអំណាចលើចៅក្រមអយ្យការទាំងអស់ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ គួរបញ្ជាក់ផងដែរថា ក្នុងករណីដែលព្រះរាជអាជ្ញាបានប្រគល់រឿងទៅឲ្យព្រះរាជអាជ្ញារងណាមួយ នោះការសម្រេចយ៉ាងណារបស់ព្រះរាជអាជ្ញារងនោះ គឺធ្វើឡើងតំណាងឲ្យអយ្យការនោះទាំងមូល ដោយយោងទៅតាមគោលការណ៍អវិភាគីយភាពដែលអយ្យការ គឺជាអង្គឯកភាពតែមួយ។ ដូច្នេះបើព្រះរាជអាជ្ញារងបានសម្រេចធ្វើការតម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញា នៃដែនសមត្ថកិច្ចមិនអាចធ្វើអធិបញ្ញាមកព្រះរាជអាជ្ញារង ដើម្បីឲ្យធ្វើការចោទប្រកាន់វិញបានឡើយ ទោះមានបណ្តឹងពីជនរងគ្រោះក៏ដោយ។

ក្នុងករណីនេះមានតែអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តែមួយគត់ ដែលអាចធ្វើអធិបញ្ញាឲ្យតម្កល់ការតម្កល់រឿងទុកឥតចាត់ការនោះ មានន័យថាសើរើរឿងក្តីឡើងវិញ ក្នុងគោលបំណងដាក់ឲ្យដំណើរការបណ្តឹងអាជ្ញា។

**ព្រះរាជអាជ្ញា៖** មានអំណាចទៅលើចៅក្រមអយ្យការដែលនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញាឱ្យចៅក្រមអយ្យការធ្វើការចោទប្រកាន់ ឬ ក៏ចាត់ឱ្យចោទប្រកាន់ ឬ ក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមដែលខ្លួនយល់ឃើញថាជាការគួរ។

[62] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២៩

ដូចនេះព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងទាំងឡាយត្រូវគោរពនូវគោលការណ៍ឋានានុក្រម ឬ អធិបញ្ញារបស់ថ្នាក់លើ។ ទោះជាយ៉ាងណាជាអញ្ញត្រកម្មពេលសវនាការ ចៅក្រមអយ្យការមានសេរីភាពខាងយោបល់របស់ខ្លួន បានន័យថា ចៅក្រមអយ្យការអាចធ្វើបណ្តឹងដោយផ្ទាល់មាត់ ទៅតាមការយល់ឃើញរបស់ខ្លួនក្នុងសវនាកា គឺគាត់មានសិទ្ធិធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ស្របតាមសតិសម្បជញ្ញៈរបស់ខ្លួនបាន។ ការធ្វើសេចក្តីសន្និដ្ឋាននេះអាចមានលក្ខណៈមិនស្របនឹងអធិបញ្ញារបស់នាយឋានានុក្រម។ ការធ្វើបណ្តឹងដោយផ្ទាល់មាត់នេះមិនមែនជាមូលដ្ឋានក្នុងការចោទប្រកាន់ ពីបទវិន័យណាមួយឡើយ។ គោលការណ៍នេះ ក៏បានកំណត់ក្នុងនីតិខ្មែរកាលពីសម័យមុនដែរ ដែលគេបានដាក់ឈ្មោះថា "ប៉ាកកាជាទាសី គឺសម្តីដោយសេរី"។

សូមគូសបញ្ជាក់ផងដែរថា រាល់ការធ្វើអធិបញ្ញា គឺមិនមានការទាក់ទងទៅនឹងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលនោះឡើយ ដោយហេតុថានៅតុលាការកំពូល គឺចៅក្រមកាត់សេចក្តីតែលើអង្គច្បាប់នោះទេមិនកាត់សេចក្តីទៅលើអង្គហេតុឡើយ ដែលផ្ទុយទៅនឹងការធ្វើអធិបញ្ញា ដែលសុទ្ធសឹងតែជានីតិវិធីដោយផ្អែកទៅលើអង្គហេតុទាំងស្រុងដើម្បីអាចធ្វើអធិបញ្ញាបាន។

## ២. ទណ្ឌកម្មផ្នែកវិន័យ នៃវិជ្ជាជីវៈក្នុងនាមជាតំណាងអយ្យការ

ក្នុងនាមជាតំណាងអយ្យការ "ព្រះរាជអាជ្ញា ត្រូវមានភារកិច្ចទទួលខុសត្រូវចំពោះកិច្ចការ ដែលបានប្រគល់ឲ្យ និងគោរពឲ្យបានម៉ឺងម៉ាត់នូវក្រមសីលធម៌របស់ខ្លួន"[63]។ មានន័យថា ព្រះរាជអាជ្ញាត្រូវតែអនុវត្តកិច្ចការទាំងឡាយដែលខ្លួនត្រូវបំពេញដោយមានទំនួលខុសត្រូវខ្ពស់ចំពោះកិច្ចការទាំងនោះ។ ដោយ យើងបានដឹងរួចមកហើយអំពី សមត្ថកិច្ច មុខងារ តួនាទី ភារកិច្ច កាតព្វកិច្ច អំណាច និងការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញានៅកថាខណ្ឌខាងលើ ដូច្នេះនៅក្នុងកថាខណ្ឌនេះយើងនិងដឹងថាតើព្រះរាជអាជ្ញា និងត្រូវទទួលរងនូវទណ្ឌកម្មផ្នែកវិន័យអ្វីខ្លះ? ដែលអាចនឹងកើតឡើងក្នុងករណីដែលគាត់មិនបានបំពេញតាមកាតព្វកិច្ចវិជ្ជាជីវៈរបស់ខ្លួន?

- **ទណ្ឌកម្មផ្នែកវិន័យ**

យោងតាមច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នៅពេលដែលព្រះរាជអាជ្ញាបានប្រព្រឹត្តអំពើដែលផ្ទុយពីកាតព្វកិច្ចវិជ្ជាជីវៈរបស់ខ្លួន ព្រះរាជអាជ្ញាត្រូវតែទទួលទណ្ឌកម្មផ្នែកវិន័យដូចនឹងចៅក្រមដែរ។ យោងតាមមាត្រា ៥៤ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញាបានបញ្ញត្តិថា "កំហុសរបស់ចៅក្រមក្នុងការបំពេញកាតព្វកិច្ចវិជ្ជាជីវៈ និងការធ្វើឲ្យប៉ះពាល់ដល់កិត្តិយស សីលធម៌ស្អាតស្អំ និងសេចក្តីថ្លៃថ្នូរប្រាស់ចាកពីក្រមសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញា គឺនាំឲ្យមានទណ្ឌកម្មខាងវិន័យតាមបទប្បញ្ញត្តិនៃច្បាប់នេះ។ ប៉ុន្តែ

[63] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា ៩៦

ការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ចៅក្រម និងព្រះរាជអាជ្ញាក្នុងការអនុវត្តច្បាប់ មិនត្រូវចាត់ទុកថាជាកំហុសខាងវិន័យឡើយ"។[64]

យោងតាមច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញាបានកំណត់ថា "ទណ្ឌកម្មវិន័យមិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេប្រសិនបើបទល្មើសណាមួយត្រូវបានប្រព្រឹត្ត"។[65] ក្នុងន័យនេះប្រសិនបើអំពើដែលព្រះរាជអាជ្ញាបានប្រព្រឹត្តនោះ គឺជាបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ហើយក៏ជាអំពើដែលផ្ទុយប្រាស់ចាកនឹងកាតព្វកិច្ចវិជ្ជាជីវៈ នោះឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចធ្វើការដាក់ទណ្ឌកម្មវិន័យទៅលើព្រះរាជអាជ្ញានោះបាន។ ប៉ុន្តែការដាក់ទណ្ឌកម្មវិន័យនេះមិនបានធ្វើឲ្យបណ្តឹងអាជ្ញារលត់ឡើយ គឺព្រះរាជអាជ្ញានៅតែត្រូវទទួលទណ្ឌកម្មផ្នែកព្រហ្មទណ្ឌចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។ ចំពោះការទទួលទណ្ឌកម្មវិន័យវិញ ព្រះរាជអាជ្ញាអាចត្រូវបានផ្អាកពីមុខងារជាបណ្តោះអាសន្ន ដោយប្រធានក្រុមប្រឹក្សាវិន័យ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ក្នុងករណី ដែលព្រះរាជអាជ្ញាកំពុងជាប់នៅក្នុងនីតិវិធីវិន័យរបស់ក្រុមប្រឹក្សាវិន័យ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[66] ដូចនេះយើងឃើញមានច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញាមាត្រា ៥៥ បានកំណត់អំពីទណ្ឌកម្មវិន័យដែលត្រូវបានបែងចែកជា ២ ថ្នាក់ដែលមានដូចតទៅ[67]៖

- **ទណ្ឌកម្មថ្នាក់ទី១**
  1. ការស្តីបន្ទោសដោយផ្ទាល់មាត់
  2. ការស្តីបន្ទោសដោយចុះក្នុងសំណុំលិខិតផ្ទាល់ខ្លួន
  3. ការផ្អាកមិនឲ្យចុះឈ្មោះក្នុងតារាងតំឡើងថ្នាក់ ឬ ឋានន្តរស័ក្តិមួយរយៈតែមិនត្រូវឲ្យលើសពី ២ ឆ្នាំទេ ឬ លុបឈ្មោះចេញពីតារាងដំឡើងថ្នាក់ និងឋានន្តរស័ក្តិវិញ ក្នុងករណីដែលមានចុះឈ្មោះរួចហើយ។
- **ទណ្ឌកម្មថ្នាក់ទី២**
  1. ការផ្លាស់ប្តូរដោយបង្ខំ អាចតម្រូវឲ្យទទួលការបណ្តុះបណ្តាលបន្ថែម
  2. ការព្យួរពីការងារមិនឲ្យមានបៀវត្ស ក្នុងរយៈពេលមិនឲ្យលើសពី ១ ឆ្នាំ
  3. ការបន្ថយមួយថ្នាក់ ឬច្រើនថ្នាក់ ឬបន្ថយឋានន្តរស័ក្តិ
  4. ការដាក់ឲ្យចូលនិវត្តន៍ដោយបង្ខំ

---

[64] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា ៥៤ កថាខណ្ឌទី ១

[65] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា ៥៤ កថាខណ្ឌទី ២

[66] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា ៥៤ កថាខណ្ឌទី ៣

[67] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា ៥៥

5. ការបញ្ឈប់ពីមុខងារដោយបង្ខំ
6. ការបណ្តេញចេញពីក្របខណ្ឌ។

ចំពោះទណ្ឌកម្មទី ២ នេះ ត្រូវធ្វើឡើយដោយព្រះរាជក្រឹត្យ បន្ទាប់ពីមានការសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ បើយោងទៅតាមមាត្រា ៩៩ ស្តីអំពីទណ្ឌកម្មវិន័យរបស់ព្រះរាជអាជ្ញាពោល គឺយកបញ្ញត្តិនៃជំពូកទី ២ (ចៅក្រម) នៃច្បាប់នេះដែលអនុវត្តចំពោះចៅក្រម និងត្រូវយកទៅអនុវត្តដូចគ្នាផងដែរចំពោះព្រះរាជអាជ្ញាទៅលើទណ្ឌកម្មផ្នែកវិន័យនេះ។[68]

## ផ្នែកទី៥៖ មុខងារ នៃស្ថាប័នអយ្យការ

ចំពោះមុខងារ នៃស្ថាប័នអយ្យការដែលយើង នឹងត្រូវយកមកធ្វើការសិក្សាលម្អិតនោះ គឺទាក់ទងទៅនឹងមុខងាររបស់តំណាងអយ្យការអមសាលាដំបូងរាជធានីខេត្តតែប៉ុណ្ណោះ។ បើយោងទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ថា "មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា"[69] និងយោងទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់បន្ថែមទៀតថា "បណ្តឹងអាជ្ញា ត្រូវអនុវត្តន៍ក្នុងនាមជាផលប្រយោជន៍ទូទៅដោយអយ្យការ"។[70] ដូចនេះព្រះរាជអាជ្ញា គឺជាម្ចាស់នៃបណ្តឹងអាជ្ញាដែលជាភាគីតំណាងឲ្យប្រយោជន៍ទូទៅក្នុងរឿងក្តីព្រហ្មទណ្ឌចំពោះមុខតុលាការ។

ដើម្បីធានារ៉ាប់រងកិច្ចការគ្រប់យ៉ាង នូវដែនអនុវត្តន៍នៃច្បាប់ព្រហ្មទណ្ឌ ក៏ដូចជាសេចក្តីសម្រេចខាងព្រហ្មទណ្ឌប្រកបដោយយុត្តិធម៌ ពោល គឺស្ថាប័នអយ្យការត្រូវប្រតិបត្តិនូវគោលការណ៍ច្បាប់ជាមូលដ្ឋានប្រកបដោយចរិតលក្ខណៈគតិយុត្ត។ ដូចបានដឹងហើយថានៅក្នុងអយ្យការនីមួយៗមានព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងដែលជាស្ថាប័នអយ្យការអមសាលាដំបូង នៃសមត្ថកិច្ចដែនដីដែលតុលាការតាំងនៅ។ ដូច្នេះ ដំណើរការនីតិវិធីនៅក្នុងរឿងក្តីណាមួយត្រូវបានធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌក្នុងនោះ គឺត្រូវមានការកំណត់នូវអត្ថិភាពនៃបទល្មើស[71] នៅក្នុងការចោទប្រកាន់របស់ព្រះរាជអាជ្ញាខាងរឿងក្តីព្រហ្មទណ្ឌ មិនត្រឹមតែកំណត់បទល្មើសចង្អុលបង្ហាញសកម្មភាព នៃអំពើល្មើសរបស់ជនប្រព្រឹត្តបទល្មើសទេ គឺកំណត់ទោសនិងនីតិវិធីនៃការអនុវត្តទោស[72] ដែលមានលក្ខណៈស៊ីសង្វាក់គ្នា និងភស្តុតាងក្នុងការសុំឲ្យអនុវត្តន៍ចំពោះមុខយុត្តាធិការស៊ើបសួរ និង

---

[68] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា ៩៩

[69] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា ១៣១

[70] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤

[71] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១ និងមាត្រា ៤

[72] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា ១

យុត្តាធិការជំនុំជម្រះ ដោយធ្វើសេចក្តីសន្និដ្ឋានបង្ហាញពីពិរុទ្ធភាពឲ្យតុលាការអនុវត្តន៍តាមច្បាប់[73] មិនតែប៉ុណ្ណោះទេ គឺត្រូវធ្វើសេចក្តីសង្ខេបអង្គហេតុ ដែលកំណត់ឈ្មោះបទល្មើស និងបង្ហាញអត្ថបទច្បាប់ដែលកំណត់បទល្មើស កំណត់ឈ្មោះ ឬ អត្តសញ្ញាណ ឬ សាវតាជាតិបុគ្គលដែលត្រូវចោទ។[74]

## ១. អំណាចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី-ខេត្ត

ចំពោះសាលាដំបូងរាជធានីខេត្ត តំណាងស្ថាប័នអយ្យការមានតែព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងប៉ុណ្ណោះ ដែលជាតំណាងស្ថាប័នអយ្យការ។ ដោយឡែកព្រះរាជអាជ្ញា គឺជានាយឋានានុក្រមរបស់ព្រះរាជអាជ្ញារងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ប៉ុន្តែព្រះរាជអាជ្ញារងដែលស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា គឺអាចប្រើប្រាស់នូវសិទ្ធិអំណាច ដែលខ្លួនមានក្នុងការធ្វើការចោទប្រកាន់ និងធ្វើការស្រាវជ្រាវទៅលើបទល្មើសណាមួយពោលគឺ "ព្រះរាជអាជ្ញារងដែលស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា អាចប្រើប្រាស់អំណាចដែលព្រះរាជអាជ្ញាមាននៅក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើស"។[75] ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីខេត្ត គឺមានអំណាចនៅក្នុងការបើកការស៊ើបអង្កេតជាបឋម ឬ ដំបូងទៅលើរឿងក្តីព្រហ្មទណ្ឌដែលខ្លួនទទួលពីមន្ត្រីនគរបាលយុត្តិធម៌ ឬ ពីប្រភពបណ្តឹងផ្ទាល់របស់រូបវន្តបុគ្គលនៅក្នុងសមត្ថកិច្ចនៃការស៊ើបអង្កេតនេះ។

- **ការតំណាងអង្គការអយ្យការអមសាលាដំបូង**

ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង គឺជាតំណាងរបស់អង្គភាពអយ្យការអមតុលាការនេះ។[76]

- **អំណាចរបស់ព្រះរាជអាជ្ញា**

ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ប៉ុន្តែកាលណាអនុវត្តដីកាសម្រេចចាត់ឲ្យស៊ើបសួរជំនួសមន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ។

ក្នុងការស៊ើបអង្កេតនេះព្រះរាជអាជ្ញាប្រើប្រាស់អំណាច ដែលក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់ឲ្យទៅមន្ត្រីនគរបាលយុត្តិធម៌ ពោល គឺដើម្បីដឹកនាំនិងសម្របសម្រួលនូវសកម្មភាពរបស់នគរបាលយុត្តិធម៌ដែលស្ថិតនៅក្រោមសមត្ថកិច្ចដែនដីខ្លួន។ មានន័យថា មន្ត្រីនគរបាលយុត្តិធម៌អនុវត្តអំណាចទាំងអស់ដែលព្រះរាជអាជ្ញាបានផ្តល់ឲ្យនៅក្នុងការស៊ើបអង្កេត ព្រះរាជអាជ្ញាអាចចុះទៅកាន់កន្លែងស៊ើបអង្កេត និងធ្វើការគ្រប់ការណែនាំ

---

[73] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤ និងមាត្រា ២៧

[74] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៤ និងមាត្រា ៤៦

[75] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៣៨

[76] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៣៦

ដែលមានប្រយោជន៍ដល់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌។ នៅក្នុងករណីចាំបាច់ និងពិសេសណាមួយព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចបានគ្រប់ពេលនៅអង្គភាពនគរបាលយុត្តិធម៌ ដោយអាចដកហូតនូវសិទ្ធិ និងសមត្ថកិច្ចស៊ើបអង្កេតរបស់មន្ត្រីសាធារណៈ និងភ្នាក់ងារនគរបាលយុត្តិធម៌ ដែលស្ថិតក្រោមអំណាចដែនសមត្ថកិច្ចរបស់ខ្លួន ដែលកំពុងស៊ើបអង្កេត ហើយរៀបចំជំនួសនូវភ្នាក់ងារមន្ត្រីថ្មីមកជំនួសវិញដើម្បីធ្វើការស៊ើបអង្កេតបន្ត។

ព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលានៅអង្គភាពនគរបាលយុត្តិធម៌។ ព្រះរាជអាជ្ញាអាចចូលរួមក្នុងការស្តាប់ចម្លើយ អាចត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ជាពិសេស គឺការគោរពទម្រង់ការច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន។[77]

- **អំណាចរបស់ព្រះរាជអាជ្ញារង**

ព្រះរាជអាជ្ញារង ដែលស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញាប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ។[78]

## ២. សមត្ថកិច្ចតាមដែនដីរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចគឺ[79]៖

- **ព្រះរាជអាជ្ញា នៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស**

**ឧទាហរណ៍៖** បទល្មើសត្រូវបានប្រព្រឹត្តនៅខេត្តព្រះសីហនុដូចនេះដែនសមត្ថកិច្ចរបស់អយ្យការសាលាដំបូងខេត្តព្រះសីហនុ។

- **ព្រះរាជអាជ្ញា នៃទីលំនៅរបស់ជនដែលគេសង្ស័យថាបានប្រព្រឹត្តបទល្មើស**

**ឧទាហរណ៍៖** ជនល្មើសបានប្រព្រឹត្តអំពើលួចនៅរាជធានីភ្នំពេញ តែគេដឹងថាជនល្មើសមានទីលំនៅនៅខេត្តព្រៃវែង។ ដូចនេះជនរងគ្រោះអាចដាក់ពាក្យបណ្តឹងនៅអយ្យការអមសាលាដំបូងខេត្តព្រៃវែងបាន។

ដែលក្នុងករណីនេះ អយ្យការអមសាលាដំបូងខេត្តព្រៃវែង ក៏ជាអ្នកមានសមត្ថកិច្ចដែរ។

- **ព្រះរាជអាជ្ញា នៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានសង្ស័យថាបានប្រព្រឹត្តបទល្មើស**

**ឧទាហរណ៍៖** ជនល្មើសបានប្រព្រឹត្តបទល្មើសនៅរាជធានីភ្នំពេញតែជនល្មើសត្រូវបានចាប់ខ្លួននៅខេត្តកំពង់ចាម ដូចនេះអយ្យការអមសាលាដំបូងខេត្តកំពង់ចាម ក៏មានសមត្ថកិច្ចដូចគ្នាដែរ។ ករណីនេះអយ្យការទាំងពីរគួរសម្របសម្រួលគ្នា ហើយសមត្ថកិច្ចគួរត្រូវបានប្រគល់ជូនអយ្យការអមសាលាដំបូងខេត្តកំពង់ចាម ព្រោះដើម្បីជាការសម្រួលដល់នីតិវិធីរឿងក្តី។

---

[77] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៣៧

[78] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៣៨

[79] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៣៩

# ជំពូកទី ២
# បណ្តឹងអាជ្ញា និង បណ្តឹងរដ្ឋប្បវេណី

# ជំពូកទី ២
# បណ្តឹងអាជ្ញា និង បណ្តឹងរដ្ឋប្បវេណី

បន្ទាប់ពីបានបង្ហាញជូនដូចនៅក្នុងជំពូកទីមួយរួចមកហើយដែរ ពោល គឺយើងបានយល់អំពីសញ្ញាណទូទៅនៃព្រះរាជអាជ្ញារួចមកហើយ ដោយឡែកនៅក្នុងចំណុចនៃបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីនៃជំពូកនេះតែម្តងដែលយើងនឹងត្រូវយល់អត្ថន័យ និងខ្លឹមសារដែរមានការបែងចែកដោយបញ្ញត្តិច្បាប់។ នេះបើយើងក្រឡេកមើលនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ យោងទៅតាមបទប្បញ្ញត្តិមាត្រា ១ បានចែងថាក្រមនីតិវិធីព្រហ្មទណ្ឌមានគោលបំណងកំណត់អំពីវិធានទាំងឡាយ ដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ ដើម្បីកំណត់ឲ្យបានច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ។ បទប្បញ្ញត្តិនៃក្រមនេះត្រូវបាន យកទៅអនុវត្តចំពោះរឿងក្តីព្រហ្មទណ្ឌ កាលណាពុំមានវិធានដោយឡែកចែងដោយច្បាប់ពិសេសទេនោះ។

ជាទូទៅ នៅពេលដែលមានបទល្មើសមួយកើតមានឡើង គឺអាចមានបណ្តឹងពីរផ្សេងគ្នាកើតមានឡើង ឬ ដែលត្រូវបានកើតមានឡើងនៅតំណាលគ្នាផងដែរ។ ពោល គឺយើងឃើញមានបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី។ ដោយនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង គឺបានទទួលស្គាល់នូវបណ្តឹងពីរប្រភេទដែលរួមមាន៖ បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីនេះ។ ហើយបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីជាបណ្តឹងពីរផ្សេងពីគ្នា។

តើអ្វីទៅជាបណ្តឹងអាជ្ញា? ហើយអ្វីទៅជាបណ្តឹងរដ្ឋប្បវេណី?

ដូច្នេះ ដើម្បីអោយមានភាពស៊ីជម្រៅទៅនឹងចំណុចខាងលើ នៃជំពូកទី២នេះផងដែរ។ យើងនិងធ្វើការបកស្រាយ និងបង្ហាញថាតើអ្វីទៅជាបណ្តឹងអាជ្ញា និងអ្វីទៅជាបណ្តឹងរដ្ឋប្បវេណី ហើយតើវាមានលក្ខណៈខុសគ្នាបែបណានៃបណ្តឹងទាំងពីរ ព្រមទាំងបណ្តឹងទាំងពីរនេះអាចមានទំនាក់ទំនងយ៉ាងដូចម្តេចនឹងគ្នាផងដែរ៖

- **ផ្នែកទី១៖** បណ្តឹងអាជ្ញា
- **ផ្នែកទី២៖** បណ្តឹងរដ្ឋប្បវេណី
- **ផ្នែកទី៣៖** ភាពខុសគ្នារវាងបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី
- **ផ្នែកទី៤៖** ទំនាក់ទំនងរវាងបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី

## ផ្នែកទី១៖ បណ្តឹងអាជ្ញា

### ១. អត្ថន័យ នៃបណ្តឹងអាជ្ញា

បណ្តឹងអាជ្ញាស្របតាមមាត្រា ២ កថាខណ្ឌទី ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថាបណ្តឹងអាជ្ញាមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើសបង្ហាញឱ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាម

ច្បាប់កំណត់។[80] ដោយមានន័យថា បណ្តឹងអាជ្ញា ឬបណ្តឹងព្រហ្មទណ្ឌ គឺត្រូវទាមទារឱ្យមានភាពជាបទល្មើសជាបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុដែលត្រូវចោទប្រកាន់ រួមទាំងបង្ហាញអំពីធាតុផ្សំគ្រប់គ្រាន់សម្រាប់បទល្មើសណាមួយទើបអាចផ្តន្ទាទោសចំពោះជននោះបាន។

## ២. កម្មវត្ថុ នៃបណ្តឹងអាជ្ញា

កម្មវត្ថុនៃបណ្តឹងអាជ្ញា ឬ ហៅថាបណ្តឹងព្រហ្មទណ្ឌ ត្រូវអនុវត្តទៅលើបុគ្គលគ្រប់រូបទាំងរូបវន្តបុគ្គលទាំងនីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយដើមកំណើតជាតិឋានៈសង្គម ធនធាន ឬ ស្ថានភាពឯទៀតឡើយ។[81]

មានន័យថា បណ្តឹងព្រហ្មទណ្ឌត្រូវអនុវត្តចំពោះបុគ្គលទូទៅ ដែលជាសមាជិកនៃសង្គមដោយមិនត្រូវប្រកាន់បក្សពួក ឬ ប្រកាន់ជាតិសាសន៍ណាមួយឡើយ។

**ឧទាហរណ៍៖** លោក "ក" ជាមន្ត្រីរាជការដែលបម្រើការនៅក្រសួងមួយ គាត់បានប្រព្រឹត្តបទល្មើសឃាតកម្ម ដែលក្រមព្រហ្មទណ្ឌមាត្រា ១៩៩ បានកំណត់ថាជាបទល្មើស។ ហេតុនេះលោក "ក" ត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ទោះបីលោក "ក" ជាមន្ត្រីរាជការក៏ដោយ។ នៅក្នុងក្រមព្រហ្មទណ្ឌបានប្បញ្ញត្តិលើកលែងតែរដ្ឋទេដែលមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ (មាត្រា ៤២ នៃក្រមព្រហ្មទណ្ឌ)។

## ៣. ការកកើត នៃបណ្តឹងអាជ្ញា

នៅក្នុងចំណុច នៃការកើតឡើងនៃបណ្តឹងអាជ្ញានេះ ពោល គឺយើងឃើញមានការបែងចែកជា ៣ (បី) ចំណុចរួមមាន៖

1. ការចាប់ផ្តើមដំណើរការ នៃបណ្តឹងអាជ្ញាដោយអយ្យការ
2. ការដាក់បណ្តឹងអាជ្ញាឱ្យមានចលនាដោយជនរងគ្រោះ
3. ការដាក់ពាក្យប្តឹងទាមទារដោយជនរងគ្រោះ

### ៣.១. ការចាប់ផ្តើមដំណើរការ នៃបណ្តឹងអាជ្ញាដោយអយ្យការ

ស្របតាមមាត្រា១៣១ នៃរដ្ឋធម្មនុញ្ញចែងថាមានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។ ក្នុងរឿងក្តីព្រហ្មទណ្ឌមិនបាច់មានបណ្តឹងព្រហ្មទណ្ឌពីជនរងគ្រោះនោះទេ ដោយអយ្យការជាស្ថាប័នមួយដែលតំណាងឱ្យសង្គមទាំងមូល ក៏អាចចាប់ផ្តើមដំណើរការនៃរឿងក្តីព្រហ្មទណ្ឌបានដែរ។[82] មាត្រា ៤ កថាខណ្ឌទី ១

[80] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២ កថាខណ្ឌទី ២

[81] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៣

[82] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា ១៣១

នៃក្រមនីតិវិធីព្រហ្មទណ្ឌបានប្បញ្ញត្តិថា បណ្តឹងអាជ្ញាអនុវត្តក្នុងនាមផលប្រយោជន៍ទូទៅដោយអយ្យការ មានន័យថាបណ្តឹងរបស់ព្រះរាជអាជ្ញា គឺធ្វើឡើងក្នុងគោលបំណងជាផលប្រយោជន៍ដល់សង្គម។[83]

ប្រសិនបើមានបទល្មើសព្រហ្មទណ្ឌអយ្យការនឹងធ្វើការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌ ហើយសុំឱ្យមានការអនុវត្តច្បាប់នូវចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។ មានន័យថាអយ្យការធ្វើការចោទប្រកាន់ហើយអយ្យការនឹងបញ្ជូនទៅដំណាក់កាលបន្តបន្ទាប់ទៀត ដោយមានដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ។

គួរបញ្ជាក់ថា ការបើកការស៊ើបសួរ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ត្រូវប្រែប្រួលទៅតាមលក្ខខណ្ឌនៃបទល្មើសនីមួយៗ។

### ៣.២. ការដាក់បណ្តឹងអាជ្ញាឲ្យមានចលនាដោយជនរងគ្រោះ

ការដាក់បណ្តឹងអាជ្ញាឱ្យមានចលនាដោយជនរងគ្រោះ មានន័យថាជនរងគ្រោះនៃបទឧក្រិដ្ឋ បទមជ្ឈិម អាចដាក់ពាក្យប្តឹងរបស់ខ្លួនដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរបាន។ កាលដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងនៅចំពោះមុខចៅក្រមស៊ើបសួរបណ្តឹងនេះ គឺមានអានុភាពប្តឹងដល់ចៅក្រមស៊ើបសួរដោយឱ្យអនុវត្តតាមមាត្រា ១៣៨ និងមាត្រា ១៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។[84]

ចំពោះអត្ថន័យនៃមាត្រា ១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ មានន័យថាចៅក្រមស៊ើបសួរធ្វើការកត់សម្គាល់នូវពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ចៅក្រមស៊ើបសួរ នឹងបញ្ជូនពាក្យប្តឹងទៅព្រះរាជអាជ្ញា ដើម្បីឱ្យព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ព្រោះចៅក្រមស៊ើបសួរមិនអាចបើកការស៊ើបសួរ ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញានោះទេ គឺត្រូវមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញា។

មានន័យថាជាទូទៅ និងជាញឹកញយបណ្តឹងអាជ្ញាត្រូវបានដាក់ឲ្យមានចលនា និងអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ ពីព្រោះអយ្យការជាអ្នកធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ប៉ុន្តែយោងតាមមាត្រា ៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌជាករណីអញ្ញត្រកម្ម ដោយបណ្តឹងអាជ្ញាអាចត្រូវបានដាក់ឲ្យមានចលនា ដោយជនរងគ្រោះផងដែរ។[85] ពោល គឺការដាក់ពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ

---

[83] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤ កថាខណ្ឌទី ១

[84] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១៣៩ និង មាត្រា ១៤០

[85] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៥

ពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ មានអានុភាពប្តឹងដល់ចៅក្រមស៊ើបសួរ អំពីបណ្តឹងអាជ្ញានៅក្នុងលក្ខខណ្ឌដែលបញ្ញត្តិដោយមាត្រា ១៣៩ និង មាត្រា ១៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ជាគោលការណ៍បណ្តឹងនេះ គឺជាសេរីភាពខាងឆន្ទៈបុគ្គលឯកជនការដាក់ពាក្យបណ្តឹងបែបនេះទាមទារឲ្យជនរងគ្រោះពិចារណាឲ្យបានល្អិតល្អន់បំផុត ដោយហេតុថា បណ្តឹងនេះអាចនឹងទទួលរងនូវប្រតិកម្មតបវិញដោយអ្នកប្តឹងអាចនឹងប្រឈមនឹងការពិន័យរដ្ឋប្បវេណី និងបណ្តឹងឲ្យជួសជុលការខូចខាតពីភាគីម្ខាងទៀត ក្នុងករណីដែលរកឃើញថាបណ្តឹងនោះធ្វើឡើងដោយរំលោភបំពាន ឬ បណ្តឹងអូសបន្លាយពេលវេលា។ ហេតុផលនេះហើយទើបមានការសន្មតថា បណ្តឹងនេះអាចជាជម្រើសចុងក្រោយរបស់ជនរងគ្រោះ ឬ អាចនិយាយឲ្យកាន់តែច្បាស់ថែមទៀតនោះ គឺបណ្តឹងបែបនេះភាគច្រើនជនរងគ្រោះ ធ្វើឡើងបន្ទាប់ពីការតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញា ឬ បន្ទាប់ពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តម្កល់សេចក្តីសម្រេចឥតចាត់ការរបស់ព្រះរាជអាជ្ញាអមសាលាដំបូងក្នុងក្របខណ្ឌជំរុញឲ្យបណ្តឹងអាជ្ញាមានចលនាចំពោះអង្គហេតុណាមួយ ដែលជនរងគ្រោះយល់ឃើញថាខ្លួនបានទទួលរងការបំពានពីអំពើនោះ ហើយអំពើនោះទៀតសោតមានចរិតលក្ខណៈជាបទល្មើសព្រហ្មទណ្ឌ។

**ដោយនៅក្នុងនីតិវិធី៖** កាលណាចៅក្រមស៊ើបសួរបានទទួលពាក្យប្តឹងសុំដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវធ្វើការកត់សម្គាល់នូវការដាក់ពាក្យប្តឹងនោះដោយដីកា ហើយបញ្ជូនពាក្យបណ្តឹងនោះទៅព្រះរាជអាជ្ញា។

ក្រោយពីបានទទួលពាក្យបណ្តឹងនោះ ព្រះរាជអាជ្ញា ត្រូវប្តឹងទៅចៅក្រមស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនចងកាតព្វកិច្ចឲ្យព្រះរាជអាជ្ញា ពោល គឺត្រូវតែបើកឲ្យស៊ើបសួរចំពោះបុគ្គលដែលមានចង្អុលបង្ហាញក្នុងពាក្យប្តឹងនោះទេ។ បានសេចក្តីថាព្រះរាជអាជ្ញាអាចបើកឲ្យស៊ើបសួរប្រឆាំងនឹងអញ្ញាតជន ទោះបីជា បណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ ចោទទៅលើឈ្មោះបុគ្គលម្នាក់ ឬ ច្រើននាក់ក៏ដោយ។

នៅក្នុងក្របខ័ណ្ឌនេះ ព្រះរាជអាជ្ញាអាចប្តឹងសុំឲ្យចៅក្រមស៊ើបសួរកុំឲ្យស៊ើបសួរបានតែក្នុងករណីដែល៖

- បណ្តឹងអាជ្ញាត្រូវបានផុតរលត់
- អំពើដែលប្តឹងមកនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌ។

ក្នុងករណីដែល ចៅក្រមស៊ើបសួរសម្រេចមិនស៊ើបសួរតាមការប្តឹងសុំរបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។ កាលបើអ្នកប្តឹងសុំមិនសុខចិត្តនឹងសេចក្តីសម្រេចនេះ ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងឧទ្ធរណ៍បានក្នុងរយៈពេល ៥ ថ្ងៃ គិតពីថ្ងៃបានជូនដំណឹងពីដីកា។

ក្នុងករណីដែលចៅក្រមស៊ើបសួរនៅតែសម្រេចស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញាបន្ទាប់ពីបានសម្រេចស៊ើបសួរ។ ចៅក្រមស៊ើបសួរត្រូវកំណត់តាមដីកាសម្រេចនូវចំនួនទឹកប្រាក់ និង រយៈពេលដែលដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបង់។ ការសម្រេចកំណត់ចំនួនទឹកប្រាក់តម្កល់នេះ ចៅក្រមស៊ើបសួរត្រូវពិនិត្យពិចារណាដោយផ្អែកទៅលើធនធាននៃដើមបណ្ដឹងរដ្ឋប្បវេណី និងការលំបាកនៃរឿងដែលអាចមើលឃើញជាមុន។ កាលបើមិនឯកភាពតាមចំនួនទឹកប្រាក់ដែលកំណត់ដោយចៅក្រមស៊ើបសួរ ដើមបណ្ដឹងរដ្ឋប្បវេណីអាចប្ដឹងឧទ្ធរណ៍បានក្នុងរយៈពេល ៥ ថ្ងៃ គិតពីថ្ងៃបានជូនដំណឹងពីដីកានេះផងដែរ។ កាលបើបានទទួលដំណឹងអំពីការកំណត់ឲ្យបង់ប្រាក់តម្កល់រួចហើយ ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវទៅបង់ប្រាក់ ដោយមានទទួលបង្កាន់ដៃដែលមានចុះហត្ថលេខាដោយប្រធានតុលាការ ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ប៉ុន្តែក្នុងករណីដែលដើមបណ្ដឹងរដ្ឋប្បវេណីខកខានមិនបង់ប្រាក់ក្នុងរយៈពេលកំណត់ទេនោះ ចៅក្រមស៊ើបសួរត្រូវប្រកាសមិនទទួលពាក្យប្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនោះដោយដីកាសម្រេច ហើយត្រូវជូនដំណឹងដល់ដើមបណ្ដឹងរដ្ឋប្បវេណីជាបន្ទាន់។ ក្នុងករណីនេះដើមបណ្ដឹងរដ្ឋប្បវេណីអាចប្ដឹងឧទ្ធរណ៍បានក្នុងរយៈពេល ៥ ថ្ងៃ គិតពីថ្ងៃបានជូនដំណឹងពីដីកា។

ប្រាក់តម្កល់ទុកត្រូវរក្សាទុកនៅក្នុងគណនីពិសេសដែលបើកនៅក្នុងធនាគារ ឬ រក្សាទុកនៅក្នុងទីកន្លែងដែលមានការធានាសន្តិសុខរឹងមាំ ដែលត្រូវជ្រើសរើសតាមការព្រមព្រៀងគ្នារបស់ប្រធាន និងព្រះរាជអាជ្ញា។

ប្រាក់តម្កល់ត្រូវបង្វិលទៅសាមីខ្លួននៅពេលបញ្ចប់នីតិវិធី លើកលែងក្នុងករណីដែលរកឃើញថាបណ្ដឹងនេះធ្វើឡើងដោយបំពាន ឬ អូសបន្លាយពេលវេលាដែលត្រូវអនុវត្តបទប្បញ្ញត្តិនៃមាត្រា ១៤១។ ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណីពុំមានលទ្ធភាពអាចបង់ប្រាក់តម្កល់ទុកបានទេ ចៅក្រមស៊ើបសួរអាចសម្រេចតាមដីកាលើកលែងមិនឲ្យបង់ប្រាក់តម្កល់នេះបាន ហើយជូនដំណឹងជាបន្ទាន់ទៅដើមបណ្ដឹងរដ្ឋប្បវេណី។

និងប្រសិនបើការស៊ើបសួរ ដែលបានបើកបន្ទាប់ពីមានពាក្យបណ្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានបិទតាមដីកាលើកលែងចោទប្រកាន់ ហើយកាលបើចៅក្រមស៊ើបសួរ យល់ឃើញថានីតិវិធីធ្វើឡើងដោយរំលោភបំពាន ឬ អូសបន្លាយពេលវេលានោះចៅក្រមស៊ើបសួរអាចសម្រេចតាមដីកាសម្រេចឲ្យដើមបណ្ដឹងរដ្ឋប្បវេណីបង់ប្រាក់ពិន័យរដ្ឋប្បវេណី (ពិន័យស៊ីវិល = ទណ្ឌកម្ម ខាងហិរញ្ញវត្ថុមួយប្រភេទដែលកំណត់ឲ្យអ្នកប្រព្រឹត្តខុសនឹងបញ្ញត្តិនៃច្បាប់ផ្នែករដ្ឋប្បវេណីបង់ពិន័យ)។ ចំនួនប្រាក់ពិន័យមិនអាចលើសចំនួនទឹកប្រាក់តម្កល់ទុកឡើយ ហើយដីកាសម្រេចឲ្យបង់ប្រាក់ពិន័យនេះ ត្រូវជូនដំណឹងដល់សាមីខ្លួនជាបន្ទាន់។ ក្នុងករណីដែលសាមីខ្លួនមិនសុខចិត្ត អាចប្ដឹងឧទ្ធរណ៍បានក្នុងរយៈពេល ៥ ថ្ងៃ គិតពីថ្ងៃបានជូនដំណឹងដីកា។

នៅពេលដែលបិទការស៊ើបសួរ ដោយដីកាលើកលែងចោទប្រកាន់ចូលជាស្ថាពរ ហើយនីតិវិធីធ្វើឡើងដោយរំលោភ ឬ អូសបន្លាយពេលវេលាបុគ្គលទាំងឡាយដែលមានឈ្មោះនៅក្នុងពាក្យបណ្ដឹងអាចដាក់ពាក្យប្ដឹងសុំការជួសជុលសំណងពីអ្នកដែលប្ដឹងពីខ្លួនទៅតុលាការជាន់ដំបូងដែលស៊ើបសួររឿងក្ដីនោះ។

### ៣.៣. ការដាក់ពាក្យបណ្ដឹងទាមទារដោយជនរងគ្រោះ

ការដាក់ពាក្យប្ដឹងទាមទារដោយជនរងគ្រោះ មានន័យថាបុគ្គលគ្រប់រូបដែលជាជនរងគ្រោះនៃបទល្មើសអាចដាក់ពាក្យបណ្ដឹងបាន។ ប៉ុន្តែពាក្យបណ្ដឹងដែលខ្លួនបានដាក់ គឺជាពាក្យបណ្ដឹងសាមញ្ញគ្មានអានុភាពនាំឱ្យធ្វើការចោទប្រកាន់ជាបទព្រហ្មទណ្ឌទេ។[86] ដោយហេតុថាគ្រប់បណ្ដឹងទាំងអស់ មិនសុទ្ធសឹងតែត្រូវបានចោទប្រកាន់នោះទេ ព្រោះការថ្លឹងថ្លែងជាសិទ្ធិអំណាចរបស់ព្រះរាជអាជ្ញាក្នុងការចោទប្រកាន់ ការតម្កល់រឿងទុកឥតចាត់ការដោយផ្អែកលើធាតុផ្សំនៃបទល្មើស។

មួយវិញទៀតបើបណ្ដឹងស្ថិតនៅគ្មានចម្លើយ ឬ ព្រះរាជអាជ្ញាសម្រេចតម្កល់ទុកឥតចាត់ការជនរងគ្រោះក៏មានសិទ្ធិទៀតដែរ ដោយអាចប្ដឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ក្នុងរយៈពេល ២ (ពីរ) ខែ គិតចាប់ពីថ្ងៃទទួលបានសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការ (មាត្រា ៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

## ៤. ការរលត់ នៃបណ្ដឹងអាជ្ញា

យោងតាមមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បណ្ដឹងអាជ្ញាអាចរលត់បានរួមមាន[87]៖

- មរណភាព នៃជនល្មើស
- ការផុតអាជ្ញាយុកាល
- ការលើកលែងទោសជាទូទៅ
- និរាករណ៍ នៃច្បាប់ព្រហ្មទណ្ឌ
- អាជ្ញាអស់ជំនុំ។

កាលណាបណ្ដឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្ដើមបានទៀតទេ ឬ ត្រូវតែបញ្ឈប់។

### មរណភាព នៃជនល្មើស

បណ្ដឹងអាជ្ញា នឹងត្រូវរលត់នៅពេលដែលជនសង្ស័យ ជនត្រូវចោទ ឬ ជនជាប់ចោទ បានទទួលមរណភាពបើផ្អែកតាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ ដែលសំដៅដល់ការទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនតែប៉ុណ្ណោះ។ ពោល គឺបុគ្គលណាជា

---

[86] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៦

[87] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៧

អ្នកប្រព្រឹត្តបទល្មើស បុគ្គលនោះជាអ្នកទទួលខុសត្រូវទោសព្រហ្មទណ្ឌ ដោយមិនអាចឱ្យអ្នកដទៃ ឬសាច់ញាតិរបស់ខ្លួនទទួលទោសជំនួសបានឡើយ។ ដូចនេះដំណាក់កាលនីតិវិធីទាំងអស់នៃសំណុំរឿងព្រហ្មទណ្ឌនឹងត្រូវបញ្ចប់ ប្រសិនបើជនសង្ស័យ ជនត្រូវចោទ ឬ ជនជាប់ចោទ បានទទួលមរណភាពដោយសារតែបណ្ដឹងអាជ្ញាត្រូវបានរលត់។

- **ការផុតអាជ្ញាយុកាល**

អាជ្ញាយុកាលនៃបទល្មើស គឺជារយៈពេលដែលកំណត់ដោយច្បាប់ ដែលក្នុងករណីដែលផុតរយៈពេលកំណត់នេះ នោះព្រះរាជអាជ្ញាពុំអាចធ្វើការចោទប្រកាន់បានទេ។[88] រយៈពេលនៃអាជ្ញាយុកាលត្រូវប្រែប្រួលទៅតាមប្រភេទនៃបទល្មើសនីមួយៗពោលគឺ ១ (មួយ) ឆ្នាំ ចំពោះបទលហុ ៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម និង ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ ហើយត្រូវរាប់គិតចាប់ពីពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត។

**ឧទាហរណ៍៖** លោក (ក) បានបង្កអំពើហិង្សាដោយចេតនាដែលជាបទមជ្ឈិម លើលោក (ខ) ដែលជាមិត្តភក្តិ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២២ ហើយធ្វើការរត់គេចខ្លួនទៅក្រៅប្រទេស។ ក្រោយមកជនរងគ្រោះមិនបានដាក់ពាក្យបណ្ដឹង ដើម្បីឱ្យមានការស៊ើបអង្កេតស្វែងរក លោក (ក) នោះឡើយ ដោយយល់ឃើញថាធ្លាប់ជាមិត្តភក្តិនឹងគ្នា។ ដូចនេះប្រសិនបើលោក (ក) ត្រឡប់មកប្រទេសកម្ពុជាវិញនៅរយៈពេល ៥ ឆ្នាំក្រោយ ពោលគឺថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៧ នោះខាងស្ថាប័នអយ្យការមិនអាចធ្វើការចោទប្រកាន់លើបទល្មើសហិង្សាដោយចេតនានេះបានទៀតទេ ដោយសារតែរយៈពេលនៃអាជ្ញាយុកាលត្រូវបានផុតកំណត់។

ដោយឡែកយើងត្រូវកត់សម្គាល់ផងដែរថា រយៈពេលនៃអាជ្ញាយុកាលនឹងត្រូវរាប់សារជាថ្មីម្ដងទៀតនៅពេលដែលបញ្ចប់កិច្ចចោទប្រកាន់ ឬ កិច្ចស៊ើបសួរនិមួយៗ មានន័យថាប្រសិនបើភ្លាមៗ ក្រោយពេលដែលរងរបួសលោក (ខ) បានដាក់ពាក្យបណ្ដឹងព្រហ្មទណ្ឌទៅកាន់មន្ត្រីនគរបាលយុត្តិធម៌ ដែលឈានដល់មានការចោទប្រកាន់ពីស្ថាប័នអយ្យការ ឬ បើកការស៊ើបសួរពីសំណាក់ចៅក្រមស៊ើបសួរនោះ រយៈពេលនៃអាជ្ញាយុកាល នឹងត្រូវរាប់សារជាថ្មី នៅពេលដែលបញ្ចប់ការចោទប្រកាន់ ឬ ការស៊ើបសួរនោះ។

- **ការលើកលែងទោសជាទូទៅ**

ការលើកលែងទោសជាទូទៅនេះ មិនសំដៅទៅលើការលើកលែងទោស ដោយរាជានុសិទ្ធិរបស់ព្រះមហាក្សត្រ ដែលជាទូទៅធ្វើឡើងជារៀងរាល់ឆ្នាំក្នុងឱកាស នៃព្រះរាជពិធីបុណ្យជាតិធំៗនោះទេ។ ការលើកលែងទោសជាទូទៅដែលធ្វើឱ្យបណ្ដឹងអាជ្ញាមួយរលត់ សំដៅលើការធ្វើច្បាប់ដែលអនុម័តដោយរដ្ឋសភាសម្រាប់លើក

[88] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២

លែងទោស ឬ លុបចោលនូវប្រភេទបទល្មើសណាមួយដែលនាំឱ្យបណ្តឹងអាជ្ញាដែលកំពុងដំណើរការក្នុងនីតិវិធីនឹងត្រូវរលត់។

**និរាករណ៍ នៃច្បាប់ព្រហ្មទណ្ឌ**

ដូចបានបញ្ជាក់ជូនខាងលើ ស្ថាប័នអយ្យការ អាចធ្វើការចោទប្រកាន់ទៅលើអំពើដែលត្រូវបានកំណត់ថាជាបទល្មើសនៅក្នុងក្រមព្រហ្មទណ្ឌបានតាមរយៈបណ្តឹងអាជ្ញា ប៉ុន្តែ ទោះបីជាមានការចោទប្រកាន់ក៏ដោយ ក៏បណ្តឹងអាជ្ញាអាចត្រូវបានរលត់ផងដែរ ប្រសិនបើបទល្មើសនោះត្រូវបាននិរាករណ៍ ពោល គឺអំពើដែលបានប្រព្រឹត្តដោយជនល្មើសនោះលែងត្រូវបានកំណត់ថាជាបទល្មើសនៅក្នុងក្រមព្រហ្មទណ្ឌតទៅទៀត។

**អាជ្ញាអស់ជំនុំ**

ប្រសិនបើជនជាប់ចោទត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរតាមរយៈសាលក្រម ឬ សាលដីកាណាមួយហើយ ជនជាប់ចោទនោះមិនអាចត្រូវបានចោទប្រកាន់ចំពោះអំពើដដែលទៀតនោះទេ ទោះបីជាការចោទប្រកាន់នោះក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងទៀតក៏ដោយ។

### ៤.១. មូលហេតុផ្សេងទៀត នៃការរលត់បណ្តឹងអាជ្ញា

ក្រៅពីមូលហេតុដែលបានរៀបរាប់ខាងលើនេះមាត្រា ៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បានចែងពីមូលហេតុចំនួន ៣ ផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញាផងដែរ[៦៩]៖

1. ដោយការសម្របសម្រួលជាមួយរដ្ឋ
2. ដោយការដកពាក្យបណ្តឹង ក្នុងករណីពាក្យបណ្តឹងនោះជាលក្ខខណ្ឌចាំបាច់ នៃការចោទប្រកាន់ពីបទព្រហ្មទណ្ឌ
3. ដោយការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្របសម្រួល។

**ដោយការសម្របសម្រួលជាមួយរដ្ឋ**

ដោយការសម្របសម្រួលជាមួយរដ្ឋ គឺសំដៅទៅលើការបង់ពិន័យអន្តរកាល ដូចជាបទល្មើសពាក់ព័ន្ធជាមួយនឹងពន្ធ ដូចជា៖ ការបង់ប្រាក់ពិន័យអន្តរការណ៍ចំពោះបទល្មើសចរាចរណ៍។

**ដោយការដកពាក្យបណ្តឹង**

ប្រសិនបើមូលហេតុនៃបណ្តឹង គឺជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ ពីបទល្មើសព្រហ្មទណ្ឌ។ ក្នុងលក្ខខណ្ឌនេះ យើងឃើញបទល្មើសមួយចំនួនជាអាទិ៍៖ បទរំលោភសេពសន្ថវៈ និង អំពើហិង្សាក្នុងគ្រួសារជាដើម។ ក្នុងបទរំលោភសេពសន្ថវៈ ប្រសិនបើជនរងគ្រោះដកពាក្យប្តឹង ដោយអះអាងថាខ្លួនបានយល់ព្រមនឹង

[៦៩] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៨

បុរសនោះនាពេលរួមភេទ ព្រះរាជអាជ្ញា នឹងមិនអាចធ្វើការចោទប្រកាន់បានទៀតទេ កំប៉ុន្តែចំពោះការរួមភេទជាមួយនឹងអនីតិជនក្រោមអាយុ ១៥ ឆ្នាំ ទោះបីជាមានការសម្តែងឆន្ទៈយល់ព្រមក៏ដោយ ក៏អំពើនោះនៅតែជាបទល្មើសព្រហ្មទណ្ឌដែលត្រូវបានជាកម្មវត្ថុ នៃការចោទប្រកាន់របស់តំណាងអយ្យការ។ ចំណែកឯ រឿងអំពើហិង្សាក្នុងគ្រួសារវិញ ប្រសិនបើប្រពន្ធ ឬ ប្តីដែលជាជនរងគ្រោះដកពាក្យបណ្តឹងចំពោះសហព័ទ្ធរបស់ខ្លួនវិញ នោះព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់បានទេ។[90] មួយវិញទៀតចំពោះករណីទ្វេពន្ធភាព ក៏ដូចគ្នាប្រសិនបើភរិយាព្រមដកពាក្យបណ្តឹងវិញរឿងនេះក៏ត្រូវបានបញ្ចប់ដែរ។

**ឧទាហរណ៍៖** ដើមបណ្តឹងរដ្ឋប្បវេណី នៃបទល្មើសទ្វេពន្ធភាពដែលបានដកពាក្យបណ្តឹងរបស់ខ្លួនដែលនាំអោយបណ្តឹងអាជ្ញាត្រូវបានរលត់។

- **ដោយការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្របសម្រួល**

ជាគោលការណ៍ បទល្មើសព្រហ្មទណ្ឌមិនអាចសម្របសម្រួលបានឡើយ។ ប៉ុន្តែច្បាប់ពិសេសអាចសម្របសម្រួលបានជាក់ស្តែងចំពោះបទល្មើសដែលប៉ះពាល់ផ្លូវចិត្ត ឬ ផ្លូវជីវភាពសេដ្ឋកិច្ច និង បទមជ្ឈិមស្រាល ឬ លហុ គូភាគីអាចផ្សះផ្សា ឬ សម្របសម្រួលគ្នាដើម្បីបញ្ចប់វិវាទបាន។[91]

**ឧទាហរណ៍៖** បទល្មើសព្រៃឈើ ការផាកពិន័យជាប្រាក់បើមិនព្រមបង់ប្រាក់ពិន័យទេ និងនាំអោយមានការចោទប្រកាន់ដោយបណ្តឹងអាជ្ញារបស់ព្រះរាជអាជ្ញា។

សរុបមក មូលហេតុនៃការរលត់នៃបណ្តឹងអាជ្ញា គឺជាមូលហេតុដែលបានកំណត់នៅក្នុងច្បាប់ជាធរមាន ហើយកាលណាបណ្តឹងអាជ្ញាត្រូវបានរលត់ដោយផ្អែកលើមូលហេតុណាមួយដូចមានរៀបរាប់ខាងលើនេះ នោះរាល់ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទៀតទេ គឺត្រូវតែបញ្ឈប់។

## ៥. ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់

### ៥.១. អាជ្ញាយុកាលនៃបទល្មើស

លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ៩ (ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់) នៃក្រមនេះចេញ ចិរវេលា នៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមានដូចតទៅគឺ[92] ៖

- ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម
- ១ (មួយ) ឆ្នាំ ចំពោះបទលហុ

[90] ច្បាប់ស្តីពីការទប់ស្កាត់គ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ មាត្រា ៣៦

[91] ច្បាប់ស្តីពីការទប់ស្កាត់ អំពើហឹង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ មាត្រា ២៦

[92] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១០

- ដោយឡែកបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងនិងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាមមិនមានអាជ្ញាយុកាលកំណត់ទេ។

**៥.២. ការផ្ដាច់រយៈពេលនៃអាជ្ញាយុកាល**

ចិរវេលានៃអាជ្ញាយុកាល ត្រូវចាប់ផ្ដើមគិតពីពេលប្រព្រឹត្តបទល្មើស។ អាជ្ញាយុកាលត្រូវផ្ដាច់ដោយគ្រប់កិច្ចនៃការចោទប្រកាន់ ឬ កិច្ចស៊ើបសួរ។ ការបញ្ចប់កិច្ចចោទប្រកាន់ ឬ កិច្ចស៊ើបសួរនីមួយៗនាំឱ្យចាប់ផ្ដើមគិតចិរវេលាថ្មីនៃអាជ្ញាយុកាល តាមការវែកញែកនៃមាត្រា ១០ (អាជ្ញាយុកាលនៃបទល្មើស) នៃក្រមនេះ។ ចិរវេលាថ្មីអាចយកទៅជំទាស់បានចំពោះជនគ្រប់រូបដែលទាក់ទិននៅក្នុងរឿងនេះ។[93]

**៦. អាជ្ញាអស់ជំនុំ**

ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេ ចំពោះអំពើដដែលទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ។[94]

## ផ្នែកទី២៖ បណ្ដឹងរដ្ឋប្បវេណី

ជនរងគ្រោះអាចដាក់ពាក្យបណ្ដឹងសាមញ្ញរបស់ខ្លួន ដែលគ្មានអនុភាពនាំឲ្យមានការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌទេ។ ហើយក្នុងករណីដែលពាក្យបណ្ដឹងស្ថិតនៅដោយគ្មានចម្លើយ ឬ ត្រូវបានតម្កល់ទុកឥតចាត់ការដោយព្រះរាជអាជ្ញាតាមរយៈការជូនដំណឹងក្នុងអំឡុងពេលយ៉ាងយូរ ០២ (ពីរ) ខែ គិតចាប់ពីថ្ងៃដែលបានចុះបញ្ជីពាក្យបណ្ដឹងជនរងគ្រោះ អាចដាក់ពាក្យបណ្ដឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលធ្វើឡើងក្នុងអំឡុងពេល ០២ (ពីរ) ខែ គិតចាប់ពីថ្ងៃដែលទទួលដំណឹងអំពីសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការ ការតវ៉ានេះត្រូវធ្វើតាមបណ្ដឹងសាមញ្ញនៅអង្គការអយ្យការដែលពាក់ព័ន្ធ។

**១. និយមន័យ នៃបណ្ដឹងរដ្ឋប្បវេណី**

បណ្ដឹងរដ្ឋប្បវេណី គឺជាបណ្ដឹងដែលមានគោលបំណងធ្វើឱ្យបានជួសជុលការខូចខាត ដែលបណ្ដាលមកពីអំពើល្មើសដល់ជនរងគ្រោះ ហើយក្នុងគោលបំណងនេះឱ្យជនរងគ្រោះបានទទួលសំណងជម្ងឺចិត្តធួនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល។[95]

**ឧទាហរណ៍៖** នារី "ក" ត្រូវបានជនល្មើស "ខ" បានធ្វើការរំលោភសេពសន្ថវៈមកលើរូបនាងរហូតដល់បានសម្រេចផល។ នារី "ក" បានដាក់ពាក្យបណ្ដឹងទៅកាន់សមត្ថកិច្ច ឬ អយ្យការដោយប្ដឹងប្រឆាំងទៅនឹងជន

---

[93] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១១

[94] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១២

[95] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២ កថាខណ្ឌទី ៣

ល្មើស "ខ" ថាបានចាប់បង្ខំរំលោភផ្លូវភេទលើរូបរាងកាយរបស់នាង និងស្នើសុំទាមទារសំណងពីអំពើល្មើសចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល។

ដូចនេះពាក្យបណ្តឹងបរិហាររបស់នារី "ក" គឺគ្រាន់តែជាបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ ពាក់ព័ន្ធនឹងផលប្រយោជន៍រដ្ឋប្បវេណីរបស់ខ្លួន (សំណងជំងឺចិត្ត) ដែលពាក់ព័ន្ធនឹងអំពើល្មើសច្បាប់របស់ជនល្មើស "ខ" តែប៉ុណ្ណោះ។ ប៉ុន្តែបណ្តឹងមួយនេះ គឺជាព័ត៌មានដែលធ្វើឲ្យសមត្ថកិច្ច ឬ ព្រះរាជអាជ្ញាធ្វើការស្រាវជ្រាវ បើលេចចេញនូវអត្ថិភាពនៃបទល្មើសនោះ សមត្ថកិច្ចត្រូវរាយការណ៍ជូនព្រះរាជអាជ្ញា ដែលជាហេតុនាំឲ្យមានបណ្តឹងអាជ្ញាដែលធ្វើឡើងដោយព្រះរាជអាជ្ញាអមសាលាដំបូង។ គេនិយាយថាបណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាម នៃផលប្រយោជន៍ទូទៅដោយអយ្យការ អយ្យការធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។

## ២. បណ្តឹងរដ្ឋប្បវេណី និងព្យសនកម្ម

នៅក្នុងនេះដែលជនរងគ្រោះ ឬ អ្នកតំណាងស្របច្បាប់នៃបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមអាចដាក់ពាក្យបណ្តឹង ដោយការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ដោយចោទប្តឹងលើបុគ្គលម្នាក់ ឬ ច្រើន ឬ ប្រឆាំងនឹងអញ្ញាតជន ហើយបណ្តឹងនេះមានអនុភាពប្តឹងអំពីបទល្មើសព្រហ្មទណ្ឌ ឬ បណ្តឹងអាជ្ញាដែលចៅក្រមស៊ើបសួរត្រូវបញ្ជូនបណ្តឹងនេះទៅព្រះរាជអាជ្ញា។

តាមបទប្បញ្ញត្តិមាត្រា ១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា បណ្តឹងរដ្ឋប្បវេណីត្រូវអនុវត្តដោយជនរងគ្រោះនៃបទល្មើស។ ដើម្បីទទួលការជួសជុលបាននូវព្យសនកម្ម ពោល គឺបណ្តឹងរដ្ឋប្បវេណីត្រូវអនុវត្តដោយជនរងគ្រោះនៃបទល្មើស និងដើម្បីទទួលការជួសជុលបានព្យសនកម្មត្រូវតែ[96] ៖

- ជាផលវិបាកផ្ទាល់ នៃបទល្មើស
- ជាព្យសនកម្មផ្ទាល់ខ្លួន
- បានកើតឡើង និងនៅក្នុងពេលបច្ចុប្បន្ន។

ព្យសនកម្មអាចជាព្យសនកម្មខាងសម្ភារៈ ខាងរូបកាយ ឬ ខាងផ្លូវចិត្ត។

### ២.១. ការជួសជុលព្យសនកម្ម

ព្យសនកម្មអាចត្រូវបានជួសជុល ដោយការបង់ជម្ងឺចិត្ត ដោយការសងទៅជនរងគ្រោះវិញនូវទ្រព្យសម្បត្តិដែលបានបាត់បង់ ឬ ដោយការធ្វើឱ្យដូចសភាពដើមវិញនូវទ្រព្យដែលគេបានបំផ្លិចបំផ្លាញ ឬ ធ្វើឱ្យខូចខាតនោះ។ សំណងជម្ងឺចិត្តត្រូវតែមានលក្ខណៈធួនល្មមជាមួយនឹងព្យសនកម្មដែលទទួលរង។[97]

[96] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១៣

[97] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១៤

ដោយមានន័យថានៅក្នុងមាត្រា ១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិថា៖ ព្យសនកម្មអាចត្រូវបានជួសជុលដោយការបង់ជម្ងឺចិត្ត ដោយការសងទៅជនរងគ្រោះវិញនូវទ្រព្យសម្បត្តិដែលបានបាត់បង់ ឬ ដោយការធ្វើឲ្យដូចសភាពដើមវិញនូវទ្រព្យដែលគេបានបំផ្លិចបំផ្លាញ ឬ ការធ្វើឲ្យខូចខាតនោះសំណងជម្ងឺចិត្តត្រូវតែមានលក្ខណៈធួនល្មមជាមួយនឹងព្យសនកម្មដែលទទួលរង។

**ឧទាហរណ៍៖** សុខ ត្រូវបានជនល្មើសឈ្មោះ សំ បានយកដំបងវាយឲ្យបែកក្បាល។ សំ បានធ្វើការព្យាបាលអស់ប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ហើយគាត់ត្រូវបានឈប់សម្រាកមួយរយៈ។ ក្នុងអំឡុងពេលដែល សុខ សម្រាកនោះធ្វើឲ្យគាត់បានខាត់បង់ពេលវេលា និងប្រាក់កាកក្នុងការរកស៊ីរបស់គាត់។ សុខ បានដាក់ពាក្យបណ្ដឹងប្ដឹងទៅឈ្មោះ សំ ហើយត្រូវបានព្រះរាជអាជ្ញាធ្វើបណ្ដឹងអាជ្ញា និងបានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទៅចៅក្រមស៊ើបសួរ បន្ទាប់មកទៀតចៅក្រមស៊ើបសួរ បានធ្វើដីកាដំណោះស្រាយបញ្ជូនឈ្មោះ សំ ទៅជំនុំជម្រះ។ នៅតំណាក់កាលជំនុំជម្រះ សុខ ដែលបានតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបានប្ដឹងសុំទាមទារសំណងជំងឺចិត្តថ្លៃខាតបង់ពេលវេលារកស៊ីចំនួន ១.០០០.០០០ (មួយលាន) រៀល ហើយនិងប្ដឹងទាមទារថ្លៃព្យាបាលចំនួន ១.០០០.០០០ (មួយលាន) រៀល។

ដូចនេះមានន័យថា សុខ បានធ្វើបណ្ដឹងរដ្ឋប្បវេណីដែលកើតចេញពីព្យសនកម្ម នៃអំពើល្មើសច្បាប់ (ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ) របស់ជនជាប់ចោទឈ្មោះ សំ។

ជនរងគ្រោះនៃអំពើល្មើសច្បាប់ អាចត្រូវបានធ្វើឡើងដោយអ្នកតំណាងស្របច្បាប់របស់ខ្លួន ដើម្បីធ្វើបណ្ដឹងរដ្ឋប្បវេណីកាលណាជនរងគ្រោះជាអនីតិជន ឬ ជនដែលស្ថិតនៅក្រោមរបបដែលច្បាប់បានការពារ (ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ និងជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភ)។[98] ក្នុងករណីដែលជនរងគ្រោះទទួលមរណភាព បណ្ដឹងរដ្ឋប្បវេណីអាចត្រូវបានផ្ដើមធ្វើដោយសិទ្ធិវន្ត។[99]

ក្រៅពីបុគ្គលដែលបានកំណត់ខាងលើនេះ បុគ្គលខាងក្រោមត្រូវបានច្បាប់អនុញ្ញាតឲ្យធ្វើសកម្មភាពបណ្ដឹងរដ្ឋប្បវេណីជំនួសជនរងគ្រោះផងនូវបុគ្គលដូចខាងក្រោមនេះ៖

- សមាគមប្រយុទ្ធប្រឆាំង នឹងអំពើហិង្សាខាងផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ ឬ អំពើហិង្សាប្រឆាំងនឹងកុមារ តែត្រូវបានគោរពនូវល័ក្ខខណ្ឌមួយ គឺគ្រប់សមាគមដែលបានប្រកាសដោយត្រឹមត្រូវ យ៉ាងតិចបំផុតតាំងពី ៣ (បី) ឆ្នាំ មុខពេលបរិច្ឆេទនៃបទល្មើស ហើយដែលកម្មវត្ថុនៃលក្ខន្តិកៈរបស់ខ្លួនរួមមានការ

[98] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១៥

[99] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១៦

តស៊ូប្រឆាំង នឹងអំពើហិង្សាខាងផ្លូវភេទ ឬ អំពើហិង្សាក្នុងគ្រួសារ ឬ អំពើហិង្សាប្រឆាំង នឹងកុមារនោះ អាចប្រើប្រាស់សិទ្ធិដែលទទួលស្គាល់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះប្រភេទបទល្មើស[100]៖

1. បៀតបៀនដោយចេតនាដល់អាយុជីវិត
2. ការបៀតបៀនដល់បូរណភាព នៃបុគ្គល
3. ការបៀតបៀនខាងផ្លូវភេទ។

- សមាគមប្រយុទ្ធប្រឆាំងនឹងការចាប់ពង្រត់ ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ សមាគមដែលមានលក្ខណៈបែបនេះត្រូវបានប្រកាសដោយត្រឹមត្រូវ យ៉ាងតិចតាំងពី ០៣ (បី) ឆ្នាំ មុនពេលបរិច្ឆេទនៃបទល្មើស ហើយកម្មវត្ថុនៃលក្ខន្តិកៈរួមមាន ការតស៊ូប្រឆាំងនឹងការចាប់ពង្រត់ ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មខាងផ្លូវភេទ អាចប្រើប្រាស់សិទ្ធិដែលបានទទួលស្គាល់ ដោយដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះបទល្មើសដែលបញ្ញត្តិដោយច្បាប់ដែលពាក់ព័ន្ធនឹងការប្រឆាំងការចាប់ពង្រត់ ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ។[101]
- សមាគមប្រយុទ្ធប្រឆាំងនឹងការប្រកាន់ពូជសាសន៍ និងការរើសអើង ត្រូវបានប្រកាសត្រឹមត្រូវយ៉ាងតិច ០៣ (បី) ឆ្នាំ មុនពេលបរិច្ឆេទនៃបទល្មើស ហើយកម្មវត្ថុនៃលក្ខន្តិកៈរួមមានការតស៊ូប្រឆាំងនឹងការប្រកាន់ពូជសាសន៍ និងការឧបត្ថម្ភដល់ជនរងគ្រោះនៃការរើសអើងស្ដីពីដើមកំណើត ជាតិពន្ធ ពូជសាសន៍ សាសនា អាចប្រើប្រាស់សិទ្ធិដែលទទួលស្គាល់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះបទល្មើសដូចបានកំណត់កាលណាបទល្មើសនេះត្រូវបានប្រព្រឹត្តដោយមូលហេតុ ដើមកំណើតជាតិ នៃបុគ្គលម្នាក់ដោយមូលហេតុថាបុគ្គលនោះជាសមាជិកប្រាកដ ឬ ដោយស្មាននៃជាតិពន្ធ ពូជសាសន៍ ឬ សាសនាណាមួយជាកំណត់នូវការរើសអើង ការបៀតបៀនដោយចេតនាដល់អាយុជីវិត ឬ ដល់បូរណភាពបុគ្គល ការបំផ្លាញ និងការធ្វើឲ្យខូចខាត។[102]

### ៣. ដើមបណ្ដឹងរដ្ឋប្បវេណី

ក្នុងរឿងក្ដីព្រហ្មទណ្ឌ ដើមបណ្ដឹងរដ្ឋប្បវេណីអាចជា៖

- ជនរងគ្រោះនៃបទល្មើស (ដោយយោងទៅតាមមាត្រា ១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)
- អ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ (ដោយយោងទៅតាមមាត្រា ១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)
- សិទ្ធិវន្តរបស់ជនរងគ្រោះ (ដោយយោងទៅតាមមាត្រា១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

[100] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១៧

[101] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១៨

[102] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១៩

- សមាគមមួយចំនួនដែលច្បាប់ទទួលស្គាល់[103]៖
  1. មានការយល់ព្រមអំពីសិទ្ធិពីជនរងគ្រោះ ឬ អ្នកតំណាងស្របច្បាប់នៃជនរងគ្រោះ (ក្នុងករណីបៀតបៀនដល់អាយុជីវិត)
  2. មានការយល់ព្រមពីសិទ្ធិវន្តនៃជនរងគ្រោះ (នៅក្នុងករណីជនរងគ្រោះទទួលមរណភាព)

**ជនរងគ្រោះនៃបទល្មើស**

បណ្តឹងរដ្ឋប្បវេណីត្រូវអនុវត្តដោយជនរងគ្រោះនៃបទល្មើស ។ ដើម្បីទទួលការជួសជុលបាន ព្យសនកម្មត្រូវតែ៖[104]

- ជាផលវិបាកផ្ទាល់នៃបទល្មើស
- ជាព្យសនកម្មផ្ទាល់ខ្លួន
- បានកើតឡើង និងនៅក្នុងពេលបច្ចុប្បន្ន។

ព្យសនកម្មអាចជាព្យសនកម្មខាងសម្ភារៈ ខាងរូបកាយ ឬ ខាងផ្លូវចិត្ត។

**អ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ**

បណ្តឹងរដ្ឋប្បវេណី អាចត្រូវធ្វើឡើងក្នុងនាមជនរងគ្រោះបាន ដោយអ្នកតំណាងស្របច្បាប់របស់ខ្លួន កាលណាជនរងគ្រោះនេះជាអនីតិជន ឬ ជានីតិជនស្ថិតនៅក្រោមរបបច្បាប់ការពារ។[105]

**សិទ្ធិវន្តរបស់ជនរងគ្រោះ**

ក្នុងករណីមរណភាពនៃជនរងគ្រោះ បណ្តឹងរដ្ឋប្បវេណីអាចត្រូវបានផ្តើមធ្វើ ឬបន្តបានដោយសិទ្ធិវន្ត។[106]

## ៤. ចុងចម្លើយ នៃបណ្តឹងរដ្ឋប្បវេណី

តាមមាត្រា ២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថាបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីព្រហ្មទណ្ឌអាចធ្វើឡើងប្រឆាំង នឹងជនទាំងឡាយដែលត្រូវជួសជុលព្យសនកម្មបណ្តាលមកពីបទល្មើសរួមមាន[107]៖

[103] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២០

[104] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១៣

[105] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១៥

[106] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១៦

[107] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២១

### ចារី សហចារី នៃបទល្មើស

**ចារី** គឺជាបុគ្គលណាដែលប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់ ហើយត្រូវចាត់ទុកថាជាចារីផងដែរ ចំពោះបុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុកចំពោះបទមជ្ឈិម។[108]

**សហចារី** កាលណាបុគ្គលច្រើននាក់បានព្រមព្រៀងគ្នាប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់ ហើយត្រូវចាត់ទុកជាសហចារីផងដែរ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក។[109]

### អ្នកផ្ដើមគំនិត អ្នកសមគំនិត

ត្រូវចាត់ទុកថាជាអ្នកផ្ដើមគំនិតក្នុងបទឧក្រិដ្ឋ ឬ បទមជ្ឈិមចំពោះបុគ្គលណាដែលជំរុញឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមតាមការណែនាំ ឬការបញ្ជា និងបានបង្កឲ្យមានបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះដោយផ្តល់អំណោយដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬក៏ដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន។[110]

ដោយឡែកអ្នកសមគំនិត ចំពោះបុគ្គលណាដែលជួយសម្រួលដោយចេតនាដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះដោយផ្តល់ជាជំនួយ ឬការឧបត្ថម្ភផ្សេងៗរបស់ខ្លួន។[111]

### អ្នកទទួលខុសត្រូវរដ្ឋប្បវេណី

អាចសុំឲ្យមានការជួសជុលព្យសនកម្មពីសិទ្ធិវ័ន្តនៃជនជាប់ចោទបានប្រសិនបើជនជាប់ចោទនេះទទួលមរណភាពនៅក្នុងពេលដំណើរការរឿងក្ដីព្រហ្មទណ្ឌ ហើយក្នុងករណីដែលជនជាប់ចោទជាអ្នកអនីតិជន ឬជនដែលត្រូវបានកម្រិតនៅសមត្ថភាព បុគ្គលដែលមានសិទ្ធិអំណាចមេបា ឬ អ្នកដែលគ្រប់គ្រងត្រូវទទួលរួមគ្នាជាមួយនឹងជនជាប់ចោទ ដើម្បីធ្វើការជុសជួលព្យសនកម្មដែលកើតចេញអំពើល្មើសនោះ។

នៅក្នុងករណីដែលជនល្មើសបានទទួលមរណភាព បណ្ដឹងរដ្ឋប្បវេណីអាចធ្វើប្រឆាំង ឬ អាចសុំឱ្យមានការជួលជុលព្យសនកម្មពីសិទ្ធិវន្ត នៃជនល្មើសទៅតុលាការព្រហ្មទណ្ឌ បានន័យថាតុលាការព្រហ្មទណ្ឌនៅតែមានសមត្ថកិច្ចដើម្បីសម្រេចលើបណ្ដឹងរដ្ឋប្បវេណី។

[108] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា ២៥

[109] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា ២៦

[110] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា ២៨

[111] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា ២៩

## ៥. ការរំលត់ នៃបណ្តឹងរដ្ឋប្បវេណី

បណ្តឹងរដ្ឋប្បវេណីក៏មានអាជ្ញាយុកាលផងដែរ បណ្តឹងរដ្ឋប្បវេណីត្រូវផុតអាជ្ញាយុកាលតាមវិធាន នៃក្រមរដ្ឋប្បវេណី។ ត្រង់នេះអាជ្ញាយុកាល នៃការរំលត់សិទ្ធិទាមទារសំណងនៃការខូចខាត គឺត្រូវផ្អែកតាមបទបញ្ញត្តិនៃអំពើអនីត្យានុកូល ដែលរយៈពេលកំណត់ដែលអាចទាមទារក្នុងអំឡុងពេល ៣ឆ្នាំ បន្ទាប់ពីពេលដែលជនរងគ្រោះបានដឹងថាអាចទាមទារសំណងការខូចខាតបាន ឬ ក្នុងអំឡុងពេល ១០ឆ្នាំ បន្ទាប់ពីអំពើអនីត្យានុកូលនោះបានប្រព្រឹត្តឡើង។[112]

ប៉ុន្តែបណ្តឹងរដ្ឋប្បវេណីនេះ មិនអាចធ្វើបានទៀតទេនៅមុខតុលាការព្រហ្មទណ្ឌ ក្រោយការផុតចិរវេលានៃអាជ្ញាយុកាល នៃបណ្តឹងអាជ្ញា។[113] មួយវិញទៀតការលះបង់ និងការដកពាក្យបណ្តឹងរបស់ជនរងគ្រោះ ក៏ជាមូលហេតុនៃការរលត់ នៃបណ្តឹងរដ្ឋប្បវេណីផងដែរ។[114]

## ផ្នែកទី៣៖ ភាពខុសគ្នារវាងបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី

យោងទៅតាមមាត្រា ២ ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ផងដែលថាបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី គឺជាបណ្តឹងពីរផ្សេងគ្នា។[115] តាមរយៈមាត្រានេះអាចអោយយើងសម្គាល់បានថាបណ្តឹងទាំងពីរនេះគឺមានចំណុចខុសគ្នា។

ភាពខុសគ្នារវាងបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី៖

- គោលបំណងនៃបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី
- ចរិតគតិយុត្ត ឬមូលដ្ឋានច្បាប់
- ទណ្ឌកម្ម
- ភាគី
- សាលាជម្រះក្តី

### គោលបំណង

**បណ្តឹងអាជ្ញា៖** ជួសជុលព្យសនកម្ម ដែលបានកើតឡើងចេញពីបទល្មើសព្រហ្មទណ្ឌ ដែលបានបង្កជាផលប៉ះពាល់ដល់សង្គមយ៉ាងធ្ងន់ធ្ងរ។

---

[112] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៧៦៥

[113] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២៦

[114] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២៥

[115] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២

**បណ្តឹងរដ្ឋប្បវេណី៖** ជួសជុលព្យសនកម្ម ដែលបានកើតឡើងចេញពីបទល្មើសព្រហ្មទណ្ឌ ដែលបានបង្កជាផលប៉ះពាល់ដល់ជនរងគ្រោះ។

- **មូលដ្ឋានច្បាប់**

**បណ្តឹងអាជ្ញា៖** ផ្អែកទៅលើក្រមព្រហ្មទណ្ឌ ដែលមានកំណត់អំពីគោលការណ៍នីត្យានុកូលភាព។

**បណ្តឹងរដ្ឋប្បវេណី៖** ផ្អែកលើអំពើអនីត្យានុកូលដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណី។

- **ទណ្ឌកម្ម**

**បណ្តឹងអាជ្ញា៖** ទោសពិន័យជាប្រាក់ និងការដាក់ពន្ធនាគារ។

**បណ្តឹងរដ្ឋប្បវេណី៖** សងជាសំណងទៅតាមព្យសនកម្ម ដែលបានកើតឡើងដោយមិនមានការដាក់ពន្ធនាគារទេ។

- **ភាគី**

**បណ្តឹអាជ្ញា៖** អយ្យការ និងជនល្មើស។

**បណ្តឹងរដ្ឋប្បវេណី៖** ជនរងគ្រោះផ្នែករដ្ឋប្បវេណី។

- **សាលាជម្រះក្តី**

**បណ្តឹងអាជ្ញា៖** ធ្វើបានតែចំពោះមុខសាលាជម្រះក្តីរឿងព្រហ្មទណ្ឌ

**បណ្តឹងរដ្ឋប្បវេណី៖** ជនរងគ្រោះ អាចធ្វើការជម្រះក្តីនៅមុខសាលាជម្រះក្តីព្រហ្មទណ្ឌក៏បាន និងរដ្ឋប្បវេណីក៏បាន។

## ផ្នែកទី៤៖ ទំនាក់ទំនងរវាងបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី

បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី គឺជាបណ្តឹងពីរផ្សេងគ្នាប៉ុន្តែមានទំនាក់ទំនងគ្នាយ៉ាងជិតស្និតនៅក្នុងរឿងក្តីព្រហ្មទណ្ឌផងដែរ។ ជាគោលការណ៍បណ្តឹងរដ្ឋប្បវេណីអាចផ្អាកបណ្តឹងព្រហ្មទណ្ឌ ហើយបណ្តឹងព្រហ្មទណ្ឌ ក៏អាចផ្អាកបណ្តឹងរដ្ឋប្បវេណីផងដែរ។[116]

ទំនាក់ទំនងនៃបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី៖

- តុលាការព្រហ្មទណ្ឌ និងតុលាការរដ្ឋប្បវេណី
- ការសម្រេចអំពីបណ្តឹងរដ្ឋប្បវេណី

[116] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៣៨៣

- **តុលាការព្រហ្មទណ្ឌ និងតុលាការរដ្ឋប្បវេណី**

ទំនាក់ទំនងសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌ និងតុលាការរដ្ឋប្បវេណី បណ្តឹងរដ្ឋប្បវេណីអាចធ្វើឡើងក្នុងពេលជាមួយគ្នា នឹងបណ្តឹងអាជ្ញានៅចំពោះមុខសាលាជម្រះក្តីព្រហ្មទណ្ឌ។ បណ្តឹងរដ្ឋប្បវេណី ក៏អាចធ្វើបានផងដែរនៅចំពោះមុខសាលាជម្រះក្តីរដ្ឋប្បវេណី ក្នុងករណីនេះបណ្តឹងរដ្ឋប្បវេណីអាចត្រូវព្យួរសិនដរាបណាមិនទាន់មានសេចក្តីសម្រេចជាស្ថាពរមួយត្រូវបានប្រកាសលើបណ្តឹងអាជ្ញា។[117]

- **ការសម្រេចអំពីបណ្តឹងរដ្ឋប្បវេណី**

ការប្រកាសជាមុនអំពីពិរុទ្ធភាព តុលាការព្រហ្មទណ្ឌនឹងអាចសម្រេចការជួសជុលព្យសនកម្មបាន លុះត្រាតែបានពិនិត្យជាមុន អំពីធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ ហើយបានប្រកាសថាជនជាប់ចោទត្រូវមានពិរុទ្ធជាមុនសិន។[118]

[117] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២២

[118] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២៣

# ជំពូកទី ៣

# ការចោទប្រកាន់របស់ព្រះរាជអាជ្ញា

# ជំពូកទី ៣
# ការចោទប្រកាន់របស់ព្រះរាជអាជ្ញា

ដោយការចោទប្រកាន់នេះបើយោងទៅតាមមាត្រា ១៣១ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិយ៉ាងច្បាស់ថា មានតែអង្គការអយ្យការតែមួយគត់ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។[119] ហេតុដូច្នេះមុននឹងឈានទៅរកការចោទប្រកាន់ទៅលើជនណាម្នាក់ទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌ លុះត្រាណា តែមានការទទួលបណ្តឹងទាមទារពីជនរងគ្រោះ ឬ អ្នកតំណាងរបស់ជនរងគ្រោះ ឬ ទទួលបានរបាយការណ៍មកពីមន្ត្រីនគរបាលយុត្តិធម៌។ បន្ទាប់ពីទទួលបានពាក្យបណ្តឹងទាមទារ បណ្តឹងបរិហារ ឬ បណ្តឹងផ្សេងទៀតតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ ជនរងគ្រោះ ជនអនាមិក ឬ តាមបណ្តាញសារព័ត៌មានក្តី ស្ថាប័នអយ្យការត្រូវតែថ្លឹងថ្លែង អំពីចំណាត់ការលើពាក្យបណ្តឹងនោះ។ ប៉ុន្តែ ព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់បានភ្លាមៗបាននោះទេ គឺព្រះរាជអាជ្ញាត្រូវធ្វើការបើកការស៊ើបអង្កេតបឋម ឬ បង្គាប់ឲ្យធ្វើការស្រាវជ្រាវបន្ថែមជាមុនសិន។[120] ម្យ៉ាងវិញទៀត ព្រះរាជអាជ្ញាមុនសម្រេចធ្វើការចោទប្រកាន់ ត្រូវពិនិត្យលើកត្តាចំបងសំខាន់ៗមួយចំនួនដូចជា៖

- កំណត់ថាតើអំពើដែលបានប្រព្រឹត្តជាបទល្មើសព្រហ្មទណ្ឌដែរ ឬទេ?
- តើអំពើដែលបានប្រព្រឹត្តនោះមានធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌគ្រប់គ្រាន់ដែរ ឬទេ?

ការចោទប្រកាន់ ត្រូវឲ្យសមស្របនឹងអំពើដែលជនសង្ស័យបានប្រព្រឹត្ត។ ក្នុងកិច្ចដំណើរការរឿងក្តីព្រហ្មទណ្ឌបន្ទាប់ពីបានកសាងសំណុំរឿងឡើងដោយបាន ធ្វើការស៊ើបអង្កេតយ៉ាងត្រឹមត្រូវរួចមក ព្រះរាជអាជ្ញាត្រូវសម្រេចថាគួរធ្វើការចោទប្រកាន់ដែរ ឬទេ។ ព្រះរាជអាជ្ញាជាម្ចាស់នៃបណ្តឹងអាជ្ញា ដែលត្រូវអនុវត្តលើរូបវន្តបុគ្គល និងនីតិបុគ្គលដោយឈរលើគោលការណ៍ឥតប្រកាន់ ពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា និន្នាការនយោបាយ ឬ ស្ថានភាពឯទៀតឡើយ។ ការចោទប្រកាន់ គឺជាចំណាត់ការនីតិវិធីដែលព្រះរាជអាជ្ញាមានអានុភាព និងសមត្ថកិច្ចពេញលេញទៅលើយុត្តាធិការស៊ើបសួរ និងជំនុំជម្រះ។ ការចោទប្រកាន់នេះដែរ គឺទាក់ទងនឹងថិរវេលានៃអាជ្ញាយុកាលនៃបទល្មើស ដែលមានរយៈពេលកំណត់ដូចជា ១៥ឆ្នាំ ចំពោះបទឧក្រិដ្ឋ ៥ ឆ្នាំ ចំពោះបទមជ្ឈិម និង១ឆ្នាំ ចំពោះបទលហុ។

បណ្តឹងអាជ្ញាមានគោលបំណង ឱ្យពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញអំពីពិរុទ្ធភាពចំពោះជនល្មើស និងផ្តន្ទាទោសជនល្មើសទៅតាមច្បាប់។ ក្នុងនាមជាបុគ្គលដែលតំណាងឱ្យផលប្រយោជន៍ទូទៅ ជាអ្នកធានារក្សាឱ្យបាននូវសណ្តាប់ធ្នាប់សាធារណៈ និងជាបុគ្គលតំណាងឱ្យស្ថាប័នអយ្យការទាំងមូល នៅក្នុងការឃ្លាំ

---

[119] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា ១៣១ថ្មី

[120] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤០

មើលការអនុវត្តច្បាប់ក្នុងសង្គមទើបតំណាងអយ្យការត្រូវបានផ្តល់ឱ្យនូវបុព្វសិទ្ធិអាចធ្វើបុរេវិនិច្ឆ័យ ដោយសន្មត់ទុកជាមុនថាជនទាំងឡាយ ដែលខ្លួនសង្ស័យថាពិតជាបានប្រព្រឹត្តបទល្មើស។ ហើយប្តឹងសុំទៅយុត្តាធិការស៊ើបសួរ ឬ យុត្តាធិការជំនុំជម្រះធ្វើការស្រាវជ្រាវ និងផ្តន្ទាទោសជននោះតាមច្បាប់។[121]

ដោយការចោទប្រកាន់ ចំពោះបទល្មើសព្រហ្មទណ្ឌ គឺជាការធ្វើបណ្តឹងអាជ្ញារបស់តំណាងអយ្យការ ហើយមុននឹងឈានទៅរកការចោទប្រកាន់បាន លុះត្រាតែពិនិត្យទៅមើលឃើញថា បទល្មើសនោះពិតជាមានធាតុផ្សំគ្រប់គ្រាន់ដូចជា៖ គោលការណ៍នីត្យានុកូល គោលការណ៍សត្យានុម័ត និងគោលការណ៍អត្តនោម័ត។

ព្រះរាជអាជ្ញា ថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្តឹង និងពាក្យបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬ ដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក ហើយព្រះរាជអាជ្ញាមានរយៈពេល ២ខែ ដើម្បីសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬ ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ដោយមុននិងសម្រេចបើកស៊ើបអង្កេតបឋមដោយខ្លួនឯង ឬ បង្គាប់ឲ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើការស្រាវជ្រាវបន្ថែមជំនួស ពោល គឺអាស្រ័យទៅតាមការយល់ឃើញរបស់ព្រះរាជអាជ្ញា។ មានន័យថា ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬ ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ដោយមុននឹងធ្វើការសម្រេចព្រះរាជអាជ្ញាបើកការស៊ើបអង្កេតជាបឋម ឬ បង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម។ ក្នុងករណីមានបទល្មើសធ្ងន់ធ្ងរ ព្រះរាជអាជ្ញារាយការណ៍ជូនអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលត្រូវរាយការណ៍បន្តជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[122] បើយោងទៅតាមមាត្រា ៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជាបានផ្តល់មធ្យោបាយដល់តំណាងអយ្យការនៅក្នុងនីតិវិធីនៃការប្តឹងសុំឱ្យមានការផ្តន្ទាទោសជនល្មើស។

តំណាងអយ្យការថ្លឹងថ្លែងអំពីជម្រើសរបស់ខ្លួនដោយពិចារណាទៅលើលក្ខខណ្ឌចាំបាច់ នៃកិច្ចនីតិវិធីដែលត្រូវធ្វើអាស្រ័យទៅតាមប្រភេទនៃបទល្មើស និងអាស្រ័យទៅតាមស្ថានភាពជាក់ស្តែង នៃបទល្មើសការចោទប្រកាន់ខាងបទព្រហ្មទណ្ឌដោយអាចធ្វើតាមមធ្យោបាយពីរ គឺការប្តឹងទៅយុត្តាធិការស៊ើបសួរ និងការប្តឹងទៅយុត្តាធិការជំនុំជម្រះ ដោយនៅក្នុងមធ្យោបាយទាំងពីរនេះផងដែរ យើងសង្កេតឃើញមានការស្តែងឡើងតាមនីតិវិធី ៣ យ៉ាងគឺ[123] ៖ ការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរ ការចោទប្រកាន់តាមរយៈការបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការចោទប្រកាន់តាមរយៈកំណត់ហេតុ នៃការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ដូច្នេះដើម្បីអោយមានភាពស៊ីជម្រៅទៅនិងនីតិវិធីទាំង៣ ខាងលើនេះយើងត្រូវសិក្សាទៅលើ៖

- ❖ **ផ្នែកទី១៖** កិច្ចចោទប្រកាន់របស់ព្រះរាជអាជ្ញា

[121] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤

[122] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤០

[123] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៣

❖ ផ្នែកទី២៖ បញ្ហាប្រឈម និងដំណោះស្រាយនៅក្នុងកិច្ចចោទប្រកាន់

## ផ្នែកទី១៖ កិច្ចចោទប្រកាន់របស់ព្រះរាជអាជ្ញា

### កថាខណ្ឌទី១៖ ការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរ (RI)

ការបើកការស៊ើបសួរសំដៅដល់ការផ្ដើមនីតិវិធីក្នុងការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ក្រោយពីទទួលការប្ដឹងរបស់ព្រះរាជអាជ្ញា ឱ្យធ្វើការស៊ើបសួរលើអង្គហេតុដែលមាននៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ។ តំណាងអយ្យការអាចប្ដឹងសុំទៅយុត្តាធិការស៊ើបសួរ ឱ្យធ្វើការស្រាវជ្រាវចំពោះអំពើដែលខ្លួនសង្ស័យថា គឺជាបទល្មើសតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

ចៅក្រមស៊ើបសួរ មិនអាចបំពេញកិច្ចស៊ើបសួរណាមួយបាន ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទេ។[124] ការបើកការស៊ើបលើអង្គហេតុរបស់ចៅក្រមស៊ើបសួរមានលក្ខណៈខុសពីការស៊ើបអង្កេតស្រាវជ្រាវរករបស់ព្រះរាជអាជ្ញា ព្រោះការស្រាវជ្រាវរបស់ព្រះរាជអាជ្ញាជាការស្រាវជ្រាវ និងស៊ើបអង្កេតរកនូវព័ត៌មាន និងភស្តុតាងទាំងឡាយណា ដែលបញ្ជាក់ពីអត្ថិភាពនៃបទល្មើសដើម្បីធ្វើការចោទប្រកាន់។ ប៉ុន្តែនៅក្នុងការបើកការស៊ើបសួររបស់ចៅក្រមស៊ើបសួរ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរវិញ ចៅក្រមស៊ើបសួរត្រូវតែបំពេញនូវកិច្ចការស្រាវជ្រាវ ដើម្បីស្វែងរកឱ្យឃើញការពិតនូវអត្ថិភាព ឬ នត្ថិភាពនៃបទល្មើសដែលព្រះរាជអាជ្ញាមានធ្វើការចោទប្រកាន់តាមរយៈសំណុំរឿង និងធ្វើការស្រាវជ្រាវលើគ្រប់ទិន្នន័យ និងព័ត៌មានក៏ដូចជាភស្តុតាងដាក់បន្ទុក និងដោះបន្ទុកដែលមាននៅក្នុងសំណុំរឿងផងដែរ។[125] បើយោងតាមមាត្រា ១២៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានចែងថាការស៊ើបសួរអាចបើកប្រឆាំងនិងបុគ្គលម្នាក់ ឬ បុគ្គលច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ប្រឆាំង និងអញ្ញាតជន ដោយអនុលោមតាមវាក្យខណ្ឌទី ២ នៃមាត្រា ៤៤ (ការបើកការស៊ើបសួរ)។

ចៅក្រមស៊ើបសួរ ដែលទទួលបណ្ដឹងអំពីអង្គហេតុ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់តំណាងអយ្យការនេះ អាចធ្វើការស៊ើបសួរតែចំពោះអង្គហេតុដែលបញ្ជូនមកឱ្យខ្លួនពិនិត្យតែប៉ុណ្ណោះ។ នៅពេលបំពេញកិច្ចស៊ើបសួរប្រសិនជាមានលេចចេញនូវអង្គហេតុថ្មីដែលអាចជាបទល្មើសព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុថ្មីនោះទៅតំណាងអយ្យការដើម្បីឱ្យតំណាងអយ្យការអាចប្ដឹងសុំឱ្យចៅក្រមស៊ើបសួរ ធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនោះតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ចៅក្រមស៊ើបសួរ

[124] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១២៤ កថាខណ្ឌទី ៣

[125] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១២៧

គ្មានអំណាចស៊ើបសួរ អំពីអង្គហេតុថ្មីណាមួយឡើយ បើសិនមិនទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីតំណាងអយ្យការនោះទេ។[126]

**ក្នុងករណីនេះមានចំណោទគតិយុត្តមួយបានចោទឡើងថា៖** ស្ថិតនៅក្នុងពេលកំពុងស៊ើបសួរហើយមានលេចចេញនូវអង្គហេតុថ្មី ដែលចៅក្រមស៊ើបសួរយល់ឃើញថាជាបទល្មើសព្រហ្មទណ្ឌ តែបែរជាតំណាងអយ្យការមិនព្រមប្ដឹងសុំចោទប្រកាន់ឱ្យស៊ើបសួរបន្ថែមទេ ដោយទោះបីជាចៅក្រមស៊ើបសួរបានជូនដំណឹងអំពីការលេចចេញនូវអង្គហេតុថ្មីរួចហើយក៏ដោយ។ ចំពោះករណីនេះ តើចៅក្រមស៊ើបសួរអាចធ្វើការស៊ើបសួរបន្ថែមទៅលើអង្គហេតុថ្មីបាន ដោយគ្រាន់តែយោងតាមបទបញ្ញត្តិនៃមាត្រា ១៣៨ និងមាត្រា ១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌស្ដីពីការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរបានដែរ ឬទេ?

**ចម្លើយ៖** គឺឆ្លើយថាបាន ដោយគ្រាន់តែមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ ដែលត្រូវធ្វើសេចក្ដីបញ្ជាក់ពីការលេចចេញនូវអង្គហេតុថ្មី ដែលជាបទល្មើសព្រហ្មទណ្ឌនោះតែប៉ុណ្ណោះ។

ដូចនោះចៅក្រមស៊ើបសួរ មិនចាំបាច់មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពីតំណាងអយ្យការឡើយ ប្រសិនបើអង្គហេតុថ្មីនោះគ្រាន់តែជាស្ថានទម្ងន់ទោស ទៅលើអង្គហេតុដែលព្រះរាជអាជ្ញាបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូងប៉ុណ្ណោះ។[127]

ការបើកការស៊ើបសួរតាមរយៈការចោទប្រកាន់របស់ព្រះរាជអាជ្ញា នេះត្រូវទាមទារឱ្យមាននូវការគោរពលក្ខខណ្ឌអនុគ្រោះមួយចំនួន ហើយត្រូវស្របទៅតាមនីតិវិធីជាក់លាក់ និងស្របតាមទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរជាដាច់ខាត និងដើម្បីបង្កើតឱ្យមានអានុភាពផ្សេងៗទៀត។

### ១. លក្ខខណ្ឌ នៃការបើកការស៊ើបសួរ

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ បានកំណត់បង្ហាញអំពីលក្ខខណ្ឌមួយចំនួនដែលនាំឲ្យរឿងក្ដីព្រហ្មទណ្ឌមួយឈានដល់ការបើកការស៊ើបសួរ ដោយស្របតាមនីតិវិធីនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា តាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌលក្ខខណ្ឌដែលនាំឲ្យមានការបើកការស៊ើបសួរ គឺសំដៅដល់លក្ខខណ្ឌប្រភេទនៃបទល្មើស ដោយត្រូវកំណត់មើលអំពីប្រភេទនៃបទល្មើសជាមុនសិន ទើបព្រះរាជអាជ្ញាអាចសម្រេចធ្វើការចោទប្រកាន់តាមរយៈនីតិវិធីនៃការបើកការស៊ើបសួរបាន។ ប្រភេទនៃបទល្មើសដែលជាលក្ខខណ្ឌដែលតម្រូវឲ្យធ្វើការបើកការស៊ើបសួរមានចំនួនពីរគឺ បទឧក្រិដ្ឋ និងបទមជ្ឈិម។[128]

---

[126] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១២៥

[127] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១២៥

[128] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១២២

### ១.១. ការបើកការស៊ើបសួរចំពោះបទឧក្រិដ្ឋ

ការវាយតម្លៃទៅលើស្ថានភាពនៃសំណុំរឿង ពោល គឺនីតិវិធីអាចធ្វើឲ្យព្រះរាជអាជ្ញាយល់ពីភាពចាំបាច់ក្នុងការស្រាវជ្រាវបន្ថែម ដើម្បីទទួលបានភស្តុតាងដែលអនុញ្ញាតឲ្យអនុវត្តបណ្តឹងអាជ្ញា ដោយភាពសមហេតុផល។ ក្នុងទស្សនៈវិស័យនេះព្រះរាជអាជ្ញាមានផ្លូវពីរគឺ បន្តការស៊ើបអង្កេត និងធ្វើបណ្តឹងទៅចៅក្រមស៊ើបសួរ ដោយនៅក្នុងការប្តឹងទៅយុត្តាធិការស៊ើបសួរ ពោល គឺត្រូវធ្វើឡើងតាមរយៈ សេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ យោងតាមបញ្ញត្តិមាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា៖ "ក្នុងករណីបទឧក្រិដ្ឋព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ"។[129]

ក្នុងករណីបទឧក្រិដ្ឋ នៅពេលដែលព្រះរាជអាជ្ញាទទួលបានពាក្យបណ្តឹងផ្ទាល់ពីជនរងគ្រោះ ឬ សំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញាត្រូវធ្វើការសាកសួរជនសង្ស័យ សាក្សី ដើមបណ្តឹង និងពិនិត្យភស្តុតាងរួចហើយត្រូវសម្រេចចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ រួមទាំងបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរដើម្បីចាត់វិធានការតាមនីតិវិធីច្បាប់បន្ត។ ប្រសិនបើ មន្ត្រីនគរបាលយុត្តិធម៌បញ្ជូនសំណុំរឿងព្រមទាំងជនសង្ស័យមកជាមួយនោះ ព្រះរាជអាជ្ញាត្រូវបញ្ជូនជនសង្ស័យ និងសំណុំរឿងនោះទៅចៅក្រមស៊ើបសួរផងដែរ។ ត្រូវបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយខានមិនបានចំពោះបទឧក្រិដ្ឋ និងចំពោះបទមជ្ឈិមវិញ ពោល គឺការស៊ើបសួរអាចធ្វើក៏បាន ឬ មិនធ្វើក៏បាន។[130] យើងឃើញថាការបើកការស៊ើបសួរមានលក្ខណៈដាច់ខាតចំពោះករណីនៃបទល្មើសមួយជាចម្បង គឺជាបទឧក្រិដ្ឋជាការចាំបាច់ណាស់ដែលការស៊ើបសួរត្រូវតែចំពោះករណីនៃបទឧក្រិដ្ឋ គឺដោយហេតុថា បទឧក្រិដ្ឋជាប្រភេទបទល្មើសដែលមានលក្ខណៈធ្ងន់ធ្ងរ និងមានអតិបរមានៃទោសដាក់ពន្ធនាគារចាប់ពី ៥ ឆ្នាំ រហូតទៅដល់ ៣០ ឆ្នាំ ឬ អស់មួយជីវិត។[131] មានន័យថា កម្រិតនៃទោសរបស់បទល្មើសប្រភេទនេះគឺមានលក្ខណៈធ្ងន់ធ្ងរ ហេតុដូច្នេះទើបតម្រូវឲ្យមានការបើកការស៊ើបសួរទាមទារឲ្យមាននូវការស្រាវជ្រាវ និងមានការពិនិត្យយ៉ាងហ្មត់ចត់ជាមុនសិនទើបអាចសម្រេចបញ្ជូនជនល្មើសទៅធ្វើការជំនុំជម្រះនៅមុខតុលាការបាន និងដើម្បីប្រាកដថាគ្មានការចោទប្រកាន់ ដោយសារការភាន់ច្រលំនោះទេ។ ដែលជាហេតុ ធ្វើឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិសេរីភាព និងសេចក្តីថ្លៃថ្នូររបស់ជនដែលត្រូវបានចោទប្រកាន់នោះទេ និង ដើម្បីធានាឲ្យបាននូវភាពយុត្តិធម៌ក្នុងដំណើរការកាត់ក្តីរបស់តុលាការផងដែរ។

[129] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៤

[130] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១២២

[131] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា ៤៦

ការបើកការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ត្រូវធ្វើឡើងដោយស្រាវជ្រាវយ៉ាងល្អិតល្អន់ចំពោះសំណុំរឿងនោះ។ ពោល គឺត្រូវតែស្រាវជ្រាវទាំងភស្តុតាងដាក់បន្ទុក និងដោះបន្ទុកដើម្បីស្វែងរក និងលាតត្រដាងនូវការពិតឲ្យកាន់តែច្បាស់មួយកម្រិតបន្ថែមទៀតក្រៅពីការជំនុំជម្រះរបស់យុត្តាធិការជំនុំជម្រះ។

ដូចបានបញ្ជាក់ខាងដើមការបើកការស៊ើបសួរមានលក្ខណៈមិនដាច់ខាតនោះទេ ចំពោះបទល្មើសដែលនឹងអាចចោទប្រកាន់ថាជាបទល្មើសមជ្ឈិម ឬ បទលហុ។ ក្នុងករណីចុងក្រោយនេះ ស្ថាប័នអយ្យការធ្វើការបើកការស៊ើបសួរ អាស្រ័យទៅលើស្ថានភាពនៃសំណុំរឿងនីតិវិធីជាអាទិ៍ នៅពេលដែលបុគ្គលដែលជាប់ពាក់ព័ន្ធមិនបានកំណត់ពីអត្តសញ្ញាណ និងមិនអាចកំណត់បានក្នុងពេលបច្ចុប្បន្ន។ មួយវិញទៀតព្រះរាជអាជ្ញា ក៏សម្រេចបើកការស៊ើបសួរផងដែរ កាលបើយល់ឃើញថាភស្តុតាងដែលប្រមូលបានពុំទាន់គ្រប់គ្រាន់ ដើម្បីប្តឹងទៅយុត្តាធិការជំនុំជម្រះបាន ហើយភស្តុតាងដែលខ្វះខាតនោះមិនអាចប្រមូលបាន ដោយការស៊ើបអង្កេតបឋម ប៉ុន្តែអាចប្រមូលមកបានលុះត្រាតែប្រើអំណាចដោយបង្ខំ ឬ បទល្មើសមជ្ឈិម និងបទឧក្រិដ្ឋទាំងឡាយដែលមានលក្ខណៈស្មុគស្មាញ សាំញ៉ាំ ដែលតម្រូវឲ្យត្រូវតែមានការពិគ្រោះ និងការស្រាវជ្រាវយូរ និងប្រកបដោយភាពពិបាក។ ដូច្នេះ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ ហើយការស៊ើបសួរត្រូវតែបើកតាមដីការបញ្ជូនរឿងរបស់ព្រះរាជអាជ្ញាដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ។ ដោយការស៊ើបសួរអាចបើកប្រឆាំងនិងបុគ្គលម្នាក់ ឬ ច្រើននាក់ដោយចង្អុលប្រាប់ឈ្មោះ ឬ ប្រឆាំងទៅនិងអញ្ញាតជន (ជនដែលមិនស្គាល់អត្តសញ្ញាណ)។[132]

**គួរកត់សម្គាល់ថា៖** ព្រះរាជអាជ្ញាអាចការបើកការស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទៅកាន់ចៅក្រមស៊ើបសួរ ក្នុងករណីបទឧក្រិដ្ឋព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរជាដាច់ខាត។ ចំពោះបទមជ្ឈិមព្រះរាជអាជ្ញា ក៏អាចធ្វើការចោទប្រកាន់បានតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបានផងដែរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ អាចធ្វើឡើងប្រឆាំងនឹងបុគ្គលដែលស្គាល់ឈ្មោះ និងបុគ្គលមិនស្គាល់ឈ្មោះ (អញ្ញាតជន)។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ គឺជាលិខិតដែលបើកឲ្យមានបណ្តឹងអាជ្ញា ដែលព្រះរាជអាជ្ញាប្តឹងទៅចៅក្រមស៊ើបសួរ ដោយសុំឲ្យស៊ើបសួរលើរឿងរ៉ាវមួយជាកំណត់ ដែលអាចត្រូវផ្តន្ទាទោសព្រហ្មទណ្ឌ។ ហេតុនេះហើយទើបដីកាសន្និដ្ឋាននេះ ទាមទារឲ្យគោរពយ៉ាងដាច់ខាតនូវលក្ខខណ្ឌមួយចំនួនជាអាទិ៍ដោយត្រូវមានបញ្ជាក់នូវ៖ សេចក្តីសង្ខេបអង្គហេតុ ឈ្មោះបទល្មើសចង្អុលបង្ហាញនូវបទបញ្ញត្តិដែលត្រូវពិគ្រោះ និងផ្តន្ទាទោស និងជាយថាហេតុឈ្មោះរបស់បុគ្គលដែលរងការស៊ើបសួរ ព្រមជាមួយគ្នានោះដីកានេះត្រូវចុះកាលបរិច្ឆេទ និងហត្ថលេខា។ ការចុះកាលបរិច្ឆេទមានគុណប្រយោជន៍ ដើម្បីធ្វើការផ្ទៀងផ្ទាត់ថាបណ្តឹងអាជ្ញាមិនទាន់ផុតរលត់អាជ្ញាយុកាលហើយចៅក្រមស៊ើបសួរមិនបានធ្វើការស៊ើបសួរមុនពេលទទួលបណ្តឹង រីឯការចុះ

[132] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៤

ហត្ថលេខារបស់ចៅក្រមដែលបានចេញសេចក្តីសម្រេចបើកការស៊ើបសួរនេះ ដើម្បីបញ្ជាក់ពីឆន្ទៈរបស់អង្គការអយ្យការក្នុងការចោទប្រកាន់។ បើពុំគោរពតាមលក្ខខណ្ឌខាងលើនោះទេ ជាហេតុនាំឲ្យមានមោឃកម្ម នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ។

### ១.២. ការបើកការស៊ើបសួរចំពោះបទមជ្ឈិម

បទមជ្ឈិម ជាប្រភេទបទល្មើសដែលមានចំនួនអតិប្បរមានៃទោសដាក់ពន្ធនាគារចាប់ពី ០៦ ថ្ងៃ ដល់ ០៥ ឆ្នាំ និងអាចបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។[133] យោងតាមមាត្រា ៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ បានកំណត់ថា៖ "ព្រះរាជអាជ្ញាអាចប្រើនីតិវិធីបញ្ជូនទៅជម្រះផ្ទាល់ ឬ នីតិវិធីបង្គាប់ឲ្យបង្ហាញខ្លួនភ្លាមចំពោះប្រភេទនៃបទល្មើសបទមជ្ឈិមនេះ ហើយព្រះរាជអាជ្ញាក៏អាចធ្វើការចោទប្រកាន់ដោយប្រើនីតិវិធីក្នុងការបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបានផងដែរ"។[134]

ព្រះរាជអាជ្ញា ក៏អាចប្រើនីតិវិធីនៃបើកការស៊ើបសួរក៏បាន និងមិនបើកការស៊ើបសួរក៏បាន ពីព្រោះយើងដឹងហើយថាបទល្មើសមជ្ឈិមខ្លះវាមិនមានលក្ខណៈស្មុគស្មាញនោះទេ មានន័យថា ចំពោះបទល្មើសមជ្ឈិមគឺគេបានផ្តល់ឆន្ទានុសិទ្ធិដល់ព្រះរាជអាជ្ញាក្នុងការសម្រេចអំពីចំណាត់ការនៃការចោទប្រកាន់របស់ខ្លួន ថាត្រូវប្រើតាមនីតិវិធីមួយណាក្នុងចំណោមនីតិវិធីទាំង ៣ ដោយព្រះរាជអាជ្ញាអាចធ្វើការថ្លឹងថ្លែងអំពីស្ថានភាពនៃបទល្មើសប្រសិនបើជនដែលត្រូវចោទបានប្រព្រឹត្តនូវបទមជ្ឈិម ប៉ុន្តែ សកម្មភាពមួយចំនួនបទមជ្ឈិមត្រូវតែបើកការស៊ើបសួរដូចជា ពេលបទល្មើសមាននូវភស្តុតាងមិនគ្រប់គ្រាន់ ឬ ជនល្មើសជាអញ្ញាតជនដែលពុំមានអត្តសញ្ញាណច្បាស់លាស់ និងករណីដែលជនល្មើសចូលរួមប្រព្រឹត្តច្រើន ដោយបានសេចក្តីថាសំណុំរឿងមិនទាន់មានព័ត៌មានគ្រប់គ្រាន់ ឬ ឯកសារមិនគ្រប់គ្រាន់ដើម្បីធ្វើការជំនុំជម្រះបាន។ ដូច្នេះហើយ ព្រះរាជអាជ្ញានិងត្រូវធ្វើការចោទប្រកាន់ទៅតាមនីតិវិធីនៃការស៊ើបសួរ។ ដែលជាហេតុមិនអាចបង្គាប់ឲ្យជនសង្ស័យចូលបង្ហាញខ្លួនភ្លាមបាន និងការដែលសំណុំរឿងមិនទាន់មូលធ្វើឲ្យមិនអាចបញ្ជូនរឿងនោះទៅជំនុំជម្រះដោយផ្ទាល់បានដែរ។

ពោល គឺនៅពេលមានបទល្មើសកើតឡើងតុលាការអាចប្រមូលភស្តុតាង ដែលអាចបញ្ជាក់ពីអត្ថិភាពនៃបទល្មើសភ្លាមៗ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ត្រូវតែធ្វើការស៊ើបសួរផងដែរ កាលណាបទមជ្ឈិមនោះមិនបានបង្ហាញភស្តុតាងពីពិរុទ្ធភាពឱ្យបានគ្រប់គ្រាន់ ដែលត្រូវធ្វើការស៊ើបសួរ ដើម្បីរកឱ្យឃើញពីអត្ថិភាពនៃបទល្មើសនោះ។

---

[133] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា ៤៧

[134] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៥

**២. នីតិវិធី នៃការបើកការស៊ើបសួរ**

យោងតាមមាត្រា ៨០ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានចែងអំពីចំណាត់ការលើពាក្យប្ដឹង និងពាក្យបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬ ដែលមន្ត្រីនគរបាលយុត្តិធម៌បានបញ្ជូនមក។[135] ក្នុងមាត្រានេះបានកំណត់បង្ហាញថានៅក្នុងរឿងក្ដីព្រហ្មទណ្ឌ មុននិងព្រះរាជអាជ្ញាធ្វើការសម្រេចចិត្តក្នុងការចោទប្រកាន់ដោយនីតិវិធីបើកការស៊ើបសួរ ឬ នីតិវិធីផ្សេងៗទៀតព្រះរាជអាជ្ញាត្រូវធ្វើការវាយតម្លៃទៅលើសំណុំរឿងដែលមានប្រភពមកពីពាក្យបណ្ដឹង ដែលព្រះរាជអាជ្ញាបានទទួលដោយផ្ទាល់តាមរយៈដើមបណ្ដឹង ឬ តាមរយៈការបញ្ជូនសំណុំរឿងមកពីមន្ត្រីនគរបាលយុត្តិធម៌។

**២.១. នីតិវិធី នៃការបើកការស៊ើបសួរតាមរយៈពាក្យបណ្ដឹងដោយផ្ទាល់**

ដើមបណ្ដឹងអាចដាក់ពាក្យបណ្ដឹងមកកាន់ព្រះរាជអាជ្ញាដោយផ្ទាល់បាន ដើម្បី សុំឲ្យព្រះរាជអាជ្ញាធ្វើចំណាត់ការទៅលើពាក្យបណ្ដឹងនោះ។ នៅក្រោយពេលដែលព្រះរាជអាជ្ញា បានទទួលពាក្យបណ្ដឹងពីសំណាក់ដើមបណ្ដឹង ព្រះរាជអាជ្ញាត្រូវធ្វើការថ្លឹងថ្លែងសម្រេចធ្វើចំណាត់ការក្នុងការចោទប្រកាន់តាមរយៈនីតិវិធីណាមួយប្រសិនបើអង្គហេតុនៅក្នុងពាក្យសំណុំរឿងនោះពិនិត្យទៅឃើញថាជាបទល្មើស។ នីតិវិធីក្នុងការថ្លឹងថ្លែង និងស្រាវជ្រាវត្រូវធ្វើឡើងតាមរយៈការសុំឲ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើការបើកការស៊ើបអង្កេតបឋម ឬ កោះហៅដើមបណ្ដឹង ឬ សាក្សីមកសួរ និងស្ដាប់ចម្លើយដោយផ្ទាល់។ បន្ទាប់ពីការស៊ើបអង្កេត និងស្រាវជ្រាវបានបញ្ចប់ហើយបានរកឃើញថាអង្គហេតុនោះជាបទល្មើស ហើយបានបំពេញនៅលក្ខខណ្ឌ ដែលនាំឲ្យមានបើកការស៊ើបសួរបានព្រះរាជអាជ្ញា និងសម្រេចចេញដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ទៅសំណាក់ចៅក្រមស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

**២.២.ការបើកការស៊ើបសួរតាមរយៈសំណុំរឿងបញ្ជូនដោយមន្ត្រីនគរបាលយុត្តិធម៌**

នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ទទួលបានពាក្យបណ្ដឹងបរិហារ និងពាក្យបណ្ដឹងទាមទារក្នុងដែនសមត្ថកិច្ចរបស់ខ្លួនហើយ មន្ត្រីនគរបាលយុត្តិធម៌អាចបើកការស៊ើបអង្កេតបឋម លើពាក្យបណ្ដឹងដែលខ្លួនទទួលបាន ឬ នៅពេលដឹងអំពីបទល្មើសនោះថាជាបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុណាមួយ រួចកសាងសំណុំរឿងបញ្ជូនទៅតំណាងអយ្យការ។ ចំពោះករណីបទល្មើសជាក់ស្ដែងដែលកើតមានឡើង មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើចាប់ខ្លួន និងឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅចំពោះមុខព្រះរាជអាជ្ញា។ ដូចនេះ នីតិវិធីក្នុងការធ្វើចំណាត់ការលើសំណុំរឿងដែលបញ្ជូនមកតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើឡើងតាមករណីដូចខាងក្រោម៖

[135] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៨០

➢ **ករណីសំណុំរឿងគ្មានវត្តមានជនសង្ស័យ (ជនសង្ស័យនៅក្រៅឃុំ)**

នៅក្នុងករណីដែលសំណុំរឿងគ្មានជនសង្ស័យ ដែលជនសង្ស័យមិនត្រូវបានបញ្ជូនមក ដោយមន្ត្រីនគរបាលយុត្តិធម៌ទេ នោះបានន័យថាជនសង្ស័យនោះមិនទាន់ត្រូវបានឃាត់ខ្លួននៅឡើយទេ។ ហើយក៏ពុំទាន់អាចបញ្ជូនសំណុំរឿងនោះទៅកាន់ព្រះរាជអាជ្ញាបានដែរ។ នៅពេលដែលព្រះរាជអាជ្ញាទទួលបានសំណុំរឿងព្រះរាជអាជ្ញា និងធ្វើការថ្លឹងថ្លែងអង្គហេតុ ដោយពិនិត្យមើលភស្តុតាងដែលមានក្នុងសំណុំរឿង របាយការណ៍សំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌ និងកោះហៅដើមបណ្តឹង ជនសង្ស័យ សាក្សី ដើម្បីសួរ និងស្តាប់ចម្លើយ។ បន្ទាប់មកនៅពេលដែលពិនិត្យទៅឃើញថាអង្គហេតុខាងលើគឺជាបទល្មើស និងបានបំពេញលក្ខខណ្ឌដែលនាំឲ្យមានការបើកការស៊ើបសួរ ព្រះរាជអាជ្ញាត្រូវធ្វើចំណាត់ការចោទប្រកាន់ដោយនីតិវិធីបើកការស៊ើបសួរ និងចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ដោយកំណត់ឈ្មោះជនត្រូវចោទម្នាក់ ឬ ច្រើននាក់ ឬ អញ្ញាតជនឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

➢ **ករណីសំណុំរឿងមានវត្តមានជនសង្ស័យ (ជនសង្ស័យជាប់ឃុំខ្លួន)**

ក្នុងករណីដែលសំណុំរឿងដែលជនសង្ស័យត្រូវបានចាប់ខ្លួន ឬ ឃាត់ខ្លួន និងបញ្ជូនខ្លួនមកដោយមន្ត្រីនគរបាលយុត្តិធម៌ ហើយត្រូវបាននាំមកបង្ហាញខ្លួននៅចំពោះមុខព្រះរាជអាជ្ញា បន្ទាប់ពីផុតពីរយៈពេលនៃការឃាត់ខ្លួនបណ្តោះអាសន្នរបស់មន្ត្រីនគរបាលយុត្តិធម៌។ វត្ថុតាង (បើមាន) និងជនសង្ស័យនៅក្នុងសំណុំរឿងដែលបានបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវបានបញ្ជូនមកដល់ព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញានិងធ្វើការសួរចម្លើយ នឹងពិនិត្យទៅលើសំណុំរឿងនោះ។ បន្ទាប់មកនៅពេលដែលពិនិត្យទៅឃើញថាអង្គហេតុខាងលើគឺជាបទល្មើស និងបានបំពេញលក្ខខណ្ឌដែលនាំឲ្យមានការបើកការស៊ើបសួរ ព្រះរាជអាជ្ញាត្រូវធ្វើចំណាត់ការចោទប្រកាន់ដោយនីតិវិធីបើកការស៊ើបសួរ និងចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ហើយព្រះរាជអាជ្ញាក៏អាចសន្និដ្ឋានសុំឲ្យចៅក្រមស៊ើបសួរសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬ សន្និដ្ឋានសុំឲ្យដាក់ជនត្រូវចោទស្ថិតក្រោមការឃុំខ្លួនជាបណ្តោះអាសន្នផងដែរ។

### ៣. ទម្រង់ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ

នៅក្នុងនីតិវិធីនៃការបើកការស៊ើបសួរ ជាចាំបាច់ ត្រូវមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទៅកាន់ចៅក្រមស៊ើបសួរ ដើម្បីបំពេញមុខងាររបស់ខ្លួននៅក្នុងការស៊ើបសួរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរត្រូវធ្វើឡើងតាមទម្រង់ដែលជាក់លាក់មួយ ដើម្បីធានាឲ្យបានពីអានុភាពស្របតាមបទបញ្ញត្តិនៃក្រមនីតិវិធី។ ទម្រង់របស់ដីកាសន្និដ្ឋានបញ្ជូនឲ្យស៊ើបរួមមានដូចតទៅ[136]៖ សេចក្តីសង្ខេបអង្គហេតុ, ការកំណត់ឈ្មោះបទល្មើស,

[136] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៤

ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ឲ្យបានច្បាស់លាស់និងបង្ក្រាបបទល្មើស និង ឈ្មោះបុគ្គលដែលត្រូវបានធ្វើការស៊ើបសួរក្នុងករណីដែលបានធ្វើការកំណត់រួច។

- **សេចក្តីសង្ខេបអង្គហេតុ**

ចំណុចនេះមានសារៈសំខាន់ណាស់ ពីព្រោះបើគ្មានអង្គហេតុណាមួយទេនោះ ចៅក្រមស៊ើបសួរនឹងមិនដឹងថាកិច្ចស៊ើបសួរនឹងត្រូវស្វែងទៅលើអង្គហេតុណាមួយទេ ព្រោះកិច្ចស៊ើបសួរអាចបើកបានតែទៅលើអង្គហេតុណាដែលព្រះរាជអាជ្ញាចោទប្រកាន់មកតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត បើគ្មានអង្គហេតុក៏គ្មានកិច្ចចោទប្រកាន់ណាមួយកើតមានដែរ។

- **ការកំណត់ឈ្មោះបទល្មើស**

ការកំណត់ឈ្មោះបទល្មើស វាមានសារៈប្រយោជន៍សម្រាប់ជំហានដំបូងនៃកិច្ចស៊ើបសួរ ព្រោះចៅក្រមស៊ើបសួរនឹងមិនអាច ឬ មិនទាន់អាចកំណត់ថាអង្គហេតុជាបទល្មើសអ្វី លុះបិទកិច្ចស៊ើបសួរសិនទើបមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការសម្រេចថាអង្គហេតុនេះជាបទល្មើសអ្វីនោះ។ ដូចនេះពិតជាមានភាពលំបាកប្រសិនបើមិនមានការកំណត់ឈ្មោះបទល្មើសណាមួយសម្រាប់បើកកិច្ចស៊ើបសួរ ទោះជាមានការកំណត់ពីឯករាជ្យភាពរបស់ចៅក្រមស៊ើបសួរលើការកំណត់បទល្មើសណាមួយជាមុនក៏ដោយ ដែលនេះ គ្រាន់តែគិតទៅលើស្មារតីនៃផលប្រយោជន៍តែប៉ុណ្ណោះ។ ប៉ុន្តែ កត្តាចម្បងនោះបើព្រះរាជអាជ្ញាសម្រេចចោទប្រកាន់ខាងបទព្រហ្មទណ្ឌ តែមិនឃើញមានសរសេរថាចោទពីបទណាមួយនោះទេ ដូច្នេះ ត្រូវចាត់ទុកថាគ្មានការចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយឡើយ។

- **ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស**

ការកំណត់នេះ គឺជាកត្តាមូលហេតុដែលព្រះរាជអាជ្ញាអះអាងពីឈ្មោះបទល្មើស តែបើមិនសរសេរចូលក្នុងដីកា មានន័យថាគ្មានមូលដ្ឋាននៃការអះអាងលើការចោទប្រកាន់ទេនេះ ពោល គឺគ្រាន់ជាការកំណត់ពីភាពច្បាស់លាស់នៅកិច្ចចោទប្រកាន់របស់ព្រះរាជអាជ្ញាប៉ុណ្ណោះ។

- **ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរប្រសិនបើអាចកំណត់បាន**

ចំណុចនេះបើបុគ្គលជាជនល្មើសត្រូវបានស្គាល់អត្តសញ្ញាណ គឺត្រូវតែមានកំណត់ឈ្មោះរបស់ជនល្មើស នោះក៏ប៉ុន្តែទោះជាមិនមានក៏មិនអីដែរ ព្រោះកិច្ចស៊ើបសួរអាចបើកប្រឆាំងគ្រប់បុគ្គល ដែលមានតម្រុយពិរុទ្ធភាពពាក់ព័ន្ធជាមួយអង្គហេតុ ទោះជាមិនមានកំណត់ឈ្មោះរបស់ជនល្មើសក៏ដោយ។

ដីកានេះចាំបាច់ត្រូវតែមានការចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា។ នេះជាទម្រង់រដ្ឋបាលដែលត្រូវតែមាន តែបើគ្មានហត្ថលេខា មានន័យថាមិនមានការទទួលស្គាល់ណាមួយរបស់ព្រះរាជអាជ្ញានោះទេ ដែលជាហេតុធ្វើឱ្យដីកានេះមិនមានអានុភាព ឬ ដីកាមិនទាន់មានការសម្រេចរបស់ព្រះរាជអាជ្ញានៅ

ឡើយ។ ដូច្នេះគ្មានកិច្ចចោទប្រកាន់ណាមួយកើតមានទេ ដោយយោងតាមសារៈសំខាន់ នៃទម្រង់ការដែលមិនអាចខ្វះបានទោះជាស្មារតីនៃផលប្រយោជន៍ ឬ ជាស្មារតីនៃច្បាប់ក៏ដោយទម្រង់នេះត្រូវបានកំណត់ជាលក្ខណៈដាច់ខាតដែលត្រូវតែគោរព បើមិនដូច្នេះទេ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវទុកជាមោឃៈ។[137] ហើយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះគ្មានអានុភាពអ្វីដល់បុគ្គលដែលមានឈ្មោះនៅក្នុងដីកានោះឡើយ។

ដោយមូលហេតុថា ការស៊ើបសួរទទួលបានពាក្យសុំមោឃភាពពី ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរជនត្រូវចោទ ឬ ដើមបណ្ដឹងរដ្ឋប្បវេណី។[138]

### ៤. ការចូលរួមរបស់អង្គការអយ្យការនៅក្នុងការស៊ើបសួរ

បើទោះបីជា ការបើកការស៊ើបសួរព្រះរាជអាជ្ញា ត្រូវប្រគល់រឿងទាំងអស់ទៅចៅក្រមស៊ើបសួរហើយក្តីក៏មិនមែនមានន័យថា ព្រះរាជអាជ្ញាអស់សិទ្ធិទៅលើសំណុំរឿងក្តីនោះដែរ។ ប៉ុន្តែការចូលរួមរបស់ព្រះរាជអាជ្ញាមិនមានលក្ខណៈទូលំទូលាយដូចទៅនឹងចៅក្រមស៊ើបសួរទេ។ ព្រោះថា ព្រះរាជអាជ្ញាពុំមានសិទ្ធិស្រាវជ្រាវដូចចៅក្រមស៊ើបសួរទេ គឺព្រះរាជអាជ្ញាគ្រាន់តែជាអ្នកចូលរួមសកម្មភាពស៊ើបសួររបស់ចៅក្រមស៊ើបសួរ។

- **ការស្នើសុំបំពេញកិច្ចការដោយព្រះរាជអាជ្ញា**

ព្រះរាជអាជ្ញា អាចពិនិត្យមើលសំណុំរឿងស៊ើបសួរ ឬ ស្នើសុំឲ្យបញ្ជូនសំណុំរឿងឲ្យមកពិនិត្យបាននៅគ្រប់ពេលវេលា។ នៅពេលដែលចៅក្រមស៊ើបសួរបញ្ជូនទៅព្រះរាជអាជ្ញានោះ ចៅក្រមត្រូវចេញដីកាបញ្ជូនសំណុំរឿងនោះ។[139] ដែលដីកានេះមានឈ្មោះថា "ដីកាបញ្ជូនរឿងឲ្យពិនិត្យ" ក្រោយពេលដែលព្រះរាជអាជ្ញាបានពិនិត្យទៅលើសំណុំរឿង ហើយយល់ឃើញថាមានប្រយោជន៍ណាមួយដល់នីតិវិធីស៊ើបសួរនោះ ព្រះរាជអាជ្ញាអាចស្នើសុំឱ្យចៅក្រមស៊ើបសួរបំពេញកិច្ចការណាមួយដោយឆន្ទានុសិទ្ធិរបស់ខ្លួន។

ការស្នើសុំឲ្យបំពេញកិច្ចការដោយព្រះរាជអាជ្ញានេះ អាចជាការឲ្យពិនិត្យភស្តុតាង ការសាកសួរសាក្សីនិងការសុមឲ្យឃុំខ្លួន ការធ្វើកោសលវិច័យ ឬ ការធ្វើប្រតិកោសលវិច័យ។ យ៉ាងណាមិញ បន្ទាប់ពីព្រះរាជអាជ្ញាបានពិនិត្យលើសំណុំរឿងដែលបានបញ្ជូនមកខ្លួនរួចហើយ ព្រះរាជអាជ្ញាមានកាតព្វកិច្ចបង្វិលសំណុំរឿងនោះទៅឲ្យចៅក្រមស៊ើបសួរវិញក្នុងចិរវេលា ២៤ ម៉ោង។[140] ចិរវេលា ២៤ ម៉ោងនេះ គិតតែម៉ោងធ្វើការតែប៉ុណ្ណោះហើយបើសិនជាចិរវេលាដែលបានកំណត់នេះផុតកំណត់ចំ ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ឬ ថ្ងៃបុណ្យ ត្រូវអូសបន្លាយរហូតដល់

[137] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៤

[138] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២៥៣

[139] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២៤៤

[140] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១៣៥

ថ្ងៃទី១ ដែលជាថ្ងៃបើកធ្វើការវិញ។[141] ការកំណត់ចិរវេលាជាក់លាក់សម្រាប់ព្រះរាជអាជ្ញាបែបនេះដើម្បីជាការរាំងស្ទះដល់នីតិវិធីនៃការស៊ើបសួរ។

ចៅក្រមស៊ើបសួរនៅពេលដែលទទួលបានពាក្យស្នើសុំនេះហើយ គាត់មានសិទ្ធិដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ៖

- គឺគាត់ធ្វើការតាមការស្នើសុំរបស់ព្រះរាជអាជ្ញា ហើយត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាវិញក្នុងរយៈពេល ១៥ ថ្ងៃ គិតចាប់ពីថ្ងៃស្នើសុំ។
- ចៅក្រមស៊ើបសួរ បើមិនព្រមតាមការស្នើសុំនោះទេ គាត់ក៏ត្រូវចេញដីកាបដិសេធក្នុងរយៈពេល ១៥ ថ្ងៃផងដែរ។ នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរត្រូវបញ្ជាក់ក្នុងសំអាងហេតុ និងមូលហេតុអោយបានច្បាស់លាស់ហើយត្រូវជូនដំណឹងពីដីកានេះទៅព្រះរាជអាជ្ញាឲ្យបានឆាប់រហ័សបំផុត។ ដើម្បីអាចឲ្យព្រះរាជអាជ្ញាធ្វើការប្តឹងទៅឧទ្ធរណ៍ទៅនឹងដីកាសម្រេចនោះ។ ជាចុងក្រោយ ចៅក្រមស៊ើបសួរមានសិទ្ធិមិនឆ្លើយតបអ្វីទាំងអស់ទៅនឹងការស្នើសុំរបស់ព្រះរាជអាជ្ញា នៅក្នុងករណីនេះព្រះរាជអាជ្ញាមានសិទ្ធិប្តឹងទៅសភាស៊ើបសួរ ដើម្បីសម្រេចជំនួសចៅក្រមស៊ើបសួរបើកាលណាក្នុងរយៈពេល ១៥ ថ្ងៃ ហើយដែលគិតចាប់ពីថ្ងៃស្នើសុំ ពោល គឺចៅក្រមស៊ើបសួរមិនបានឆ្លើយតបមកវិញ។

### ៤.១. ការសួរ និងស្តាប់ចម្លើយ

ព្រះរាជអាជ្ញា អាចមានវត្តមាននៅក្នុងពេលសួរចម្លើយជនត្រូវចោទ ឬ នៅពេលស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី សាក្សី ឬ នៅក្នុងពេលសួរផ្ទាល់ជាមួយចៅក្រមស៊ើបសួរបាន ដោយនៅក្នុងដំណាក់កាលនេះព្រះរាជអាជ្ញាមានសិទ្ធិសួរផងដែរ។ ដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ បើចៅក្រមស៊ើបសួរមិនអនុញ្ញាត ចំពោះការបើកសំណួររបស់ព្រះរាជអាជ្ញានោះទេ ក្រឡាបញ្ជីត្រូវចុះនិទ្ទេសស្តីពីការមិនអនុញ្ញាតនេះនៅក្នុងកំណត់ហេតុ។

- **ការវាយតម្លៃអំពីស្ថានភាពនៃសំណុំរឿង**

បន្ទាប់ពីទទួលបានបណ្តឹងអាជ្ញាតាមរយៈការប្តឹងបរិហារ ឬ កំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌មុននឹងសម្រេចធ្វើការចោទប្រកាន់នោះព្រះរាជអាជ្ញា ត្រូវតែធ្វើការវាយតម្លៃទៅលើស្ថានភាព នៃអង្គហេតុដែលមាននៅក្នុងសំណុំរឿងព្រមទាំងភស្តុតាង ធាតុផ្សំនៃបទល្មើសដែលប្រមូលបានជាមុនសិន។

ការវាយតម្លៃនៃសំណុំរឿងនេះ គឺជានីតិវិធីមួយដែលតម្រូវឲ្យតំណាងអយ្យការធ្វើការថ្លឹងថ្លែង ថាតើស្ថានភាពនៃបទល្មើស គោរពតាមលក្ខខណ្ឌនៃការបញ្ជូនរឿងឲ្យស៊ើបសួរហើយឬនៅ? នៅក្នុងករណីដែលលក្ខខណ្ឌ

[141] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២៣១

ត្រូវបានបំពេញហើយនោះព្រះរាជអាជ្ញា និងសម្រេចចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទៅចៅក្រមស៊ើបសួរ។

- **ការរៀបចំតាក់តែងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ**

ដើម្បីរៀបចំតាក់តែងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរឲ្យបានល្អ ត្រូវតែការរៀបចំឈ្មោះជនល្មើស ឬ ជនសង្ស័យ និងរៀបចំអង្គហេតុ។ ការរៀបចំឈ្មោះជនល្មើស ឬ ជនសង្ស័យសំដៅទៅដល់ការរៀបរាប់ឈ្មោះជនល្មើស ឬ ជនសង្ស័យទៅតាមលំដាប់លំដោយនៃប្រព្រឹត្តបទល្មើស និងការរៀបរាប់អំពីសាវតាជាតិរបស់ជននោះ (បើមាន) តែក្នុងករណីដែលមិនស្គាល់ជនល្មើសអាចដាក់ថាអញ្ញាតជនបាន។ ចំណែកឯការរៀបចំអង្គហេតុវិញ យើងត្រូវពិនិត្យទៅលើឯកសារមួយចំនួនដូចជា៖

- របាយការណ៍សំយោគរបស់សមត្ថកិច្ច OPJ ឬ បណ្តឹងរបស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី
- ចម្លើយបំភ្លឺរបស់ជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងជនសង្ស័យ
- ភស្តុតាង និងឯកសារផ្សេងៗទៀតក្នុងសំណុំរឿង

ជាគោលការណ៍ ក្នុងការរៀបចំពីអង្គហេតុយើងត្រូវធ្វើយ៉ាងណាឲ្យអង្គហេតុនោះ មានលក្ខណៈគ្រប់គ្រាន់ និងស៊ីចង្វាក់ទៅនឹងមាត្រាច្បាប់ដែលបានកំណត់អំពីបទល្មើសនោះ ដែលត្រូវការចោទប្រកាន់បញ្ជាក់ឲ្យបានច្បាស់លាស់អំពីកាលបរិច្ឆេទ និងទីកន្លែងប្រព្រឹត្តបទល្មើសបន្ទាប់ពីតំណាងអយ្យការ រៀបចំតាក់តែងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ រួចហើយត្រូវធ្វើការជូនដំណឹងទៅដល់ភាគី។

- **ការជូនដំណឹងអំពីការសម្រេចចេញដីកាសន្និដ្ឋានឲ្យស៊ើបសួរ**

នៅក្នុងច្បាប់នីតិវិធីយើងពុំឃើញមានបញ្ញត្តិជាកាតព្វកិច្ច ថាតំណាងអយ្យការត្រូវតែជូនដំណឹងទៅភាគីអំពីការសម្រេចនៃការសន្និដ្ឋានឲ្យស៊ើបសួរនោះទេ។ តែជាទូទៅរាល់សេចក្តីសម្រេចរបស់អយ្យការដែលពាក់ព័ន្ធទៅនឹងផលប្រយោជន៍របស់ភាគី ត្រូវតែមានការជូនដំណឹងដល់ភាគី នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដែលជាសេចក្តីសម្រេចរបស់តំណាងអយ្យការក្នុងការបញ្ជូនរឿងឲ្យទៅស៊ើបសួរដល់ចៅក្រមស៊ើបសួរ។ ដូចនេះការជូនដំណឹងអំពីដីកានេះនឹងបានផ្តល់ឲ្យជនរងគ្រោះ អំពីចំណាត់ការលើបណ្តឹងរបស់ខ្លួន ហើយម្យ៉ាងទៀតសម្រាប់ជនជាប់ចោទវិញ នឹងបានដឹងលក្ខខណ្ឌនៃការចោទប្រកាន់មកលើខ្លួន និងជាផលប្រយោជន៍ក្នុងការត្រៀមខ្លួនទៅក្នុងដំណាក់កាលចំពោះមុខចៅក្រមស៊ើបសួរ។

### ៤.២. ការប្រគល់វត្ថុដែលចាប់យកឲ្យទៅម្ចាស់ដើមវិញ

ការប្រគល់វត្ថុ ដែលចាប់យកទៅឲ្យទៅម្ចាស់ដើមវិញ ដោយព្រះរាជអាជ្ញាមានសមត្ថកិច្ចបង្គាប់ឲ្យប្រគល់វត្ថុដែលចាប់យកនោះទៅឲ្យម្ចាស់ដើមវិញ គឺបានតែនៅក្នុងដំណាក់កាលនៃការស៊ើបអង្កេតតែប៉ុណ្ណោះ។ ប្រសិនបើវត្ថុទាំងនោះពុំមានប្រយោជន៍សម្រាប់ការសំដែងការពិតទេនោះ ហើយប្រសិនបើកម្មសិទ្ធិលើវត្ថុនោះ

គ្មានការជំទាស់អ្វីប្រាកដប្រជាទេ។ ប៉ុន្តែសម្រាប់វត្ថុដែលមានគ្រោះថ្នាក់ចំពោះមនុស្ស ឬ ចំពោះទ្រព្យសម្បត្តិ ដូចជាអាវុធ ឬ ជាតិផ្ទុះ ព្រមទាំងវត្ថុដែលត្រូវបានកាន់កាប់ដោយខុសច្បាប់ គឺមិនអាចប្រគល់ឱ្យវិញបានទេ។ វត្ថុទាំងនោះត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ឬ ត្រូវបំផ្លាញចោល។

ក្នុងករណីមិនព្រមប្រគល់ឱ្យវិញទេ អ្នកប្តឹងអាចប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាបាន។

នៅពេលដែលសំណុំរឿងបានទៅដល់ដៃចៅក្រមស៊ើបសួរហើយ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញាគ្មានសមត្ថកិច្ចក្នុងការប្រគល់ទេ ព្រោះថារាល់ការសម្រេចទាក់ទងទៅនឹងកិច្ចការនេះ ត្រូវធ្វើឡើងដោយចៅក្រមស៊ើបសួរវិញ។ កាលណាមានការចោទប្រកាន់ធ្វើឡើងនៅចំពោះមុខយុត្តាធិការស៊ើបសួរ ឬ យុត្តាធិការជំនុំជម្រះ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញានៅតែមានសមត្ថកិច្ច កាលណាការស៊ើបសួរត្រូវបានបញ្ចប់ដោយសេចក្តីសម្រេចលើកលែងចោទប្រកាន់ជាស្ថាពរ។[142] ដូច្នេះ ការប្រគល់វត្ថុដែលរឹបអូសជូនម្ចាស់ដើមវិញ កាលបើតុលាការដែលទទួលពាក្យប្តឹងបានចេញសេចក្តីសម្រេចមួយជាស្ថាពរ ហើយពុំបានសម្រេចសេចក្តីលើការប្រគល់វត្ថុដល់ម្ចាស់ដើមវិញទេនោះព្រះរាជអាជ្ញា ឬ អគ្គព្រះរាជអាជ្ញាមានសមត្ថកិច្ចទៅតាមករណីនីមួយៗ ដើម្បីសម្រេចដោយឯកឯងលើពាក្យសុំឱ្យមានការប្រគល់វត្ថុដល់ម្ចាស់ដើមវិញនេះ នៅពេលដែលកម្មសិទ្ធិនៃវត្ថុនោះពុំមានការជំទាស់អ្វីជាប្រាកដប្រជាទេ។[143]

ប៉ុន្តែ នៅក្នុងដំណាក់កាលដែលមិនទាន់ចេញដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរក៏មានសមត្ថកិច្ចប្រគល់វត្ថុទាំងឡាយណា ដែលបានចាប់ទៅឲ្យម្ចាស់ដើមវិញដែល គឺដោយឆន្ទានុសិទ្ធិ ឬ មានអ្នកប្តឹងមុនពេលដែលធ្វើការសម្រេចនេះ។ ចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាដើម្បីទទួលមតិយោបល់ ហើយបើទោះបីជាព្រះរាជអាជ្ញាមានមតិយោបល់ផ្ទុយពីចៅក្រមស៊ើបសួរក៏ដោយ ក៏ចៅក្រមស៊ើបសួរមានសិទ្ធិចេញដីកាសម្រេចដោយឆន្ទានុសិទ្ធិរបស់ខ្លួនដោយមានសំអាងហេតុត្រឹមត្រូវ រួចឲ្យដំណឹងជាបន្ទាន់ទៅព្រះរាជអាជ្ញា ព្រមទាំងអ្នកប្តឹង និងមេធាវីអ្នកប្តឹង ប្រសិនបើក្នុងករណីសម្រេចខាងលើរបស់ចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញាយល់ឃើញថា ការសម្រេចរបស់ចៅក្រមស៊ើបសួរនោះធ្វើឡើងដោយមិនសមស្រប ព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍ចំពោះការសម្រេចនោះបាន ដោយក្នុងរយៈពេល ៥ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹង។

### ៤.៣. ដំណើរការ នៃការឃុំខ្លួន

នៅពេលដែលឃុំខ្លួនជនត្រូវចោទ ព្រះរាជអាជ្ញាអាចសុំឲ្យដោះលែងជនត្រូវចោទបានគ្រប់ពេលវេលា។ ហើយចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ ថ្ងៃ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេល ៥

[142] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១១៩

[143] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១២០

ថ្ងៃនេះទេ។ ព្រះរាជអាជ្ញា ប្ដឹងសុំតាមពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ដោយដីកាដែលសម្រេចមិនព្រមដោះលែងត្រូវមានសំអាងហេតុ។[144]

### ៤.៤. ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

គ្រប់បុគ្គលដែលត្រូវបានតំណាងអយ្យការ ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរត្រូវបានផ្លាស់ប្ដូរឋានៈរបស់ខ្លួនទៅជាជនត្រូវចោទ។ ជនត្រូវចោទ អាចត្រូវបានចៅក្រមស៊ើបសួរដកហូតសិទ្ធិសេរីភាពខ្លះ ដូចជាហាមឃាត់មិនឱ្យផ្លាស់ប្ដូរលំនៅឋាន ឬ ត្រូវមកបង្ហាញខ្លួនតាមការណែនាំរបស់ចៅក្រមស៊ើបសួរ និងមិនឱ្យធ្វើដំណើររកព្រំប្រទល់ដែនដី កំណត់ដោយចៅក្រមស៊ើបសួរអាទិ៍[145] ឬ ចៅក្រមស៊ើបសួរអាចសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្នថែមទៀតផង។ ព្រោះតែ អានុភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះនាំឱ្យមានការកំណត់ឋានៈ ដែលជាមធ្យោបាយសម្រាប់ដកហូតសិទ្ធិសេរីភាព ចំពោះពលរដ្ឋដូចនេះហើយទើបនៅក្នុងបទបញ្ញត្តិនៃមាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងអំពីទម្រង់ចាំបាច់មួយចំនួនដែលតម្រូវឱ្យតំណាងអយ្យការ ដែលជាម្ចាស់បណ្ដឹងអាជ្ញាត្រូវតែគោរពជាដាច់ខាត នៅមុនពេលចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅឱ្យចៅក្រមស៊ើបសួរ។

ចៅក្រមស៊ើបសួរដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ តាមគំនិតផ្ដើមផ្ទាល់របស់ខ្លួន ឬ តាមសេចក្ដីសន្និដ្ឋានសរុបរបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួនអំពីកាតព្វកិច្ចដែលតម្រូវទៅលើជនត្រូវចោទ។ កាលណា ចៅក្រមស៊ើបសួរដែលទទួលបណ្ដឹងតាមសេចក្ដីសន្និដ្ឋានពីព្រះរាជអាជ្ញា ដោយសុំឱ្យដាក់ខ្លួនជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ បើចៅក្រមស៊ើបសួរមិនព្រមសម្រេចតាមការសុំទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធការសុំនេះ។

ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ នៅពេលដែលជនត្រូវចោទកំពុងអនុវត្តវិធានការនៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនេះ ព្រះរាជអាជ្ញាមានសិទ្ធិសុំកែប្រែការធ្វើការត្រួតពិនិត្យតាមផ្លូវតុលាការនេះបាន។ ក្នុងករណីនេះ ចៅក្រមត្រូវជូនជាព័ត៌មានដល់ព្រះរាជអាជ្ញា និងជនត្រូវចោទឲ្យបានឆាប់បំផុត។ បើផុតរយៈពេល ៥ ថ្ងៃ ចៅក្រមស៊ើបសួរមិនសម្រេចនោះទេ ព្រះរាជអាជ្ញាដាក់ពាក្យបណ្ដឹងទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[146]

---

[144] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២១៦

[145] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១២៦ "កាតព្វកិច្ច នៃត្រួតពិនិត្យតាមផ្លូវតុលាការ"

[146] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២២៦

## ៤.៥.ដីកាសន្និដ្ឋានស្ថាពរបញ្ចប់ការស៊ើបសួររបស់អង្គការមហាអយ្យការ

នៅពេលដែលកិច្ចស៊ើបសួរចប់សព្វគ្រប់ ចៅក្រមស៊ើបសួរ និងបិទការស៊ើបសួររបស់ខ្លួនតាមរយៈដីកាដំណោះស្រាយ។[147] ប៉ុន្តែមុននឹងចេញដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរត្រូវតែជូនដំណឹងអំពីការបញ្ចប់ការបើកការស៊ើបសួររបស់ខ្លួននេះទៅដល់ជនដែលត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី មេធាវី ជាពិសេសចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាដែលជាម្ចាស់បណ្តឹងអាជ្ញាផ្ទាល់។

ការជូនដំណឹងទៅដល់ព្រះរាជអាជ្ញា គឺជាកាតព្វកិច្ចរបស់ចៅក្រមស៊ើបសួរដែលត្រូវបំពេញ។ ចៅក្រមស៊ើបសួរ មិនត្រូវបិទការស៊ើបសួរដោយស្ងាត់ៗនោះទេ គឺត្រូវតែជូនដំណឹងដល់ភាគី នៃរឿងក្តីឲ្យបានដឹងក្នុងគោលបំណង ដើម្បីឲ្យភាគីស្នើសុំទៅចៅក្រមស៊ើបសួរ នៅក្នុងការបំពេញកិច្ចណាមួយ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ ហើយ ក៏អាចឲ្យធ្វើការរៀបចំមធ្យោបាយការពារខ្លួនផ្សេងទៀតបានទាន់ពេលវេលាផងដែរ។ ទម្រង់នៃការជូនដំណឹង ចៅក្រមស៊ើបសួរ ត្រូវធ្វើតាមរយៈលិខិតរដ្ឋបាលមួយប្រភេទមានឈ្មោះជាលិខិតជូនដំណឹង ឬ ជូនព័ត៌មាន ក្រោយពីជូនដំណឹងរយៈពេល ២ ថ្ងៃ រួចមកចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យតាមរយៈដីកាមួយប្រភេទ គឺដីកាបញ្ជូនរឿងឲ្យពិនិត្យ ចៅក្រមស៊ើបសួរធ្វើការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដោយសារមានហេតុផលពីយ៉ាង៖

1. ដើម្បីឲ្យព្រះរាជអាជ្ញា ពិនិត្យមើលសំណុំរឿងថាតើគួរតែមានការយល់ស្រប ដូចចៅក្រមស៊ើបសួរដែរឬទេ? ឬមួយ ក៏ចង់ឲ្យចៅក្រមស៊ើបសួរបំពេញកិច្ចណាមួយទៀតបើយល់ថាមានប្រយោជន៍?
2. ដើម្បីឲ្យព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានស្ថាពរលើសំណុំរឿងនោះ។

ប្រសិនបើព្រះរាជអាជ្ញា យល់ឃើញថាចៅក្រមស៊ើបសួរ ត្រូវតែបំពេញកិច្ចណាមួយដែលចាំបាច់នោះ ព្រះរាជអាជ្ញាត្រូវធ្វើការស្នើសុំទៅចៅក្រមស៊ើបសួរ ដើម្បីបំពេញកិច្ចដូចដែលមានចែងក្នុងមាត្រា ១៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧។

បើព្រះរាជអាជ្ញា យល់ឃើញថាការស៊ើបសួរអាចបញ្ចប់បានហើយ ព្រះរាជអាជ្ញាត្រូវចេញដីកាសន្និដ្ឋានស្ថាពរក្នុងរយៈពេល ១៥ ថ្ងៃ ប្រសិនបើជនត្រូវចោទនៅក្នុងឃុំ ១ ខែ និងប្រសិនបើជនត្រូវចោទនៅក្រៅឃុំ។[148] ដីកានេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងបញ្ជាក់ពីសំអាងហេតុ និងមូលហេតុឲ្យបានច្បាស់លាស់។ ដីកានេះត្រូវចេញដោយព្រះរាជអាជ្ញា ហើយនៅក្នុងផ្នែកនៃសេចក្តីសម្រេចនៃដីកានេះ ព្រះរាជអាជ្ញាអាចប្តឹងឲ្យចៅក្រមស៊ើបសួរបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬ លើកលែងចោទប្រកាន់។ ដីកានេះត្រូវមានចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រាផងដែរ។ ក្រោយពីធ្វើការសន្និដ្ឋានស្ថាពរហើយ ព្រះរាជអាជ្ញាត្រូវបញ្ជូនដីកា

[147] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២៤៧

[148] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២៤៦

នោះដាក់ចូលក្នុងសំណុំរឿង ហើយផ្ញើរជូនទៅចៅក្រមស៊ើបសួរវិញ។ បន្ទាប់ពីទទួលបានសំណុំរឿងពីព្រះរាជអាជ្ញាដោយភ្ជាប់មកជាមួយដីកាសន្និដ្ឋានស្ថាពរហើយនោះ ដោយក្រោមការស៊ើបសួរ មិនអាចបំពេញកិច្ចណាមួយទៀតបានទេ ហើយត្រូវតែបិទការស៊ើបសួរដោយចេញដីកាដំណោះស្រាយតែម្តង។

ដីកាដំណោះស្រាយនេះ គឺជាដីកាសម្រេចរបស់ចៅក្រមស៊ើបសួរក្នុងការសម្រេចបិទកិច្ចស៊ើបសួររបស់ខ្លួន ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរនេះ គឺស្តែងឡើងតាមរូបភាពពីរយ៉ាង៖

- ដីកាបញ្ជូនទៅជំនុំជម្រះ
- ដីកាលើកលែងចោទប្រកាន់។

ការចេញដីកាដំណោះស្រាយចៅក្រមស៊ើបសួរ ត្រូវធ្វើការសម្រេចដោយលក្ខណៈឯករាជ្យ និងដោយឆន្ទានុសិទ្ធិរបស់ខ្លួន។ បើទោះបីជាមានការចង្អុលបង្ហាញពី ព្រះរាជអាជ្ញានៅក្នុងដីកាសន្និដ្ឋានស្ថាពរក៏ដោយព្រោះថាចៅក្រមស៊ើបសួរ មិនត្រូវជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានដោយព្រះរាជអាជ្ញាទេ។ មានន័យថាប្រសិនបើក្នុងដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា ធ្វើការលើកលែងចោទប្រកាន់ក៏ដោយ ក៏នៅក្នុងដីកាដំណោះស្រាយចៅក្រមស៊ើបសួរ ក៏នៅតែមានសិទ្ធិក្នុងការចោទប្រកាន់ដដែល "ដោយការបញ្ជូនទៅជំនុំជម្រះ" ប្រសិនបើអង្គហេតុដែលចៅក្រមស៊ើបសួរ ធ្វើការស៊ើបសួរនោះគាត់យល់ថា អង្គហេតុនោះបង្កើតបានជាបទល្មើសព្រហ្មទណ្ឌ។ ម្យ៉ាងវិញទៀត បើសិនជាព្រះរាជអាជ្ញាធ្វើការចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានស្ថាពរក៏ដោយ ក៏ចៅក្រោមស៊ើបសួរនៅតែមានសិទ្ធិសម្រេចលើកលែងចោទប្រកាន់ដោយដីកាដំណោះស្រាយរបស់ខ្លួនដែល ដោយដីកានោះគេហៅថា "ដីកាលើកលែងចោទប្រកាន់"។ បើកាលណាចៅក្រមស៊ើបសួរ យល់ឃើញថាអង្គហេតុដែលគាត់ធ្វើការស៊ើបសួរនោះ គាត់យល់ថាអំពើប្រព្រឹត្តមិនមែនជាបទល្មើស ឬ ជនប្រព្រឹត្តបទល្មើសនោះនៅតែមិនស្គាល់ ឬ នៅតែគ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ។

បន្ទាប់ពីចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយរបស់ខ្លួនរួចហើយ។ គាត់ត្រូវធ្វើការជូនដំណឹងដ៏ខ្លីបំផុតទៅព្រះរាជអាជ្ញា[149] ដើម្បីទុកឱកាសដល់ព្រះរាជអាជ្ញា នៅក្នុងការប្រើសិទ្ធិរបស់ខ្លួនក្នុងការធ្វើពាក្យបណ្តឹងទៅឧទ្ធរណ៍ប្រសិនបើគាត់យល់ថា មានចំណុចមិនប្រក្រតីណាមួយ នៅក្នុងដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ។

### ៥. អនុភាព នៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ

បន្ទាប់ពីព្រះរាជអាជ្ញា សម្រេចចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានឲ្យស៊ើបសួរ វានាំឲ្យដីកានេះបង្កើតឲ្យមានអានុភាពមួយចំនួនដូចជា ការផ្តាច់រយៈពេលនៃអាជ្ញាយុកាលនៃបទល្មើស ការផ្ទេរសមត្ថកិច្ចដល់ចៅក្រមស៊ើបសួរឲ្យបើកកិច្ចស៊ើបសួរ និងការកំណត់ព្រំដែនសមត្ថកិច្ច ឬ កំណត់អំពីវិសាលភាពនៃការស៊ើបសួរ។

[149] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២៤៧

**ការផ្តាច់រយៈពេលនៃអាជ្ញាយុកាល នៃបទល្មើស**

ចិរវេលានៃអាជ្ញាយុកាល ត្រូវចាប់ផ្តើមពីពេលប្រព្រឹត្តបទល្មើស។ ប៉ុន្តែចិរវេលា ឬ អាជ្ញាយុកាលនៃបទល្មើសនេះត្រូវផ្តាច់ និងរលត់ទៅវិញដោយគ្រប់កិច្ចនៃការចោទប្រកាន់ ឬ កិច្ចស៊ើបសួរ។[150] មានន័យថាគ្រប់កិច្ចចោទប្រកាន់របស់ព្រះរាជអាជ្ញា មិនថាតាមរយៈការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ការបង្ហាញខ្លួនភ្លាម ឬ ការបើកការស៊ើបសួរនោះទេ វាជាសញ្ញាណនៃការចោទប្រកាន់មួយដែលនាំឲ្យមានការផ្តាច់អាជ្ញាយុកាល នៃបទល្មើស។ រីឯគ្រប់កិច្ចនៃការស៊ើបសួរសំដៅទៅដល់កិច្ច ដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ដែលកិច្ចនោះក៏មានអានុភាពផ្តាច់អាជ្ញាយុកាល នៃបណ្តឹងអាជ្ញាយុកាលផងដែរ។

**ការផ្ទេរសមត្ថកិច្ចដល់ចៅក្រមស៊ើបសួរឲ្យបើកការស៊ើបសួរ**

គ្មានការស៊ើបសួរណាមួយ អាចបើកបានដោយគ្មានកិច្ចចោទប្រកាន់របស់ព្រះរាជអាជ្ញាទេ លើកលែងការដាក់ឲ្យមានចលនា នៃបណ្តឹងអាជ្ញាដោយជនរងគ្រោះ។ កិច្ចស៊ើបសួរដែលបើកដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរត្រូវចាត់ទុកជាមោឃៈ។ ការប្តឹងមោឃភាពត្រូវប្តឹងទៅសភាស៊ើបសួរគ្រប់ពេលវេលានៅពេលដែលមានការរកឃើញថាការស៊ើបសួរណាមួយខុសពីនីតិវិធី។ នៅពេលដែលចេញដីកាដំណោះស្រាយ គឺមានអានុភាពលុបលាងមោឃភាពនៃនីតិវិធីមុន មានន័យថា ទោះបីជាកិច្ចស៊ើបសួរណាមួយដែលអាចជាកម្មវត្ថុនៃមោឃភាពក៏ដោយ ក៏មិនអាចលើកមកពិចារណាម្តងទៀតនៅពេលជំនុំជម្រះបានទេ។

**ការកំណត់ព្រំដែនសមត្ថកិច្ច ឬ កំណត់អំពីវិសាលភាពនៃការស៊ើបសួរ**

ការបើកការស៊ើបសួរ គឺជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ក៏ប៉ុន្តែចៅក្រមស៊ើបសួរអាចមានសមត្ថកិច្ចក្នុងការបើកការស៊ើបសួរបាន លុះត្រាតែ មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដែលសម្រេច នឹងចេញដោយតំណាងអយ្យការបញ្ជូនឲ្យស៊ើបសួរ ដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ។[151] ចំពោះការស៊ើបសួរ គឺចៅក្រមស៊ើបសួរមានសមត្ថកិច្ចស្រាវជ្រាវ បានតែចំពោះអង្គហេតុដែលចង្អុលបង្ហាញ នៅក្នុងដីកាបញ្ជូនឲ្យស៊ើបសួរតែប៉ុណ្ណោះ។ ក្នុងករណីដែលមានលេចឡើងនូវអង្គហេតុថ្មីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌណាមួយ ដែលកំពុងត្រូវបានធ្វើការស៊ើបសួរ ចៅក្រមស៊ើបត្រូវជូនព័ត៌មានអំពីអង្គហេតុថ្មីនោះទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាអាចប្តឹងទៅចៅក្រមស៊ើបសួរឲ្យធ្វើការស៊ើបសួរបន្ថែមទៅលើអង្គហេតុថ្មីនោះបាន តាមរយៈការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។[152] រាល់ការបើកការស៊ើបសួរបន្ថែម គឺដូចទៅនឹងការបើកការស៊ើបសួរដែល ប្រសិនបើការបើកការស៊ើបសួរបន្ថែមនោះធ្វើឡើងដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពីសំណាក់ព្រះរាជ

[150] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១១

[151] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១២៤

[152] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១២៥

អាជ្ញានោះទេ ការស៊ើបសួរបន្ថែមនោះនឹងក្លាយទៅជាមោឃៈ លើកលែងតែនៅក្នុងករណីដែលអង្គហេតុថ្មីនោះ ពិនិត្យទៅឃើញថាជាបទល្មើសដដែល ប៉ុន្តែមាននូវស្ថានទម្ងន់ទោសលើអង្គហេតុ ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដំបូងនោះដោយចៅក្រមស៊ើបសួរ មិនចាំបាច់ត្រូវសុំដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពីព្រះរាជអាជ្ញាទេ។

ចៅក្រមស៊ើបសួរ មានអំណាចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលគ្រប់រូប ដែលមានតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាយ៉ាងខ្លាំងថាបានចូលរួមប្រព្រឹត្តបទល្មើស ទោះបីជាគ្មានការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក៏ដោយ។

## កថាខណ្ឌទី២៖ ការចោទប្រកាន់តាមរយៈការបញ្ជូនទៅជំនុំជម្រះផ្ទាល់

ការចោទប្រកាន់តាមរយៈការបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជានីតិវិធីដែលព្រះរាជអាជ្ញាបញ្ជាឲ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅចំពោះមុខតុលាការជាន់ដំបូង ដើម្បីធ្វើការជំនុំជម្រះដោយផ្ទាល់តាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដោយដីកានេះត្រូវចង្អុលប្រាប់ពីតុលាការព្រមទាំងទីកន្លែង កាលបរិច្ឆេទ និងម៉ោងពេលនៃសវនាការ ដីកានេះត្រូវបញ្ជាក់ថាជនជាប់ចោទអាចពឹងមេធាវីឱ្យអមខ្លួនបាន។[153] ការទទួលយកការបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺមានគោលបំណងធានាដល់ប្រសិទ្ធិភាពនៃស្ថាប័នអយ្យការ និងដល់សិទ្ធិរបស់ជនល្មើសក្នុងការទទួលបាននូវការជំនុំជម្រះរបស់តុលាការ ដោយ ទាមទារឱ្យមានការធ្វើការចោទប្រកាន់ជនល្មើស និងត្រូវបញ្ជូនអង្គហេតុទៅយុត្តាធិការជំនុំជម្រះតែម្តង ដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីណាផ្សេងទៀតឡើយ។ មិនត្រឹមតែប៉ុណ្ណោះ វាបានពន្លឿនក្នុងការដោះស្រាយក្នុងដំណើរការនៃនីតិវិធីនេះអោយមានលក្ខណៈឆាប់រហ័ស និងទទួលបានការជម្រះនៅក្នុងពេលសមស្រប។ ពីព្រោះ ការចោទប្រកាន់ត្រូវបានផ្ទេរពីសមត្ថកិច្ចរបស់អង្គការអយ្យការទៅចៅក្រមជំនុំជម្រះដើម្បីធ្វើការជំនុំជម្រះតែម្តង។ យ៉ាងណាមិញ ដើម្បីឲ្យនីតិវិធីនេះអាចប្រព្រឹត្តទៅបាន គឺទាមទារឲ្យមានការគោរពលក្ខខណ្ឌមួយចំនួន ហើយត្រូវអនុវត្តឲ្យស្របតាមនីតិវិធីមួយជាក់លាក់ ដែលនីតិវិធីនេះត្រូវតែធ្វើឡើងតាមទម្រង់ការ នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដើម្បីឈានឲ្យមាននូវអានុភាពទៅដល់ចំណាត់ការយុត្តាធិការជំនុំជម្រះផងដែរ។

### ១. លក្ខខណ្ឌ នៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់

មុននឹងឈានទៅដល់ការសម្រេចចោទប្រកាន់ តាមនីតិវិធីបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ចាំបាច់ទាមទារឲ្យព្រះរាជអាជ្ញា គោរពនូវលក្ខខណ្ឌមួយចំនួនដើម្បីធ្វើការចោទប្រកាន់បាន។ ប៉ុន្តែ ដោយផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌមិនបានកំណត់លក្ខខណ្ឌច្បាស់លាស់នោះទេ គ្រាន់តែបញ្ជាក់ពីចំណុចមួយចំនួន ដែលអាចឱ្យព្រះ

[153] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៦

រាជអាជ្ញាប្រើប្រាស់នៅក្នុងនីតិវិធីបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ដោយនៅក្នុងនោះ គឺសំដៅទៅដល់លក្ខខណ្ឌនៃបទល្មើសត្រូវបានបំពេញ និងលក្ខខណ្ឌនៃសាវតាជាតិរបស់ជនល្មើសដែលចាំបាច់ត្រូវបំពេញ។

### ១.១. លក្ខខណ្ឌ នៃបទល្មើស

ជាទូទៅ បទល្មើសដែលបានកើតឡើងហើយច្បាប់ទទួលស្គាល់ថាជាបទល្មើស លុះត្រាតែមានចែងនៅក្នុងច្បាប់យ៉ាងជាក់ច្បាស់ថាជាបទល្មើស និងច្បាប់បានកំណត់ថាវាជាអំពើល្មើស។ អំពើមួយដែលអាចចាត់ទុកថាជាបទល្មើសត្រូវតែមានធាតុផ្សំគ្រប់គ្រាន់ ដែលនាំឱ្យបទល្មើសនោះកំណត់ចំណាត់ថ្នាក់តាមប្រភេទ នៃទម្ងន់ទោសចំពោះរូបភាព នៃអំពើដែលបានប្រព្រឹត្ត។

ជាគោលគំនិត ការអនុវត្តនីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ អាចធ្វើបានចំពោះតែបទមជ្ឈិម និងបទលហុតែប៉ុណ្ណោះ ដោយសារតែបទល្មើសប្រភេទនេះមានលក្ខណៈស្រាល មិនសូវស្មុគស្មាញ និងមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដែលអាចជំនុំជម្រះបាន ដែលវាជាកត្តាមួយជួយជម្រុញដល់ការពន្លឿន នៃនីតិវិធីតុលាការឱ្យបានឆាប់រហ័ស ដែលមិនអូសបន្លាយពេលវេលា និងផ្តល់សេវាយុត្តិធម៌បានល្អប្រសើរផងដែរ។

- **ចំពោះបទមជ្ឈិម**

បទមជ្ឈិម សំដៅដល់បទល្មើសទាំងឡាយណា ដែលមានអតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវវងនោះមានរយៈពេលលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងក្រោម ឬ ស្មើ ៥ (ប្រាំ) ឆ្នាំ និងអាចត្រូវបានបន្ថែមជាទោសពិន័យផងដែរ។[154] ថ្វីត្បិតតែក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ពុំបានចែងច្បាស់ថាជាប្រភេទបទមជ្ឈិមបែបណាដែលអាចអនុញ្ញាតឲ្យព្រះរាជអាជ្ញាអនុវត្តនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដែលជាបទល្មើសជាក់ស្តែង ឬ មិនជាក់ស្តែងក៏ដោយ ក៏ប៉ុន្តែគេបានផ្តល់ឆន្ទានុសិទ្ធិដល់ព្រះរាជអាជ្ញាក្នុងការថ្លឹងថ្លែង និងសម្រេចដោយយោងទៅតាមស្ថានភាពនៃបទល្មើស។

ប្រសិនបើព្រះរាជអាជ្ញា បានពិនិត្យឃើញថាមានភស្តុតាងគ្រប់គ្រាន់ តុលាការនឹងធ្វើការជំនុំជម្រះសម្រេចសេចក្តីលើបទល្មើសបាន ដោយព្រះរាជអាជ្ញានឹងប្រើនីតិវិធីក្នុងការចោទប្រកាន់នេះ តែក៏អាចធ្វើការបើកស៊ើបសួរ ឬ ការចូលបង្ហាញខ្លួនបានផងដែរ ដោយហេតុថាមានករណីបទមជ្ឈិមមួយចំនួន ត្រូវឲ្យមានការចោទប្រកាន់តាមនីតិវិធីផ្សេងៗផងដែរ។ ជាក់ស្តែងប្រសិនបើ មានករណីស្ថានភាពនៃបទមជ្ឈិមដែលមានភាពស្មុគស្មាញក្នុងការដោះស្រាយ និងមានស្ថានភាពដោយឡែកដូចជា មិនទាន់រកឃើញភស្តុតាងគ្រប់គ្រាន់ មិនទាន់ស្គាល់អត្តសញ្ញាណជនល្មើសជាដើម គឺតម្រូវទាមទារឲ្យមានការបើកការស៊ើបអង្កេត ដើម្បីស្វែងរកភស្តុតាងឲ្យបានគ្រប់គ្រាន់ និងជាក់លាក់ស្របតាមនីតិវិធី។

[154] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា ៤៧

- **ចំពោះបទលហុ**

ព្រះរាជអាជ្ញាត្រូវតែជ្រើសរើសយកវិធីនៃការចោទប្រកាន់នេះ ពោល គឺមិនមានបទបញ្ញត្តិណាផ្សេងដែលអនុញ្ញាតឲ្យព្រះរាជអាជ្ញាបើកការស៊ើបសួរ ឬ ប្រើនីតិវិធីនៃការបង្ហាញខ្លួនភ្លាមចំពោះបទលហុនោះទេ។ មូលហេតុ គឺដោយសារតែបទលហុជាបទល្មើសតូចតាចដោយមានអតិបរមានៃទោស ដាក់ពន្ធនាគារមានរយៈពេលក្រោម ឬ ស្មើ ៦ ថ្ងៃ និងអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ ឬ ត្រឹមតែជាបទល្មើសដែលត្រូវផ្តន្ទាទោសដែលគ្រាន់តែពិន័យជាប្រាក់ប៉ុណ្ណោះ។[155] ដោយមើលឃើញថាបទលហុ ជាប្រភេទបទល្មើសដែលត្រូវផ្តន្ទាទោសស្រាល និងតូចតាច ដូចនេះគ្មានជម្រើសផ្សេងដែលល្អជាងការកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់នោះទេ។ ផ្ទុយទៅវិញ ប្រសិនបើព្រះរាជអាជ្ញាសម្រេចប្រើនីតិវិធីបើកការស៊ើបសួរ ឬ ការបង្ហាញខ្លួនភ្លាមវាអាចធ្វើឲ្យមានផលប៉ះពាល់ ឬ ទទួលរងការបំពានដល់សិទ្ធិសេរីភាពយ៉ាងធ្ងន់ធ្ងររបស់ជនជាប់ចោទ ដោយហេតុថានីតិវិធីនៃការបើកការស៊ើបសួរ ឬ ការបង្ហាញខ្លួនភ្លាមទាមទារឱ្យមានការឃុំខ្លួនជនជាប់ចោទទុករហូតដល់បង្ហាញខ្លួននៅចំពោះមុខតុលាការជំនុំជម្រះ។

គួរបញ្ជាក់ផងដែរថា ទោះបីជាការចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ចំពោះករណីបទលហុ ឬ បទមជ្ឈិមក៏ដោយ ក៏ការបញ្ជូនទៅជំនុំជម្រះនេះត្រូវតែធ្វើឡើងតាមរយៈដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ដែរ។ នៅពេលជនរងគ្រោះដែលជាដើមបណ្តឹងរដ្ឋប្បវេណី ឬ បុគ្គលផ្សេងទៀតដែលបានដាក់ពាក្យបណ្តឹង ក្រោយពេលពិនិត្យឃើញថាសំណុំរឿងជាបទលហុ ព្រះរាជអាជ្ញាអាចធ្វើការកោះហៅជនជាប់ចោទ ឱ្យចូលខ្លួននៅចំពោះមុខតុលាការ ដោយប្រើដីកាកោះហៅបញ្ជូនទៅជម្រះផ្ទាល់។[156]

### **១.២. លក្ខខណ្ឌ នៃសាវតាររបស់ជនល្មើស**

ក្រៅពីការកំណត់ឲ្យបានអំពីប្រភេទនៃបទល្មើសហើយ ព្រះរាជអាជ្ញាចាំបាច់ត្រូវរកឲ្យឃើញអំពីសាវតាជាតិរបស់ជនល្មើស នេះក៏ជាលក្ខខណ្ឌចាំបាច់មួយដែរ ព្រោះជាស្មារតីក្នុងការធ្វើបណ្តឹងអាជ្ញា គឺមានគោលបំណងមិនត្រឹមតែស្វែងរកអត្ថិភាពនៃបទល្មើសទេ អ្វីដែលសំខាន់នោះ គឺចង់ឲ្យមានការផ្តន្ទាទោសចំពោះជនល្មើសទៀតផង។ ការចោទប្រកាន់តាមទម្រង់ជាដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដែលមិនស្គាល់ជនល្មើសមិនអាចប្រព្រឹត្តទៅបានទេ។ ម្យ៉ាងទៀតក្រមនីតិវិធីទទួលស្គាល់វិសាលភាព នៃបណ្តឹងចំពោះជនជាប់ចោទ គឺមានន័យថាតុលាការ នឹងជំនុំជម្រះតែជនណាដែលមានក្នុងពាក្យដែលប្តឹងមកខ្លួនប៉ុណ្ណោះ។ ដូចនេះការស្គាល់អត្តសញ្ញាណរបស់ជនល្មើសជាលក្ខខណ្ឌត្រូវតែមានដែលខ្វះមិនបាន។

---

[155] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា ៤៨

[156] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៩

## ២. នីតិវិធី នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

នៅពេលដែលព្រះរាជអាជ្ញា ទទួលពាក្យបណ្ដឹងហើយយល់ឃើញថា សំណុំរឿងដែលខ្លួនទទួលបាន ដែលមានលក្ខខណ្ឌ នៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ត្រូវបានបំពេញ ព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់ភ្លាម ដោយមិនមានភាពចាំបាច់ក្នុងការស្រាវជ្រាវបន្ថែមទេ ព្រះរាជអាជ្ញាត្រូវធ្វើការបញ្ជូនរឿងក្ដីទៅតុលាការជំនុំជម្រះតែម្ដងតាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ សម្រាប់កោះហៅជនជាប់ចោទឱ្យចូលសវនាការដើម្បីធ្វើការជំនុំជម្រះដែលមិនឆ្លងកាត់ដំណាក់កាលស៊ើបសួរទេ។

ចំពោះការជំនុំជម្រះផ្ទាល់នេះ គឺធ្វើទៅបានក្នុងករណីបទមជ្ឈិម និងបទលហុតែប៉ុណ្ណោះ ដែលជាបទល្មើសមានលក្ខណៈស្រាលមិនសូវបង្កជាភាពអសន្តិសុខដល់សង្គមខ្លាំង។ មានន័យថាព្រះរាជអាជ្ញា មានសិទ្ធិជ្រើសរើសវិធីបញ្ជូនជនជាប់ចោទទៅជំនុំជម្រះផ្ទាល់បាននៅពេលយល់ឃើញថានីតិវិធីនេះ ផ្ដល់សារៈប្រយោជន៍ដើម្បីពន្លឿននីតិវិធី ក៏ប៉ុន្តែអត្តសញ្ញាណរបស់ជនល្មើសជាលក្ខខណ្ឌចាំបាច់ នៅក្នុងនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ដែលទាមទារការកំណត់ឲ្យបាននូវអត្តសញ្ញាណរបស់ជនល្មើសដោយខានមិនបាន។[157] ករណីប្រសិនបើចៅក្រមជំនុំជម្រះដែលបានទទួលសំណុំរឿងពីព្រះរាជអាជ្ញា តាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ បានពិនិត្យឃើញថាសំណុំរឿងនេះ មិនអាចជំនុំជម្រះបានដោយសារតែមានភាពស្មុគស្មាញ ភស្តុតាងមិនគ្រប់គ្រាន់ ឬ មានការពាក់ព័ន្ធនឹងបុគ្គលដែលស្វែងរកក្នុងការបញ្ជាក់អត្ថិភាពនៃបទល្មើស ចៅក្រមជំនុំជម្រះអាចនឹងបង្វិលសំណុំរឿងនេះទៅព្រះរាជអាជ្ញាវិញ។ មានន័យថាប្រសិន បើជនល្មើសជាអញ្ញាតជន នោះព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់ តាមដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់បានឡើយ។

ចំពោះការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះនេះព្រះរាជអាជ្ញា ឬ អាជ្ញាសាលាក៏អាចប្រគល់ឲ្យជនជាប់ចោទផ្ទាល់ផងដែរ។[158] ក្រៅពីអាជ្ញាសាលា និងព្រះរាជអាជ្ញាដីកាកោះនេះក៏អាចប្រគល់ជូនប្រធានពន្ធនាគារ ឬ ប្រធានមណ្ឌលឃុំខ្លួនដោយក្រឡាបញ្ជី ដោយនគរបាលយុត្តិធម៌ ឬ តាមផ្នែករដ្ឋបាល។[159] ដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាលិខិតដែលព្រះរាជអាជ្ញាអាចបញ្ជូនសំណុំរឿង និងជនជាប់ចោទទៅតុលាការជំនុំជម្រះ។ ចំណែកឯ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាលិខិតចោទប្រកាន់មួយរបស់ព្រះរាជអាជ្ញាដែលប្រើចំពោះបទមជ្ឈិម ឬ បទលហុ និងមានអានុភាពបញ្ជាជនជាប់ចោទឱ្យចូលបង្ហាញខ្លួននៅចំពោះមុខតុលាការជាន់ដំបូង។

[157] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៦

[158] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៥៨ និង ៤៥៩

[159] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៦៣

### ២.១. ចិរវេលា នៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

នៅពេលដែលតុលាការ បានទទួលបណ្ដឹងដោយការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដោយដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬ សាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ប្រធានតុលាការត្រូវតែគិតគូរតាមរយៈពេលដែលមានចែងក្នុងបញ្ញត្តិច្បាប់ ដើម្បីធានាថាជនជាប់ចោទមានរយៈពេលសមរម្យ ក្នុងការរៀបចំខ្លួនត្រៀមឡើងសវនាការនេះ សម្រាប់ស្ថានភាពខុសគ្នាៗចំពោះទីតាំងដែលជនជាប់ចោទឈរជើងនៅ។[160] ដូចនេះ ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ពីរយៈពេលដែលត្រូវគោរព រវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឱ្យដល់ជនជាប់ចោទ និងថ្ងៃកំណត់ឱ្យចូលបង្ហាញខ្លួននៅមុខតុលាការត្រូវកំណត់ដូចតទៅ[161]៖

- មានរយៈពេល ១៥ ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដី នៃទីស្នាក់ការរបស់តុលាការជាន់ដំបូង
- មានរយៈពេល ២០ ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀត នៃព្រះរាជាណាចក្រកម្ពុជា។
- មានរយៈពេល ២ ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា
- មានរយៈពេល ៣ ខែ ប្រសិនបើជនជាប់ចោទរស់នៅកន្លែងផ្សេងក្រៅពីខាងលើ ។[162]

ដោយចិរវេលាខាងលើនេះត្រូវតែគោរព បើពុំដូច្នោះទេនិងនាំអោយមានមោឃភាពនៃនីតិវិធី នៃការកោះហៅលើកលែងតែជនជាប់ចោទយល់ព្រមចូលបង្ហាញខ្លួនដោយស្ម័គ្រចិត្ត។

### ២.២. របៀប នៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

ការប្រគល់ដីកាកោះ និងចុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដោយព្រះរាជអាជ្ញា អាចត្រូវប្រគល់ឱ្យជនជាប់ចោទដោយផ្ទាល់ដៃរបស់ព្រះរាជអាជ្ញា។[163] នៅដើមដីកាដែលមានការចុះកាលបរិច្ឆេទ ទីកន្លែងកំណើត ទីលំនៅឋានរបស់ជនជាប់ចោទត្រូវមានការចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា។[164]

បន្ថែមពីនេះទៅទៀត ព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសស្ដីពីកាលបរិច្ឆេទ និងទីកន្លែងប្រគល់ដីកានៅលើដើមដីកា ហើយជនជាប់ចោទត្រូវចុះហត្ថលេខានៅដើមដីកានេះដែរ។[165] ម្យ៉ាងវិញទៀត ក្រៅពីព្រះរាជអាជ្ញាដីកានេះក៏អាចត្រូវបានប្រគល់ដោយបុគ្គលផ្សេងទៀតផងដែរ ដែលបុគ្គលទាំងនោះរួមមាន៖ អាជ្ញាសាលា ក្រឡាបញ្ជី

---

[160] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២៩២

[161] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៥៧

[162] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៥៧

[163] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៥៨

[164] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៥៦

[165] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៥៨ កថាខណ្ឌទី ២

អាជ្ញាធររដ្ឋបាល ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវឃុំខ្លួនពីបទល្មើសផ្សេងទៀត តាមរយៈអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ។ យ៉ាងណាមិញ ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល អាជ្ញាធរពន្ធនាគារ មន្ត្រីនគរបាលជាតិ ឬ អាវុធហត្ថ ដែលព្រះរាជអាជ្ញាសុំឱ្យប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ត្រូវតែគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញា។[166] ក្នុងនោះយើងឃើញថា អាជ្ញាសាលាមិនត្រឹមតែអាចប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់បាននោះទេ ក៏ប៉ុន្តែអាជ្ញាសាលា ក៏អាចប្រគល់ចុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់បានផងដែរ ដោយប្រើគ្រប់មធ្យោបាយដើម្បីប្រគល់ដីកានេះ ឱ្យដល់ជនជាប់ចោទដោយផ្ទាល់ដៃ ឬ ដល់មេឃុំ ឬ ចៅសង្កាត់។[167] ក្នុងករណីដែលអាជ្ញាសាលាបានជួបប្រទះជនជាប់ចោទនៅក្នុងផ្ទះ ឬ នៅកន្លែងដទៃទៀត អាជ្ញាសាលាត្រូវប្រគល់ចុងដីកាកោះដល់សាមីខ្លួន ដោយចារលើសេចក្តីដើមដីកាថាបានប្រគល់ចុងដីកាដល់ជនជាប់ចោទដោយផ្ទាល់ដៃ និងត្រូវចុះនិទ្ទេសស្តីពីកាលបរិច្ឆេទ និងទីកន្លែងនៃការប្រគល់ ព្រមទាំងចុះហត្ថលេខាដោយជនជាប់ចោទលើដើមដីកា ហើយដើមដីកាត្រូវបញ្ជូនវិលត្រឡប់ ទៅកាន់ព្រះរាជអាជ្ញាវិញភ្លាម។[168]

លើសពីនេះទៅទៀត ប្រសិនបើជនជាប់ចោទអវត្តមានពីលំនៅឋានរបស់ខ្លួន អាជ្ញាសាលាត្រូវប្រគល់ចុងដីកាឱ្យដល់បុគ្គលទាំងឡាយណា ដែលជានីតិជនដែលមានវត្តមាននៅក្នុងលំនៅឋាននោះ ដោយឱ្យចុះសេចក្តីលើដើមដីកា ថាចុងដីកាត្រូវប្រគល់ឱ្យបុគ្គលដែលមានវត្តមាននៅលំនៅឋាន ហើយក៏ត្រូវចុះនិទ្ទេសស្តីពីអត្តសញ្ញាណនៃបុគ្គលនោះ និងកាលបរិច្ឆេទនៃការប្រគល់ដីកា ព្រមទាំងចុះហត្ថលេខារបស់បុគ្គលដែល ទទួលដីកាដោយសន្យាថានិងប្រគល់ដីកានេះក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយដើមដីកាក៏ត្រូវបង្វិលជូនព្រះរាជអាជ្ញាវិញភ្លាមផងដែរ។[169] បន្ថែមពីនេះ អាជ្ញាសាលាអាចប្រគល់ចុងដីកាឱ្យដល់មេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រង នៅក្នុងករណីដូចតទៅ[170]៖

- ជនជាប់ចោទមិនព្រមទទួលដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់
- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទ
- គ្មានបុគ្គលណាម្នាក់ ដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទយល់ព្រមទទួលដីកាទេ។

[166] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៦៣

[167] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៥៩

[168] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៦០

[169] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៦១

[170] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៦២

នៅពេលដែលអាជ្ញាសាលា ប្រគល់ចុងដីកាឱ្យដល់មេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រង ត្រូវចុះនិទ្ទេសនៅលើដើមដីកាអំពីអត្តសញ្ញាណ និងឋានៈរបស់បុគ្គលដែលបានទទួលចុងដីកា ព្រមទាំងកាលបរិច្ឆេទនៃការប្រគល់ដីកា ហើយបុគ្គលដែលទទួលចុងដីកាត្រូវចុះហត្ថលេខារបស់ខ្លួននៅដើមដីកា និងដើមដីកាត្រូវបង្វិលត្រឡប់ជូនព្រះរាជអាជ្ញាវិញភ្លាម ព្រមទាំងសន្យាថានឹងប្រគល់ដីកានោះ ក្នុងរយៈពេលដ៏ខ្លីបំផុតឱ្យដល់ជនជាប់ចោទ។ ក្នុងករណីប្រសិនបើជនជាប់ចោទគ្មានលំនៅឋាន ឬ ទីសំណាក់ ឬ ក៏រស់នៅក្រៅដែនដីជាតិ ព្រះរាជអាជ្ញាក៏អាចធ្វើការចោទប្រកាន់លើជនជាប់ចោទនេះ តាមផ្លូវដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់បានផងដែរ ហើយកាលបរិច្ឆេទនៃការធ្វើដីកាត្រូវចាត់ទុកថាជាកាលបរិច្ឆេទ នៃការប្រគល់ដីកា។[171]

### ២.៣. លក្ខខណ្ឌដែលនាំអោយមានសពុលភាពលើដីកាកោះហៅជំនុំជម្រះផ្ទាល់

តាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ តម្រូវឲ្យមានរយៈពេលសមស្រប ដើម្បីឲ្យជនជាប់ចោទបានត្រៀមលក្ខណៈឡើងសវនាការ។ ការកំណត់នេះមានរយៈពេលខុសៗគ្នា ដែលវាអាស្រ័យទៅលើស្ថានភាព ឬទីតាំងដែលជនជាប់ចោទមានវត្តមានស្នាក់នៅ ដើម្បីធានាបានថាជនជាប់ចោទមានរយៈពេលសមរម្យក្នុងការរៀបចំខ្លួនសម្រាប់ត្រៀមឡើងសវនាការ។ យោងតាមមាត្រា ៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានធ្វើការកំណត់រយៈពេល នៃការចេញដីកាកោះហៅជនជាប់ចោទដូចតទៅ[172]៖

- ១៥ ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃតុលាការជាន់ដំបូង
- ២០ ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងមួយផ្សេងទៀតនៃដែនដីជាតិ
- ២ ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជា
- ៣ ខែ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងមួយផ្សេងទៀត។

### ២.៤. ផលវិបាក នៃការពុំគោរពទៅតាមរយៈពេល នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

ក្នុងករណីប្រសិនបើការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឱ្យចូលបង្ហាញខ្លួនពុំបានគោរពតាមរយៈពេលដែលច្បាប់បានកំណត់ទេនោះ វានឹងនាំឱ្យមានផលវិបាកហើយតុលាការ ត្រូវមានចំណាត់ការតាមករណីដូចខាងក្រោម៖[173]

[171] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៦៤

[172] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៦៦

[173] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៩១

- ប្រសិនបើជនជាប់ចោទមិនចូលបង្ហាញខ្លួន តុលាការពិនិត្យមោឃភាព នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ ដីកាកោះហៅឱ្យចូលបង្ហាញខ្លួន។ តុលាការបង្គាប់ឱ្យចេញដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ជាថ្មីម្តងទៀត លើកលែងតែបណ្តឹងអាជ្ញាត្រូវផុតរលត់។
- ប្រសិនបើជនជាប់ចោទចូលបង្ហាញខ្លួននៅពេលសវនាការ តុលាការអាចពិនិត្យមើលសំណុំរឿង ក្នុងករណីជនជាប់ចោទយល់ព្រមយ៉ាងជាក់លាក់ឱ្យជំនុំជម្រះភ្លាម។ ប៉ុន្តែ បើជនជាប់ចោទមិនព្រមឱ្យជំនុំជម្រះភ្លាមទេ តុលាការបង្គាប់ឱ្យលើកសំណុំរឿងនេះទៅជំនុំជម្រះនៅសវនាការពេលក្រោយទៀត។

ម្យ៉ាងវិញទៀត នីតិវិធីនេះនឹងត្រូវបានប្រកាសមោឃភាព កាលណាដែលដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់មានអានុភាពធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ជនជាប់ចោទ លើកលែងតែជនជាប់ចោទ ចូលមកបង្ហាញខ្លួនដោយស្ម័គ្រចិត្ត។ មោឃភាព នៃដីកាកោះហៅឱ្យចូលសវនាការដែលប្រគល់ឱ្យជនជាប់ចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ឬ អ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចនឹងត្រូវប្រកាសបាន កាលណាដីកាកោះហៅនេះមានអានុភាពធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីពាក់ព័ន្ធតែប៉ុណ្ណោះ។[174]

### ៣. ទម្រង់ នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

យោងតាមមាត្រា ៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់អំពីទម្រង់របស់ដីកាបញ្ជូនរឿងទៅជម្រះផ្ទាល់។ ដើម្បីឱ្យចៅក្រមជំនុំជម្រះយល់ឃើញថា រឿងក្តីដែលព្រះរាជអាជ្ញាបានចោទប្រកាន់ពិតជាមានភាពធ្ងន់ល្មមអាចនឹងចោទប្រកាន់បាន នោះព្រះរាជអាជ្ញាត្រូវតែធ្វើដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។

ទម្រង់របស់ដីកាកោះហៅបញ្ជូនទៅជម្រះផ្ទាល់ បានកំណត់នូវចំណុចជាផលប្រយោជន៍ ដ៏សំខាន់ក្នុងកិច្ចជំនុំជម្រះហើយទម្រង់ នៃដីកានោះរួមមានដូចជា៖ អត្តសញ្ញាណជនជាប់ចោទ សេចក្តីសង្ខេបនៃអង្គហេតុ ឈ្មោះបទល្មើស អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស។

ដោយដីកានោះត្រូវតែមានទម្រង់ការច្បាស់លាស់ និងជាក់លាក់ដើម្បីងាយស្រួលដល់ចៅក្រមជំនុំជម្រះពិនិត្យ និងវិនិច្ឆ័យថាបទល្មើសដែលចោទប្រកាន់នោះពិតជាត្រឹមត្រូវតាមនីតិវិធីច្បាប់។ ម្យ៉ាងវិញទៀត ទម្រង់ការនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះ ក៏ជាព័ត៌មានយ៉ាងសំខាន់សម្រាប់ជនជាប់ចោទ យល់អំពីមូលហេតុនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា ព្រមទាំងសិទ្ធិ និងកាតព្វកិច្ចរបស់ជនជាប់ចោទក្នុងការបង្ហាញខ្លួនតាមការកំណត់ដោយមានចែងនៅក្នុងដីកានេះ។ ដូចនេះ ទម្រង់ការនៃដីកាកោះហៅទៅជំនុំជម្រះផ្ទាល់រួមមាន៖[175]

174 ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៩២

175 ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៦

- **អត្តសញ្ញាណនៃជនជាប់ចោទ**

ការកំណត់ពីអត្តសញ្ញាណជនជាប់ចោទ គឺមានប្រយោជន៍ដល់កិច្ចជំនុំជម្រះត្រង់ដែននៃការប្តឹងចំពោះបុគ្គល និងមានន័យគ្រប់គ្រាន់ថាជាបណ្តឹងចោទប្រកាន់ចំពោះជនល្មើស ព្រោះប្រសិនបើគ្មានការកំណត់អត្តសញ្ញាណនៃជនជាប់ចោទទេ មានន័យថាគ្មានការចោទប្រកាន់លើបទព្រហ្មទណ្ឌកើតមានឡើងនោះទេ។

- **សេចក្តីសង្ខេបអង្គហេតុ**

ការកំណត់ពីសេចក្តីសង្ខេបអង្គហេតុ គឺមានប្រយោជន៍ដល់កិច្ចជំនុំជម្រះត្រង់ដែននៃការប្តឹងចំពោះអង្គហេតុ និងនាំឱ្យយើងដឹងថាបណ្តឹងប្តឹងអំពីអ្វី ព្រោះបើមិនកំណត់អង្គហេតុមានន័យថាព្រះរាជអាជ្ញាមិនបានចោទប្រកាន់លើអង្គហេតុនោះទេ ជាហេតុនាំឱ្យគ្មានបណ្តឹង។

- **ឈ្មោះបទល្មើស**

សំដៅដល់បទល្មើសដែលព្រះរាជអាជ្ញា សម្រេចចោទប្រកាន់ចំពោះជនជាប់ចោទ។ ចំពោះបទចោទប្រកាន់តុលាការមិនជាប់កាតព្វកិច្ចចំពោះឈ្មោះបទល្មើសទេ ដោយសារតុលាការជាប់កាតព្វកិច្ចចំពោះដែននៃការប្តឹងចំពោះអង្គហេតុ និងបុគ្គលតែប៉ុណ្ណោះ។ ដូចនេះ តុលាការអាចសម្រេចអំពីប្រភេទបទល្មើសផ្សេងដោយសេរីចំពោះអង្គហេតុនោះលើបុគ្គលនោះ។

- **អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស**

គឺសំដៅទៅលើបទល្មើស ដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ដោយត្រូវពឹងផ្អែកទៅលើបទបញ្ញត្តិនៃច្បាប់។ ក្រៅពីទម្រង់នៃដីកាខាងលើព្រះរាជអាជ្ញា ក៏ត្រូវចង្អុលប្រាប់ដល់ជនជាប់ចោទពីតុលាការ ព្រមទាំងទីកន្លែងចោទប្រកាន់ កាលបរិច្ឆេទ និងម៉ោងពេលនៃសវនាការផងដែរ។ ព្រោះការជូនដំណឹងនេះមានភាពងាយស្រួលដោយមិនចាំបាច់ចេញដីកាកោះហៅឱ្យចូលសវនាការទេ ដោយហេតុថាទម្រង់ការនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់បានបញ្ជាក់ប្រាប់ដល់ជនជាប់ចោទរួចអស់ហើយ។

### ៤. អានុភាព នៃដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់

ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ គឺជាដីកាដែលចេញដោយព្រះរាជអាជ្ញាក្នុងការចោទប្រកាន់លើបទល្មើសព្រហ្មទណ្ឌ ដោយបានបង្កើតនូវអានុភាពមួយចំនួនរួមមាន៖ ការផ្តាច់អាជ្ញាយុកាលនៃបទល្មើស ការផ្ទេរសមត្ថកិច្ច និងការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុ និងជនជាប់ចោទ។

- **ការផ្តាច់អាជ្ញាយុកាលនៃបទល្មើស**

យើងបាននិយាយរួចទៅហើយ ទាក់ទងនឹងការបង្អាក់អាជ្ញាយុកាលនៃបទល្មើស។ បណ្តឹងអាជ្ញាមិនអាចធ្វើបានជាដាច់ខាត កាលបើវាផុតអាជ្ញាយុកាលសំរាប់ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌ។ អាជ្ញាយុកាលចំពោះបទល្មើស នឹងត្រូវផ្តាច់កាលណាមានកិច្ចចោទប្រកាន់កើតមាន ពោល គឺចាប់ផ្តើមគិតថិរវេលាថ្មីនៃអាជ្ញា

យុកាលដែលជាហេតុនាំឱ្យមានការផ្ដាច់អាជ្ញាយុកាលនៃបទល្មើស។ នេះជាចំណុច ដែលមានសារៈសំខាន់ ព្រោះថាបើមិនមានការចែងពីចំណុចនេះទេ អាជ្ញាយុកាលមិនត្រូវផ្ដាច់ ទោះបីបើមានការចោទប្រកាន់រួចហើយក៏ដោយ។ ដូច្នេះអាចមានករណីនៅពេលបញ្ជូនទៅដល់តុលាការហើយ តែបែរជារលត់បណ្ដឹងអាជ្ញាទៅវិញ ករណីនេះតុលាការនឹងសម្រេចឲ្យជននោះរួចខ្លួន។ អាជ្ញាយុកាលចាប់រាប់ដោយគិតចាប់ពីពេលប្រព្រឹត្តបទល្មើស ឬ គិតចាប់ពីពេលមានការបញ្ចប់កិច្ចចោទប្រកាន់ ឬ កិច្ចស៊ើបសួរ។

យោងតាមមាត្រា ១០ នៃក្រមនៅតិវិធីព្រហ្មទណ្ឌបានកំណត់អំពីអាជ្ញាយុកាល នៃបទល្មើសនេះគឺៈ ១៥ ឆ្នាំ ចំពោះបទឧក្រិដ្ឋ, ៥ ឆ្នាំ ចំពោះបទមជ្ឈិម និង១ ឆ្នាំ ចំពោះបទលហុ។[176]

- **ការផ្ទេរសមត្ថកិច្ចទៅតុលាការ**

យោងតាមមាត្រា ២៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានចែងថា "អង្គការអយ្យការធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់"។[177] ការកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ គឺជាកិច្ចចោទប្រកាន់មួយរបស់ព្រះរាជអាជ្ញា ដែលជាតំណាងរបស់អង្គការអយ្យការ។ តាមរយៈដីកានេះបាននាំឲ្យមានអវត្តមាន នៃកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ តែវាបានផ្ទេរសមត្ថកិច្ចពីអយ្យការទៅយុត្តាធិការជំនុំជម្រះវិញ។

ជាទូទៅតុលាការមានសមត្ថកិច្ចជំនុំជម្រះ បានលុះត្រាតែមានបណ្ដឹងមកខ្លួនតែប៉ុណ្ណោះ។ ក្នុងរឿងក្ដីព្រហ្មទណ្ឌសាលាដំបូង ត្រូវបានទទួលពាក្យបណ្ដឹងដោយដីកាបញ្ជូនទៅតុលាការជំនុំជម្រះផ្ទាល់របស់ព្រះរាជអាជ្ញា។[178] ជាគោលការណ៍ តុលាការនឹងគ្មានសមត្ថកិច្ចលើរឿងក្ដីនេះទេ ដរាបណាមិនមានបណ្ដឹងប្រគល់មកខ្លួន ហើយកិច្ចជំនុំជម្រះដែលបើកដោយគ្មានបណ្ដឹងនោះ ជាការបើកការជំនុំជម្រះដោយខុសច្បាប់ ជនដែលត្រូវច្បាប់ប្រគល់សិទ្ធិអាចធ្វើបណ្ដឹងឧទ្ធរណ៍ករណីជាសាលក្រមរបស់សាលាដំបូង និងធ្វើបណ្ដឹងសារទុក្ខករណីជាសាលដីកាបស់សាលាឧទ្ធរណ៍ និងអាចប្ដឹងសើរើបានបើសេចក្ដីសម្រេចតុលាការចូលជាស្ថាពរ។ ផ្ទុយពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលត្រូវបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរឱ្យបើកកិច្ចស៊ើបសួរ តែដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ត្រូវបានប្រគល់សំណុំរឿងទៅឱ្យតុលាការធ្វើការជំនុំជម្រះតែម្ដង ដោយពុំឆ្លងកាត់ដំណាក់កាលចៅក្រមស៊ើបសួរឡើយ។

---

[176] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១០

[177] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២៧ កថាខណ្ឌទី ១

[178] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២៩១

### ការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុ និងជនជាប់ចោទ

យោងតាមមាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានបញ្ញត្តិពីដែនកំណត់ចំពោះអង្គហេតុ។ ដែនកំណត់ចំពោះអង្គហេតុមានន័យថា៖ តុលាការអាចជំនុំជម្រះបានត្រឹមអង្គហេតុដែលមានក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់តែប៉ុណ្ណោះ។[179] ដូចដែលបានឃើញពីការកំណត់ចំណុចមួយរបស់ទម្រង់ដីកា គឺកំណត់អំពីសេចក្តីសង្ខេបនៃអង្គហេតុ ដោយតុលាការធ្វើការជំនុំជម្រះតែទៅលើអង្គហេតុ និងបុគ្គលដែលបានកំណត់ក្នុងកំណត់ហេតុស្តីអំពី។ ការបង្គាប់ឲ្យមានការបង្ហាញខ្លួន តុលាការមិនអាចលើកយកអង្គហេតុនិងបុគ្គលទាំងឡាយណា ដែលមិនបានសរសេរក្នុងដីកានោះមកជំនុំជម្រះផ្ទាល់បានទេ។ ទោះជាមានការកំណត់អង្គហេតុរួចហើយក៏ដោយ តែជួនកាលមានករណីមួយចំនួនដែលតុលាការនឹងបង្គាប់ឲ្យបង្វិលសំណុំរឿងឲ្យព្រះរាជអាជ្ញាវិញ ដោយសារករណីបទមជ្ឈិម ឬ បទលហុ ត្រូវជំនុំជម្រះដោយចៅក្រមទោល ឯករណីបទឧក្រិដ្ឋចាំបាច់ត្រូវជំនុំជម្រះជាក្រុមសមូហភាពដែលមានចៅក្រមបីរូប។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់នេះ ចេញក្នុងករណីចោទប្រកាន់លើបទមជ្ឈិម ឬ បទលហុ ដូចនេះបើតុលាការយល់ថាជាបទឧក្រិដ្ឋវិញ នោះតុលាការនឹងបង្វិលសំណុំរឿងមកព្រះរាជអាជ្ញាដើម្បីបើកការស៊ើបសួរវិញ។[180] ចំណែកឯការកំណត់ដែនសមត្ថកិច្ច នៃការប្តឹងចំពោះបុគ្គលមានន័យថា៖ តុលាការនឹងអាចជំនុំជម្រះចំពោះតែជនណា ដែលបានចង្អុលឈ្មោះក្នុងដីកានេះតែប៉ុណ្ណោះ។ តុលាការមិនអាចធ្វើការជំនុំជម្រះលើជនទាំងឡាយណា ដែលមិនមានការចោទប្រកាន់របស់ព្រះរាជអាជ្ញានោះទេ ដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ក៏បានកំណត់ពីអត្តសញ្ញាណរបស់ជនល្មើស ដែលជាលក្ខខណ្ឌមួយក្នុងចំណោមទម្រង់នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដែរ។

គួរបញ្ជាក់ផងដែរថា ក្នុងករណីការចោទប្រកាន់ធ្វើឡើងដោយដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គ្មានអានុភាពបង្ខំឲ្យជនជាប់ចោទឲ្យចូលសវនាការទេ ជនជាប់ចោទមានសេរីភាពក្នុងការបង្ហាញខ្លួននៅមុខសវនាការ។[181]

## កថាខណ្ឌទី៣៖ការចោទប្រកាន់តាមរយៈកំណត់ហេតុនៃការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម

ការបង្គាប់ឲ្យបង្ហាញខ្លួនភ្លាម ជានីតិវិធីក្នុងការចោទប្រកាន់ខាងបទព្រហ្មទណ្ឌរបស់ព្រះរាជអាជ្ញា ដែលអាចបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាម ចំពោះមុខតុលាការជាន់ដំបូងដោយផ្ទាល់ និងត្រូវធ្វើឡើងតាមរយៈ កំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម។ នីតិវិធីនេះបញ្ញត្តិឡើងដើម្បីជម្រុញដល់ដំណើរការរឿងក្តីឲ្យបានឆាប់រហ័ស ជៀសវាងការកកស្ទះនូវសំណុំរឿងនៅក្នុងស្ថាប័នតុលាការ ក៏ដូចជាដើម្បីសម្រួល

---

[179] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៣៤៨

[180] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២៩១

[181] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៣០២

ដល់វិស័យយុត្តិធម៌នៅក្នុងតុលាការនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ ប៉ុន្តែ ពេលខ្លះមានការយល់ឃើញថាការធ្វើឱ្យឆាប់រហ័សពេកនៃសំណុំរឿង វាក៏បានធ្វើឱ្យប៉ះពាល់ទៅដល់សិទ្ធិរបស់ភាគីនៃរឿងក្តីដែរ។ ដូច្នេះហើយទើបក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ ចំពោះនីតិវិធីបង្ហាញខ្លួនភ្លាមនេះ ដែលអាចអនុវត្តទៅបាន លុះត្រាតែមានការបំពេញនូវលក្ខខណ្ឌមួយចំនួន ហើយដំណើរការប្រព្រឹត្តទៅត្រូវឱ្យស្របតាមនីតិវិធី និងឈានទៅដល់ការបង្កើតឱ្យមានអានុភាពមួយចំនួនផងដែរ។

### ១. លក្ខខណ្ឌ នៃការបង្ហាញខ្លួនភ្លាម

ប្រសិនបើមានគ្រប់លក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នោះព្រះរាជអាជ្ញាអាចជ្រើសរើសយកនូវការចោទប្រកាន់ តាមរយៈនីតិវិធីនៃការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមនៅ ចំពោះមុខតុលាការមានជាអាទិ៍[182]៖

- **បទល្មើសត្រូវតែជាបទល្មើសមជ្ឈិមជាក់ស្តែង**

បើពិនិត្យមើលមាត្រា ៤៧ ដដែលនេះ ត្រង់ចំណុចទី១ នេះច្បាប់ប្រើពាក្យថា បទល្មើសជាបទល្មើសជាក់ស្តែង ហើយបានចង្អុលបង្ហាញទៅមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង) ដែលបានចែងថា បទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង ជាបទល្មើសដែលកំពុងប្រព្រឹត្ត ទើបប្រព្រឹត្តរួចភ្លាម ឬ កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក។ ជនដែលគេសង្ស័យត្រូវបានសាធារណជន ស្រែកដេញប្រដាប់ចាប់ប្រកឹងបុគ្គលដែលត្រូវបានគេរកឃើញមានវត្ថុ ឬ ស្លាកស្នាម ឬ តម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឲ្យគេសន្និដ្ឋានបានថាបុគ្គលនោះបានប្រព្រឹត្ត ឬ ចូលរួមប្រព្រឹត្តបទល្មើស។[183] និងមាត្រា ៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង) ដែលបានចែងថា គឺត្រូវបានចាត់ទុកជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែងផងដែរ ទោះបីជាស្ថិតនៅក្រៅករណីដែលមានចែងក្នុងមាត្រា ៨៦ ខាងលើនេះក៏ដោយ ពោល គឺគ្រប់បទឧក្រិដ្ឋ ឬ បទមជ្ឈិមទាំងឡាយណា ដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះ។ ការស្នើសុំឲ្យព្រះរាជអាជ្ញា ឬ មន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬ ភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីនោះ។[184] ដូច្នេះ ក្រៅពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង ព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់តាមនីតិវីធីនេះបានឡើយ ដោយហេតុថា នីតិវិធីមួយនេះមិនអាចត្រូវយកអនុវត្តបានឡើយក្នុងករណីបទល្មើសនេះជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមមិនជាក់ស្តែង ឬ បទលហុ។ ក្នុងករណីចុងក្រោយនេះ ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌។

---

[182] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៧

[183] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៨៦

[184] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៨៨

**ការផ្តន្ទាទោស**

បទល្មើស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ ឆ្នាំ និងយ៉ាងច្រើន ៥ ឆ្នាំ។ ចិរវេលានៃការផ្តន្ទាទោសនេះ យើងត្រូវមើលទៅលើអតិបរមានៃទោសដែលបានចែងក្នុងច្បាប់។ បទមជ្ឈិមមានការផ្តន្ទាទោសជាអប្បបរមា ១(មួយ) ឆ្នាំ និងអតិបរមា ៥(ប្រាំ) ឆ្នាំ។

**ជនជាប់ចោទជានីតិជន**

មានន័យថា ការដែលជនជាប់ចោទត្រូវដល់នីតិភាព ដែលមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ដែលអាចទទួលខុសត្រូវព្រហ្មទណ្ឌបាន។ នីតិវិធីនៃការបង្ហាញខ្លួនភ្លាម គឺជានីតិវិធីមួយដែលការជំនុំជម្រះមានភាពឆាប់រហ័សជាងនីតិវិធីដទៃទៀត ហើយក្នុងនីតិវិធីនេះ តុលាការអាចសម្រេចឲ្យមានការឃុំខ្លួនបណ្តោះអាសន្នចំពោះជនជាប់ចោទផងដែរ។ ដូចនេះ យើងមិនអាចអនុវត្តនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាមទៅលើអនីតិជនបានទេ។ ពោល គឺដើម្បីជៀសវាងការប៉ះពាល់ដល់សិទ្ធិការពារ ការរំលោភសិទ្ធិសេរីភាព ផលប្រយោជន៍របស់អនីតិជន ដូចដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ទើបច្បាប់តម្រូវឲ្យអនុវត្តនីតិវិធីនេះ ចំពោះតែនីតិជនតែប៉ុណ្ណោះ។

**រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន**

ព្រះរាជអាជ្ញាត្រូវតែមានភស្តុតាង និងធាតុផ្សំគ្រប់គ្រាន់ដោយពុំមានការសង្ស័យ ឬ មូលហេតុធន់ល្មមក្នុងការដាក់បន្ទុកដើម្បីធ្វើការចោទប្រកាន់ ប្រសិនបើគ្មានបន្ទុកភស្តុតាងគ្រប់គ្រាន់ទេ ព្រះរាជអាជ្ញាមិនគួរធ្វើការចោទប្រកាន់តាមនីតិវិធីនេះទេ។ បើគ្មានភស្តុតាង ឬ ហេតុផលរឹងមាំសម្រាប់ដាក់បន្ទុកជនជាប់ចោទទេ នេះអាចជាឱកាសដល់ជនជាប់ចោទក្នុងករណី ដែលមានសេចក្តីសម្រេចស្ថាពរឲ្យជនជាប់ចោទរួចខ្លួន ជាហេតុនាំឲ្យព្រះរាជអាជ្ញាពុំអាចធ្វើការចោទប្រកាន់សារជាថ្មីបានដោយសារតែគោលការណ៍អាជ្ញាអស់ជំនុំ។

### ២. នីតិវិធី នៃការបង្ហាញខ្លួនភ្លាម

នៅក្នុងនីតិវិធីនៃការបង្ហាញខ្លួនភ្លាម គឺជានីតិវិធីមួយដែលមានលក្ខណៈខុសប្លែកពីនីតិវិធីទាំងពីរខាងលើដោយហេតុថា នីតិវិធីនេះមានចែងយ៉ាងច្បាស់នៅក្នុងច្បាប់។ យោងតាមបញ្ញត្តិនៃមាត្រា ៤៨ និងមាត្រា ៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌអាចកំណត់បាន ពីនីតិវិធីនៃការបង្ហាញខ្លួនភ្លាមជាពីរដំណាក់កាលគឺ នីតិវិធីក្នុងដំណាក់កាលព្រះរាជអាជ្ញា និងនីតិវិធីក្នុងដំណាក់កាលយុត្តាធិការ។[185]

#### ២.១. នីតិវិធីចាត់ការនៅចំពោះមុខព្រះរាជអាជ្ញា

ជាជំហានដំបូងគឺ ជនជាប់ចោទចាំបាច់ត្រូវតែជាជនដែលត្រូវបានឃាត់ខ្លួនតាមរយៈមាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ បន្ទាប់ពីផុតរយៈពេលឃាត់ខ្លួនក្រោមការវិនិច្ឆ័យចំពោះមាត្រានេះហើយ ចំពោះ

[185] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៨ និង ៣០៤

រយៈពេលឃាត់ខ្លួននេះព្រះរាជអាជ្ញាសម្រេចអោយដោះលែងវិញ ឬ ព្រះរាជអាជ្ញាសម្រេចឱ្យមានការបញ្ជូនខ្លួនជននោះមកចាត់ការតាមនីតិវិធី។[186] ក្នុងករណីដែលបញ្ជូនជននេះមកព្រះរាជអាជ្ញា ពោល គឺព្រះរាជអាជ្ញានឹងសម្រេចថាខ្លួននឹងត្រូវប្រើនីតិវិធីណាមួយសម្រាប់ចោទប្រកាន់ទៅលើជននោះ។[187] ក្នុងករណីដែលបំពេញលក្ខខណ្ឌគ្រប់គ្រាន់ដែលអាចប្រើការបង្ហាញខ្លួនភ្លាមនេះព្រះរាជអាជ្ញានឹងធ្វើដូចតទៅៈ

- **ពិនិត្យអត្តសញ្ញាណរបស់ជនដែលត្រូវបានបញ្ជូនមក**

ការធ្វើនេះដើម្បីសម្គាល់ថានរណាជាជនល្មើស ហើយជននោះមានអត្តសញ្ញាណ ដូចអ្វីដែលកំណត់ហេតុបានកត់ត្រានោះដែរ ឬទេ។

- **ត្រូវឲ្យដំណឹងដល់ជននោះអំពីរឿងហេតុដែលចោទប្រកាន់ និងឈ្មោះបទល្មើស**

ការទទួលយកបែបនេះ ព្រោះវាជាសិទ្ធិរបស់ជនជាប់ចោទក្នុងការដឹងលឺ អំពីមូលហេតុដែលគេចោទប្រកាន់មកខ្លួនហើយថាជាបទអ្វី ដែលនេះជាស្មារតីលើការទទួលស្គាល់សិទ្ធិមនុស្សរបស់ប្រទេសកម្ពុជា។

- **ទទួលចម្លើយរបស់បុគ្គលនោះប្រសិនសាមីខ្លួនចង់និយាយ**

នេះក៏ជាសិទ្ធិសេរីភាព របស់ជនជាប់ចោទលើការអះអាងគ្រប់បែបយ៉ាង។ ដោយលើកយកព័ត៌មានគ្រប់យ៉ាងដែលខ្លួនបានដឹង ដើម្បីជាផលប្រយោជន៍របស់ខ្លួននៅក្នុងសំណុំរឿង។

- **ធ្វើកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម**

ដើម្បីជាការចោទប្រកាន់ទៅតុលាការ ព្រះអាជ្ញាត្រូវចេញកំណត់ហេតុស្តីពីការបង្គាប់អោយចូលបង្ហាញខ្លួនភ្លាមរួចបញ្ជូនទៅតុលាការជាន់ដំបូងដើម្បីចាត់តាំងចៅក្រមជំនុំជម្រះ (ដោយប្រធានតុលាការ) ក្នុងការបើកសវនាការ។ ក្នុងកំណត់ហេតុនេះ ចាំបាច់ត្រូវតែមានការចែងនូវចំណុច ដែលព្រះរាជអាជ្ញាបានប្រាប់ជនជាប់ចោទអំពីសិទ្ធិក្នុងការពឹងពាក់មេធាវី ដែលអាចជ្រើសរើសដោយខ្លួនឯងបាន ឬ ចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ ក្នុងករណីនេះមេធាវីត្រូវទទួលដំណឹងភ្លាម ដើម្បីទទួលស្គាល់នូវសិទ្ធិ និងមានរយៈគ្រប់គ្រាន់ដើម្បីការពារខ្លួនរបស់ជនជាប់ចោទ។

ទម្រង់ការដែលរៀបរាប់ខាងលើ ត្រូវតែកត់ចូលកំណត់ហេតុ បើមិនដូចនេះទេនីតិវិធីត្រូវទុកជាមោឃៈ។ នៅពេលដល់កំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមត្រូវបានធ្វើចប់សព្វគ្រប់រួចហើយ ជនជាប់ចោទនឹងត្រូវបានបង្ខាំងទុកដោយកងកម្លាំងការពារ និងបញ្ជូនជននោះ ព្រមទាំងសំណុំរឿងនៅចំពោះមុខតុលាការដែលត្រូវបើកសវនាការនៅថ្ងៃនោះតែម្តង។[188]

---

[186] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១០៣

[187] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៩៦

[188] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៨ កថាខណ្ឌទី ៦

## ២.២. នីតិវិធីចាត់ការនៅចំពោះមុខយុត្តាធិការជំនុំជម្រះ

បន្ទាប់ពីតុលាការជាន់ដំបូងទទួលបណ្តឹង តាមរយៈកំណត់ហេតុស្តីពីការបង្គាប់ឲ្យបង្ហាញខ្លួនភ្លាមៗ តុលាការនឹងផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជនជាប់ចោទឲ្យច្បាស់លាស់ ត្រឹមត្រូវ និងធ្វើរបាយការណ៍សង្ខេបអំពីអង្គហេតុដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់។ តុលាការប្រាប់ដល់ជនជាប់ចោទថា ខ្លួនអាចមានរយៈពេលដើម្បីរៀបចំសម្រាប់ការពារខ្លួនបាន។[189] ក្នុងករណីដែលជននោះសុំរយៈពេលការពារខ្លួន ដោយយល់ឃើញថារយៈពេលដែលបានកំណត់នោះ ពុំគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួននោះទេ គឺអាចសុំរយៈពេលបន្ថែមបាន ឬតុលាការយល់ឃើញថារឿងក្តីនោះមិនអាចទាន់ជំនុំជម្រះបានទេ ដោយសារមានសាលក្រមសំអាងហេតុ ដូច្នេះតុលាការអាចលើកទៅជំនុំជម្រះនៅពេលក្រោយបាន។ ហេតុដែលត្រូវសំអាងនេះ គឺជាមូលហេតុដែលតុលាការអាចធ្វើការបង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្នបានផងដែរ។ ដូចបានចែង និងកំណត់ក្នុងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ដូចតទៅ[190]៖

- ដើម្បីបញ្ចប់បទល្មើស ឬ បង្ការបទល្មើសកុំឲ្យកើតជាថ្មី
- ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬ ជនរងគ្រោះ ឬ ដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត
- ដើម្បីរក្សាភស្តុតាង ឬ តម្រុយជាសម្ភារៈ
- ដើម្បីរក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធីច្បាប់
- ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ
- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំអោយមានភាពច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។

យោងតាមមាត្រា ២២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា "តុលាការទាមទារក្នុងការចេញដីកាបង្គាប់ឲ្យឃុំខ្លួន ព្រោះថាដីកាសម្រេចពីការឃុំខ្លួនបណ្តោះអាសន្នមានអានុភាព តែទៅលើជនជាប់ចោទនេះតែប៉ុណ្ណោះ។ ឯដីកាបង្គាប់ឲ្យឃុំខ្លួន មានអានុភាពជាការបញ្ជាដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនឲ្យទទួលយក និងឲ្យឃុំខ្លួនជននោះផងទៀត។[191] សាលក្រមលើសេចក្តី ត្រូវតែប្រកាសក្នុងរយៈពេលដែលមិនអាចលើសពី ២សប្តាហ៍ គិតពីពេលបង្ហាញខ្លួននៅចំពោះមុខតុលាការ។ ការឃុំខ្លួនបណ្តោះអាសន្ន ត្រូវបញ្ចប់ដោយពេញច្បាប់ក្រោយផុតរយៈពេលនេះ។ មានន័យថា ជនជាប់ចោទនឹងត្រូវដោះលែងឲ្យមានសេរីភាព ព្រោះវិធាននៃការឃុំខ្លួនបណ្តោះអាសន្ន ជាវិធានការដែលបំពានដល់សិទ្ធិសេរីភាពរបស់មនុស្សយ៉ាងខ្លាំង ហើយម្យ៉ាងទៀតជន

[189] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤៨

[190] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២០៥

[191] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ២២០

នេះមិនទាន់ត្រូវផ្តន្ទាទោសដោយតុលាការទេ។ ប្រសិនបើតុលាការយល់ឃើញថាលក្ខខណ្ឌ នៃការបង្ហាញខ្លួនភ្លាម ដោយមានចែងនៅក្នុងមាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មិនត្រូវបានបំពេញទេ ឬ ក៏ដោយសារមានភាពសាំញ៉ាំ នៃសំណុំរឿង ដែលតម្រូវឱ្យធ្វើការស្រាវជ្រាវបន្ថែម តុលាការត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីបើកការស៊ើបសួរ។ ខណៈនោះជនជាប់ចោទត្រូវទៅបង្ហាញខ្លួននៅថ្ងៃនោះតែម្តង ដោយនៅចំពោះមុខចៅក្រមស៊ើបសួរ បើពុំដូច្នោះទេជនជាប់ចោទត្រូវតែដោះលែងឱ្យមានសេរីភាពវិញដោយឯកឯង។

ការឃុំខ្លួននៃនីតិវិធីនេះ ទាមទារអោយមាននូវរយៈពេលកំណត់មួយដែរ ព្រោះដើម្បីធានាថាមិនមានការបំពានណាមួយហួសហេតុទៅដល់សេរីភាពរបស់ជននោះ ទោះដោយសារការជំនុំជម្រះយឺតយ៉ាវក៏ដោយ។

### ៣. អានុភាព នៃការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម

ប្រសិនបើព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់តាមនីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ដែលជានីតិវិធីចោទប្រកាន់ដែលស្តែងឡើងដោយកំណត់ហេតុ ឬ ស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមនេះ នោះកំណត់ហេតុនេះនិងកើតមានឡើងនូវអានុភាពដូចតទៅះ

- **ការផ្តាច់អាជ្ញាយុការនៃបទល្មើស**

ការចេញកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមដោយព្រះរាជអាជ្ញា គឺជាកិច្ចចោទប្រកាន់ជនល្មើស។ ដោយកិច្ចចោទប្រកាន់មានអានុភាពផ្តាច់អាជ្ញាយុកាលនៃបទល្មើសព្រហ្មទណ្ឌ មូលហេតុដែលនាំឲ្យមានការផ្តាច់អាជ្ញាយុកាល គឺដូចនឹងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដែរ ដោយចាប់ផ្តើមគិតពីថិរវេលាថ្មីនៃអាជ្ញាយុកាល។

- **ការផ្ទេរសមត្ថកិច្ចទៅតុលាការ**

ជាការផ្ទេរសមត្ថកិច្ចពីអយ្យការ អ្នកយុត្តាធិការជំនុំជម្រះតាមរយៈ កំណត់ហេតុស្តីពីការបង្គាប់ចូលបង្ហាញខ្លួនភ្លាមរបស់ព្រះរាជអាជ្ញា។ តុលាការនឹងគ្មានសមត្ថកិច្ចលើការជំនុំជម្រះលើរឿងក្តីនោះទេ ប្រសិនបើមិនមានកិច្ច ឬ បណ្តឹងចោទប្រកាន់ប្រគល់មកខ្លួន។ ពោល គឺសមត្ថកិច្ចត្រូវបានផ្ទេរមកយុត្តាធិការជំនុំជម្រះតែម្តងដោយពុំឆ្លងកាត់យុត្តាធិការស៊ើបសួរឡើយ។

- **ចំណងតុលាការចំពោះដែនបណ្តឹង ចំពោះអង្គហេតុ និងបុគ្គល**

(**ការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុ និងជនជាប់ចោទ**)

កំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមរបស់ព្រះរាជអាជ្ញា គឺមានការកំណត់អំពីអង្គហេតុ និងពីបុគ្គលដែលព្រះរាជអាជ្ញាចង់ធ្វើការចោទប្រកាន់ទៅលើ។ តុលាការអាចជំនុំជម្រះបានតែលើអង្គហេតុណាដែលមានចែងក្នុងកំណត់ហេតុ និងបុគ្គលដែលបានកំណត់ស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ហើយអាចជំនុំជម្រះតែលើជនណាដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់តែប៉ុណ្ណោះ ។ ប្រសិនបើបុគ្គលណា ដែលកោះហៅ

ឱ្យចូលទៅចំពោះមុខតុលាការក្នុងឋានៈជាសាក្សី អាចត្រូវចោទប្រកាន់ក្នុងឋានៈជាជនដៃដល់ ឬ អ្នកសមគំនិត បុគ្គលនោះនឹងអាចត្រូវជំនុំជម្រះបានក្រោយពីត្រូវបានចោទប្រកាន់។[192]

# ផ្នែកទី២៖ បញ្ហាប្រឈម និងដំណោះស្រាយនៅក្នុងកិច្ចចោទប្រកាន់

## កថាខណ្ឌទី១៖ បញ្ហាប្រឈម

### ១. ភាពខ្វះចន្លោះនៃច្បាប់

ភាពខ្វះចន្លោះនៃច្បាប់ពោល គឺសំដៅទៅដល់ការកើតមានឡើងនូវបទល្មើសថ្មីៗ ដោយស្តែងឡើងនិងបង្កអោយមានព្យសនកម្មធ្ងន់ធ្ងរដែលប៉ះពាល់ទៅដល់សង្គម តែពុំទាន់មានច្បាប់ចែង ឬ មានហើយតែពុំបានយកមកធ្វើការអនុវត្តនោះឡើយ ឬ បានយកមកអនុវត្តដែរ តែការអនុវត្តនោះហួសព្រំដែន ដែលច្បាប់បានកម្រិតចែង។ យោងទៅតាម អនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌ឆ្នាំ ២០២២ នេះយើងឃើញមានការបញ្ញត្តិស្តីអំពីការត្រួតពិនិត្យលើកិច្ចការអយ្យការ កិច្ចការព្រហ្មទណ្ឌ កិច្ចការស្រាវជ្រាវ កិច្ចស៊ើបអង្កេត កិច្ចការងារគ្រប់គ្រងវត្ថុតាងនិងផលនៃបទល្មើស ព្រមទាំង រៀបចំយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍ការងារបច្ចេកទេសនៃវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ដោយនាយកដ្ឋានកិច្ចការអយ្យការនិងព្រហ្មទណ្ឌ។ ហើយនៅអនុក្រឹត្យដដែលនេះ យើងក៏ឃើញមានបញ្ញត្តិនៃការបង្កើតឡើងនូវអង្គភាពមួយ គឺនាយកដ្ឋានកិច្ចការអយ្យការទទួលបន្ទុកសម្របសម្រួល តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីអំពីការអនុវត្តមុខងារសិទ្ធិអំណាច និងសកម្មភាពអនុវត្តច្បាប់របស់អង្គការគ្រប់ជាន់ថ្នាក់។[193]

### ២. ការពុំមានភស្តុតាង និងសាក្សីច្បាស់លាស់

ការជំនុំជម្រះក្តីនៅក្នុងតុលាការ ចំពោះរឿងក្តីណាមួយ គឺភស្តុតាងជាអង្គសំខាន់នៅក្នុងការអំណះអំណាង ដែលបញ្ជាក់ពីមូលហេតុនៅក្នុងការដោះ ឬ ដាក់បន្ទុកជនណាម្នាក់ ប៉ុន្តែមានធាតុផ្សំសំខាន់ដែរនោះគឺសាក្សី។

បើភស្តុតាងដែលប្រមូលបាន មានលក្ខណៈមិនច្បាស់លាស់ ឬ មានមិនគ្រប់គ្រាន់ គឺមិនអាចយកជាការបានទេសម្រាប់យកជាអំណះអំណាងនៅក្នុងការចោទប្រកាន់ ថាបុគ្គលនោះពិតជាបានប្រព្រឹត្តនូវបទល្មើសនោះមែន។ ចំណែកឯកសារសំអាងត្រូវដាក់ធ្វើជាភស្តុតាង មានការកោសលុប ឬ ពុំមានឯកសារច្បាប់ដើម ឬ មិនមានការទទួលស្គាល់ ពីស្ថាប័នជំនាញក្នុងការត្រួតពិនិត្យ ថាឯកសារសំអាងនោះពិតជាមិនក្លែងក្លាយពិតមែន។

[192] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៣៤៨ និង ៣៤៩

[193] អនុក្រឹត្យស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌ លេខ១៣០ អនក្រ.បក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២ មាត្រា២៦ និង ២៧

ប៉ុន្តែព្រះរាជអាជ្ញានៅតែធ្វើការចោទប្រកាន់តាមរយៈឯកសារ ឬ ក្រោមរូបភាពដែលពុំច្បាស់លាស់នោះ។ ម្យ៉ាងទៀតនៅក្នុងលក្ខខណ្ឌ ដែលបុគ្គលជាសាក្សីបានផ្តល់ចម្លើយមិនច្បាស់លាស់ដោយសារស្ថានភាពអាយុ ឬការទទួលរងនូវការគំរាមកំហែង ឬ សកម្មភាពផ្សេងៗទៀតដែលសាក្សីកំពុងទទួលរង និងថាតើសាក្សីនោះពិតជាបានស្ថិតនៅក្នុងហេតុការណ៍ដែលបានកើតឡើងនោះពិតមែនដែរ ឬទេ?

**ឧទាហរណ៍៖** ការសូកប៉ាន់សាក្សី (សវនាការមន្ត្រីអាដហុកត្រូវលើកព្រោះខ្វះសាក្សីសំខាន់) បន្ទាប់ពីការកោះហៅអតីតមន្ត្រីអាដហុក និងសាក្សីមន្ត្រីអាដហុកវ័យចំណាស់ចំនួន៥រូប ដែលត្រូវបានតុលាការកម្ពុជាចោទប្រកាន់ថាបានសូកប៉ាន់ និងសមគំនិតសូកប៉ាន់សាក្សី អំឡុងពេលពួកគេបំពេញការងារមន្ត្រីសិទ្ធិមនុស្ស។

### ៣. ការបំពាននៅលើគោលការណ៍អនាគតិ

ច្បាស់ណាស់ថានៅក្នុងកិច្ចបំពេញនូវកិច្ចការធ្វើមួយ ពោល គឺត្រូវគោរពទៅតាមបញ្ញត្តិដោយពុំអាចមាននូវភាពលំអៀងណាមួយកើតមាននោះទេ ដែលទាំងនេះ គឺជាការបង្កអោយមាននូវភាពអយុត្តិធម៌ដែលអាចកើតមានឡើងផងដែរ។ ហេតុដូច្នេះ ហើយទើបច្បាប់បានបញ្ញត្តិឡើងនូវច្បាប់ក្រមសីលធម៌ចៅក្រម ដែលច្បាប់នេះអនុវត្តចំពោះចៅក្រម និងព្រះរាជអាជ្ញាផងដែរ នៅរាល់ការបំពេញនៅកិច្ចរបស់ខ្លួន។ ពោល គឺត្រូវជៀសវាងនូវអគតិទាំង ៤ គឺ៖ ឆន្ទាគតិ ទោសាគតិ ភយាគតិ និងមោហាគតិ។[194]

- ឆន្ទាគតិ (ភាពមិនលំអៀងព្រោះស្រឡាញ់)
- ទោសាគតិ (ភាពមិនលំអៀងព្រោះទោសៈ ឬស្អប់)
- ភយាគតិ (ភាពមិនលំអៀងព្រោះភ័យខ្លាច)
- មោហាគតិ (ភាពមិនលំអៀងព្រោះមោហៈ ល្ងង់ និងអវិជ្ជា)

### ៤.ខ្វះធនធានមនុស្សដែលមានចំណេះជំនាញ និងការយល់ដឹងរបស់មន្ត្រីអនុវត្តន៍ច្បាប់នៅមានកម្រិត

នៅក្នុងកិច្ចនៃការបំពេញមុខងារនៅក្នុងរឿក្តីអ្វីមួយ គឺត្រូវធ្វើឡើងដោយមានភាពត្រឹមត្រូវ និងច្បាស់លាស់ ទន្ទឹមនិងមានភាពត្រឹមត្រូវនិងច្បាស់នេះផងដែរ គឺយើងត្រូវការនូវធនធានមនុស្សដែលមានចំណេះដឹងភាពប៉ិនប្រសប់យល់ដឹងទៅនិងច្បាប់ និងដំណើរនីតិវិធីនៅក្នុងការអនុវត្តច្បាប់ ដើម្បីឲ្យមានរលូនច្បាស់លាស់ត្រឹមត្រូវទើបប្រព្រឹត្តទៅបានល្អប្រសើរ។

ការយល់ដឹងរបស់មន្ត្រីដែលអនុវត្តច្បាប់ គឺជាកត្តាមួយដែលសំខាន់នៅក្នុងដំណើរ នៃការប្រព្រឹត្តទៅនៃនីតិវិធីក្នុងរឿងក្តីផងដែរ ជាពិសេសព្រះរាជអាជ្ញាដែលដើរតួនាទីយ៉ាងសំខាន់ ដើម្បីធានាដល់ការអនុវត្តនៅក្នុង

[194] ក្រមសីលធម៌ចៅក្រមអនុម័តដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមថ្ងៃទី០៥ខែកុម្ភៈឆ្នាំ២០០៧ដែលបោះពុម្ពផ្សព្វផ្សាយ ដោយតុលាការកំពូល

សំណុំរឿងដល់ការអនុវត្តសាលក្រមស្ថាពរ ឬ ដីកាសម្រេចនានារបស់ស្ថាប័នអយ្យការ ដោយស្របទៅតាមវិជ្ជាជីវៈនិងការហ្វឹកហ្វឺនផ្នែកច្បាប់ ព្រមទាំងគោរពបាននូវគោលការណ៍ បញ្ញត្តិច្បាប់ និងក្រមសីលធម៌ដែលច្បាប់បានកំណត់។ ប៉ុន្តែ ផ្ទុយមកវិញនៅតែមានព្រះរាជអាជ្ញាមួយចំនួនដែលខ្វះនូវសមត្ថភាព និងចំណេះជំនាញច្បាស់លាស់នៅក្នុងការអនុវត្តនូវវិជ្ជាជីវៈរបស់ខ្លួន តួយ៉ាងដូចជាករណីដែលព្រះរាជអាជ្ញារង ចេញកម្មសិក្សា ឬទើបតាំងស៊ុបដែលចុះអនុវត្តជាក់ស្តែងដំបូងៗ ដែលខ្វះនូវបទពិសោធន៍ ធ្វើអោយការអនុវត្តផ្ទុយពីច្បាប់ដោយសារតែខ្លួននៅមានកម្រិតនៅក្នុងការអនុវត្តផ្ទាល់។ ចំពោះមន្ត្រីដែរអនុវត្តនានាដូចជា មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តធម៌ មន្ត្រីរាជការ មន្ត្រីពន្ធនាគារ និងភ្នាក់ងារសាធារណៈមួយចំនួនទៀត ដែលការអនុវត្តនៅមានកម្រិត។

### ៥. ការអនុវត្តនីតិវិធី និងការបញ្ជូនដីកាដោះលែងមានភាពយឺតយ៉ាវ

ដោយហេតុថា អយ្យការបញ្ជូនសុំណុំរឿងយឺតយ៉ាវមិនបានកោះហៅសាក្សី ឬ ភាគីមកបំពេញកិច្ចក្នុងនីតិវិធីដោយមិនបានអនុវត្តទៅតាមគោលការណ៍ច្បាប់ (ពេលវេលា) មានភាពមិនត្រឹមត្រូវទៅលើការតម្កល់រឿងទុកឥតចាត់ការ ដែលបណ្តាលឲ្យមានការកកស្ទះនូវសំណុំរឿងច្រើនពេកនៅតុលាការ ការបញ្ជូនដីកា និង ការផ្សព្វផ្សាយលើដីកាសម្រេចឲ្យដោះលែងតាមរយៈសេចក្តីសម្រេចរបស់សាលក្រម ឬ សាលដីកាសម្រេចដាក់ជនជាប់ចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងសេចក្តីសម្រេចនានារបស់តុលាការ ដែលនេះពាក់ព័ន្ធជាមួយមន្ត្រីទទួលបន្ទុកកិច្ចការរបស់ព្រះរាជអាជ្ញា ដែលត្រូវបញ្ជូនទៅពន្ធនាគារមានភាពយឺតយ៉ាវ ឬ គ្មានឆន្ទៈធ្វើការងារ ឬ ជួបឧបសគ្គ ឬ ត្រូវរាំងស្ទះដោយករណីប្រធានសក្តិណាមួយ ទើបបណ្តាលឲ្យមានការអាក់ខាននូវការដោះលែងទណ្ឌិត ឬ អ្នកជាប់ឃុំ ដែលកត្តាទាំងនេះផងដែរបានធ្វើឲ្យមានការអូសបន្លាយពេលវេលានៅក្នុងការដោះលែង និងការអនុវត្តនៅក្នុងនីតិវិធីនានា។

### ៦. ការរត់គេចខ្លួនរបស់ទណ្ឌិត ឬពិរុទ្ធជន

ការរត់គេចខ្លួនរបស់ទណ្ឌិត ឬ ពិរុទ្ធជន គឺសំដៅដល់ការមិនសហការរវាងព្រះរាជអាជ្ញា ជាមួយនិងមន្ត្រីនៃស្ថាប័នពាក់ព័ន្ធ ជាពិសេស មន្ត្រីនគរបាលយុត្តិធម៌នៅពេលតុលាការប្រកាសសាលក្រមផ្តន្ទាទោសជនជាប់ចោទ ឬ ចេញដីកាបង្គាប់អោយចាប់ខ្លួនតែជនល្មើសនោះបានរត់គេចខ្លួន ឬ ស្ថិតនៅក្រៅឃុំ (មិនទាន់រត់គេច) ដោយបានដឹងអំពីការសម្រេចសេចក្តីនេះមុន ដែលជាហេតុនាំឲ្យទណ្ឌិត ឬ ពិរុទ្ធជនជាជនដែលបានប្រព្រឹត្តបទល្មើសនេះរត់គេចខ្លួនបាត់ទៅ ទើបមិនអាចអនុវត្តទណ្ឌកម្មនៃការប្រព្រឹត្តបទល្មើសបាន។ ដោយហេតុថា ព្រះរាជអាជ្ញាធ្វើការបង្គាប់ទៅមន្ត្រីនគរបាលយុត្តិធម៌ឲ្យអនុវត្ត តែការអនុវត្តនេះមានភាពយឺតយ៉ាវទើបធ្វើអោយមិនមានប្រសិទ្ធិភាព ដែលអាចធ្វើអោយជនជាប់ចោទរត់គេចខ្លួនចេញក្រៅប្រទេស ឬ លាក់ខ្លួនជាសំងាត់គេចផុតពីសំណាញ់ច្បាប់។

## ៧. ការអន្តរាគមន៍របស់អ្នកមានអំណាច និងកត្តានយោបាយ

តំណាងអយ្យការ គឺជាម្ចាស់នៃបណ្តឹងអាជ្ញាដែលច្បាប់បានកំណត់ និងឲ្យសិទ្ធិអំណាចក្នុងការការពារផលប្រយោជន៍ជាសាធារណៈ។ ប៉ុន្តែដោយការអនុវត្តច្បាប់មួយចំនួន យើងឃើញមានការប្រឈមពាក់ព័ន្ធនឹងការអន្តរាគមន៍របស់អ្នកមានអំណាច នៅក្នុងដំណើរការនៃនីតិវិធីរបស់តុលាការ ដែលជាហេតុនាំឲ្យមានការលំបាកនៅក្នុងការអនុវត្តច្បាប់របស់មន្ត្រីអនុវត្តច្បាប់។

បញ្ហាប្រឈមរបស់តំណាងអយ្យការ នៅក្នុងនីតិវិធីនៃការចោទប្រកាន់ដោយមានការអន្តរាគមន៍របស់អ្នកមានអំណាចមានដូចជាៈ

១. ធាតុផ្សំនៃបទល្មើសមិនគ្រប់គ្រាន់ តែតំណាងអយ្យការធ្វើការចោទប្រកាន់ ដោយតាមការចង្អុលបង្ហាញរបស់អ្នកមានអំណាចមួយចំនួនទៅដល់ជនណាម្នាក់ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន។ ប្រយោជន៍ផ្ទាល់ខ្លួនរបស់អ្នកមានអំណាចទាំងអស់នេះទៀតសោត គឺកើតឡើងដោយការគុំគួន និង កំហឹង ឬ មានបំណងចង់ធ្វើបាបជនណាម្នាក់ ដែលនិយាយប៉ះពាល់ ឬបានធ្វើអ្វីមួយដែលនាំឲ្យខាតបង់ប្រយោជន៍ខ្លួន។ ត្រង់ចំណុចនេះធ្វើឲ្យព្រះរាជអាជ្ញាមានការពិបាកក្នុងការចោទប្រកាន់ ដែលខុសពីបញ្ញត្តិនៃច្បាប់ចែង និងជាពិសេស គឺខុសពីសតិសម្បជញ្ញៈរបស់ខ្លួនទៀតផង។

២. ធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ តែតំណាងអយ្យការមិនធ្វើការចោទប្រកាន់ ដោយហេតុថាមានការអន្តរាគមន៍ពីសំណាក់អ្នកមានអំណាច ដែលនាំឲ្យមានការខូចប្រយោជន៍សាធារណៈ ជាការពិតជាក់ស្តែងនៅក្នុងសង្គមរស់នៅសព្វថ្ងៃមនុស្សភាគច្រើន គឺស្រឡាញ់នូវអំណាច បុណ្យសក្តិ និង ទ្រព្យសម្បត្តិរបស់ខ្លួន ដែលជនទាំងអស់នោះហើយ នៅពេលដែលមានការប្រព្រឹត្តនៅទោសកំហុសអ្វីមួយដែលខុសពីច្បាប់ និយាយរួមគឺប្រព្រឹត្តនូវបទល្មើសណាមួយដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជណាចក្រកម្ពុជា គឺរមែងតែប្រើប្រាស់នូវអំណាច និង ទឹកប្រាក់របស់ខ្លួនមកធ្វើការសង្កត់លើឆន្ទានុសិទ្ធិក្នុងការចោទប្រកាន់របស់ព្រះរាជអាជ្ញា។

ក្រៅពីបញ្ហាប្រឈម ដែលកើតចេញឡើងដោយការអន្តរាគមន៍ពីអ្នកមានអំណាចនោះ យើងក៏មានកត្តានយោបាយ ដែលជាកត្តាចម្បងមួយទៀត និងមានការពិបាកជាងកត្តាផ្សេងៗខាងលើទៅទៀត។ ទោះបីនៅក្នុងប្រទេសកម្ពុជាមានច្បាប់គ្រប់គ្រាន់ សម្រាប់ដាក់ឲ្យអនុវត្តយ៉ាងណាក៏ដោយ កត្តានយោបាយនៅតែជាកត្តាមួយយ៉ាងសំខាន់ដែលអាចធ្វើអោយមានការប្រែប្រួលនៃការអនុវត្តច្បាប់។ ដោយហេតុថា នៅពេលដែលមានចុងចម្លើយជាសកម្មជននយោបាយ ព្រះរាជអាជ្ញាត្រូវធ្វើការពិនិត្យមើលពីធាតុផ្សំនៃបទល្មើស ការប្រព្រឹត្ត និងការស៊ើបសួរទៅលើអង្គហេតុឲ្យបានច្បាស់លាស់។ ជាពិសេសទៅទៀត គឺត្រូវធ្វើការពិនិត្យទៅលើភស្តុតាងដែលប្រមូលបានឲ្យបានច្បាស់លាស់មុននឹងធ្វើការចោទប្រកាន់ជននោះ។ បន្ថែមពីនេះទៅទៀត នៅក្នុងការចោទប្រកាន់នូវសំណុំរឿងដែលទាក់ទងទៅនឹងនយោបាយ ព្រះរាជអាជ្ញាត្រូវធ្វើការផ្ចិតផ្ចង់ពិនិត្យនូវទម្រង់ អក្ខរាវិរុទ្ធ

ចំណុចផ្សេងៗទៀតនៃដីកានីមួយៗឲ្យបានហ្មត់ចត់។ ផលវិបាកចម្បងទៅលើការពិនិត្យនូវឯកសារផ្សេងៗខាងលើ និងក្នុងការបំពេញនូវកិច្ចផ្សេងៗនោះ គឺការចោទប្រកាន់របស់ព្រះរាជអាជ្ញាខ្លះគាត់អាចនឹងពិបាក និងមានភាពតានតឹងក្នុងការចោទៅលើជននោះពីបទល្មើសណាមួយដែលជននោះបានប្រព្រឹត្តជាជាក់ស្តែង។

### ៨. កត្តាខ្វះខាតនូវសម្ភារបច្ចេកទេស និងសម្ភារផ្សេងៗក្នុងការបំពេញមុខងារ

ដោយយល់ឃើញថា កត្តាខ្វះខាតទៅលើផ្នែកសម្ភារបច្ចេកទេសនានានេះ ជាកត្តាសំខាន់មួយផងដែរដែលនាំអោយមានការអាកខាត ឬក៏អនុវត្តនូវកិច្ចនោះពុំបានល្អប្រសើរ ឬមិនមានភាពរលូននៃនីតិវិធីផងដែរ។ ដោយនេះជាផ្នែកមួយដែលចាំបាច់នូវក្នុងកិច្ចនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា ក្នុងករណីដែលការបំពេញនូវកិច្ចការនេះមិនបានល្អ មិនមានភាពត្រឹមត្រូវ និងមិនច្បាស់លាស់នោះទេ ពោល គឺធ្វើអោយព្រះរាជអាជ្ញានិងទទួលបាននូវព័ត៌មានមិនពិត ឬ ខ្វះចន្លោះនូវព័ត៌មានដែលជាហេតុបណ្តាលអោយកើតជាបញ្ហាប្រឈម ដែលអាចកើតមានឡើងក្នុងការអនុវត្តនីតិវិធី។ ព្រោះ កត្តាសម្ភារៈនេះជាចំណែកសំខាន់មួយដែលនៅក្នុងកិច្ចការស៊ើបអង្កេត ដែលព្រះរាជអាជ្ញាត្រូវចាត់មន្ត្រីដែលមានសមត្ថកិច្ចឲ្យធ្វើការពិនិត្យ ឬ ដោយតាមរយៈការចុះទៅដោយផ្ទាល់របស់ព្រះរាជអាជ្ញានៅក្នុងការបំពេញនៃកិច្ចនោះ។ ដូច្នេះ សម្ភារៈទាំងអស់នេះគឺជាកត្តាសំខាន់សម្រាប់ធ្វើការស្វែងរកភស្តុតាងដូចជា៖ ទៅលើការពិនិត្យ DNA ការធ្វើកោសលវិច័យ ការស្រាវជ្រាវ និងរុករកនូវបទល្មើសដែលធំៗ ឬបទល្មើសដែលមានភាពស្មុគស្មាញជាដើម។ ដែលនាំឲ្យព្រះរាជអាជ្ញាទទួលបាននៅភស្តុតាង ឬព័ត៌មានលម្អិត ច្បាស់លាស់ និងត្រឹមត្រូវ ដើម្បីធ្វើការចោទប្រកាន់ទទួលបាននូវភាពត្រឹមត្រូវ សុក្រឹត្យ និងយុត្តិធម៌ផងដែរ។ កត្តានៃការកង្វះខាតផ្នែកសម្ភារៈនេះផងដែរ ដែលជាផ្នែកមួយធ្វើអោយព្រះរាជអាជ្ញាពិបាកនៅក្នុងការស្វែងរកនូវភស្តុតាងនានាអោយបានគ្រប់គ្រាន់សម្រាប់ធ្វើការដាក់បន្ទុក ឬដោះបន្ទុកជននោះផងដែរ។

## កថាខណ្ឌទី២៖ ដំណោះស្រាយ

### ១. ការបង្កើតលិខិតបទដ្ឋានគតិយុត្ត

ដើម្បីធ្វើការដោះស្រាយនូវចំណុចខ្វះខាតនៃច្បាប់ រដ្ឋាភិបាលគួរតែមានការគិតគូរ និងយកចិត្តទុកដាក់ឲ្យបានហ្មត់ចត់អំពីបញ្ហាច្បាប់ផ្សេងៗដែលទាក់ទងនឹងព្រះរាជអាជ្ញា ព្រោះយើងបានដឹងហើយថាព្រះអាជ្ញា គឺជាតួអង្គដ៏សំខាន់នៅក្នុងដំណើរការនៃរឿងក្តីព្រហ្មទណ្ឌ ប្រសិនបើច្បាប់មានភាពទន់ខ្សោយ ឬ អសកម្មមិនអាចផ្តល់អំណាចទៅដល់ការអនុវត្តតួនាទីរបស់ព្រះរាជអាជ្ញាបាននោះទេ គឺអាចបណ្តាលឲ្យស្ថាប័នមួយនេះមានភាពលំអៀង និងអយុត្តិធម៌ចំពោះជនដែលទន់ខ្សោយ។ ដូច្នេះហើយ រដ្ឋាភិបាល ក្រសួងយុត្តិធម៌ និងស្ថាប័ននីតិបញ្ញត្តិគួរតែបង្កើតនូវលិខិតបទដ្ឋានគតិយុត្ត ឬ ច្បាប់ពិសេសបន្ថែមទៀត និងគួរតែវិសោធនកម្មទៅលើភាពខ្វះចន្លោះនៃច្បាប់ ដើម្បីពង្រឹងការអនុវត្តច្បាប់ឲ្យមានភាពរឹងមាំនិងរិតបន្តឹងអ្នកអនុវត្តច្បាប់ឲ្យខ្លាំង ព្រមទាំងចងក្រង

នីតិវិធីដែលនៅស្ទើរ ឬខ្វះខាត និងខ្វះចន្លោះ ដោយបំពេញបន្ថែមអោយមានភាពគ្រប់គ្រាន់សម្រាប់អនុវត្តតាមយ៉ាងម៉ឹងម៉ាត់បំផុត។

ជាក់ស្តែងដូចមាននៅក្នុងអនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌ ឆ្នាំ២០២២ បានបញ្ញត្តិអំពីនាយកដ្ឋានកិច្ចការអយ្យការអាចចូលរួមរៀបចំកសាងសេចក្តីព្រាងច្បាប់ និង លិខិតបទដ្ឋានគតិយុត្តនានា ដែលទាក់ទងនឹងកិច្ចការអយ្យការដែលអាចចូលរួមពិនិត្យ និងផ្តល់ជាយោបល់លើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលរៀបចំឡើងដោយក្រសួង ឬស្ថាប័នផ្សេងៗដែលពាក់ព័ន្ធនឹងកិច្ចការអយ្យការ។ ហេតុនេះ នាយកដ្ឋានកិច្ចការអយ្យការគួរខិតខំបំពេញនូវភារកិច្ចរបស់ខ្លួនឲ្យអស់ពីលទ្ធភាព និងធ្វើយ៉ាងណារកឲ្យឃើញនូវចំណុចខ្សោយ ដែលតែងតែកើតមានឡើងនូវចំណុចខ្វះខាតក្នុងការអនុវត្តជាក់ស្តែង របស់ព្រះរាជអាជ្ញា និងមន្ត្រីដែលមានសមត្ថកិច្ចអនុវត្តន៍សាលក្រមព្រហ្មទណ្ឌ។

## ២. វិធាននៃភស្តុតាងនៅក្នុងនីតិវិធីព្រហ្មទណ្ឌ

"វិធាននៃភស្តុតាងនៅក្នុងនីតិវិធីព្រហ្មទណ្ឌ" ភស្តុតាង គឺជាព្រឹត្តហេតុ ឬ អង្គហេតុទាំងឡាយដែលអង្គហេតុនេះត្រូវបានកំណត់ដោយច្បាប់ទៅលើទម្រង់នីតិវិធីនានារបស់វាដើម្បីបង្ហាញ ឬបដិសេធទៅលើព្រឹត្តិការណ៍នៃបទល្មើសណាមួយបានដោយអង្គហេតុបង្ហាញពីការដាក់បន្ទុក ឬ ដោះបន្ទុកចំពោះការទទួលខុសត្រូវបុគ្គល ព្រមទាំងបានកំណត់នូវកម្រិតខ្ពស់ ឬ ទាប ធ្ងន់ ឬ ស្រាល ទៅលើការទទួលខុសត្រូវរបស់បុគ្គលនោះទៀតផង (ម.១ កថាខណ្ឌ ១ នៃក្រ.នី.ព្រ និង ម.២៤ នៃក្រ.ព្រ) ដែលរួមមាន៖

-**បន្ទុកនៃភស្តុតាង៖** ការកំណត់ពីបន្ទុកនៃភស្តុតាង ជាគោលការណ៍សច្ចធារណ៍នៃនិរទោស មានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជា (មាត្រា ៣៨) និងលិខិតតុបករណ៍អន្តរជាតិ។

-**មធ្យោបាយបង្ហាញភស្តុតាង៖** រាល់ភស្តុតាងដែលបង្ហាញពុំមានតម្លៃធ្ងន់ ឬ ស្រាលទេច្បាប់បានផ្តល់ឲ្យចៅក្រមជាអ្នកសម្រេច ដោយផ្អែកលើជំនឿពិតប្រាកដរបស់ចៅក្រម (ម.៣២១ ក្រ.នី.ព្រ)។ ការផ្តល់ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌអាចជូនបានដោយសេរីលើកលែងតែច្បាប់ចែងផ្ទុយ។

-**សក្ខីភាព៖** សាក្សី គឺជាជនដែលនិយាយអ្វីដែលខ្លួនបានឃើញ ឬ បានលឺដោយផ្ទាល់ខ្លួន។ មនុស្សដែលអាចធ្វើជាសាក្សីបាន គឺមនុស្សទូទៅ និងនគរបាលយុត្តិធ៌មផងដែររួមមាន៖ (១) ឪពុកម្តាយ និងបុព្វជនគ្រប់រូបរបស់ជនត្រូវចោទ (២) កូនប្រុស កូនស្រី និងបច្ឆាជនគ្រប់រូបផ្សេងទៀតរបស់ជនត្រូវចោទ (៣) បងប្អូនប្រុសស្រីរបស់ជនត្រូវចោទ (៤) បងប្អូនថ្លៃប្រុសស្រីរបស់ជនត្រូវចោទ (៥) ប្តី ឬ ប្រពន្ធរបស់ជនត្រូវចោទ ទោះបីជាបានលែងលះគ្នាហើយក៏ដោយ (៦) កុមារអាយុតិចជាង ១៤ ឆ្នាំ។ ដោយ សាក្សីត្រូវទទួលខុសត្រូវចម្លើយចំពោះមុខច្បាប់។

-**ការសារភាពៈ** ការសារភាពជាប្រភេទមួយនៃភស្តុតាង ដូចភស្តុតាងដទៃទៀតដែរ (ម.៣២១-៣២៤ ក្រ.នី.ព្រ) សារភាពដែលជាចម្លើយក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬ ខាងផ្លូវចិត្តគ្មានតម្លៃជាភស្តុតាងទេ។ ជនសង្ស័យត្រូវបានសួរចម្លើយដោយនគរបាលយុត្តិធម៌ និងមានសមត្ថកិច្ច និងកត់ត្រាក្នុងកំណត់ហេតុផងដែរ។

-**ការពិនិត្យគ្រប់មុខសញ្ញាៈ** ដើម្បីផ្តន្ទាទោស ឬ មិនផ្តន្ទាទោសចៅក្រមត្រូវស្វែងរកការពិតក្នុងសំណុំរឿង ដោយចៅក្រមស៊ើបសួរ ឬ ចៅក្រមជំនុំជម្រះត្រូវពិនិត្យលើកំណត់ហេតុមន្ត្រីនគរបាលយុត្តិធម៌ កោសលវិច័យរបស់អ្នកជំនាញ ឬ វត្ថុតាងនានាដែលបានមកពីមន្ត្រីនគរបាលប្រគល់ឲ្យ។ ចៅក្រមស៊ើបសួរ ត្រូវចុះពិនិត្យដល់កន្លែងកើតហេតុដើម្បីពិនិត្យការពិតជាក់ស្តែង។

-**សក្ខីកម្មក្លែងក្លាយៈ** គឺសំដៅដល់សាក្សី ដែលផ្តល់សក្ខីកម្មក្លែងក្លាយ ឬ កុហក។

### ៣. ត្រូវគោរពនិងអនុវត្តន៍ឲ្យបានត្រឹមត្រូវ ចំពោះគោលការណ៍និងបញ្ញត្តិច្បាប់

ដូច្នេះតួអង្គព្រះរាជអាជ្ញា ត្រូវតែទទួលបាននូវសិទ្ធិអំណាចខាងវិជ្ជាជីវៈរបស់ខ្លួនតាមផ្លូវច្បាប់ ឲ្យអស់ពីច្បាប់ចែង និងអនុវត្តន៍ដោយទំនួលខុសត្រូវលើមុខការរបស់ខ្លួនឲ្យបានត្រឹមត្រូវ សុក្រឹត្យ យុត្តិធម៌ និងមិនមានភាពលំអៀងទៅម្ខាងណាឡើយ។ ដូចនេះ បើតាមច្បាប់ក្រមសីលធម៌ចៅក្រម ដែលត្រូវបានអនុវត្តចំពោះព្រះរាជអាជ្ញាផងដែរ ពោល គឺព្រះរាជអាជ្ញាត្រូវវៀរចាកឲ្យបាននូវអគតិធម៌ទាំង ៤ គឺៈ ឆន្ទាគតិ ទោសាគតិ ភយាគតិ និងមោហាគតិ ដូចដែលព្រះរាជអាជ្ញា ឬ ចៅក្រមទាំងអស់បានធ្វើសច្ចាប្រណិធាននៅមុនពេលខ្លួនចូលកាន់ដំណែង។ នៅក្នុងករណីដែលកើតមានឡើងនូវភាពអយុត្តិធម៌ទាំងអស់នេះ ដែលកើតចេញពីព្រះរាជអាជ្ញានោះ គឺយើងអាចប្តឹងទៅអគ្គព្រះរាជអាជ្ញាដែលទទួលបន្ទុកគ្រប់គ្រងទៅលើព្រះរាជអាជ្ញានោះផ្ទាល់ និងទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដើម្បីចាត់វិធានការដោះស្រាយ។

### ៤. ការបន្ថែមមន្ត្រីជំនាញ និងការបណ្តុះបណ្តាលផ្នែកច្បាប់ចំពោះមន្ត្រីដែលអនុវត្ត

ត្រូវមានការបណ្តុះបណ្តាលក្រមនីតិវិធីព្រហ្មទណ្ឌ ទៅដល់មន្ត្រីទាំងឡាយដែលនាំឲ្យមានចំណេះដឹងទូលំទូលាយក្នុងការអនុវត្តច្បាប់ឲ្យមានប្រសិទ្ធភាព និងត្រឹមត្រូវទៅតាមបញ្ញត្តិច្បាប់ ដែលមានចែងក្នុងក្រមនេះ។ ជាពិសេស គឺផ្តល់នូវពុទ្ធិដល់មន្ត្រីដែលមានតួនាទីយ៉ាងសំខាន់នៅក្នុងកិច្ចដំណើរការក្នុងរឿងក្តីព្រហ្មទណ្ឌឲ្យបានដឹងពីតួនាទី និងភារកិច្ចរបស់ពួកគាត់ឲ្យបានល្អប្រសើរ និងប្រកាន់យកឲ្យបានខ្ជាប់ខ្ជួន ដូចដែលក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិមក។ ម្យ៉ាងវិញទៀត មានការអប់រំ ការផ្សព្វផ្សាយបណ្តុះបណ្តាលក្នុងគោលបំណងជៀសវាងកុំឲ្យមានវិវាទសមត្ថកិច្ចកើតមានឡើងនៅក្នុងកិច្ចដំណើរការនៃរឿងក្តីព្រហ្មទណ្ឌ។

ធ្វើការបង្កើនធនធានមនុស្សដែលមានចំណេះជំនាញលើប្រព័ន្ធយុត្តិធម៌ដូចជា ចៅក្រម ព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌បន្ថែម តាមរយៈការប្រឡងជ្រើសរើស និងបណ្តុះបណ្តាលប្រកបដោយវិជ្ជាជីវៈ និងដើម្បីជួយសម្រួលដល់កិច្ចជំនុំជម្រះរឿងក្តី ដែលមានភាពយឺតយ៉ាវ ដោយសារការខ្វះខាតនៅធនធានមនុស្សដែល

មានវិជ្ជាជីវៈក្នុងការអនុវត្តលើកិច្ចដំណើរការនៃរឿងក្ដីព្រហ្មទណ្ឌនេះ។ ការបណ្ដុះបណ្ដាលផ្នែកច្បាប់ចំពោះមន្ត្រីអនុវត្ត គឺជាចំណែកមួយយ៉ាងធំធេងសម្រាប់សកម្មភាពអនុវត្តមុខងាររបស់មន្ត្រីអនុវត្តឲ្យកាន់តែមានប្រសិទ្ធិភាព និងគុណធម៌ក្នុងការបំពេញវិជ្ជាជីវៈរបស់ខ្លួន។

### ៥. ការពន្លឿននីតិវិធីនៅក្នុងការដោះស្រាយ

ពាក់ព័ន្ធទៅនឹងការបញ្ជូនដីកាដោះលែង និងផ្សព្វផ្សាយអំពីព័ត៌មាននានា និងការអនុវត្តច្បាប់ផងដែរនោះ។ ស្ថាប័នអយ្យការ និងស្ថាប័នដែលពាក់ព័ន្ធគួរតែពន្លឿននឹងពង្រឹងនូវសមត្ថភាពកិច្ចការងារទូទៅនៃកិច្ចនីតិវិធី និងកិច្ចការរដ្ឋបាលឲ្យមានភាពទាន់សម័យដែលឆាប់រហ័ស ព្រមទាំងការអនុវត្តន៍ច្បាប់នានាដោយត្រូវប្រព្រឹត្តទៅតាមគោលការណ៍និងច្បាប់បានបញ្ញត្តិចែងជាកំហិត។ ក្នុងនោះផងដែរចំណុចនៃការសហប្រតិបត្តិការទៅលើដំណើរការនៃប្រព័ន្ធទំនើបកម្មនេះ។ ពោល គឺឈានទៅដល់ការធ្វើសមាហរនកម្មមួយដែលវានឹងធ្វើឲ្យប្រព័ន្ធនៃការបញ្ជូនដីកា និងផ្សព្វផ្សាយរវាងស្ថាប័នអយ្យការ និងស្ថាប័នពាក់ព័ន្ធដទៃ ដែលមានសមត្ថកិច្ចឲ្យកាន់តែល្អប្រសើរឆាប់រហ័សហើយនឹងមិនងាយជួបនឹងបញ្ហារាំងស្ទះ ឬ ប្រធានសក្តិណាមួយជាយថាហេតុឡើយ។

### ៦. ការចាត់វិធានការតឹងរឹង ចំពោះការរត់គេចខ្លួនរបស់ទណ្ឌិត ឬពិរុទ្ធជន

វិធានការនេះ ត្រូវមានការសហការពីគ្រប់ស្ថាប័នដែលពាក់ព័ន្ធនានា ដើម្បីជាជំនួយដល់ស្ថាប័នតុលាការក្នុងការអនុវត្តនីតិវិធីឲ្យបានឆាប់រហ័ស ដូច្នេះ ការសហការនេះជាជំនួយដ៏សំខាន់មួយ ដែលអាចធ្វើឲ្យដំណើរការនៅក្នុងរឿងក្ដីទទួលបាននូវយុត្តិធម៌ និងមិនធ្វើឲ្យបាត់បង់នូវផលប្រយោជន៍របស់គូភាគី។

នៅពេលដែលចៅក្រមជំនុំជម្រះ បានប្រកាសសាលក្រមសម្រេចផ្ដន្ទាទោសជនជាប់ចោទនោះពីបទឧក្រិដ្ឋ ឬបទមជ្ឈិមអ្វីមួយ ប៉ុន្តែ ពេលប្រកាសសាលក្រមនេះជនជាប់ចោទអវត្តមាននោះតុលាការអាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទ ដោយដីកានេះមានអនុភាពអនុវត្តភ្លាមៗ ហើយព្រះរាជអាជ្ញាជាអ្នកអនុវត្តតាមអំណាចដីកានេះដោយបញ្ជាទៅកងកម្លាំងសាធារណៈ ដើម្បីចុះទៅដល់ទីតាំងនៃជននោះស្ថិតនៅភ្លាមៗ ប៉ុន្តែប្រសិនបើជននោះបានរត់គេងខ្លួនមុនបាត់ ព្រះរាជអាជ្ញាត្រូវផ្សព្វផ្សាយដល់មន្ត្រីមូលដ្ឋាន នៃទីលំនៅដែលជននោះរស់នៅ និងមន្ត្រីនៅក្បែរៗនោះដើម្បីចាំឃ្លាំមើលជននោះប្រសិនបើឃើញជនជាប់ចោទនោះ មន្ត្រីមូលដ្ឋាន ឬ ភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌អាចចាប់ជននោះបានភ្លាមៗ ប៉ុន្តែ ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាផងដែរ។ ការអនុវត្តបែបនេះ ក៏មានភាពលំបាកផងដែរ លើការចាប់ជនជាប់ចោទមកផ្ដន្ទាទោសតាមច្បាប់ ទោះអនុវត្តតាមអំណាចសាលក្រមព្រហ្មទណ្ឌចូលជាស្ថាពរហើយ ឬ តាមដីកាបង្គាប់ឲ្យចាប់ខ្លួនក្ដីព្រោះជនជាប់ចោទរស់នៅក្រៅឃុំដោយហេតុថាព្រះរាជអាជ្ញាអនុវត្តជាក់ស្ដែងនៅរាល់ពេលដែលមានបទល្មើសឧក្រិដ្ឋ និងបទមជ្ឈិម និង

ពង្រឹងលើការយាមកាមយ៉ាងតឹងរឹង ការពារអ្នកទោសក្នុងពន្ធនាគារនោះកុំឲ្យមានករណីបញ្ហារត់គេច ឬ បញ្ហានានាកើតមានឡើង។

## ៧. ការចាត់វិធានការ និងបង្កើតនូវយន្តការច្បាប់ដើម្បីការពារនិងទប់ស្កាត់

ត្រូវរក្សាបាននូវឯករាជ្យភាព នៃអំណាចតុលាការជៀសវាងការទទួលរងនៃឥទ្ធិពលខាងក្រៅពីស្ថាប័ន ឬមជ្ឈដ្ឋានដទៃទៀត ដែលជាហេតុនាំឲ្យមានភាពអយុត្តិធម៌កើតមានឡើង។ ដូច្នេះរាជរដ្ឋាភិបាល ស្ថាប័នតុលាការនិងក្រសួងយុត្តិធម៌ ព្រមទាំងស្ថាប័នពាក់ព័ន្ធដទៃទៀតត្រូវយកចិត្តទុកដាក់ទៅលើបញ្ហានេះ និងពង្រឹងទៅលើកិច្ចអនុវត្តនៃច្បាប់អោយបានខ្ជាប់ខ្ជួន ដោយភាពម៉ឺងម៉ាត់និងហ្មត់ចត់បំផុត។ ដែលត្រូវបង្កើតនូវយន្តការ ក៏ដូចជាបញ្ញត្តិច្បាប់ដើម្បីធ្វើការអនុវត្តបានយ៉ាងដាច់ខាតចំពោះបញ្ហានេះ។ ព្រមទាំងមានការរៀបចំ និងធានាបាននូវបណ្ដាញសន្តិសុខ និងសុវត្ថិភាពជូនចៅក្រម និងព្រះរាជអាជ្ញាក្នុងពេលសវនាការ ដើម្បីធានានិងធ្វើឲ្យប្រាកដថាសុវត្ថិភាពរបស់ពួកគាត់ត្រូវធានា និងការពារបាន 100% ចៀសផុតពីគ្រោះថ្នាក់ និងការគំរាមកំហែងក្នុងពេលដែលគាត់បំពេញការងាររបស់ខ្លួន ដើម្បីធានាបាននូវឯករាជ្យភាពរបស់អង្គចៅក្រម ឬ ព្រះរាជអាជ្ញាពីបញ្ហាទាំងអស់នេះ ដែលនាំអោយកិច្ចនេះប្រព្រឹត្តទៅបានយ៉ាងល្អប្រសើរត្រឹមត្រូវទៅតាមច្បាប់ និងទទួលបាននូវភាពយុត្តិធម៌ផងដែរ។

## ៨. ការបំពេញបន្ថែមនៅលើសម្ភារបច្ចេកទេសក្នុងការបំពេញមុខងារ

ត្រូវមានការឧបត្ថម្ភលើផ្នែកសម្ភារបច្ចេកទេស ដើម្បីពន្លឿននិងផ្ដល់មានភាពងាយស្រួលដល់តុលាការក្នុងការផ្ដល់យុត្តិធម៌ដ៏ពិតប្រាកដជូនប្រជាពលរដ្ឋ។ សម្ភារបច្ចេកទេស គឺជាវត្ថុដ៏សំខាន់នៅក្នុងកិច្ចការស្វែងរកអោយបានភស្តុតាងលើវត្ថុតាងនានា និងជាផ្នែកមួយជួយសម្រួលដល់កិច្ចនីតិ នៅក្នុងការរុករកបាននូវភស្តុតាងពិតប្រាកដ នៅក្នុងការចោទប្រកាន់របស់ព្រះរាជអាជ្ញាដើម្បីជាការដាក់បន្ទុក ឬ ដោះបន្ទុកដល់គូភាគី។

# សេចក្តីសន្និដ្ឋាន
# និងការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងការបកស្រាយយ៉ាងក្បោះក្បាយខាងលើរួចមក យើងអាចសន្និដ្ឋានបានថា ស្ថាប័នអយ្យការ ពិតជាបានដើរតួនាទីយ៉ាងសំខាន់បំផុតនៅក្នុងកិច្ចនីតិវិធីនៃការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌ។ ដោយនៅក្នុងស្ថាប័នអយ្យការផងដែរ យើងឃើញមានអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ដែលតំណាងដោយព្រះរាជអាជ្ញានិងព្រះរាជអាជ្ញារង ដែលមានសមត្ថកិច្ចទទួលបន្ទុកនៅក្នុងការបំពេញនៃកិច្ចការមួយនេះផងដែរ។ ហើយស្ថាប័នអយ្យការ ក៏ត្រូវធានារ៉ាប់រងលើការអនុវត្តសេចក្តីសម្រេចខាងបទល្មើសព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន។ អង្គការអយ្យការធ្វើការក្នុងនាមជាអ្នកបម្រើដល់ផលប្រយោជន៍ជាសាធារណៈសុទ្ធសាធជូនដល់សង្គម ហើយភារកិច្ចចម្បងរបស់អយ្យការ គឺការធ្វើចំណាត់ការចំពោះបទល្មើស។ ព្រះរាជអាជ្ញាមានសិទ្ធិធ្វើការចោទប្រកាន់ ពោល គឺទៅតាមនីតិវិធីច្បាប់ដែលបានកំណត់។ លើសពីនេះផងដែរ យើងក៏ឃើញមានការផ្តល់អោយនូវសិទ្ធិសម្រាប់ព្រះរាជអាជ្ញានៅក្នុងការសម្រេចចោទ ពោលគឺ អាចធ្វើទៅតាមឆន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញាផងដែរ កាលបើខ្លួនយល់ឃើញថាជាការសមគួរ និងត្រឹមត្រូវដោយតាមរយៈការរិះគិតពិចារណា ថ្លឹងថ្លែង និងស្រាវជ្រាវបានយ៉ាងហ្មត់ចត់ទៅតាមភស្តុតាង ក៏ដូចជាព័ត៌មានជាក់លាក់ និងច្បាស់លាស់ហើយមានភាពត្រឹមត្រូវដែលខ្លួនប្រមូលបាន។

តាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ បានផ្តល់វិធី ៣យ៉ាង សម្រាប់ឲ្យព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ទៅលើបទល្មើសនោះគឺ ការបើកការស៊ើបសួរ ការបញ្ជូនរឿងទៅជំនុំជម្រះដោយផ្ទាល់ និងការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមៗ។ នៅក្នុងវិធីទាំង ៣យ៉ាង នៃការចោទប្រកាន់របស់ព្រះរាជអាជ្ញានេះ គឺត្រូវធ្វើឡើងដោយអាស្រ័យទៅតាមបទល្មើស ឬ ស្ថានភាពជាក់ស្តែងដែលកើតមានឡើង។ ដូច្នេះហើយ ថាតើព្រះរាជអាជ្ញាគួរតែសម្រេចជ្រើសរើសចោទ និងដាក់អោយដំណើរការនៃរឿងក្តីនេះ នៅក្នុងដំណាក់កាលនៃនីតិវិធីណាមួយដែលព្រះរាជអាជ្ញាយល់ឃើញថាសមស្រប និងគ្រប់ទៅតាមលក្ខខណ្ឌដែលច្បាប់បានកំណត់នោះ។ បន្ទាប់ពីបានធ្វើការសិក្សាយ៉ាងលម្អិតទៅលើនីតិវិធីនៃការចោទប្រកាន់នីមួយៗរបស់ព្រះរាជអាជ្ញា យើងបានរកឃើញនិងកំណត់បាននូវមូលហេតុ ដែលនាំឲ្យមានការបង្កើតឡើងនូវនីតិវិធីនៃការចោទប្រកាន់ ដែលមានលក្ខណៈផ្សេងៗគ្នាដោយតម្រូវទៅតាមស្ថានភាពជាក់ស្តែងនៃបទល្មើស ពោល គឺដើម្បីធានាបាននូវភាពច្បាស់លាស់ ត្រឹមត្រូវសុក្រឹត្យ មានតម្លាភាព និងបង្កឲ្យមានភាពឆាប់រហ័សនៃរឿងក្តីព្រហ្មទណ្ឌ។ ភាពច្បាស់លាស់ និងត្រឹមត្រូវទាំងអស់នេះត្រូវបានកំណត់គ្រប់ដំណាក់កាល នៃនីតិវិធីនៃការចោទប្រកាន់ទាំងអស់ ដើម្បីស្វែងរកយុត្តិធម៌យ៉ាងពិតប្រាកដជូនដល់ជនរងគ្រោះ និងជនជាប់ចោទ ព្រមទាំងការពារនូវផលប្រយោជន៍សាធារណៈ និងបញ្ឈប់រាល់ភាពចលាចលនានានៅក្នុងសង្គម។ ប្រសិនបើ ការចោទប្រកាន់នៅក្នុងរឿងក្តីមិនមានភាពច្បាស់លាស់ និង

ត្រឹមត្រូវនោះទេ ច្បាស់ណាស់ថានឹងកើតមានឡើងនូវផលវិបាកជាច្រើន ដោយមិនចំពោះតែទៅលើចុងបណ្ដឹង និងដើមបណ្ដឹងនោះទេ គឺសូម្បីតែរដ្ឋយើងក៏បង់ផលប្រយោជន៍ផងដែរ។ ចំពោះចុងបណ្ដឹង គឺអាចនឹងខាតបង់ពេលវេលាប្រសិនបើមានការចាប់ឃុំព្រមទាំងខាតបង់ប្រាក់កាស ជាពិសេស គឺកិត្តិយសកេរ្តិ៍ឈ្មោះ ឬអាចទទួលរងនូវភាពអយុត្តិធម៌ ដែលបណ្ដាលមកពីការពុំបានស៊ើបអង្កេតឲ្យបានច្បាស់លាស់ និងត្រឹមត្រូវពីសំណាក់តំណាងអយ្យការ។ ចំណែកឯ ដើមបណ្ដឹងវិញក៏មានផលប៉ះពាល់ផងដែរ ដូចជាការខាតបង់ប្រាក់កាស និងពេលវេលា ក៏ដូចជាការមិនបានទទួលភាពយុត្តិធម៌ ឬ សំណងប៉ះប៉ូវផ្លូវចិត្តជាដើម ព្រោះតាមរយៈគោលការណ៍វិមតិសង្ស័យដែលត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ដែលបណ្ដាលឲ្យជនល្មើសអាចរួចផុតពីការចោទប្រកាន់បាន។ ដូច្នេះ ដើម្បីធានាពីភាពច្បាស់លាស់ ការពារសិទ្ធិ និងបញ្ចៀសផលប៉ះពាល់នៃរឿងក្ដីការធ្វើឡើងតាមរយៈនីតិវិធីបើកការស៊ើបសួរ ដែលជាជម្រើសល្អបំផុតព្រោះថានីតិវិធីនេះនឹងបើកការស្រាវជ្រាវ រុករកនូវព័ត៌មានលម្អិតបន្ថែមទៀតតាមរយៈចៅក្រមស៊ើបសួរ។ នីតិវិធីនីមួយៗត្រូវតែធ្វើឡើង ដោយមានភាពច្បាស់លាស់ ហើយយើងឃើញថានៅក្នុងនីតិវិធីទាំងអស់នេះ គឺពិតជាមានភាពពិតប្រាកដមែន ក៏ប៉ុន្តែនៅក្នុងន័យនេះផងដែរ។ យើងឃើញថា ប្រសិនបើនៅរាល់បទល្មើសទាំងអស់ដែលកើតមានឡើង ពោល គឺមិនសុទ្ធសឹងតែមានលក្ខណៈ ឬ ស្ថានភាពដូចគ្នានោះទេ ដូច្នេះព្រះរាជអាជ្ញាត្រូវធ្វើការពិនិត្យ និងថ្លឹងថ្លែងអោយបានហ្មត់ចត់ទៅលើបទល្មើសដែលកើតឡើងជាក់ស្ដែង ថាតើគួរចោទប្រកាន់ទៅតាមនីតិវិធីមួយណាដើម្បីបង្កអោយមានភាពឆាប់រហ័សនៃសំណុំរឿង និងមិនប៉ះពាល់ទៅដល់ផលប្រយោជន៍ផងដែរ។

សរុបជារួមមកស្ថាប័នអយ្យការ ជាស្ថាប័នមួយដែលដើរតួនាទីយ៉ាងសំខាន់ នៅក្នុងកិច្ចការពារផលប្រយោជន៍ជាសាធារណៈជូនទៅដល់សង្គមដែលមិនអាចខ្វះបាន។ ស្ថាប័នអយ្យការ ក៏ត្រូវធានារ៉ាប់រងលើការអនុវត្តសេចក្ដីសម្រេចខាងបទល្មើសព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន ដែលមានព្រះរាជអាជ្ញាជាតំណាងនៅក្នុងកិច្ចការនៃស្ថាប័ននេះ និងត្រូវមានវត្តមានជាចាំបាច់បំផុតក្នុងដំណើរការនៃនីតិវិធីនៅក្នុងសំណុំរឿងក្ដីព្រហ្មទណ្ឌ ដែលជាដំណើរនៃនីតិវិធីដំបូងគេបង្អស់ មុននិងអាចឈានទៅដល់នីតិវិធីបន្តបន្ទាប់ទៀតបាន ដូច្នេះ បើគ្មានការចូលរួមក្នុងការចោទប្រកាន់ពីសំណាក់ព្រះរាជអាជ្ញាទេក៏ពុំមាននូវកិច្ចស៊ើបសួរ ឬ កិច្ចជំនុំជម្រះកើតឡើងផងដែរ។

## ២. ការផ្ដល់អនុសាសន៍

ឆ្លងតាមការបកស្រាយលម្អិតរួចមកហើយ យើងអាចធ្វើការវិនិច្ឆ័យបានថា ស្ថាប័នអយ្យការគឺជាស្ថាប័នមួយ ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងនីតិវិធីនៃការចោទប្រកាន់ទាំងអស់ពិតមែន។ នីតិវិធីទាំងនេះអាចប្រព្រឹត្តទៅបានរលូនល្អ ត្រឹមត្រូវ មានតម្លាភាព និងប្រកបដោយភាពយុត្តិធម៌បាន លុះត្រាតែ ព្រះរាជអាជ្ញាបានបំពេញនូវតួនាទីរបស់ខ្លួនអោយបានល្អដោយមាន

ភាពត្រឹមត្រូវ ច្បាស់លាស់ ហ្មត់ចត់ និងប្រកាន់យកតែភាពទៀងត្រង់ សច្ចៈធម៌ គុណធម៌ និងយុត្តិធម៌ នៅរាល់កិច្ចដំណើរការនៅក្នុងរឿងក្តីរបស់ខ្លួន ដែលរាល់សកម្មភាពទាំងនេះតម្រូវអោយមានៈ

- ព្រះរាជអាជ្ញា ត្រូវមានសុភវិនិច្ឆ័យឲ្យបានត្រឹមត្រូវចំពោះជម្រើសណាមួយ ដែលនិងត្រូវធ្វើការចោទប្រកាន់ដើម្បីឲ្យភាគីទាំងសងខាង ពោល គឺទាំងជនរងគ្រោះនិងជនបង្កអាចទទួលបាននូវភាពយុត្តិធម៌ពីការវិនិច្ឆ័យដែលត្រឹមត្រូវ និងច្បាស់លាស់នោះ។ ហើយ ដែលយើងឃើញថាវាអាចនាំឲ្យមានផលប៉ះពាល់ដល់សិទ្ធិរបស់ភាគីណាមួយនៅពេលដែលព្រះរាជអាជ្ញា ធ្វើការវិនិច្ឆ័យខុសដែលជាហេតុបណ្តាលឲ្យមានការខាតបង់ និងប៉ះពាល់ដល់ផលប្រយោជន៍ ពេលវេលា និងកិត្តិយសរបស់ភាគីទាំងពីរ។
- មានការបណ្តុះបណ្តាលក្រមនីតិវិធីព្រហ្មទណ្ឌ ទៅដល់មន្ត្រីទាំងឡាយដែលនាំឲ្យមានចំណេះដឹងទូលំទូលាយក្នុងការអនុវត្តច្បាប់ឲ្យមានប្រសិទ្ធិភាព និងភាពត្រឹមត្រូវទៅតាមច្បាប់បញ្ញត្តិដែលមានចែងក្នុងក្រមនេះ។ ជាពិសេស គឺផ្តល់នូវពុទ្ធិដល់មន្ត្រីដែលមានតួនាទីយ៉ាងសំខាន់នៅក្នុងកិច្ចដំណើរការក្នុងរឿងក្តីព្រហ្មទណ្ឌឲ្យបានដឹងពីតួនាទី និងភារកិច្ចរបស់ពួកគាត់ឲ្យបានល្អប្រសើរ និងប្រកាន់យកឲ្យបានខ្ជាប់ខ្ជួន ដូចដែលក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិមក។ ម្យ៉ាងវិញទៀត មានការអប់រំ ការផ្សព្វផ្សាយបណ្តុះបណ្តាល ក្នុងគោលបំណងជៀសវាងកុំឲ្យមានវិវាទសមត្ថកិច្ចកើតមានឡើង នៅក្នុងកិច្ចដំណើរការរឿងក្តីព្រហ្មទណ្ឌ។
- ធ្វើការបង្កើនធនធានមនុស្សដែលមានចំណេះជំនាញ លើប្រព័ន្ធយុត្តិធម៌ដូចជា ចៅក្រម ព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌បន្ថែម តាមរយៈការប្រឡងជ្រើសរើស និងបណ្តុះបណ្តាលប្រកបដោយវិជ្ជាជីវៈ និងដើម្បីជួយសម្រួលដល់កិច្ចជំនុំជម្រះរឿងក្តី ដែលមានភាពយឺតយ៉ាវ ដោយសារការខ្វះខាតនៅធនធានមនុស្សដែលមានវិជ្ជាជីវៈក្នុងការអនុវត្តលើកិច្ចដំណើរការនៃរឿងក្តីព្រហ្មទណ្ឌនេះ។
- ត្រូវមានការបណ្តុះបណ្តាលចៅក្រម និងព្រះរាជអាជ្ញាឲ្យបានច្រើនបន្ថែមទៀត នឹងមានការបញ្ជូនចៅក្រមនិងព្រះអាជ្ញាទៅសិក្ខាសិលានៅឯក្រៅប្រទេស ដើម្បីផ្លាស់ប្តូរនូវបទពិសោធន៍ និងប្រមូលចំណេះដឹងដើម្បីយកមកអនុវត្ត និងដោះស្រាយនូវបទល្មើសថ្មីៗ ដែលកំពុងកើតមានឡើងនាពេលបច្ចុប្បន្ន។ ស្របពេលដែល អង្គការនីតិបញ្ញត្តិបានអនុម័តច្បាប់ថ្មីៗមួយចំនួន ដោយឡែកត្រូវមានការធានាថា ចៅក្រមត្រូវបានទទួលការបណ្តុះបណ្តាលផ្នែកច្បាប់ដ៏ត្រឹមត្រូវ និងប្រកបដោយសមត្ថភាពមានបុគ្គលិកលក្ខណៈដែលមានក្រមសីលធម៌។
- ព្រះរាជអាជ្ញា គួរតែព្យាយាមក្នុងការស្វែងរកភស្តុតាងដាក់បន្ទុក ឬ ដោះបន្ទុក ដូចជាការចុះស្វែងរកសាវតាជាតិដោយផ្ទាល់របស់ចៅក្រមស៊ើបសួរបើសិនជាអាច។

- ស្ថាប័នតុលាការ គួរតែត្រូវបានយកចិត្តទុកដាក់ទៅលើទីតាំង អគារ និងបន្ទប់ដែលជាកន្លែងធ្វើការឲ្យមានលក្ខណៈធំល្មម ដែលសមស្របទៅនិងចំនួនមន្ត្រីដែលបម្រើនៅក្នុងស្ថាប័ននោះ។
- រក្សាបាននូវឯករាជ្យភាព នៃអំណាចតុលាការ ជៀសវាងការទទួលរងនៃឥទ្ធិពលខាងក្រៅពីស្ថាប័នដទៃទៀត ឬ ពីមជ្ឈដ្ឋានជុំវិញដែលជាហេតុនាំឲ្យមានភាពអយុត្តិធម៌។
- ត្រូវមានការយកចិត្តទុកដាក់ដល់បញ្ហាប្រាក់បៀវត្ស និងការផ្តល់ជាសេវាថៃទាំសុខភាព ព្រមទាំងសេវាផ្សេងៗទៀតដល់មន្ត្រីតុលាការ ដែលជាឬសគល់ដ៏សំខាន់នៃប្រព័ន្ធតុលាការ ជាពិសេសការទទួលបានជំនឿទុកចិត្តពីប្រជាពលរដ្ឋ។ ប្រាក់បៀវត្សមន្ត្រីតុលាការ គួរតែផ្តល់ឲ្យបានសមស្របទៅនឹងស្ថានភាពក្នុងពេលបច្ចុប្បន្ន ដើម្បីទ្រទ្រង់ជីវភាពល្អប្រសើរនៅក្នុងគ្រួសារចៅក្រម និងព្រះរាជអាជ្ញា ព្រមទាំងមន្ត្រីតុលាការដើម្បីជៀសវាងនៅការទទួលការស៊ីសំណូក។ ដោយ បង្កើតឲ្យមានអំពើពុករលួយដែលធ្វើឲ្យប្រព័ន្ធយុត្តិធម៌កម្ពុជារងគ្រោះ និងដើម្បីធានាប្រសិទ្ធភាពនៃការងារនិងឯករាជ្យ។
- ត្រូវមានការឧបត្ថម្ភលើផ្នែក សម្ភារបច្ចេកទេស និងសម្ភាររដ្ឋបាល ដើម្បីពន្លឿននៃកិច្ចការរបស់តុលាការ និងការផ្តល់យុត្តិធម៌ដ៏ពិតប្រាកដជូនប្រជាពលរដ្ឋ។ សម្ភារបច្ចេកទេស គឺជាវត្ថុដ៏សំខាន់ក្នុងការធ្វើកោសលវិច័យលើវត្ថុតាងនានា ដើម្បីស្វែងរកការពិតជូនដល់គូភាគី ដោយឡែកសម្ភាររដ្ឋបាលជាឧបករណ៍ជំនួយដល់កិច្ចគ្រប់គ្រងទូទៅរបស់តុលាការដូចជា៖ ការកត់ត្រា ការរក្សាទុកឯកសារសំខាន់ៗ និងការគ្រប់គ្រងសំណុំរឿងក្តីតាមប្រព័ន្ធអេឡិចត្រូនិចជាដើម។
- ត្រូវមានការសហការពីគ្រប់ស្ថាប័នដែលពាក់ព័ន្ធនានា ដើម្បីជាជំនួយដល់ស្ថាប័នតុលាការ ក្នុងការអនុវត្តនីតិវិធីឲ្យបានឆាប់រហ័ស ដូច្នេះការសហការនេះជាជំនួយដ៏សំខាន់មួយ ដែលអាចធ្វើឲ្យដំណើរការនៅក្នុងរឿងក្តីទទួលបាននូវភាពយុត្តិធម៌ និងមិនធ្វើឲ្យបាត់បង់នូវផលប្រយោជន៍របស់គូភាគី។
- ត្រូវមានការរៀបចំបណ្តាញសន្តិសុខ និងសុវត្ថិភាពជូនចៅក្រម និងព្រះរាជអាជ្ញាក្នុងពេលសវនាការ ដើម្បីធានា និងធ្វើឲ្យប្រាកដថាសុវត្ថិភាពរបស់ពួកគាត់ត្រូវធានាការពារបាន 100% ចៀសផុតពីគ្រោះថ្នាក់និងការគំរាមកំហែងក្នុងពេលដែលគាត់បំពេញការងាររបស់ខ្លួន ដើម្បីធានាបាននូវឯករាជ្យរបស់អង្គចៅក្រម។

ការសហការជាបច្ច័យល្អមួយ ដែលអាចបង្កើតឲ្យមានវប្បធម៌ ក្នុងការជួយគ្នាទៅវិញទៅមកដល់ក្មេងជំនាន់ក្រោយផងដែរ។ បើទោះបីជាយ៉ាងណាសាលាដំបូងរាជធានីខេត្ត-ក្រុង បានខិតខំបំពេញតួនាទីរបស់ខ្លួនឲ្យអស់ពីសមត្ថភាព ដើម្បីផ្តល់នូវយុត្តិធម៌ជូនដល់ប្រជាពលរដ្ឋទាំងអស់ ដែលនេះជាការបញ្ជាក់អំពីការយកចិត្តទុកដាក់របស់សាលាដំបូងរាជធានីខេត្ត-ក្រុង ក៏ដូចជាស្ថាប័នពាក់ព័ន្ធនានា និងបានខិតខំយកចិត្តទុកដាក់ពិនិត្យលើបញ្ហាដែលបានលើកឡើងទាំងអស់ខាងលើនេះផងដែរ។ ពីព្រោះថា បញ្ហាទាំងអស់នេះគឺជាបញ្ហាដ៏ធំចំពោះមន្ត្រីតុលាការ ហើយវាក៏ជាបញ្ហាដ៏សំខាន់ផងដែរ ដែលធ្វើឲ្យប្រព័ន្ធយុត្តិធម៌កម្ពុជាមានការធ្លាក់ចុះ។

# ឯកសារយោង

# ឯកសារយោង

## ❖ លិខិតបទដ្ឋានគតិយុត្ត

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣

២. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

៣. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

៤. ច្បាប់ស្តីពីការរៀបចំតុលាការ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤

៥. ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤

៦. ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចុះថ្ងៃទី១៦ កក្កដា ឆ្នាំ២០១៤

៧. ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ១៩៩៣

៨.គោលការណ៍ណែនាំស្តីពី តួនាទីរបស់ព្រះរាជអាជ្ញា អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៨ ចាប់ពីថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩០ នៅប្រទេសគុយបា ទីក្រុងហាវ៉ាណា

៩. បទវិចារណកថា៖ យន្តនាការដោះស្រាយការកកស្ទះសំណុំរឿងឆ្នាំ ២០២០ ៖ នយោបាយយុត្តិធម៌ចាស់ប៉ះកំណែទម្រង់ថ្មី

១០. អនុក្រឹត្យស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌ លេខ១៣០ អនក្រ.បក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២

១១. ក្រមសីលធម៌ចៅក្រម អនុម័តដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៧ ដែលបោះពុម្ពផ្សព្វផ្សាយដោយតុលាការកំពូល

## ❖ ឯកសារជាសៀវភៅ និងអត្ថបទផ្សេងៗ

១. សាស្ត្រាចារ្យ ហ៊ី សោភា នីតិវិធីព្រហ្មទណ្ឌ (មេរៀន)

២. សាស្ត្រាចារ្យ មីន សំអុល, នីតិវិធីព្រហ្មទណ្ឌ, ឆ្នាំ២០១៨

៣. សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, នីតិវិធីព្រហ្មទណ្ឌ, ឆ្នាំ២០១៦

៤. លោកស្រី ឌី លីឡា និងលោក ខាន់ សុខានីតិវិធីព្រហ្មទណ្ឌ

៥. សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌទូទៅ, ឆ្នាំ២០១២

៦. សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចសារណាបញ្ចប់ការសិក្សារបស់និស្សិត។

## ❖ គេហទំព័រផ្សេងៗ

១. បណ្ណាល័យអេឡិចត្រូនិចភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

https://www.elibrary-rule.com

២. កិច្ចពិភាក្សាស្តីពីអង្គការអយ្យការ និងការធ្វើបណ្តឹងអាជ្ញា

https://www.youtube.com/watch?v=bSQPNdGg4FM

៣. អង្គការអយ្យការ

https://www.youtube.com/watch?v=YFrx66fA7dc

៤. ការចោទប្រកាន់ និងស្ថាប័នអយ្យការ

https://www.youtube.com/watch?v=ITDrwk0keq0

៥. ទំព័រស្វែងយល់ពីច្បាប់ ប្រធានបទស្តីពី នីតិវិធីនៃការចោទប្រកាន់

- https://drive.google.com/file/d/0B242T0ZzfZmvZHhaUTh2a2tEblk/view?resourcekey=0 wHTwfHsv1Q6fpb5tKzb7lw
- https://www.linkedin.com/

៦. ផេកស្វែងយល់អំពីច្បាប់ "មជ្ឈមណ្ឌលនីតិក្រម" ដែលមានការលើកយកមកបង្ហាញជូនជាច្រើនដើម្បីជាជំនួយស្មារតី ទាក់ទិនទៅនិងការចោទប្រកាន់របស់អយ្យការ ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ឯកឧត្តម កើត រិទ្ធ និងលោកគ្រូសាស្ត្រាចារ្យ ហ៊ី សោភា ព្រមទាំងមានអត្ថបទ និងឯកសារច្បាប់ដទៃជាច្រើនទៀត

https://fb.watch/mtX4xfjy_Q/?mibextid=R5ymit

# ឧបសម្ព័ន្ធ

## តារាងឧបសម្ព័ន្ធ

| | |
|---|---|
| **ឧបសម្ព័ន្ធទី ១** | ពាក្យបណ្ដឹង |
| **ឧបសម្ព័ន្ធទី ២** | ដីកាកោះ |
| **ឧបសម្ព័ន្ធទី ៣** | កំណត់ហេតុសួរចម្លើយ |
| **ឧបសម្ព័ន្ធទី ៤** | ដីកាសម្រេចបញ្ចូលសំណុំរឿង |
| **ឧបសម្ព័ន្ធទី ៥** | ដីកាសម្រេចមិនឃុំខ្លួន |
| **ឧបសម្ព័ន្ធទី ៦** | ដីកាបង្គាប់ឱ្យចូលខ្លួន |
| **ឧបសម្ព័ន្ធទី ៧** | ដីកាបញ្ជូនព័ត៌មាន |
| **ឧបសម្ព័ន្ធទី ៨** | ដីកាបញ្ជូនសំណុំរឿងឲ្យពិនិត្យ |
| **ឧបសម្ព័ន្ធទី ៩** | ដីកាសន្និដ្ឋានស្ថាពរ |
| **ឧបសម្ព័ន្ធទី ១០** | លិខិតជូនព័ត៌មានអំពីការបិទការស៊ើបសួរ |
| **ឧបសម្ព័ន្ធទី ១១** | លិខិតជូនដំណឹងពីដីកាដំណោះស្រាយ |
| **ឧបសម្ព័ន្ធទី ១២** | ដីកាសម្រេចដាក់រឿងជំនុំជម្រះ |
| **ឧបសម្ព័ន្ធទី ១៣** | ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ |
| **ឧបសម្ព័ន្ធទី ១៤** | ដីកាកោះបញ្ជូនទៅជំនុំជំរះផ្ទាល់ |
| **ឧបសម្ព័ន្ធទី ១៥** | សេចក្ដីសុំប្ដឹងតវ៉ា |
| **ឧបសម្ព័ន្ធទី ១៦** | កំណត់ហេតុស្ដីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម |
| **ឧបសម្ព័ន្ធទី ១៧** | ដីកាបង្គាប់ឲ្យនាំខ្លួនជនត្រូវចោទ |
| **ឧបសម្ព័ន្ធទី ១៨** | ដីកាបង្គាប់ឲ្យចាប់ខ្លួន |
| **ឧបសម្ព័ន្ធទី ១៩** | លិខិតជូនដំណឹងដើមបណ្ដឹងរដ្ឋប្បវេណី |
| **ឧបសម្ព័ន្ធទី ២០** | លិខិតជូនដំណឹងជនត្រូវចោទ |
| **ឧបសម្ព័ន្ធទី ២១** | កំណត់ហេតុស្ដីពីការបង្ហាញខ្លួនលើកដំបូង |
| **ឧបសម្ព័ន្ធទី ២២** | ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ |
| **ឧបសម្ព័ន្ធទី ២៣** | ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ |
| **ឧបសម្ព័ន្ធទី ២៤** | ដីកាបង្គាប់ឲ្យទទួលថែរក្សាវត្ថុចាប់យក |
| **ឧបសម្ព័ន្ធទី ២៥** | ដីកាសម្រេចលើកលែងចោទប្រកាន់ |

| | |
|---|---|
| **ឧបសម្ព័ន្ធទី ២៦** | ដីកាកោះហៅឲ្យជនជាប់ចោទចូលរួមសវនាការ |
| **ឧបសម្ព័ន្ធទី ២៧** | ដីកាបញ្ជូនទៅជំនុំជម្រះ |
| **ឧបសម្ព័ន្ធទី ២៨** | សេចក្ដីសម្រេចអធិបញ្ញាឲ្យចោទប្រកាន់ |
| **ឧបសម្ព័ន្ធទី ២៩** | ដីកាឆែកឆេរលំនៅដ្ឋាន |
| **ឧបសម្ព័ន្ធទី ៣០** | កំណត់ហេតុទទួលវត្ថុចាប់យក |
| **ឧបសម្ព័ន្ធទី ៣១** | ដីកាបញ្ជាឲ្យចូលខ្លួន |
| **ឧបសម្ព័ន្ធទី ៣២** | ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម |
| **ឧបសម្ព័ន្ធទី ៣៣** | ដីកាសន្និដ្ឋានសុំឲ្យឃុំខ្លួនបណ្ដោះអាសន្ន |
| **ឧបសម្ព័ន្ធទី ៣៤** | ដីកាផ្ទេរសមត្ថកិច្ច |
| **ឧបសម្ព័ន្ធទី ៣៥** | ដីកាបង្គាប់ឲ្យឃុំខ្លួន |
| **ឧបសម្ព័ន្ធទី ៣៦** | ដីកាបង្គាប់ឲ្យដោះលែង |
| **ឧបសម្ព័ន្ធទី ៣៧** | ដីកាបង្គាប់ឲ្យឈប់ចាប់ខ្លួន |

**ឧបសម្ព័ន្ធទី ១**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម
សាលាដំបូងខេត្តកណ្ដាល
ចូល
លេខ.................................
ថ្ងៃ 09 ខែ 09 ឆ្នាំ២០២០
ម៉ោង 08 ^ 40

## ពាក្យបណ្ដឹង

ខ្ញុំបាទឈ្មោះ                                អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ និងប្រពន្ធឈ្មោះ                    អាយុ៣២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ២៦៩ ផ្លូវ១៥៦ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**សូមគោរពចូលមក**

**ឯកឧត្ដម ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកណ្ដាល**

*ជាទីគោរព ។*

**កម្មវត្ថុ:** សំណើសុំប្ដឹងពីឈ្មោះ                    ភេទប្រុស អាយុ៦៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិស្វាយជ្រៃ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល ។

**ពីបទ:** ហិង្សាដោយចេតនា មកលើរូបខ្ញុំបាទនិងប្រពន្ធខ្ញុំបាទកាលពីថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១៧ ត្រង់ចំណុចភូមិស្វាយជ្រៃ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល ។

**យោង:** -រូបថតដែលថតកាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ ចំនួន០៣(បី)សន្លឹក បានបញ្ជាក់អំពីសកម្មភាពដែលឈ្មោះ                    បានប្រើហិង្សាមកលើខ្ញុំបាទ ។

-ខ្សែអាត់វីឌីអូចំនួន៤៥វិនាទីដែលថតកាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ បានបញ្ជាក់អំពីសកម្មភាពដែលឈ្មោះ                    បានប្រើហិង្សាមកលើខ្ញុំបាទ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ មានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្ដម ព្រះរាជអាជ្ញា** មេត្តាជ្រាបថា: កាលពីថ្ងៃទី២១ ខែមិនា ឆ្នាំ២០១៧ ជិតដល់ថ្ងៃសែនឆេងម៉េងខ្ញុំបាទបានទូរស័ព្ទទៅម្ដាយមីងឈ្មោះ                    ស្នើសុំការអនុញ្ញាតពីម្ដាយមីងដើម្បីធ្វើការចាក់ដីជុំវិញផ្នូរម្ដាយរបស់ខ្ញុំបាទដែលស្ថិតនៅក្នុងភូមិស្វាយជ្រៃ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល (**ផ្នូរម្ដាយរបស់ខ្ញុំបាទបញ្ចុះលើដីម្ដាយមីងខ្ញុំបាទ**)ពេលនោះម្ដាយមីងខ្ញុំបាទ                    ក៏បានអនុញ្ញាតឲ្យខ្ញុំបាទធ្វើការចាក់ដីជុំវិញផ្នូរម្ដាយរបស់ខ្ញុំបាទដែលមានទីតាំងក្នុងភូមិ,ឃុំខាងលើ លុះថ្ងៃបន្ទាប់ថ្ងៃទី២២ ខែមិនា ឆ្នាំ២០១៧ ម៉ោងបីរសៀលខ្ញុំបាទក៏បានទូរស័ព្ទឲ្យឡានគេចូលចាក់ដីបានចំនួន០៣(បី)ឡាន ពេលដែលកំពុងតែចាក់ដីនោះក៏ត្រូវបានឈ្មោះ                    បានមកធ្វើការហាមឃាត់មិនឲ្យចាក់ដីបន្តទៀតឡើយដោយគាត់បានអះអាងថាដីខាងលើជាដីរបស់គាត់                    ទាំងដែលដីខាងលើជាដីកម្មសិទ្ធិស្របច្បាប់

**ឧបសម្ព័ន្ធទី ២**

ចំណាន វណ្ណថា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខ: ១៥៣១អក
ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០

# ដីកាកោះ

អធិការដ្ឋាននគរបាលស្រុកមុខកំពូល
ចូល លេខ...348... ថ្ងៃទី...២៩... ខែ...០៩... ឆ្នាំ២០២០ ម៉ោង...១១:០០...នាទី

ស្នងការដ្ឋាននគរបាលខេត្តកណ្ដាល
ចូល អញ្ជើញឈ្មោះ : ថ្ងៃទី...... ខែ........ឆ្នាំ...... ម៉ោង
អោយចូលនៅ : លេខ..................... ន.ប

**យើង** **តំណាងអយ្យការ អមសាលាដំបូងខេត្តកណ្ដាល**

ភេទប្រុស អាយុ ៦៥ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ភូមិស្វាយជ្រុំ ឃុំព្រែកឯបង ស្រុកមុខកំពូល ខេត្តកណ្ដាល ជា **ជនសង្ស័យ** ។

អយ្យការអមសាលាដំបូងខេត្តកណ្ដាល
នៅថ្ងៃទី *២២ ខែ តុលា ឆ្នាំ ២០២០* វេលាម៉ោង **០២.០០នាទី រសៀល**។

**ដើម្បីសាកសួរ** : ពាក់ព័ន្ធនឹងករណី៖ " **ចាំឡូដោយចេតនា** " តាមពាក្យបណ្ដឹងរបស់ឈ្មោះ និងឈ្មោះ ។

**បញ្ជាក់** : សាមីខ្លួន ត្រូវអញ្ជើញតាមដីកាកោះនេះ អោយបានទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

ថ្ងៃចន្ទ ៤កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
ខេត្តកណ្ដាល ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០
**តំណាងអយ្យការ**

យើង, ឈ្មោះ................................................ បានប្រគល់ដីកាកោះនេះអោយ ................ភេទ......អាយុ...65...ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅ ភូមិ.............. ឃុំ/សង្កាត់.............. ស្រុក/ក្រុង.............. ខេត្ត/រាជធានី.............. នៅថ្ងៃទី...01... ខែ...10... ឆ្នាំ...2020... ផ្ទាល់រូបមកហើយដោយយើងបានទុកចុងដីកានេះមួយច្បាប់អោយសាមីខ្លួន ហើយប្រាប់ថា អោយសាមីខ្លួនប្រគល់ចុងដីកានេះដល់ក្រឡាបញ្ជីនៅពេលខ្លួនចូលទៅដល់តុលាការ ឬ អយ្យការ។

**អ្នកទទួល**
ហត្ថលេខា ឬ ស្នាមម្រាមដៃ

**អ្នកប្រគល់**
ហត្ថលេខា

**ឧបសម្ព័ន្ធទី ៣**

ᵀ/₂

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខៈ១៥៣១អក
ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០

# កំណត់ហេតុសួរចម្លើយ

ឆ្នាំពីរពាន់ម្ភៃ ខែតុលា ថ្ងៃទីម្ភៃពីរ វេលាម៉ោង ដប់បួន និង សូន្យ នាទី រសៀល

**យើង** **ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តកណ្ដាល**

ដោយមានលោក ជាក្រឡាបញ្ជី អមផង បានសួរកត់យកចម្លើយរបស់៖

| | |
|---|---|
| នាមត្រកូលនិងនាមខ្លួន | ៖ ភេទប្រុស អាយុ ៦៧ឆ្នាំ ជា ជនសង្ស័យ។ |
| ជនជាតិ | ៖ ខ្មែរ / សញ្ជាតិ៖ ខ្មែរ មុខរបរ៖ នៅផ្ទះ លេខទូរស័ព្ទៈ ។ |
| ប្រពន្ធឈ្មោះ | ៖ មានកូន ៤នាក់ ។ |
| ទីកន្លែងកំណើត | ៖ ភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល ។ |
| ទីលំនៅបច្ចុប្បន្ន | ៖ ភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល។ |
| ឪពុកបង្កើតឈ្មោះ | ៖ ម្ដាយឈ្មោះ ។ |
| កំរិតវប្បធម៌ | ៖ ថ្នាក់ទី៦ចាស់ / ទោសពីមុន៖ មិនមាន។ |

*សួរ/ឆ្លើយ៖* ខ្ញុំបាទ ត្រូវជាពូបង្កើតរបស់ឈ្មោះ ភេទស្រី អាយុ ៣២ឆ្នាំ ព្រោះឪពុករបស់នាងគឺជាបងបង្កើតរបស់ខ្ញុំ រីឯឈ្មោះ ត្រូវជាកូនរបស់បងស្រីខ្ញុំបង្កើតឈ្មោះ ។

*សួរ/ឆ្លើយ៖* នៅថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១៧ វេលាម៉ោង៤រសៀល ឈ្មោះ បានហៅឡានដឹកដីទម្ងន់៥តោនឱ្យយកដីមកចាក់នៅលើដីរបស់បងស្រីខ្ញុំឈ្មោះ ចំនួន៥ឡាន និងចាក់នៅជុំវិញផ្ទះរបស់បងស្រីខ្ញុំឈ្មោះ និងត្រូវជាម្ដាយរបស់ឈ្មោះ ចំនួន០៥ឡានដែរ។ ពេលឃើញចាក់ដីដូចនេះ ខ្ញុំបាទម្នាក់ឯងបានដើរទៅសួរនាំឈ្មោះ ដោយសារផ្ទះខ្ញុំនៅក្បែរនោះដែរ ហើយខ្ញុំក៏សួរថា *ហេតុអ្វីហ្អែងមកចាក់ដីនៅទីនេះ ក្នុងគោលបំណងអ្វី* ? ប៉ុន្តែឈ្មោះ បានឆ្លើយតបមកខ្ញុំដោយពាក្យមិនសមរម្យថា *អាញ់ចាក់ដីស្រេចតែអាញ់ គ្មានទើសក្បាលកណ្ដុយម៉ែអាណាទេ។* ខ្ញុំក៏បានប្រាប់ឈ្មោះនោះថា *បើចង់ជេរ ជេរត្រឹមអាញ់ បានហើយកុំជេរដល់ម៉ែអាញ់* វាក៏ឆ្លើយថា *ស្រេចតែអាញ់* ហើយ ខ្ញុំក៏ប្រាប់វាថា *ប្រយ័ត្នអាញ់វាយ* វាក៏បានឌឺខ្ញុំថា *ហែងវាយមកៗ* ពេលនោះខ្ញុំក៏ទាញកអាវឈ្មោះ ប៉ុន្តែមានឈ្មោះ ជាម្ចាស់ឡានដឹកដីបានមកអោបខ្ញុំពីក្រោយ ហើយឈ្មោះ បានយកដុំឥដ្ឋតាន់មួយដុំមកវាយក្បាលខ្ញុំបែកចំនួន ០៤ថ្មេរ ហើយឈ្មោះ ក៏បានរត់ចេញពីកន្លែងកើតហេតុ ចំណែកឈ្មោះ ក៏បានយកដុំថ្មបំរ៉ុងគប់មកលើខ្ញុំទៀត ប៉ុន្តែមិនហ៊ានគប់ក៏រត់ចេញពីផ្ទះគេចមកនៅភ្នំពេញបាត់។

សួរ/ឆ្លើយ៖ ដីដែលសាងសង់ផ្ទះនោះគឺជាកម្មសិទ្ធរបស់បងស្រីរបស់ខ្ញុំឈ្មោះ: សព្វថ្ងៃគាត់រស់នៅជាមួយខ្ញុំ ដោយសារគាត់មិនមានប្តី និងកូនទេ។ ចំពោះមូលហេតុដែលសាងសង់ផ្ទះនៅលើដីរបស់ឈ្មោះ: ហ៊ាង ឡេងហួយ ដោយសារតែឈ្មោះ: និងឈ្មោះ: ត្រូវជាបងប្អូនបង្កើតជាមួយគ្នា ហើយណាមួយហ៊ុងស៊ុយចិនសែនបានទាយថាអាចសង់ផ្ទះបានតែនៅលើទីតាំងដីនោះតែប៉ុណ្ណោះ មិនអាចធ្វើកន្លែងផ្សេងបាន។

សួរ/ឆ្លើយ៖ គោលបំណងដែលខ្ញុំទៅសួរគេរឿងចាក់ដីនោះគឺគ្រាន់តែចង់ដឹងថាគេចាក់ដីដើម្បីធ្វើអ្វី ហើយគ្រាន់ចង់ដឹងថាគេចាក់នោះមានសុំម្ចាស់ដីគេហើយឬនៅតែប៉ុណ្ណោះ។ ខ្ញុំមិនដែលគិតថាដីដែលសាងសង់ផ្ទះរបស់បងស្រីខ្ញុំនោះជាដីរបស់ខ្ញុំម្តងណាទេ ។

បញ្ឈប់កំណត់ហេតុនៅវេលាម៉ោង ដប់ប្រាំ និង សូន្យ នាទី នាថ្ងៃខែឆ្នាំដដែល។

បានអានឱ្យសាមីខ្លួនស្តាប់ឆ្លើយថាត្រឹមត្រូវហើយ ហើយយល់ព្រមផ្តិតម្រាមដៃឬចុះហត្ថលេខាជាមួយយើង។

**អ្នកឆ្លើយ**

**ក្រឡាបញ្ជី**

**ព្រះរាជអាជ្ញារង**

**ឧបសម្ព័ន្ធទី ៤**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងខេត្តកណ្តាល

លេខៈ ០២៤.. ដក.សប

# ដីកាសម្រេចបញ្ចូលសំណុំរឿង[1]

**យើង** **តំណាងអយ្យការ អមសាលាដំបូងខេត្តកណ្តាល**

**-បានឃើញ៖** សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៥៣១ អ.ក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ ដែលមានឈ្មោះ ភេទប្រុស អាយុ ៣៨ឆ្នាំ និងឈ្មោះ ភេទស្រី អាយុ ៣២ឆ្នាំ ជាដើមបណ្តឹងរដ្ឋប្បវេណី និងឈ្មោះ ភេទប្រុស អាយុ ៦៥ឆ្នាំ ជាជនសង្ស័យ ពាក់ព័ន្ធនឹងករណី ហិង្សាដោយចេតនា ប្រព្រឹត្តនៅ ភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ ។ *(សំណុំរឿងនៅដំណាក់កាលអយ្យការ)*

**-បានឃើញ៖** សំណុំរឿងព្រហ្មទណ្ឌលេខៈ ១២១០ អ.ក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧ ដែលមានឈ្មោះ ភេទប្រុស អាយុ ៦៣ឆ្នាំ ជាដើមបណ្តឹងរដ្ឋប្បវេណី និងឈ្មោះ ភេទប្រុស អាយុ ៣៨ឆ្នាំ និងឈ្មោះ ភេទស្រី អាយុ៣២ឆ្នាំ ជាជនត្រូវចោទ ពាក់ព័ន្ធនឹងករណី ហិង្សាដោយចេតនា ប្រព្រឹត្តនៅ ភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ ។ *(សំណុំរឿងនៅដំណាក់កាលចៅក្រមស៊ើបសួរ)*

## ក្រោយពីបានពិនិត្យសំណុំរឿងខាងលើរួចមក

**-យល់ឃើញថា៖** សំណុំរឿងទាំងពីរខាងលើ គូរភាគីទំនាស់បានប្តឹងគ្នាទៅវិញទៅមក ទីកន្លែងប្រព្រឹត្ត និងអំពើល្មើសដូចគ្នា។ ម្យ៉ាងទៀតសំណុំរឿងទាំងពីរនេះ មិនទាន់មានសំណុំរឿងណាមួយត្រូវបានតុលាការបើកសវនាការនៅឡើយទេ។

**-យល់ឃើញថា៖** ដើម្បីងាយស្រួលក្នុងកិច្ចដំណើរការនីតិវិធីស៊ើបអង្កេត និងជៀងវាងចំណាត់ការសំណុំរឿងពីរដែលមានគូរភាគីក្នុងអង្គហេតុដដែលៗ គប្បីបញ្ចូលសំណុំរឿងព្រហ្មទណ្ឌលេខៈ ១៥៣១ អ.ក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ ទៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខៈ ១២១០ អ.ក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧ ទៅជាសំណុំរឿងតែមួយ។

## ហេតុដូចនេះសម្រេច

-បញ្ចូលសំណុំរឿងព្រហ្មទណ្ឌលេខៈ ១៥៣១ អ.ក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ ទៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខៈ ១២១០ អ.ក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧ ដើម្បីចាត់ការតាមផ្លូវច្បាប់ ។

ថ្ងៃសុក្រ ៧កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ខេត្តកណ្តាល ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០

តំណាងអយ្យការ

[1] មាត្រា ២៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ស្តីពីការបញ្ចូលនីតិវិធី ។

**ឧបសម្ព័ន្ធទី ៥**

០៧/៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

លេខ ៖ ៤៧៦១

# ដីកាសម្រេចមិនឃុំខ្លួន

**យើង ម្លូខ ទិសាល** ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល

-បានឃើញមាត្រា ២០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៖ ១២១០ អក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៖ ០៤០ ដកសស ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញកំណត់ហេតុសួរចម្លើយជនត្រូវចោទឈ្មោះ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០ ។

*ក្រោយពីបានពិនិត្យលើសំណុំរឿងចប់សព្វគ្រប់ យល់ឃើញថា:*

ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ ៦៥ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិស្វាយជ្រំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល ឪពុកឈ្មោះ ម្ដាយឈ្មោះ ប្រពន្ធឈ្មោះ មានកូន ០៤នាក់ ជានីតិជន ។

ត្រូវជាប់ចោទពីបទ ៖ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិស្វាយជ្រំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

**យល់ឃើញថា:**

-បទល្មើសជាបទមជ្ឈិម
-ជននេះមិនបង្កការលំបាកដល់ការស៊ើបសួរ
-ជននេះមានអាសយដ្ឋាន និងមានមុខរបរពិតប្រាកដ
-ការសម្រេចមិនឃុំខ្លួននេះ មិនប៉ះពាល់ដល់នីតិវិធីរបស់តុលាការទេ

**ហេតុដូច្នេះសម្រេច**

-មិនឃុំខ្លួនឈ្មោះខាងលើ ដោយអនុញ្ញាតឱ្យមានសេរីភាពធម្មតាវិញ តែត្រូវឱ្យឈ្មោះនេះចូលទៅបង្ហាញខ្លួននៅចំពោះមុខសាលាដំបូងជាដរាប កាលណាមានដីកាកោះហៅ ។

ថ្ងៃអង្គារ ៨រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
កណ្ដាល, ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០

បានទទួលដំណឹងរួចហើយ
កណ្ដាល ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ២០២០
ព្រះរាជអាជ្ញារង

**ចៅក្រមស៊ើបសួរ**

៣០

ព្រះរាជអាជ្ញារង

## ឧបសម្ព័ន្ធទី ៦

<u>គំរូដីកាបង្គាប់ឲ្យចូលខ្លួន៖</u>

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

<u>**សាលាដំបូងខេត្ត.............**</u>

លេខអយ្យការ: .........................

លេខស៊ើបសួរ: .........................

លេខ:.........................

## <u>ដីកាបង្គាប់ឲ្យចូលខ្លួន</u>

**យើង ..................... ចៅក្រមស៊ើបសួរសាលាដំបូងខេត្ត............ ។**

បានឃើញក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ: នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌស៊ើបសួរនោះ: ទាក់ទងនឹងការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ .................... ចុះថ្ងៃទី .......... ខែ..........ឆ្នាំ ........... របស់តំណាងអយ្យការអមសាលាដំបូងខេត្ត .................. ដែលបើកការប្រឆាំងនឹងជនត្រូវចោទឈ្មោះ ...................... ពីបទ: .................... ប្រព្រឹត្តនៅភូមិ ........ ឃុំ ........ ស្រុក .......... ខេត្ត .......... កាលពីថ្ងៃទី........ ខែ.......... ឆ្នាំ........ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា......... នៃច្បាប់............................ ។

## <u>បង្គាប់មក</u>

ឈ្មោះ .................. ភេទ..... អាយុ....... រស់នៅភូមិ ....... ឃុំ........ស្រុក.........ខេត្ត...................

<u>**ឲ្យចូលមកកាន់សាលាដំបូងខេត្ត..................................**</u> ។

- **នៅថ្ងៃទី .................. ខែ ............. ឆ្នាំ ............ វេលាម៉ោង ............................** ជាកំណត់ ។
- ដើម្បី ឆ្លើយបំភ្លឺពីដំណើររឿងពាក់ព័ន្ធ និងសំណុំរឿងព្រហ្មទណ្ឌខាងលើ ។

សាមីខ្លួនត្រូវចូលមកបង្ហាញខ្លួនឲ្យទាន់ពេលវេលា តាមការកំណត់ខាងលើ និងយកលិខិតផ្សេងៗ ដែលទាក់ទងនិងសំណុំរឿងខាងលើមកជាមួយផងប្រសិនបើមាន។

ក្នុងករណីមិនចូលខ្លួនតាមការកំណត់ខាងលើទេ <u>**យើងនឹងចេញបញ្ជាឱ្យកម្លាំងសាធារណៈបង្ខំសាមីខ្លួនឱ្យចូលមកបង្ហាញខ្លួនទី យើងចេញដីកាបង្គាប់ឱ្យនាំខ្លួន ។**</u>

ធ្វើនៅ........... ថ្ងៃទី .......... ខែ .......... ឆ្នាំ..........

**ចៅក្រមស៊ើបសួរ**

**ហត្ថលេខា និង ត្រា**

**ឧបសម្ព័ន្ធទី ៧**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងព្រហ្មទណ្ឌលេខ ៖ ១២១០ អក
ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ ២០១៧
លេខ ៖...521...................

## ដីកាបញ្ជូនពត៌មាន

យើង ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល

បញ្ជាឱ្យបញ្ជូនសំណុំរឿងស៊ើបសួរទាក់ទងនឹងឈ្មោះ ឈ្មោះ នឹងឈ្មោះ

ជាជនត្រូវចោទ នៅក្នុងការស៊ើបសួរពីបទៈ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

ទៅព្រះរាជអាជ្ញា ដើម្បីធ្វើសេចក្តីសន្និដ្ឋាន ឬផ្តល់យោបល់លើការបិទការស៊ើបសួរលើសំណុំរឿងព្រហ្មទណ្ឌលេខ ១២១០ អក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧ ។

ថ្ងៃព្រហស្បត្តិ៍ ០៧ រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
កណ្តាល ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ ២០២១
**ចៅក្រមស៊ើបសួរ**

**យោបល់របស់តំណាងអយ្យការ**

យើង.... ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តកណ្តាល ។
បានឃើញដីកាបញ្ជូនពត៌មានខាងលើ
បានឃើញសំណុំរឿងស៊ើបសួរលើឈ្មោះ......... ..................................
ក្រោយពីបានពិនិត្យសំណុំរឿងស៊ើបសួរចប់ ស្នើសុំ ៖
..............................បិទការស៊ើបសួរ..............................

ថ្ងៃ..................ខែ..........ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
កណ្តាល ថ្ងៃទី..04.. ខែ..02.. ឆ្នាំ២០..21
**ព្រះរាជអាជ្ញារង**

**ឧបសម្ព័ន្ធទី ៨**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល
សំណុំរឿងលេខៈ ១៨៥០ អ.ក
ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧
លេខៈ 1382 "ព"

## ដីកាបញ្ជូនសំណុំរឿងឲ្យពិនិត្យ

យើង **ខួន ឧត្តី** ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល។

-បានឃើញមាត្រា ២៤៦ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

-បានឃើញសំណុំរឿងស៊ើបសួរដែលទាក់ទងនឹងជនត្រូវចោទ៖

១/ ឈ្មោះ [illegible] ភេទប្រុស អាយុ ៣០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកធនាគារអេស៊ីលីដា ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល ប្រពន្ធឈ្មោះ [illegible] មានកូន ០១នាក់ ឪពុកឈ្មោះ [illegible] (ក) ម្ដាយឈ្មោះ [illegible] (ក) ជានីតិជន ទោសពីមុន គ្មាន ។

២/ ឈ្មោះ [illegible] ភេទស្រី អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ មុខរបរបុគ្គលិក ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិផ្លូវត្រី ឃុំថ្មគរ ស្រុកល្វាឯម ខេត្តកណ្ដាល ប្រពន្ធឈ្មោះ [illegible] មានកូន ០១នាក់ ឪពុកឈ្មោះ [illegible] (ក) ម្ដាយឈ្មោះ [illegible] (ក) ជានីតិជន ទោសពីមុន គ្មាន ។

ត្រូវដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទៈ **ជេរប្រមាថជាសាធារណៈ និងហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ៣០៧ និងមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

បញ្ជាឲ្យបញ្ជូនសំណុំរឿងស៊ើបសួរនេះ ទៅ**ព្រះរាជអាជ្ញា** ដើម្បីធ្វើសេចក្ដីសន្និដ្ឋាន ឬ ផ្ដល់យោបល់ទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
កណ្ដាល ថ្ងៃទី 17 ខែ [illegible] ឆ្នាំ២០១៨
**ចៅក្រមស៊ើបសួរ**

ខួន ឧត្តី

បានអនុវត្តន៍
**ក្រឡាបញ្ជី**

ផាន់ ផារិទ្ធិ

**ឧបសម្ព័ន្ធទី ៩**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខ ១២១០ អ.ក

ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧

លេខ : ២៤១ ដកសព

# <u>ដីកាសន្និដ្ឋានស្ថាពរ</u>

**យើង** **តំណាងអយ្យការ អមសាលាដំបូងខេត្តកណ្ដាល**

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ៖ ០៤០ ដកសស ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨ ។

-បានឃើញសំណុំរឿងស៊ើបសួរលេខ៖ ០២២ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកណ្ដាល។

-បានឃើញ ដីកាបញ្ជូនសំណុំរឿងឲ្យពិនិត្យលេខ៖ ៥២១ ចុះថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**ឃើញថា៖**

១-នាម-គោត្តនាម ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ។ ទីកន្លែងកំណើតភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល។ ទីលំនៅបច្ចុប្បន្នផ្ទះលេខ២៦៩ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ឪពុកឈ្មោះ ម្ដាយឈ្មោះ ។ ប្រពន្ធឈ្មោះ

មានកូនចំនួន ០២នាក់ ។ ☑នីតិជន ។ ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

២-នាម-គោត្តនាម ភេទស្រី អាយុ៣២ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ។ ទីកន្លែងកំណើតភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល។ ទីលំនៅបច្ចុប្បន្នផ្ទះលេខ២៦៩ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ឪពុកឈ្មោះ ម្ដាយឈ្មោះ ។ ប្ដីឈ្មោះ

មានកូនចំនួន ០២នាក់ ។ ☑នីតិជន ។ ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

៣-នាម-គោត្តនាម ភេទប្រុស អាយុ៦៧ឆ្នាំ ជនជាតិខ្មែរ មុខរបរនៅផ្ទះ។ ទីកន្លែងកំណើតនិងទីលំនៅបច្ចុប្បន្ននៅភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល។ ឪពុកឈ្មោះ
ម្ដាយឈ្មោះ ។ ពោះម៉ាយ មានកូនចំនួន ០៤នាក់ ។ ☑នីតិជន ។ ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ ហិង្សាដោយចេតនា (ទៅវិញទៅមក) ប្រព្រឹត្តនៅភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល កាលពីថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

**ឃើញថា៖** កាលពីថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១៧ វេលាម៉ោង ១៦ និង ១០នាទី មានករណីហិង្សាដោយចេតនាទៅវិញទៅមកមួយកើតឡើង ស្ថិតនៅចំនុចដីឡូត៍ឈ្មោះ ហ៊ាង ណាងហ៊ួយ ក្នុងភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខ

កំពូល ខេត្តកណ្ដាល បង្កឡើងដោយឈ្មោះ ភេទប្រុស អាយុ៣៨ឆ្នាំ និងប្រពន្ធឈ្មោះ ភេទស្រី អាយុ៣២ឆ្នាំ វាយគ្នាជាមួយឈ្មោះ ភេទប្រុស អាយុ៦៧ឆ្នាំ។ ដំណើររឿងគឺឈ្មោះ បានទៅហាមឃាត់ឈ្មោះ និងប្រពន្ធឈ្មោះ កុំឱ្យដាក់ដីបន្ថែមលើម៉ុងឡោច របស់ឈ្មោះ ខណៈពេលនោះក៏មានការទាស់សំដីគ្នា រួមឈ្មោះ ប្រតាយប្រតប់គ្នា ជាមួយឈ្មោះ និង របួសរាងៗខ្លួន។

**យល់ឃើញថា៖**

-យោងតាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ចម្លើយរបស់ជនត្រូវចោទ ព្រមទាំងភស្តុតាងនានាក្នុងសំណុំរឿង គឺអាចបញ្ជាក់ឱ្យឃើញថា៖ កាលពីថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១៧ វេលាម៉ោង ១៦ និង ១០នាទី មានករណីហិង្សាដោយចេតនាទៅវិញទៅមកមួយកើតឡើង ស្ថិតនៅចំនុចដីឡូតិ៍ឈ្មោះ ក្នុងភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល បង្កឡើងដោយឈ្មោះ ភេទប្រុស អាយុ៣៨ឆ្នាំ និងប្រពន្ធឈ្មោះ ភេទស្រី អាយុ៣២ឆ្នាំ វាយគ្នាជាមួយ ទៅវិញទៅមកប្រាកដមែន។

-មានភស្តុតាងដាក់បន្ទុកលើឈ្មោះ ភេទប្រុស អាយុ៣៨ឆ្នាំ, ឈ្មោះ ភេទស្រី អាយុ៣២ឆ្នាំ និង ភេទប្រុស អាយុ៦៧ឆ្នាំ ពីបទ៖ ហិង្សាដោយចេតនា (ទៅវិញទៅមក) ប្រព្រឹត្តនៅភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល កាលពីថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

<u>**ហេតុដូច្នេះ**</u>

ប្តឹងសុំឱ្យចៅក្រមស៊ើបសួរសម្រេច៖

បញ្ជូនជនត្រូវចោទ៖

១-ឈ្មោះ ភេទប្រុស អាយុ៣៨ឆ្នាំ

២-ឈ្មោះ ភេទស្រី អាយុ៣២ឆ្នាំ

៣-ឈ្មោះ ភេទប្រុស អាយុ៦៧ឆ្នាំ

ទៅជំនុំជម្រះ ពីបទ៖ ហិង្សាដោយចេតនា (ទៅវិញទៅមក) ប្រព្រឹត្តនៅភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល កាលពីថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

ថ្ងៃព្រហស្បតិ៍ ៧រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

កណ្ដាល, ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១

**តំណាងអយ្យការ**

ព្រះរាជអាជ្ញារង

**ឧបសម្ព័ន្ធទី ១០**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

លេខ...5ឱ3.............

# លិខិតជូនពត៌មានអំពីការបិទការស៊ើបសួរ

យើង ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល

ប្រាប់មកជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ ៣៨ ឆ្នាំ សញ្ជាតិ ខ្មែរ មុខរបរ កសិករ មានទីកន្លែងកំណើតភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្នផ្ទះលេខ ២៦៩ សង្កាត់ទឹកល្អក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ មានកូន ០២ នាក់ ឪពុកឈ្មោះ ម្តាយឈ្មោះ ជានីតិជន ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

ឱ្យបានដឹងថា ៖ ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល បានបិទការស៊ើបសួរ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ១២១០ អក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧ ពីបទ ហិង្សាដោយអចេតនា ប្រព្រឹត្តនៅភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

យើងនឹងបញ្ជូនសំណុំរឿងទៅតំណាងអយ្យការក្នុងរយៈពេល២ថ្ងៃទៀត។

អាស្រ័យហេតុនេះ សូមលោក-លោកស្រីទទួលជាដំណឹង ។

ថ្ងៃ ព្រហស្បត្តិ៍ ០៧ រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

កណ្តាល ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១

ចៅក្រមស៊ើបសួរ

យើង...................................បានប្រគល់លិខិត

ជូនដំណឹងនេះដល់ឈ្មោះ.................................

ទីលំនៅភូមិ..........................ឃុំ........................

ស្រុក............................ខេត្ត...........................

នៅថ្ងៃទី.....ខែ..........ឆ្នាំ.........ផ្ទាល់ដៃរួចហើយ ។

ធ្វើនៅថ្ងៃទី...........ខែ...............ឆ្នាំ២០....

អ្នកទទួល អ្នកប្រគល់

**ឧបសម្ព័ន្ធទី ១១**

07

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

លេខ...៣៩០...........

## លិខិតជូនដំណឹងពីដីកាដំណោះស្រាយ

យើង ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល

បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ១២១០ អក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧ ពីបទ: **ហិង្សាដោយចេតនា (ទៅវិញទៅមក)** ប្រព្រឹត្តនៅភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ អំពើល្មើសព្រហ្មទណ្ឌដែលមានចែងត្រូវផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

សូមជូនដំណឹងដល់ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ ៣៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កសិករ ទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ២៦៩ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេ

ត្បិតសំណុំរឿងខាងលើនេះយើងបានសម្រេច ៖

១- ចោទប្រកាន់លើជនត្រូវចោទ:

១.១. ឈ្មោះ (អត្តសញ្ញាណខាងលើ)

១.២. ឈ្មោះ (អត្តសញ្ញាណខាងលើ)

១.៣. ឈ្មោះ (អត្តសញ្ញាណខាងលើ)

ពីបទ: **ហិង្សាដោយចេតនា (ទៅវិញទៅមក)** ប្រព្រឹត្តនៅភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល កាលពីថ្ងៃ ០១៧ អំពើល្មើសព្រហ្មទណ្ឌដែលមានចែងត្រូវផ្ដន្ទាទោសតាមបញ្ញត្តិមាត្រ ទណ្ឌ។

២- បញ្ជូនជនត្រូវចោទឈ្មោះ (អត្តសញ្ញាណខាងលើ) ឈ្មោះ (អត្តសញ្ញាណខាងលើ) និងឈ្មោះ (អត្តសញ្ញាណខាងលើ) ព្រមទាំងសំណុំរឿងខាងលើ និងបញ្ជីរាយនាមជនដែលជាប់ទាក់ទិនក្នុងសំណុំរឿងនេះទៅសាលាដំបូងខេត្តកណ្ដាល ដើម្បីជំនុំជម្រះតាមផ្លូវច្បាប់ ។

ថ្ងៃ[illegible] ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស២៥៦៤

កណ្ដាល ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០២១

**ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធទី ១២**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

**ដីកាសម្រេចដាក់រឿងជំនុំជម្រះ**

លេខ ៖....០៤.....ដកសជជរ

យើង                    ចៅក្រមជំនុំជម្រះនៃសាលាដំបូងខេត្តកណ្ដាល

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ៖ ១២១០ អក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្ដាល។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ៖ ២៨១ ដកសព ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល។

**សម្រេច**

១-ដាក់សំណុំរឿងព្រហ្មទណ្ឌលេខ ៖ ១២១០ អក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧ មានជនជាប់ចោទ៖

ក-ឈ្មោះ                    ភេទប្រុស អាយុ៣៨ ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ ២៦៩ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ (ក្រៅឃុំ)

ខ-ឈ្មោះ                    ភេទស្រី អាយុ៣២ ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ២៦៩ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ (ក្រៅឃុំ)

គ-ឈ្មោះ                    ភេទប្រុស អាយុ៦៧ ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល។(ក្រៅឃុំ)

ត្រូវដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ ហិង្សាដោយចេតនា (ទៅវិញទៅមក) ប្រព្រឹត្តនៅភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ បទល្មើសដែលបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ទៅជំនុំជម្រះ។

ជូន ចៅក្រមជំនុំជម្រះ នៃសាលាដំបូងខេត្តកណ្ដាល ដើម្បីជំនុំជម្រះជាសាធារណៈនៅថ្ងៃទី..២៥.. ខែ..សីហា.... ឆ្នាំ២០២១ វេលាម៉ោង ......០៩........៖ ០០ នាទីព្រឹក/~~រសៀល~~ បន្ទប់សវនាការលេខ ០២។

២-សមាសភាពចូលរួមក្នុងនីតិវិធីសវនាការ ៖

-លោក                    ចៅក្រមជំនុំជម្រះ

-លោក  .........................  តំណាងអយ្យការ

-លោក                    ក្រឡាបញ្ជីសវនាការ

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
កណ្ដាល ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២១
ចៅក្រមជំនុំជម្រះ

**ឧបសម្ព័ន្ធទី ១៣**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ ............
ចុះថ្ងៃទី ....... ខែ .............. ឆ្នាំ ២០១៦
លេខ ៖ ..............................អ.យ.ណ

**<u>ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ</u>**

**យើង** [redacted] **ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។**

**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ ............. ចុះថ្ងៃទី ...... ខែមិថុនា ឆ្នាំ ២០១៦ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**បានឃើញ** របាយការណ៍សំយោគលេខ ............ រ.ប.ក ចុះថ្ងៃទី...... ខែមិថុនា ឆ្នាំ២០១៦ របស់អធិការដ្ឋាននគរបាលខណ្ឌដង្កោ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

**<u>ក្រោយពីបានពិនិត្យឯកសារខាងលើ</u>**

**យល់ឃើញថាមានតម្រុយសន្មត**

១. ឈ្មោះ **កកកកកក** ហៅ **ខ្វង** ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើត ភូមិរាំងដេក ឃុំគគីរធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ទីលំនៅបច្ចុប្បន្ន ផ្ទះជួល ភូមិក្បាលទំនប់ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ **ទទទទទទ** (រ) ម្ដាយឈ្មោះ **ននននន** (រ) ប្រពន្ធឈ្មោះ **សសសស** (រ) មានកូន ០១នាក់ ជានីតិជន ទោសពីមុនគ្មាន។

២. ឈ្មោះ **ខខខខ** ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ កាន់សាសនាព្រះពុទ្ធ ទីកន្លែកំណើត ភូមិគរ ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្ដាល ទីលំនៅបច្ចុប្បន្ន ផ្ទះជួល ភូមិក្បាលទំនប់ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ **ងងងងង** (រ) ម្ដាយឈ្មោះ **ឆឆឆឆឆ** (ស) ប្រពន្ធឈ្មោះ **បបបបប** (រ) មានកូន ០៣នាក់ ជានីតិជន ទោសពីមុនគ្មាន។

**បានប្រព្រឹត្តអំពើដូចតទៅ**

កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ១៩និង០០នាទី កម្លាំងចម្រុះរបស់គណ:បញ្ជាការឯកភាពខណ្ឌដង្កោ បានចុះត្រួតពិនិត្យអាវុធជាតិផ្ទុះទៅលើយានជំនិះគ្រប់ប្រភេទ លើបណ្ដោយផ្លូវ២១៧ ត្រង់ចំណុចមុខវត្តសំបូរមាស ភូមិម័ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។ លុះដល់ម៉ោងប្រហែល ១៩និង៥០នាទី មានជនសង្ស័យចំនួន ០២នាក់ ឈ្មោះ **កកកកកក** ហៅ **ខ្វង** ភេទប្រុស អាយុ ២៧ឆ្នាំ និងឈ្មោះ **ខខខខ** ភេទប្រុស អាយុ ២៥ឆ្នាំ ជិះម៉ូតូ០១គ្រឿង ម៉ាកដូវេ ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 1AW-3628 ទិសដៅពីជើង ទៅត្បូង ហើយសមត្ថកិច្ចក៏បានឆែកឆេរឃើញមាន ក្រាមពណ៌សថ្លាចំនួន ០៣កញ្ចប់ថង់តូច ប្រភេទមេតំហ្វេតាមីនមានទម្ងន់ ០,៣៨ក្រាម (សូន្យក្រាមសាមសិបប្រាំបី) នៅក្នុងកាបូបលុយរបស់ជនសង្ស័យឈ្មោះ **កកកកកក** ហៅ **ខ្វង** រួចសមត្ថកិច្ចក៏ធ្វើការឃាត់ខ្លួនជនសង្ស័យទាំង ០២នាក់ និងវត្ថុតាងមកសាកសួរនៅអធិការដ្ឋានខណ្ឌដង្កោ។ ក្រោយពីការសាកសួរ ជនសង្ស័យបានសារភាពថា ជនសង្ស័យបានចូលលុយគ្នា ទិញថ្នាំញៀន ពីបុរសម្នាក់មិនស្គាល់ឈ្មោះ នៅម្ដុំផ្លូវ៦០ម៉ែត្រ ភូមិព្រែកតាគង់ សង្កាត់ចាក់អង្រែ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ចំនួន ០៣កញ្ចប់តូច ក្នុងតម្លៃ ៣០ ដុល្លារអាមេរិក។

អំពើខាងលើជាបទល្មើស **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខវត្តសំបូរមាស ផ្លូវ២១៧ ភូមិម៉ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៦ តាមមាត្រា **៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**បានឃើញ** មាត្រា ៤៤ និង មាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## <u>សម្រេច</u>

**បើកការស៊ើបសួរលើអង្គហេតុខាងលើ និង**

☑ ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យលើ៖

១. ឈ្មោះ **កកកកកក** ហៅ **ខ្វង** ភេទប្រុស អាយុ ២៧ឆ្នាំ (ឃាត់ខ្លួន)

២. ឈ្មោះ **ខខខខ** ភេទប្រុស អាយុ ២៥ឆ្នាំ (ឃាត់ខ្លួន)

ពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខវត្តសំបូរមាស ផ្លូវ២១៧ ភូមិម៉ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៦ តាមមាត្រា **៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

☑ ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្នលើជនខាងលើ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែមិថុនា ឆ្នាំ២០១៦

**ជ.ព្រះរាជអាជ្ញា**

**ឧបសម្ព័ន្ធទី ១៤**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូង..............................

សំណុំរឿងរដ្ឋប្បវេណីលេខ:.........

ថ្ងៃទី.........ខែ............ឆ្នាំ២០១.......

លេខ:.................................../អ.យ

# ដីកាកោះបញ្ជូនទៅជំនុំជំរះផ្ទាល់

**យើង .........................................អយ្យការអមសាលាដំបូង...........................។**

**បញ្ជាឲ្យចូលទៅបង្ហាញខ្លួននៅសវនាការ:**

១/នាម-គោត្តនាម..................................ហៅ..............................ភេទ□ប្រុស□ស្រី អាយុ......ឆ្នាំ

ជាតិ.........................................របររកស៊ី...............................................................ទី

កន្លែងកំណើត...................................ឃុំ-សង្កាត់...........................ស្រុក-ខណ្ឌ......................

ខេត្ត-ក្រុង..............................................។

ទីលំនៅបច្ចុប្បន្ន.................................ឃុំ-សង្កាត់...........................ស្រុក-ខណ្ឌ...................

ខេត្ត-ក្រុង..............................................។

ទោសពីមុន...........ឪពុកឈ្មោះ........................"□រ-□ស" ម្តាយឈ្មោះ.......................“□រ-□ស”

ប្តី ឬ ប្រពន្ធឈ្មោះ...................... "□រ-□ស" មានកូន.........នាក់ ឬ □នៅលីវ□អនីតិជន □នីតិជន។

២/នាម-គោត្តនាម..................................ហៅ..............................ភេទ□ប្រុស□ស្រី អាយុ......ឆ្នាំ

ជាតិ...............................របររកស៊ី..................................................................................

ទីកន្លែងកំណើត..................................ឃុំ-សង្កាត់...........................ស្រុក-ខណ្ឌ...................

ខេត្ត-ក្រុង..............................................។

ទីលំនៅបច្ចុប្បន្ន.................................ឃុំ-សង្កាត់...........................ស្រុក-ខណ្ឌ...................

ខេត្ត-ក្រុង..............................................។

ទោសពីមុន...........ឪពុកឈ្មោះ........................"□រ-□ស" ម្តាយឈ្មោះ.......................“□រ-□ស”

ប្តី ឬ ប្រពន្ធឈ្មោះ...................... "□រ-□ស" មានកូន.........នាក់ ឬ □នៅលីវ□អនីតិជន □នីតិជន។

អ្នកត្រូវចោទប្រកាន់ពីអង្គហេតុ:

......................................................................................................................................

......................................................................................................................................

......................................................................................................................................

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

ជាបទល្មើស:....................................................................................

ប្រព្រឹត្តនៅ.......................................................ឃុំ-សង្កាត់.................................................

ស្រុក-ខណ្ឌ.......................................................ខេត្ត-ក្រុង................................................ ....

កាលពីថ្ងៃទី..........ខែ.................ឆ្នាំ២០១......តាមបញ្ញត្តិមាត្រា................................................

នៃ...........................................................................................................................។

សវនាការនេះ និងប្រព្រឹត្តទៅនៅថ្ងៃទី.......ខែ...........ឆ្នាំ២០១...វេលាម៉ោង.........

នៅ...........................................................................................................................។

សាមីខ្លួនអាចពឹងពាក់មេធាវីឲ្យអមខ្លួនបាន។

សាមីខ្លួនត្រូវបង្ហាញខ្លួនឲ្យទានពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនឹងជីភាពសាមីខ្លួន ឬ ដំណើររឿងខាងលើមកជាមួយផង ប្រសិនបើមាន។

.................................,ថ្ងៃទី.........ខែ.............ឆ្នាំ២០១....

**ព្រះរាជអាជ្ញា/រង**

**ឧបសម្ព័ន្ធទី ១៥**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ

លេខ........................ចុះថ្ងៃទី..........
ខែ.....................ឆ្នាំ.......................
សំណុំរឿងព្រហ្មទណ្ឌលេខ ..........
ចុះថ្ងៃទី.......ខែ ឧសភា ឆ្នាំ ២០១៦

## សេចក្ដីសុំប្ដឹងតវ៉ា

ឆ្នាំពីរពាន់..........................................ខែ..............................ថ្ងៃទី..........................................
វេលាម៉ោង.................................................................................................................។
យើង..................................................ក្រឡាបញ្ជី អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
បានឃើញឈ្មោះ.....................................................................................................
ចូលមកចំពោះមុខយើង នៅការិយាល័យក្រឡាបញ្ជីនៃ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ហើយសុំប្ដឹង.............................និង..................................................លេខ.........................................
ចុះថ្ងៃទី..........................ខែ...............................ឆ្នាំ...........................ត្រង់ចំណុចៈ............................
.........................................................................................................................................
.........................................................................................................................................
.........................................................................................................................................
.........................................................................................................................................
.........................................................................................................................................
.........................................................................................................................................
.........................................................................................................................................
.........................................................................................................................................

ឈ្មោះនេះទទួលថានឹងធ្វើពាក្យបណ្ដឹងបន្ថែម ឲ្យទាន់ពេលវេលា។

ក្រែងពុំប្រាកដ យើងបានសូត្រសេចក្ដីនេះ ឲ្យឈ្មោះ........................................................ស្ដាប់ហើយ ឲ្យចុះហត្ថលេខា ឬ "ផ្ដិតមេដៃ" ជាមួយយើង។

**អ្នកប្ដឹង** **ក្រឡាបញ្ជី**

**ឧបសម្ព័ន្ធទី ១៦**

<u>គំរូកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម</u>

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**អយ្យការអមសាលាដំបូង**

**ក្រុងភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ.......

ចុះថ្ងៃទី.....ខែ.......ឆ្នាំ២០០..

## កំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម

ឆ្នាំពីរពាន់...............ខែ............ថ្ងៃទី................វេលាម៉ោង..............។

**យើង**....................................តំណាងអយ្យការអមសាលាដំបូងក្រុងភ្នំពេញ

បានឃើញសំណុំរឿងលេខ[៨] ......................ចុះថ្ងៃទី.........ខែ.........ឆ្នាំ.......

របស់........................................................។

បុគ្គលដែលនៅចំពោះមុខយើង បានផ្តល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម :

នាមត្រកូល.......................នាមខ្លួន...............................ហៅ..........

ភេទ........អាយុ.......ឆ្នាំជាតិ................របររកស៊ី..............................

**ទីកន្លែងកំណើត**..........................ឃុំ-សង្កាត់..................................

ស្រុក-ខណ្ឌ................................ខេត្ត-ក្រុង..............................

**ទីលំនៅបច្ចុប្បន្ន**.......................... ឃុំ-សង្កាត់..................................

ស្រុក-ខណ្ឌ....................................ខេត្ត-ក្រុង............................

ទោសពីមុន........ឪពុកឈ្មោះ....................“រ.ស”ម្តាយឈ្មោះ...................“

រ.ស” ប្តី ឬប្រពន្ធឈ្មោះ...................“រ.ស”មានកូន.........ឬនៅលីវ

អនីតិជន☐ ឬនីតិជន☐ ។

---

[៨] លេខសំណុំរឿងរបស់អង្គភាពនគរបាលយុត្តិធម៌

**យើងប្រាប់ដល់បុគ្គលនេះនូវអង្គហេតុដែលខ្លួនត្រូវបានចោទប្រកាន់មានដូចតទៅ**

:........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

............................................................................................... ។

**អង្គហេតុនេះជាបទល្មើស**................................................................................

......ប្រព្រឹត្តនៅ..........................................................................................

កាលពីថ្ងៃទី.........ខែ..........ឆ្នាំ២០០.....ដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា.................

......នៃច្បាប់........................................................................................ ។

**យើងបានទទួលចម្លើយពីជននេះដូចតទៅ:**.........................................................

.........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

.........................................................................................................។

**យើងបានប្រាប់ដល់ជននេះថា** : ខ្លួនមានសិទ្ធិសុំពឹងមេធាវី តាមការជ្រើសរើសរបស់ខ្លួន ឬស្នើសុំឱ្យ មានការចាត់តាំងមេធាវីដោយអនុលោមតាមបញ្ញត្តិច្បាប់ ។

**ជននេះបានឆ្លើយថា :**

☐ ខ្ញុំជ្រើស លោក/លោកស្រីមេធាវី ............................... ។

☐ ខ្ញុំសូមស្នើសុំឱ្យមានការចាត់តាំងមេធាវីស្របតាមបញ្ញត្តិច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

☐ ខ្ញុំមិនត្រូវការមេធាវីទេក្នុងពេលនេះ ។

**យើងបានបញ្ជាក់ថា :**

☐ លោក/លោកស្រីមេធាវី..............................អាចពិនិត្យសំណុំរឿងនិងទាក់ទង ជាមួយ ជនជាប់ចោទ ។

☐ យោងលើសំណើសុំឱ្យមានការចាត់តាំងមេធាវីស្របតាមបញ្ញត្តិច្បាប់ស្តីពីលក្ខន្តិកៈមេធាវីតំណាង គណៈមេធាវីត្រូវបានជូនដំណឹងភ្លាម ។

☐ លោក/លោកស្រីមេធាវី..............................អវត្តមាន ។

បានឃើញមាត្រា ៤៧ មាត្រា ៤៨ និងមាត្រា ៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

## សម្រេច

**បញ្ជូនជនជាប់ចោទឈ្មោះ**...................................................................... ......ទៅតុលាការដើម្បីធ្វើការជំនុំជម្រះ តាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ចំពោះអង្គហេតុ និងបទល្មើសជួច ខាងលើ ។

ក្រោយពីបានអាន ជនជាប់ចោទបានចុះហត្ថលេខាជាមួយយើង ។

**ជនជាប់ចោទ** **តំណាងអយ្យការ**

**ឧបសម្ព័ន្ធទី ១៧**

គំរូដីកាបង្គាប់ឲ្យនាំខ្លួន:

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្ត.............

លេខអយ្យការ: .........................

លេខស៊ើបសួរ: .........................

លេខ:.........................

**ដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទ**

យើង ........................ ចៅក្រមស៊ើបសួរសាលាដំបូងខេត្ត........................ ។

បានឃើញក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ: នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: ៦០០ ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៧ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌស៊ើបសួរនោះ ទាក់ទងនឹងការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ........................ ចុះថ្ងៃទី ........ ខែ ........ ឆ្នាំ .......... របស់តំណាងអយ្យការអមសាលាដំបូងខេត្ត ............ ដែលបើកការប្រឆាំងនឹងជនត្រូវចោទ ............................ ពីបទ: .................. ប្រព្រឹត្តនៅភូមិ ............ សង្កាត់ .......... ក្រុង .......... ខេត្ត ............ កាលពីថ្ងៃទី .......... ខែ ...... ឆ្នាំ .......... តាមបញ្ញត្តិមាត្រា ............ នៃច្បាប់....................................................... ។

យល់ឃើញថា ........................................................................................................ ។

យល់ឃើញថា ........................................................................................................ ។

យល់ឃើញថា ........................................................................................................ ។

**ហេតុដូច្នេះសម្រេច**

- បង្គាប់ឲ្យនាំខ្លួនឈ្មោះ ..................... ភេទ........ អាយុ.......ឆ្នាំ កើតនៅថ្ងៃទី .... ខែ .... ឆ្នាំ ....... មានទីកន្លែងកំណើតនៅភូមិ...............ឃុំ............ស្រុក...............ខេត្ត.............. និងរស់នៅបច្ចុប្បន្ននៅភូមិ............... ឃុំ............ស្រុក...............ខេត្ត............. ឪពុកឈ្មោះ: .................. ម្ដាយឈ្មោះ: ................. មកកាន់សាលាដំបូងខេត្ត....................... ដើម្បីសាកសួរយកព័ត៌មានផ្សេងៗ ទាក់ទងនឹងសំណុំរឿងព្រហ្មទណ្ឌខាងលើ ។

- បង្គាប់មក ភ្នាក់ងារមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ អនុវត្តដីកានេះឲ្យបានសម្រេច ។

................., ថ្ងៃទី............ខែ ......... ឆ្នាំ .............

ចៅក្រមស៊ើបសួរ

ហត្ថលេខា និង ត្រា

**ឧបសម្ព័ន្ធទី ១៨**

គំរូដីកាបង្គាប់ឲ្យចាប់ខ្លួន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្ត............

លេខអយ្យការ: ........................

លេខស៊ើបសួរ: ........................

លេខ:........................

## ដីកាបង្គាប់ឱ្យចាប់ខ្លួន

យើង ...............ចៅក្រមស៊ើបសួរសាលាដំបូងខេត្ត.......................។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: .................. ចុះថ្ងៃទី ............ ខែ .......... ឆ្នាំ ............។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: .............. ចុះថ្ងៃទី .............. ខែ .......... ឆ្នាំ .......... របស់តំណាងអយ្យការអមសាលាដំបូងខេត្ត......................... ។

បានឃើញដីកាបញ្ជូនឲ្យឆ្លើយលេខ: .................... ចុះថ្ងៃទី .......... ខែ .......... ឆ្នាំ ............ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្ត.................................. ។

**ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់**

**យល់ឃើញថា**

- ................................................................................................................................

-.................................................................................................................................

-.................................................................................................................................

**<u>ហេតុដូច្នេះសម្រេច</u>**

១- បង្គាប់ឲ្យភ្នាក់ងារមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ឲ្យចាប់ និងនាំខ្លួនជនឈ្មោះ..............ភេទ........ជាតិ.......អាយុ ............ឆ្នាំ កើតនៅភូមិ.................ឃុំ............ស្រុក...................ខេត្ត..................... រស់នៅភូមិ...............ឃុំ............... ស្រុក.................ខេត្ត..............ឪពុកឈ្មោះ ............ ម្ដាយឈ្មោះ ................. នៅលីវមានប្រពន្ធឈ្មោះ........................ ទោសពីមុន............................................. ។

២- បង្គាប់ឲ្យប្រធានពន្ធនាគារខេត្តកំពង់ធំ ទទួលយកជននេះ រហូតដល់មានបទបញ្ជាកថ្មីសម្រេចផ្សេងពីនេះ ។

៣- បង្គាប់ឲ្យភ្នាក់ងារមានសមត្ថកិច្ច នៃកម្លាំងសាធារណៈទាំងអស់នៅពេលត្រូវបានបង្ហាញដីកានេះ ត្រូវអនុវត្តឲ្យបានល្អនៅក្នុងករណីចាំបាច់ ។

............, ថ្ងៃទី........... ខែ......... ឆ្នាំ............

**ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធទី ១៩**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល
មន្ទីរស៊ើបសួរលេខ(៣)
លេខ ១៣២២.......

**លិខិតជូនដំណឹងដើមបណ្ដឹងរដ្ឋប្បវេណី**

យើង **ខូន ឌុទ្ធី** ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល។

ជូនដំណឹងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ: [illegible] ភេទស្រី អាយុ ៤៤ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិព្រៃបាំង ឃុំស៊ីធរ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ។

ជ្រាបថា: ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល បានបិទការស៊ើបសួរសំណុំរឿងលេខ: ១៤៥០ អ.ក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ពីបទ: **ជេរប្រមាថជាសាធារណៈ និងហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ៣០៧ និងមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។ ចៅក្រមស៊ើបសួរ បានបញ្ចប់ការស៊ើបសួរហើយ ។

អាស្រ័យហេតុនេះ សូមជ្រាបជាដំណឹង។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
កណ្ដាល ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨
**ចៅក្រមស៊ើបសួរ**

ខូន ឌុទ្ធី

យើង.................................បានប្រគល់លិខិត ជូនដំណឹងនេះដល់ឈ្មោះ.............................
ទីលំនៅភូមិ.......................ឃុំ.......................ស្រុក.......................ខេត្ត.......................នៅថ្ងៃទី.......
ខែ.................ឆ្នាំ...........ផ្ទាល់ដៃរួច ហើយ។

ធ្វើនៅថ្ងៃទី..........ខែ..................ឆ្នាំ២០១៨

អ្នកទទួល អ្នកប្រគល់

**ឧបសម្ព័ន្ធទី ២០**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល
មន្ទីរស៊ើបសួរលេខ(គ)
លេខ ១៣៦ ស.......

## លិខិតជូនដំណឹងជនត្រូវចោទ

យើង **ខួន ឫទ្ធី** ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល។

ជូនដំណឹងជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ ៣០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកធនាគារ អេស៊ីលីដា ទីលំនៅបច្ចុប្បន្ននៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល ។

ជ្រាបថា: ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល បានបិទការស៊ើបសួរសំណុំរឿងលេខ: ១៤៥០ អ.ក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ពីបទ: **ជេរប្រមាថជាសាធារណៈ និងហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ៣០៧ និងមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។ ចៅក្រមស៊ើបសួរ បានបញ្ចប់ការស៊ើបសួរហើយ ។

អាស្រ័យហេតុនេះ សូមជ្រាបជាដំណឹង។

ថ្ងៃ[illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
កណ្ដាល, ថ្ងៃទី១២ ខែ ឆ្នាំ២០១៨
**ចៅក្រមស៊ើបសួរ**

ខួន ឫទ្ធី

យើង.......................................បានប្រគល់លិខិត ជូនដំណឹងនេះដល់ឈ្មោះ..................................
ទីលំនៅភូមិ.........................ឃុំ.........................ស្រុក..........................ខេត្ត..........................នៅថ្ងៃទី......
ខែ..................ឆ្នាំ...........ផ្ទាល់ដៃរួច ហើយ។

ធ្វើនៅថ្ងៃទី..........ខែ..................ឆ្នាំ២០១៨

អ្នកទទួល អ្នកប្រគល់

**ឧបសម្ព័ន្ធទី ២១**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សំណុំរឿងលេខ:..............................

លេខស៊ើបសួរ:..............................

# កំណត់ហេតុស្ដីពីការបង្ហាញខ្លួនលើកដំបូង

(មាត្រា ១៨៣, ១៨៤, ២៨០ និងមាត្រា២៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ដប់ប្រាំបួន ខែកុម្ភៈ ថ្ងៃទីដប់ប្រាំ វេលាម៉ោង .............................. ។

យើង **គីម សុគន្ធា** ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប អមដោយលោកស្រី **គុជ មករា** ជាក្រឡាបញ្ជីអមផង ។

បុគ្គលដែលនៅចំពោះមុខយើង បានផ្ដល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម ៖

ឈ្មោះ [illegible] ស [illegible] ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ កើតនៅភូមិជលែង ឃុំមានជ័យ ស្រុក ខេត្តកំពង់ធំ អាស័យដ្ឋាននៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាម ខេត្តសៀមរាប មុខរបរ រើសអេតចាយ ឪពុកឈ្មោះ [illegible] "ស" ម្ដាយឈ្មោះ [illegible] (រ) កំរិតវប្បធម៌ ថ្នាក់ទី២ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ "គ្មាន" ។

តើអ្នកឯងចេះអាន និង សរសេរភាសាខ្មែរដែរ ឬ ទេ?

□ ចេះអាន និងចេះសរសេរភាសាខ្មែរ □ មិនចេះអាន និងមិនចេះសរសេរភាសាខ្មែរ

□ ជននេះបានប្រកាសថា ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០ (ដប់)ឆ្នាំ ដែលស្ថិតនៅលំនៅបច្ចុប្បន្ន ។

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ជននេះ ឲ្យបានដឹងយ៉ាងច្បាស់អំពីរឿងក្ដីនីមួយៗ ដែលព្រះរាជអាជ្ញាបានប្ដឹងមកយើងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ១៧៨ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០១៩ ដោយជននេះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ: អំពើលួច ប្រព្រឹត្តនៅចំណុចហាងក្រែបស៊ុហ្វូត ផ្លូវ៦០ម៉ែត្រ ភូមិធ្លកអណ្ដូង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ ២០១៨ បទល្មើសដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា៣៥៣ និង មាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

យើងបានជូនដំណឹងដល់ជននេះថា យើងនឹងដាក់ជននេះឲ្យស្ថិតនៅក្រោមការពិនិត្យចំពោះរឿងក្ដីដែលយើងទើបនឹងរៀបរាប់ឲ្យជននេះដឹងយ៉ាងច្បាស់ ។

លោក-លោកស្រី .............................. ជាមេធាវី[1] នៃជនត្រូវចោទ ដែលត្រូវបានកោះហៅនៅថ្ងៃទី.............................................. ហើយដើម្បីឲ្យ លោក-លោកស្រីមេធាវី អាចត្រៀមរៀបចំការពារក្ដីខ្លួនបាន ។

យើងបានប្រាប់ដល់ជននេះអំពី ៖

- សិទ្ធិទទួលបានជំនួយមេធាវី ដែលជននេះអាចជ្រើសរើសពឹងពឹងមេធាវីដោយខ្លួនឯង ឬអាចសុំឲ្យតុលាការចាត់តាំងមេធាវីណាម្នាក់ឲ្យ ។

[1] ករណីយមានមេធាវី

- ប្រសិនបើមិនធ្វើការជ្រើសរើសពីងមេធាវីដោយខ្លួនឯងទេ មេធាវីមួយរូបនឹងត្រូវចាត់តាំងដោយឯកឯងដោយសារតែជននេះ ជាអនីតិជន ។

ជននេះ បានប្រកាសប្រាប់ថា ៖ ☐ ខ្ញុំជ្រើសរើសមេធាវីដោយខ្លួនឯង ☐ ខ្ញុំស្នើសុំឲ្យចាត់តាំងមេធាវី មួយរូបឲ្យខ្ញុំ ☐ ខ្ញុំបដិសេធជំនួសពីមេធាវី ។

យើងបានប្រាប់ដល់ជនត្រូវចោទថា គាត់មានសិទ្ធិអាចនៅស្ងៀមមិនផ្ដល់ចម្លើយ ក៏បាន ឬអាចធ្វើសេចក្ដីប្រកាសផ្សេងៗ ឬអាចឲ្យយើងសួរចម្លើយក៏បាន ។

ជននេះបានប្រកាសថា ៖ ..............................................................................................

..............................................................................................................................

..............................................................................................................................

លោក-លោកស្រីមេធាវី..............................................បានផ្ដល់សេចក្ដីកត់សម្គាល់ការពារថា ៖

..............................................................................................................................

..............................................................................................................................

..............................................................................................................................

យើងបានជូនដំណឹងដល់ជននេះថា យើងសម្រេចដាក់គាត់ឲ្យស្ថិតនៅក្រោមការពិនិត្យ ៖

☐ ចំពោះអង្គហេតុទាំងអស់ដែលយើងបានប្រាប់ឲ្យដឹង ។

☐ ចំពោះតែអង្គហេតុដែលរៀបរាប់ខាងក្រោម ដែលយើងបញ្ជាក់ប្រាប់ជននេះអំពីឈ្មោះនៃបទល្មើស

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

យើងបានប្រាប់ដល់ជនត្រូវចោទ អំពីសិទ្ធិក្នុងការសុំឲ្យយើងធ្វើកិច្ចស៊ើបសួរមួយ ឬច្រើន ឬក៏អាចធ្វើពាក្យប្ដឹងសុំមោឃភាពនៃកិច្ចស៊ើបសួរដោយផ្អែកតាមមូលដ្ឋាននៃមាត្រា ២៥៣ ប្ដឹងឧទ្ធរណ៍តាមបញ្ញត្តិមាត្រា២៦៧ នៅក្នុងពេលនៃដំណើរការនៃការស៊ើបសួរ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

